# អង្គការសហប្រជាជាតិ

# ក្រមង

# អនុសាសន៍នៃការពិនិត្យជាសកលតាមកាលកំណត់ ( UPR )
# ដែលកម្ពុជាបានទទួលយក

# និងអនុសាសន៍ពាក់ព័ន្ធនានា
# ដែលចេញដោយយន្តការសិទ្ធិមនុស្សសហប្រជាជាតិ


អង្គការសហប្រជាជាតិ

អង្គការសហប្រជាជាតិ
សិទ្ធិមនុស្ស
ការិយាល័យឧត្តមស្នងការ
កម្ពុជា

ខែសីហា ឆ្នាំ២០១៧


ចែកជូនដោយឥតគិតថ្លៃ

# ក្រម

# អនុសាសន៍នៃការពិនិត្យជាសកលតាមកាលកំណត់
# ដែលកម្ពុជាបានទទួលយក
# និងអនុសាសន៍ពាក់ព័ន្ធនានា
# ដែលចេញដោយយន្តការសិទ្ធិមនុស្សសហប្រជាជាតិ

រៀបរៀងដោយការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា

# មាតិការឿង

ឲឲឲ⊗ឲឲឲ


ទំព័រ

កថាមុខ ៧

អំពីយន្តការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ ១០

ស្ថាប័នសន្ធិសញ្ញាសិទ្ធិមនុស្ស

នីតិវិធីពិសេសនៃក្រុមប្រឹក្សាសិទ្ធិមនុស្ស ១៣

I. *ការផ្តល់សច្ចាប័ន និងការចូលជាសមាជិកសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិ និងសន្ធិសញ្ញាពាក់ព័ន្ធនានា ព្រមទាំងកិច្ចសហប្រតិបត្តិការជាមួយនឹងប្រព័ន្ធសិទ្ធិមនុស្សសហប្រជាជាតិ និងសហគមន៍អន្តរជាតិ រួមទាំងតុលាការឧក្រិដ្ឋកម្មអន្តរជាតិ ១៥*

ក. ការផ្តល់សច្ចាប័ន ១៥

ខ. កិច្ចសហប្រតិបត្តិការជាមួយយន្តការសិទ្ធិមនុស្ស និងស្ថាប័នសិទ្ធិមនុស្ស ១៧

គ. កិច្ចសហប្រតិបត្តិការជាមួយនីតិវិធីពិសេស ២០

ឃ. កិច្ចសហប្រតិបត្តិការអន្តរជាតិទូទៅលើវិស័យសិទ្ធិមនុស្ស ២១

ង. យន្តការបង្ការថ្នាក់ជាតិ៖ កាតព្វកិច្ចតាមពិធីសារបន្ថែមនៃអនុសញ្ញាប្រឆាំងទារុណកម្ម ២៣

ច. ការអប់រំជាទូទៅអំពីសិទ្ធិមនុស្ស និងសន្ធិសញ្ញាសិទ្ធិមនុស្ស ២៤

II. *កំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ និងនីតិរដ្ឋ ២៩*

ក. កំណែទម្រង់ច្បាប់ទូទៅ ២៩

ខ. ប្រព័ន្ធយុត្តិធម៌ និងតុលាការដែលមានប្រសិទ្ធភាព និងឯករាជ្យ ៣៣

គ. កំណែទម្រង់ប្រព័ន្ធយុត្តិធម៌ និងការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ ៣៨

ឃ. មធ្យោបាយសំរាប់ប្រព័ន្ធយុត្តិធម៌ និងការទទួលបានសេវាកម្មច្បាប់/ ជំនួយផ្នែកច្បាប់ដល់ជនក្រីក្រ ដែលកាន់តែប្រសើរឡើង ៤១

ង. យុត្តិធម៌អនីតិជន ៤៤

ច. ការមិនបញ្ជូនត្រឡប់ ៤៦

III. *សេរីភាពនៃការបញ្ចេញមតិ(រួមទាំងសេរីភាពព័ត៌មាន)សេរីភាពសមាគមនិងសេរីភាពនៃការប្រមូលផ្តុំ*

ក. សេរីភាពនៃការបញ្ចេញមតិ និងកំណែទម្រង់ច្បាប់ ៤៩

ខ. សេរីភាពនៃការប្រមូលផ្តុំ ៥២

គ. សេរីភាពសមាគម រួមទាំងសហជីព ៥៣

ឃ. ប្រព័ន្ធផ្សព្វផ្សាយតាមអ៊ិនធើណិត និងការទទួលបានព័ត៌មាន ៥៥

IV. *និទណ្ឌភាព និងអ្នកការពារសិទ្ធិមនុស្ស* *៥៧*

V. *កំណែទម្រង់ការបោះឆ្នោត និងការចូលរួមនយោបាយ* *៦១*

VI. *ស្ថាប័នជាតិសិទ្ធិមនុស្ស* *៦៧*

VII. *អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា* *៧១*

VIII. *ការប្រតិបត្តិច្បាប់* *៧៣*

ក. ទារុណកម្ម ការប្រព្រឹត្តិមិនគប្បី និងការប្រតិបត្តិច្បាប់ ៧៣

ខ. លក្ខខណ្ឌនៅពន្ធនាគារ និងការឃុំខ្លួន ៧៥

IX. *ការអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គម* *៧៩*

ក. ការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម/គោលដៅអភិវឌ្ឍន៍សហស្សវត្ស ៧៩

ខ. ការកាត់បន្ថយភាពក្រីក្រ ទ្រព្យសម្បត្តិ/គម្លាតជនបទ-ទីក្រុង ៨២

គ. ការទទួលខុសត្រូវធុរកិច្ច/មុខរបរ ៨៤

X. *ដីធ្លី និងសិទ្ធិលំនៅដ្ឋាន* *៨៩*

ក. ការកាន់កាប់ដីធ្លី ការបណ្តេញចេញ និងការតាំងទីលំនៅថ្មី និងក្របខ័ណ្ឌច្បាប់ ៨៩

ខ. ដំណើរការដីធ្លីដោយមានតម្លាភាព និងមានការចូលរួម ៩៥

គ. ដីសម្បទាន ៩៧

XI. *សុខភាព និងការអប់រំ សំណាញ់សុវត្ថិភាពនិងក្រុមងាយរងគ្រោះ ក្រុមជនភាគតិច* *១០១*

ក. សុខភាព រួមទាំងHIV ១០១

ខ. ការអប់រំ ១០៥

គ. សំណាញ់សុវត្ថិភាព និងក្រុមងាយរងគ្រោះ ១០៨

ឃ. ជនភាគតិច ១១០

XII. *សិទ្ធិស្ត្រី សិទ្ធិកុមារ និងសិទ្ធិជនពិការ* *១១៥*

ក. កិច្ចការពារទូទៅដល់ស្ត្រី និងកុមារ ១១៥

ខ. សមភាពយេនឌ័រ និងការរើសអើងប្រឆាំងនារីភេទ ១១៧

គ. អំពើហឹង្សាប្រឆាំងនារីភេទ និងកុមារ ១២០

ឃ. ពលកម្មកុមារ ១២៦

ង. គ្រួសារ ១២៨

ច. ការជួញដូរ ១៣១

ឆ. ពិការភាព ១៣៤

XIII. *អនុសាសន៍នានាពាក់ព័ន្ធនឹងគោលដៅអភិវឌ្ឍន៍ចីរភាព* *១៣៧*

# កថាមុខ

ឞឞឞ⊗ឈឈឈ

យន្តការពិនិត្យជាសកលតាមកាលកំណត់(UPR) របស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស គឺជាដំណើរការតែមួយគត់ អំពីកំណត់ត្រាសិទ្ធិមនុស្សរបស់សមាជិកនីមួយៗ ទាំង១៩៣ប្រទេសនៃអង្គការសហប្រជាជាតិ។ ដោយមានគោលដៅខ្ពស់បំផុត ក្នុងការធ្វើឲ្យកាន់តែប្រសើរដល់ស្ថានភាពសិទ្ធិមនុស្ស នៅគ្រប់រដ្ឋដែលស្ថិតនៅក្រោមការពិនិត្យ UPRត្រូវបានបង្កើតឡើង ដើម្បីបង្កើន គាំទ្រ និងពង្រីកការលើកស្ទួយ និងការការពារសិទ្ធិមនុស្សនៅតាមប្រទេសនីមួយៗ។ UPR គឺជាដំណើរការខិតខំប្រឹងប្រែងរបស់រដ្ឋ ដែលផ្តល់ឱកាសដល់រដ្ឋនីមួយៗ ប្រកាសពីការចាត់វិធានការនានា ដើម្បីធ្វើឲ្យប្រសើរដល់ស្ថានភាពសិទ្ធិមនុស្ស នៅក្នុងប្រទេស និងបំពេញកាតព្វកិច្ចសិទ្ធិមនុស្សរបស់ខ្លួន នៅចំពោះមុខរដ្ឋដទៃទៀត និងចំពោះមុខសាធារណៈជនទូទៅ។ UPR បង្កើតឱកាសផ្តល់ជំនួយបច្ចេកទេសដល់រដ្ឋនានា និងលើកកំពស់សមត្ថភាពរបស់ពួកគេក្នុងការដោះស្រាយបញ្ហាប្រឈមសិទ្ធិមនុស្សប្រកបដោយប្រសិទ្ធភាព និងចែករំលែកការអនុវត្តន៍ល្អៗនៅក្នុងវិស័យសិទ្ធិមនុស្ស រវាងរដ្ឋនានានិងដៃគូដទៃទៀត។ ជាទិដ្ឋភាពចំបងមួយរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស UPRត្រូវបានបង្កើតឡើង ដើម្បីធានាឲ្យមានការពិនិត្យដោយស្មើភាពគ្នាដល់រដ្ឋទាំងអស់ នៅពេលស្ថានភាពសិទ្ធិមនុស្សរបស់ពួកគេត្រូវបានយកមកវាយតំលៃម្តងៗ។ គ្រប់រដ្ឋត្រូវស្ថិតនៅក្រោមដំណើរការដូចគ្នា និងការពិនិត្យដូចគ្នាដោយមិនគិតពីការផ្តល់សច្ចាប័នលើសន្ធិសញ្ញាសិទ្ធិមនុស្សនោះទេ។ សព្វថ្ងៃនេះ មិនមានយន្តការសកលដទៃណារបៀបនេះនោះទេ។

កម្ពុជាត្រូវបានពិនិត្យដំបូងក្រោមដំណើរការUPR កាលពីខែធ្នូ ឆ្នាំ២០០៩។ នៅចុងបញ្ចប់នៃការពិនិត្យលើកដំបូងរបស់ខ្លួន កម្ពុជាបានទទួលយកទាំង៩១អនុសាសន៍ ដែលធ្វើឡើងដោយរដ្ឋនានា។[១] ជុំដំបូងនៃដំណើរការUPR បានចប់សព្វគ្រប់កាលពីខែតុលា ឆ្នាំ២០១១ នៅពេលដែលរដ្ឋសមាជិកទាំងអស់ ១៩៣ របស់អង្គការសហប្រជាជាតិ ត្រូវបានពិនិត្យ។ បន្ទាប់មកជុំទីពីរ បានចាប់ផ្តើម ហើយកម្ពុជាត្រូវបានពិនិត្យជាលើកទីពីរ កាលពីថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៤។ គ្រប់ទិន្នន័យព័ត៌មាន ត្រូវបានដាក់ចូលសំរាប់ការត្រួតពិនិត្យលើកទី២នេះ រួមមានរបាយការណ៍ជាតិរបស់រាជរដ្ឋាភិបាល និងកម្រងព័ត៌មានពីយន្តការសិទ្ធិមនុស្សសហប្រជាជាតិ និងអង្គការមិនមែនរដ្ឋាភិបាល ហើយព័ត៌មានទាំងនេះ សុទ្ធតែអាចរកបាននៅក្នុងគេហទំព័ររបស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស។[២] កិច្ចសន្ទនានៃការពិនិត្យនេះ ក៏អាចរកមើលផងដែរនៅក្នុងគេហទំព័រនេះ។[៣]

---

១· អនុសាសន៍ទាំងនេះ អាចរកបាននៅគេហទំព័រ៖ http://www.ohchr.org/EN/HRBodies/UPR/Pages/KHSession6.aspx

២ ·ឯកសារទាំងនេះអាចរកបាននៅគេហទំព័រ http://www.ohchr.org/EN/HRBodies/UPR/Pages/KHSession18.aspx. ដើម្បីរកមើលការដាក់ឯកសាររបស់អង្គការមិនមែនរដ្ឋាភិបាល និងទីភ្នាក់ងារសហប្រជាជាតិនីមួយៗ សូមចុចលើរឹមទំព័រនៃគេហទំព័រនោះ។

៣ ·សូមមើលគេហទំព័រ៖ http://webtv.un.org/watch/cambodia-review-18th-session-of-universal-periodic-view/3119784522001/

ក្នុងកំឡុងពេលពិនិត្យចុងក្រោយនេះនាឆ្នាំ២០១៤ មានអនុសាសន៍ចំនួន២០៥ បានដាក់ជូនកម្ពុជា បង្ហាញនូវការវាយតំលៃជារួមមួយអំពីតថភាពនៃកិច្ចការពារសិទ្ធិមនុស្សនៅកម្ពុជា ព្រមទាំងចំណុចធកល្វៃង និងឱកាសពាក់ព័ន្ធនានា ដើម្បីពង្រឹងដល់កិច្ចការពារនេះ។ ក្នុងខែមករា កម្ពុជាបានទទួលអនុសាសន៍ចំនួន ១៧១ ហើយបានសុំពន្យារពេលធ្វើសេចក្តីសំរេចលើអនុសាសន៍ដែលនៅសល់ចំនួន៣៤ រហូតដល់សម័យប្រជុំខែមិថុនា របស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស។ នៅថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៤ កម្ពុជាបានប្រកាសពីជំហរចុងក្រោយរបស់ខ្លួនថា ខ្លួនព្រមទទួលយកតែ១៦៣ អនុសាសន៍ប៉ុណ្ណោះ និងសូមធ្វើការកត់សំគាល់ចំពោះអនុសាសន៍ចំនួន៤២ទៀត។ អនុសាសន៍ទាំង១៦៣ ដែលកម្ពុជាបានទទួលយក ហើយប្តេជ្ញាថានឹងចាត់វិធានការបន្ទាប់មកនោះ ត្រូវបានបោះពុម្ពផ្សាយនៅក្នុងតារាងខាងក្រោមនេះ។

ដើម្បីបង្ហាញពីការរីកចំរើននៅជុំបន្ទាប់នៃUPR នៅឆ្នាំ២០១៨ រដ្ឋាភិបាលត្រូវចាត់វិធានការជាក់ស្តែងឆ្ពោះទៅរកការអនុវត្តន៍អនុសាសន៍ទាំងនេះ។ ត្រូវមានការអនុវត្តន៍តាមដ៏មានអត្ថន័យ និងឯកភាពគ្នាចំពោះអនុសាសន៍UPR ដើម្បីធានាថារាល់កិច្ចប្រឹងប្រែងរបស់រាជរដ្ឋាភិបាល អង្គការសង្គមស៊ីវិល ទីភ្នាក់ងារសហប្រជាជាតិ និងសហគមន៍អន្តរជាតិ ព្រមទាំងដៃគូចូលរួមដទៃទៀត នឹងត្រូវចាត់វិធានការឲ្យបានជាក់ច្បាស់ ឆ្ពោះទៅរកការរីកចំរើនដ៏មានអត្ថន័យ។ កិច្ចខិតខំប្រឹងប្រែងបែបនេះ នឹងរួមចំណែកដល់ការអនុវត្តន៍អនុសាសន៍នានា ដែលបានដាក់ចេញកាលពីមុនៗ ដោយយន្តការសិទ្ធិមនុស្សសហប្រជាជាតិដទៃទៀត។ ឯកសារបោះពុម្ពនេះ ចងក្រងនូវអនុសាសន៍ UPR ទាំងអស់ដែលកម្ពុជាបានទទួលយក កាលពីឆ្នាំ២០០៩ និងឆ្នាំ២០១៤ និងបង្ហាញពីអនុសាសន៍នីមួយៗ ដែលទាក់ទងទៅនឹងអនុសាសន៍នានារបស់ស្ថាប័នសិទ្ធិមនុស្សដទៃទៀត ដូចជាគណៈកម្មាធិការនានានៃអ្នកជំនាញការឯករាជ្យអន្តរជាតិ ដែលមានតួនាទីឃ្លាំមើលការអនុវត្តសន្ធិសញ្ញាដោយរដ្ឋភាគីដែលបានផ្តល់សច្ចាប័នលើសន្ធិសញ្ញាសិទ្ធិមនុស្សទាំងនោះ ព្រមទាំងអ្នករាយការណ៍ពិសេសរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្សសហប្រជាជាតិអំពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា។ ការបោះពុម្ពលើកទី២ នៃកម្រងអនុសាសន៍នេះ ក៏មានរួមបញ្ចូលអនុសាសន៍ចុងក្រោយរបស់អ្នករាយការណ៍ពិសេសដែលបានផ្តល់ជូនកាលពីខែកញ្ញា ឆ្នាំ២០១៦ ព្រមទាំងអនុសាសន៍នានាចេញដោយគណៈកម្មាធិការស្តីពីសិទ្ធិកុមារអំពីការអនុវត្តពិធីសារបន្ថែមទាំងពីរនៃអនុសញ្ញាសិទ្ធិកុមារ កាលពីខែកុម្ភៈ ឆ្នាំ២០១៥ និងអនុសាសន៍ចេញដោយគណៈកម្មាធិការសិទ្ធិមនុស្ស អំពីការអនុវត្តកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយនៅកម្ពុជា កាលពីខែមីនា ឆ្នាំ២០១៥ដែរ។ ការអនុវត្តន៍ដ៏ជោគជ័យ នឹងជួយដល់ការព្រាងរបាយការណ៍បន្ទាប់របស់UPR កាន់តែមានភាពងាយស្រួល។

ដើម្បីសំរេចបានគោលបំណងនេះ ជាសំខាន់ រដ្ឋត្រូវកំណត់ពីស្ថាប័នជាក់លាក់នានារបស់ខ្លួន ដើម្បីទទួលខុសត្រូវក្នុងការអនុវត្តន៍អនុសាសន៍តាមវិស័យជាក់លាក់រៀងៗខ្លួន ព្រមទាំងការចាត់វិធានការជាក់លាក់ដើម្បីបំពេញតាមអនុសាសន៍ទាំងនេះ។ ជាប្រការសំខាន់ដែលត្រូវរំលឹកថា ការចាត់វិធានការចំពោះការទទួលខុសត្រូវនេះ មិនត្រូវអាស្រ័យទាំងស្រុងលើនីតិប្រតិបត្តិនោះទេ។ មានអនុសាសន៍ខ្លះ តម្រូវឱ្យអនុម័ត ឬកែសម្រួលច្បាប់ តួយ៉ាងសភានឹងត្រូវមានតួនាទីយ៉ាងសំខាន់នោះ។ ជាក់ស្តែងកាលពីខែវិច្ឆិកា ឆ្នាំ២០១៤

គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា និងការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជាបានសហការរៀបចំសិក្ខាសាលាជាតិមួយ ដើម្បីផ្សព្វផ្សាយអនុសាសន៍UPR។ គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជាដឹកនាំដំណើរការសិក្ខាសាលា ដើម្បីកំណត់ពីស្ថាប័នរដ្ឋណាខ្លះ ដែលត្រូវទទួលខុសត្រូវចំពោះអនុសាសន៍នីមួយៗ។

ទិដ្ឋភាពតែមួយគត់នៃដំណើរការUPRគឺថាវាឆ្លុះបញ្ចាំងនូវការប្រមូលផ្តុំនៃទស្សនៈអន្តរជាតិអំពីស្ថានភាពសិទ្ធិមនុស្សនៅតាមប្រទេសនីមួយៗដែលស្ថិតក្រោមការពិនិត្យ ហើយអនុសាសន៍ដែលជាលទ្ធផលពីការពិនិត្យនេះ ត្រូវបានទទួលយកដោយស្ម័គ្រចិត្ត និងជាសាធារណៈ ដោយរដ្ឋដែលស្ថិតក្រោមការពិនិត្យ។ ដូច្នេះ អនុសាសន៍ទាំងនេះអាចក្លាយជាឧបករណ៍នៃការតស៊ូមតិដ៏មានអំណាចបំផុតសំរាប់ដៃគូពាក់ព័ន្ធទាំងអស់។ រដ្ឋនីមួយៗគួរបរិយាយនៅក្នុងផែនការជាក់ស្តែងដើម្បីអនុវត្តឬគាំទ្រដល់ការអនុវត្តន៍អនុសាសន៍UPR ការទទួលខុសត្រូវក្នុងការអនុវត្តន៍អនុសាសន៍UPR ជាការពិតហើយ ជារបស់រដ្ឋាភិបាល ក៏ប៉ុន្តែសង្គមស៊ីវិលក៏អាចនិងគួរដើរតួសំខាន់ក្នុងការជួយដល់កិច្ចខិតខំប្រឹងប្រែងរបស់រដ្ឋាភិបាលនៅក្នុងវិស័យនេះដែរ។ សង្គមស៊ីវិលក៏ដើរតួនាទីសំខាន់ផងដែរក្នុងការតាមឃ្លាំមើលស្ថានភាពនៃការអនុវត្តន៍អនុសាសន៍ទាំងនេះ។ រួមជាមួយអនុសាសន៍នានារបស់យន្តការជំនាញ ដូចជាគណៈកម្មាធិការឃ្លាំមើលសន្ធិសញ្ញា និងអ្នករាយការណ៍ពិសេសនានា អនុសាសន៍UPRថ្លែងពីបញ្ហានានាដែលមានលក្ខណៈទូលំទូលាយគ្របដណ្តប់លើវិស័យនានាដែលក្នុងនោះ ទីភ្នាក់ងារសហប្រជាជាតិជារឿយៗតែងផ្តល់ការគាំទ្រដល់រដ្ឋាភិបាល។ ក្នុងករណីនេះ ដោយទទួលយកការណែនាំពីអនុសាសន៍ទាំងនេះ ទីភ្នាក់ងារសហប្រជាជាតិអាចផ្តល់ជំនួយដ៏មានសារៈសំខាន់ដល់ការអនុវត្តន៍UPR នៅក្នុងវិស័យជាក់លាក់ដែលខ្លួនមានសមត្ថកិច្ច។

អនុសាសន៍ពីគ្រប់យន្តការសិទ្ធិមនុស្សអាចប្រើជាកាតាលីករ-ហើយធ្លាប់បានអនុវត្តបែបនេះនៅតាមបណ្តាប្រទេសជាច្រើន-សំរាប់រដ្ឋាភិបាល សង្គមស៊ីវិល សហគមន៍អន្តរជាតិ និងប្រព័ន្ធសហប្រជាជាតិ ចូលរួមប្រឹងប្រែងក្នុងការអនុវត្តអនុសាសន៍ទាំងនេះ ដើម្បីធ្វើឲ្យកិច្ចការពារសិទ្ធិមនុស្សកាន់តែប្រសើរ។ ឱកាសអនុវត្តដូចគ្នាបែបនេះនៅកម្ពុជាមិនគួរត្រូវបានបោះបង់ឡើយ។ ដោយមានកិច្ចសហការយ៉ាងជិតស្និតជាមួយដៃគូជាច្រើន ដែលបានយកចិត្តយ៉ាងជ្រាលជ្រៅដល់ការលើកស្ទួយសិទ្ធិមនុស្សនៅកម្ពុជា ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស ត្រៀមខ្លួនជាស្រេច ដើម្បីចូលរួមក្នុងការអនុវត្តអនុសាសន៍ទាំងនេះជាមួយពួកគេ ដោយឆ្លៀតយកប្រយោជន៍ពីការបើកជាថ្មីដល់កំណែទម្រង់ដ៏ទាន់ពេល ដើម្បីចាប់ផ្តើមដំណើរការអនុវត្តUPR នេះដោយម៉ឺងម៉ាត់។ ការិយាល័យឧត្តមស្នងការបានជួយដល់ការបោះពុម្ពនេះ ថាជាជំហានដំបូងនៅក្នុងទិសដៅនេះ។ នេះគឺជាការឧទ្ទិសដល់ប្រជាជនកម្ពុជា និងអ្នកទាំងឡាយណាដែលចូលរួមការពារសិទ្ធិមនុស្សរបស់ពួកគេ។

លោកស្រី វ៉ាន់ហ៊ី លី
តំណាងការិយាល័យ
OHCHR-Cambodia
ខែមិថុនា ឆ្នាំ២០១៧

# អំពីយន្តការសិទ្ធិមនុស្សសហប្រជាជាតិ

*ដំណើរការ*UPR

ការពិនិត្យត្រូវធ្វើឡើងរៀងរាល់៤.៥ឆ្នាំម្តង ដោយក្រុមការងារUPR ដែលមានសមាជិកចំនួន៤៧រដ្ឋនៃក្រុមប្រឹក្សាសិទ្ធិមនុស្ស ទោះជាយ៉ាងនេះក៏ដោយ រដ្ឋសមាជិកដទៃទៀតរបស់អង្គការសហប្រជាជាតិ ក៏អាចចូលរួមក្នុងកិច្ចពិភាក្សា/សន្ទនាជាមួយរដ្ឋដែលស្ថិតនៅក្រោមការពិនិត្យផងដែរ។ រដ្ឋនីមួយៗដែលស្ថិតក្រោមការពិនិត្យ ត្រូវបានជួយដោយក្រុមនៃរដ្ឋបីដែលដឹងថាជា "troikas" ធ្វើជាអ្នករាយការណ៍។ ការជ្រើសរើសtroikas សំរាប់រដ្ឋនីមួយៗ ត្រូវធ្វើតាមរយៈការចាប់ឆ្នោត បន្ទាប់ពីការបោះឆ្នោតជ្រើសរើសសមាជិកក្រុមប្រឹក្សាសិទ្ធិមនុស្ស នៅក្នុងមហាសន្និបាតអង្គការសហប្រជាជាតិ។

ការត្រួតពិនិត្យនេះ ផ្អែកលើឯកសារបី៖

១. ព័ត៌មានដែលផ្តល់ឲ្យដោយរដ្ឋ ដែលស្ថិតក្រោមការពិនិត្យ ដែលអាចធ្វើតាមទម្រង់ជា "របាយការណ៍ជាតិ"។

២. ព័ត៌មានដែលមាននៅក្នុងរបាយការណ៍របស់អ្នកជំនាញការ និងក្រុមឯករាជ្យខាងសិទ្ធិមនុស្ស រួមមាននីតិវិធីពិសេស ស្ថាប័នសន្ធិសញ្ញាសិទ្ធិមនុស្ស និងស្ថាប័នសហប្រជាជាតិដទៃទៀត។

៣. ព័ត៌មានពីដៃគូដទៃទៀត រួមទាំងស្ថាប័នសិទ្ធិមនុស្សជាតិ និងអង្គការមិនមែនរដ្ឋាភិបាល។

UPR វាយតំលៃពីវិសាលភាពដែលរដ្ឋគោរពកាតព្វកិច្ចសិទ្ធិមនុស្សរបស់ខ្លួនដូចមានចែងក្នុង៖

(១). ធម្មនុញ្ញសហប្រជាជាតិ

(២). សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស

(៣). លិខិតុបករណ៍សិទ្ធិមនុស្សដែលរដ្ឋនោះជាភាគី (សន្ធិសញ្ញាសិទ្ធិមនុស្សនានាដែលរដ្ឋនោះបានផ្តល់សច្ចាប័ន)

(៤). ការសន្យា និងការប្តេជ្ញាចិត្តដោយស្ម័គ្រចិត្តធ្វើដោយរដ្ឋនោះ (ឧ. គោលនយោបាយសិទ្ធិមនុស្សជាតិ និង/ឬកម្មវិធីនានាដែលត្រូវអនុវត្ត) និង

(៥). ច្បាប់មនុស្សធម៌អន្តរជាតិដែលនៅជាធរមាន។

ការពិនិត្យប្រព្រឹត្តទៅតាមរយៈកិច្ចសន្ទនាគ្នាជាអន្តរកម្មរវាងរដ្ឋស្ថិតនៅក្រោមការពិនិត្យ និងសមាជិកដទៃទៀតរបស់សហប្រជាជាតិ។ កិច្ចពិភាក្សានេះប្រព្រឹត្តទៅក្នុងកំឡុងពេលកិច្ចប្រជុំរបស់ក្រុមការងារ UPR ដែលសមាជិកណាក៏ដោយរបស់អង្គការសហប្រជាជាតិ អាចតាំងសំណួរ យោបល់ និង/ឬធ្វើអនុសាសន៍ដល់រដ្ឋដែលស្ថិតនៅក្រោមការពិនិត្យ។ រយៈពេលនៃការត្រួតពិនិត្យ គឺ៣ម៉ោង និង៣០នាទី។

បន្ទាប់ពីការពិនិត្យដោយក្រុមការងារ troikaនឹងរៀបចំរបាយការណ៍មួយ ដោយមានការចូលរួមពីរដ្ឋដែលស្ថិតក្រោមការពិនិត្យ និងជំនួយពីការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស។ របាយការណ៍នេះដែលត្រូវទុកជា "របាយការណ៍លទ្ធផល" រៀបរាប់យ៉ាងសង្ខេបពីកិច្ចសន្ទនាគ្នា

នោះ។ ដូច្នេះ របាយការណ៍នេះ មានសំណួរ យោបល់ និងអនុសាសន៍ដែលដាក់ដោយរដ្ឋនានាដល់រដ្ឋដែលស្ថិតក្រោមការពិនិត្យ ព្រមទាំងការឆ្លើយតបរបស់រដ្ឋដែលស្ថិតក្រោមការពិនិត្យ។

ពេលវេលាត្រូវបានផ្តល់ឲ្យក្រុមការងារដើម្បីអនុម័ត "របាយការណ៍លទ្ធផល" នីមួយៗរបស់រដ្ឋដែលស្ថិតក្រោមការពិនិត្យ ក្នុងកំឡុងសម័យប្រជុំនោះ។ រដ្ឋដែលស្ថិតក្រោមការពិនិត្យ មានឱកាសផ្តល់យោបល់បឋមទៅលើអនុសាសន៍នានា ជ្រើសរើសថាព្រមទទួលយក ឬគ្រាន់តែធ្វើការកត់សំគាល់លើអនុសាសន៍ទាំងនោះ។ ទាំងអនុសាសន៍ដែលបានទទួលយក និងអនុសាសន៍ដែលគ្រាន់តែធ្វើការកត់សំគាល់ ត្រូវបានដាក់បញ្ចូលទៅក្នុងរបាយការណ៍នេះ។

បន្ទាប់មក របាយការណ៍នេះ ត្រូវដាក់ជូនសម័យប្រជុំពេញអង្គរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស ដើម្បីទទួលការអនុម័ត។ នៅពេលនោះ រដ្ឋដែលស្ថិតក្រោមការពិនិត្យអាចឆ្លើយទៅនឹងសំណួរ និងបញ្ហានានាដែលមិនទាន់បានឆ្លើយគ្រប់គ្រាន់នៅកំឡុងពេលក្រុមការងារ និងឆ្លើយតបចំពោះអនុសាសន៍ដែលត្រូវបានលើកឡើងដោយរដ្ឋនានាក្នុងកំឡុងពេលនៃការត្រួតពិនិត្យ។ ពេលវេលាក៏មានផ្តល់ជូនរដ្ឋសមាជិក និងរដ្ឋសង្កេតការណ៍ដែរដែលចង់សំដែងមតិរបស់ខ្លួនអំពីលទ្ធផលនៃការត្រួតពិនិត្យនេះ និងក៏មានផ្តល់ជូនស្ថាប័នសិទ្ធិមនុស្សជាតិ អង្គការមិនមែនរដ្ឋាភិបាល និងដៃគូដទៃទៀត ដើម្បីផ្តល់យោបល់ជាទូទៅដែរ។

រដ្ឋដែលស្ថិតក្រោមការពិនិត្យ តែងតែមានការទទួលខុសត្រូវបឋមដើម្បីអនុវត្តអនុសាសន៍នានាដែលមាននៅក្នុងរបាយការណ៍លទ្ធផលចុងក្រោយ។ UPR ធានាថា គ្រប់ប្រទេសត្រូវទទួលខុសត្រូវចំពោះការរីកចំរើន ឬការខកខានក្នុងការអនុវត្តអនុសាសន៍ទាំងនេះ។ ក្នុងកំឡុងការត្រួតពិនិត្យលើកក្រោយ រដ្ឋត្រូវបានរំពឹងថា នឹងផ្តល់ព័ត៌មានអំពីវិធានការនានាដែលខ្លួនបានចាត់ឡើង ដើម្បីអនុវត្តអនុសាសន៍នានាដែលបានផ្តល់ឲ្យកាលពីលើកមុន ព្រមទាំងអំពីការវិវត្តន៍ណាមួយនៅក្នុងវិស័យសិទ្ធិមនុស្ស។ សហគមន៍អន្តរជាតិមានតួនាទីជួយអនុវត្តអនុសាសន៍ទាំងនេះ តាមរយៈការផ្តល់ជំនួយបច្ចេកទេស និងការកសាងសមត្ថភាពដោយពិគ្រោះយោបល់ជាមួយរដ្ឋសាមី។

## *ស្ថាប័នសន្ធិសញ្ញាសិទ្ធិមនុស្ស*

ស្ថាប័នសន្ធិសញ្ញាឃ្លាំមើលការអនុវត្តសន្ធិសញ្ញាសិទ្ធិមនុស្សស្នូល (មានសន្ធិសញ្ញាសិទ្ធិមនុស្សទាំងអស់៩ និងពិធីសារបន្ថែមនៃអនុសញ្ញាប្រឆាំងទារុណកម្ម)។ ស្ថាប័នសន្ធិសញ្ញា គឺជាគណៈកម្មាធិការនៃអ្នកជំនាញឯករាជ្យ និងមានសមត្ថភាពសិទ្ធិមនុស្សដែលគេទទួលស្គាល់ ដែលត្រូវបានតែងតាំង និងបោះឆ្នោតជ្រើសរើសដោយរដ្ឋភាគីនៃសន្ធិសញ្ញាសំរាប់អណត្តិកំណត់រយៈពេល៤ឆ្នាំ ហើយអាចបោះឆ្នោតជាថ្មីបាន។

រដ្ឋភាគីនីមួយៗនៃសន្ធិសញ្ញា មានកាតព្វកិច្ចចាត់វិធានការ ដើម្បីធានាថា បុគ្គលគ្រប់រូបនៅក្នុងរដ្ឋរបស់ខ្លួនអាចទទួលបានសិទ្ធិនានាដូចមានចែងក្នុងសន្ធិសញ្ញា។ ដើម្បីសំរេចគោលបំណងនេះ រដ្ឋត្រូវដាក់របាយការណ៍តាមកាលកំណត់របស់ខ្លួន("របាយការណ៍រដ្ឋ") ជូនស្ថាប័នសន្ធិសញ្ញាសាមីអំពីការអនុវត្តតាម

កាតព្វកិច្ចសន្ធិសញ្ញានោះ។ របាយការណ៍រដ្ឋដំបូងត្រូវដាក់ជូនស្ថាប័នសន្ធិសញ្ញាក្នុងរយៈពេល២ឆ្នាំ ក្រោយពីការផ្តល់សច្ចាប័នលើសន្ធិសញ្ញានោះ ហើយបន្ទាប់មកទៀត ត្រូវដាក់ជូនរៀងរាល់៤ ឬ៥ឆ្នាំម្តង។ ស្ថាប័នសន្ធិសញ្ញា ពិភាក្សារបាយការណ៍រដ្ឋនៅក្នុងសម័យប្រជុំរបស់ខ្លួន ជាមួយតំណាងរបស់រដ្ឋនីមួយៗដែលពាក់ព័ន្ធ។ អង្គការមិនមែនរដ្ឋាភិបាល និងស្ថាប័នជាតិសិទ្ធិមនុស្សតែងតែចងក្រងព័ត៌មានបន្ថែមសំរាប់ដាក់ជូនស្ថាប័នសន្ធិសញ្ញាក្នុងទម្រង់មួយដែលហៅថា "របាយការណ៍ប្រៀបធៀប" ឬ "របាយការណ៍ស្រមោល"។

ក្រោយពីការពិនិត្យលើរបាយការណ៍រដ្ឋរួច ស្ថាប័នសន្ធិសញ្ញានីមួយៗចេញ"សេចក្តីសង្កេតសន្និដ្ឋាន" ដែលមានការវាយតំលៃរួមរបស់ខ្លួនពីការរីកចំរើននិងចំណុចខ្វះខាតនៅក្នុងការអនុវត្តសន្ធិសញ្ញាសិទ្ធិមនុស្ស និងអនុសាសន៍ឱ្យមានការកែលំអដល់ការសំរេចបាននូវសិទ្ធិទាំងនេះ។ អនុសាសន៍ចុងក្រោយពីស្ថាប័នសន្ធិសញ្ញាចំនួន៦ខាងក្រោមនេះ ត្រូវបានឆ្លុះបញ្ចាំងនៅក្នុងឯកសារបោះពុម្ពនេះ ដោយសារតែអនុសាសន៍ទាំងនេះពាក់ព័ន្ធនឹងអនុសាសន៍UPR៖

- គណៈកម្មាធិការសិទ្ធិមនុស្ស(CCPR) ឃ្លាំមើលការអនុវត្តកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ(១៩៦៦) និងពិធីសារបន្ថែមនៃកាតិកាសញ្ញានេះ។
- គណៈកម្មាធិការសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ចនិងវប្បធម៌(CESCR) ឃ្លាំមើលការអនុវត្តកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌(១៩៦៦)
- គណៈកម្មាធិការលុបបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍(CERD) ឃ្លាំមើលការអនុវត្តអនុសញ្ញាអន្តរជាតិស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍(១៩៦៥)
- គណៈកម្មាធិការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនារីភេទ (CEDAW) ឃ្លាំមើលការអនុវត្តអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនារីភេទ(១៩៧៩) និងពិធីសារបន្ថែម (១៩៩៩)
- គណៈកម្មាធិការប្រឆាំងទារុណកម្ម(CAT) ឃ្លាំមើលការអនុវត្តអនុសញ្ញាប្រឆាំងទារុណកម្ម និងការប្រព្រឹត្ត ឬទណ្ឌកម្មឯទៀតដែលឃោរឃៅ អមនុស្សធម៌ និងបន្ទាបបន្ថោក(១៩៨៤)
- គណៈកម្មាធិការសិទ្ធិកុមារ(CRC) ឃ្លាំមើលការអនុវត្តអនុសញ្ញាស្តីពីសិទ្ធិកុមារ(១៩៨៩) និងពិធីសារបន្ថែមទាំងពីរ(២០០០)

កម្ពុជាក៏ជារដ្ឋភាគីនៃអនុសញ្ញាស្តីពីការការពារជនគ្រប់រូបពីការបាត់ខ្លួនដោយបង្ខំ(CED) និងអនុសញ្ញាស្តីពីសិទ្ធិជនពិការ(CRPD)ដែរ ក៏ប៉ុន្តែកម្ពុជាមិនទាន់បានដាក់របាយការណ៍របស់ខ្លួនជូនស្ថាប័នសន្ធិសញ្ញានីមួយៗនៃអនុសញ្ញាទាំងពីរនេះនៅឡើយទេ ហេតុដូច្នេះ ក៏មិនទាន់មានអនុសាសន៍ណាមួយទាក់ទងនឹងអនុសញ្ញាទាំងពីរនេះដែរ (របាយការណ៍CRPD ត្រូវដល់កាលបរិច្ឆេទកាលពីថ្ងៃទី២០ មករា ឆ្នាំ២០១៥ និងរបាយការណ៍CED ត្រូវដល់កាលបរិច្ឆេទកាលពីថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៥)។

ខាងក្រោមនេះ គឺជាស្ថានភាពរបាយការណ៍សំរាប់ស្ថាប័នសន្ធិសញ្ញាដូចបានរៀបរាប់ខាងលើ៖

- ✓ CCPR៖ របាយការណ៍បន្ទាប់ ត្រូវដល់កាលបរិច្ឆេទនៅខែមេសា ឆ្នាំ២០១៩
- ✓ CESCR៖ របាយការណ៍បន្ទាប់ ត្រូវដល់កាលបរិច្ឆេទកាលពីថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១២
- ✓ CERD៖ របាយការណ៍បន្ទាប់ ត្រូវដល់កាលបរិច្ឆេទកាលពីថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១២
- ✓ CEDAW៖ របាយការណ៍បន្ទាប់ ត្រូវដល់កាលបរិច្ឆេទនៅថ្ងៃទី១ ខែតុលា ឆ្នាំ២០១៧
- ✓ CAT៖ របាយការណ៍បន្ទាប់ ត្រូវដល់កាលបរិច្ឆេទកាលពីថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១៤
- ✓ CRC៖ របាយការណ៍បន្ទាប់ ត្រូវដល់កាលបរិច្ឆេទនៅថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០១៨

### *នីតិវិធីពិសេសនៃក្រុមប្រឹក្សាសិទ្ធិមនុស្ស*

នីតិវិធីពិសេសនៃក្រុមប្រឹក្សាសិទ្ធិមនុស្សគឺជាអ្នកជំនាញការសិទ្ធិមនុស្សឯករាជ្យ ឬក្រុមនៃអ្នកជំនាញបែបនេះដែលរាយការណ៍ និងប្រឹក្សាយោបល់អំពីសិទ្ធិមនុស្សតាមទស្សនៈវិស័យប្រធានបទឬទស្សនៈវិស័យតាមប្រទេសជាក់លាក់។ អ្នកជំនាញការទាំងនេះរួមមាន អ្នករាយការណ៍ពិសេស តំណាងពិសេស ក្រុមការងារនិងអ្នកជំនាញឯករាជ្យ។ គិតត្រឹមខែមិថុនា ឆ្នាំ២០១៥ ក្រុមប្រឹក្សាសិទ្ធិមនុស្ស មើលខុសត្រូវលើអាណត្តិអ្នករាយការណ៍ពិសេសតាមប្រធានបទ ចំនួន៤១ និងអ្នករាយការណ៍ពិសេសតាមប្រទេស ចំនួន១៤ គ្របដណ្តប់លើសិទ្ធិមនុស្សទាំងអស់ ពោលគឺសិទ្ធិពលរដ្ឋ នយោបាយ សេដ្ឋកិច្ច សង្គមកិច្ច និងសិទ្ធិវប្បធម៌។

អ្នកកាន់អាណត្តិនីតិវិធីពិសេស បំរើការងារក្នុងសមត្ថភាពផ្ទាល់ខ្លួនរបស់ខ្លួន មានន័យថាពួកគេមិនមែនជាសមាជិកបុគ្គលិកសហប្រជាជាតិ មិនទទួលប្រាក់បៀវត្សសំរាប់ការងារ ហើយមិនតំណាងឱ្យប្រទេសរបស់ពួកគេ ឬផលប្រយោជន៍ពិសេសសំរាប់ក្រុមណាមួយ។ អ្នកកាន់អាណត្តិនីមួយៗ អាចបំរើការងារយ៉ាងយូរ៦ឆ្នាំ។ឋានៈឯករាជ្យនេះ មានបំណងអនុញ្ញាតិឱ្យអ្នកជំនាញទាំងនេះ អនុវត្តមុខងាររបស់ខ្លួនដោយមិនលំអៀង។ ក្នុងការបំពេញការទទួលខុសត្រូវរបស់ខ្លួន អ្នកកាន់អាណត្តិទទួលបានការគាំទ្រពីការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស(OHCHR)។

អាណត្តិរបស់អ្នករាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា ផ្អែកលើកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស ដែលបានចុះហត្ថលេខាកាលពីឆ្នាំ១៩៩៣។ តួនាទីរបស់អ្នករាយការណ៍ពិសេស គឺវាយតំលៃអំពីស្ថានភាពសិទ្ធិមនុស្ស រាយការណ៍ជាសាធារណៈពីស្ថានភាពនេះ និងធ្វើការជាមួយរដ្ឋាភិបាល សង្គមស៊ីវិលនិងអ្នកដទៃទៀត ដើម្បីជំរុញកិច្ចសហប្រតិបត្តិការអន្តរជាតិនៅក្នុងវិស័យនេះ។ អ្នករាយការណ៍ពិសេសធ្វើទស្សនកិច្ច ឬបំពេញបេសកកម្មទៀងទាត់មកកាន់កម្ពុជា និងរាយការណ៍ប្រចាំឆ្នាំជូនក្រុមប្រឹក្សាសិទ្ធិមនុស្ស។ ការិយាល័យOHCHR ផ្តល់ជំនួយបច្ចេកទេស និងភស្តុភារដល់អ្នករាយការណ៍ពិសេស។ អ្នករាយការណ៍ពិសេសសព្វថ្ងៃគឺលោកស្រីសាស្ត្រាចារ្យ រ៉ូណា ស្មឹត (ជនជាតិអង់គ្លេស) លោកស្រីត្រូវបានតែងតាំងជាអ្នករាយការណ៍ពិសេស កាលពីខែមីនា ឆ្នាំ២០១៥។ របាយការណ៍របស់អ្នករាយការណ៍ពិសេសប្រចាំប្រទេសដូចខាងក្រោមនេះ ត្រូវបានឆ្លុះបញ្ចាំងនៅក្នុងកម្រងឯកសារបោះពុម្ពនេះ។

A/HRC/7/42: 2008

A/HRC/15/46: 2010

A/HRC/18/46: 2011

A/HRC/21/63: 2012

A/HRC/21/63/Add.1/Rev.1: 2012

A/HRC/24/36: 2013

A/HRC/27/70: 2014

កម្ពុជា មិនទាន់បានទទួលយកដំណើរទស្សនកិច្ចជាផ្លូវការដោយនីតិវិធីពិសេសតាមប្រធានបទនៅឡើយទេ លើកលែងតែដំណើរទស្សនកិច្ចឆ្នាំ២០០៥ របស់អ្នករាយការណ៍ពិសេសស្តីពីលំនៅដ្ឋានសមរម្យថាជាផ្នែកមួយនៃសិទ្ធិមានកំរិតជីវភាពសមរម្យ។ អនុសាសន៍របស់គាត់ក៏មានរួមបញ្ចូលនៅក្នុងកម្រងឯកសារបោះពុម្ពនេះដែរ ក្រោមអត្ថបទយោង E/CN.4/2006/41/Add.3.

# I. ការផ្តល់សច្ចាប័ន និងការចូលជាសមាជិកសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិ និងសន្ធិសញ្ញាពាក់ព័ន្ធនានា ព្រមទាំងកិច្ចសហប្រតិបត្តិការជាមួយនឹងប្រព័ន្ធសិទ្ធិមនុស្សសហប្រជាជាតិ និងសហគមន៍អន្តរជាតិ រួមទាំងតុលាការឧក្រិដ្ឋកម្មអន្តរជាតិ

## *ក. ការផ្តល់សច្ចាប័ន*

| *អនុសាសន៍នៃការពិនិត្យជាសកលតាមកាលកំណត់ (២០១៨)* |
|---|
| ១១៨.៦. ផ្តល់សច្ចាប័នដល់អនុសញ្ញាអន្តរជាតិស្តីពីការការពារសិទ្ធិរបស់ពលករទេសន្តរប្រវេសន៍ទាំងអស់ និងសមាជិកគ្រួសាររបស់ពួកគេ។ (អេក្វាឌ័រ)<br>១១៨.៧. ពិចារណាផ្តល់សច្ចាប័នដល់អនុសញ្ញាអន្តរជាតិស្តីពីការការពារសិទ្ធិរបស់ពលករទេសន្តរប្រវេសន៍ទាំងអស់ និងសមាជិកគ្រួសាររបស់ពួកគេ ដែលខ្លួនបានចុះហត្ថលេខាក្នុងឆ្នាំ២០០៤។ (អេហ្ស៊ីប)<br>១១៨.៨. ចាត់វិធានការចាំបាច់នានា ដើម្បីផ្តល់សច្ចាប័នដល់អនុសញ្ញាអន្តរជាតិស្តីពីការការពារសិទ្ធិរបស់ពលករទេសន្តរប្រវេសន៍ទាំងអស់ និងសមាជិកគ្រួសាររបស់ពួកគេ។ (ហ្គាណា)<br>១១៨.៩. ផ្តល់សច្ចាប័នដល់អនុសញ្ញារបស់ UNESCO ប្រឆាំងការរើសអើងនៅក្នុងការអប់រំ។ (ប្រេស៊ីល)<br>១១៨.១០. ផ្តល់សច្ចាប័នដល់អនុសញ្ញារបស់ UNESCO ប្រឆាំងការរើសអើងនៅក្នុងការអប់រំ។ (ឆាដ)<br>១១៨.១១. ចាត់វិធានការផ្តល់សច្ចាប័នអនុសញ្ញារបស់UNESCO ប្រឆាំងការរើសអើងនៅក្នុងការអប់រំ។ (អូទ្រីស)<br>១១៨.១២. បន្តដំណើរការទទួលយកលិខិតូបករណ៍សិទ្ធិមនុស្សស្នូល។ (អារ៉ាប៊ីសាអូឌីត) |
| *អនុសាសន៍នៃការពិនិត្យជាសកលតាមកាលកំណត់ (២០០៩)* |
| ១. សូមពិចារណាផ្តល់សច្ចាប័នលើអនុសញ្ញាអន្តរជាតិដើម្បីការពារដល់ជនគ្រប់រូបពីការបាត់ខ្លួនដោយបង្ខំ(CED) និងអនុសញ្ញាស្តីពីសិទ្ធិជនពិការ(CRPD) ពិធីសារបន្ថែមចំនួនពីរនៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ(ICCPR) ពិធីសារបន្ថែមនៃអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ និងCRPD និងអនុសញ្ញាលេខ១៦៩ របស់អង្គការពលកម្មអន្តរជាតិ និងសូមប្រតិបត្តិតាមគោលដៅសិទ្ធិមនុស្ស ដែលកំណត់ដោយសេចក្តីសម្រេចលេខ៩/១២ របស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស។ (ប្រេស៊ីល)<br>២. សូមចុះហត្ថលេខានិងផ្តល់សច្ចាប័នCED និងពិធីសារបន្ថែមនៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌(ICESCR)។ សូមផ្តល់សច្ចាប័នលើពិធីសារបន្ថែមនៃ ICCPR ពិធីសារបន្ថែមនៃ CEDAW និង CRPD និងពិធីសារបន្ថែមនៃអនុសញ្ញានេះ។ (អេស្ប៉ាញ) |

៣. សូមពិចារណាផ្តល់សច្ចាប័នលើអនុសញ្ញា CRPD និងធានាឲ្យមានការអនុវត្តតាមអនុសញ្ញានេះទាំងស្រុងនៅក្នុងច្បាប់ជាតិ។ (ណូវែលហ្សេឡង់)

៤. សូមពិចារណាផ្តល់សច្ចាប័នលើពិធីសារបន្ថែមនៃអនុសញ្ញា CEDAW ដែលត្រូវបានចុះហត្ថលេខាកាលពីឆ្នាំ ២០០១។ (ស្លូវ៉ាគី)

### *គណៈកម្មាធិការសិទ្ធិមនុស្ស* (CCPR/C/SR.3157) (២០១៥)

៥. [...] ម្យ៉ាងវិញទៀត គណៈកម្មាធិការជម្រុញលើកទឹកចិត្តឲ្យរដ្ឋភាគី ចូលជាសមាជិកនៃពិធីសារបន្ថែមនៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ពាក់ព័ន្ធនឹងនីតិវិធីបណ្តឹងបុគ្គល។

### *គណៈកម្មាធិការសិទ្ធិកុមារ៖ កុមារក្នុងជម្លោះប្រដាប់អាវុធ* (២០១៥)

CRC/C/OPAC/KHM/CO/1

៣៤. គណៈកម្មាធិការផ្តល់អនុសាសន៍ថា ដើម្បីពង្រឹងបន្ថែមទៀតដល់ការអនុវត្តសិទ្ធិកុមារ រដ្ឋភាគីផ្តល់សច្ចាប័នលើពិធីសារបន្ថែមនៃអនុសញ្ញាសិទ្ធិកុមារស្តីពីនីតិវិធីបណ្តឹង។

### *គណៈកម្មាធិការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ* (២០១៣)

CEDAW/C/KHM/CO/4-5

៩. គណៈកម្មាធិការបញ្ជាក់ឡើងវិញពីអនុសាសន៍មុនៗរបស់ខ្លួន (CEDAW/C/KHM/CO/3, កថាខណ្ឌទី១០) និងផ្តល់អនុសាសន៍ឲ្យរដ្ឋភាគី បោះពុម្ពផ្សាយអនុសញ្ញា និងពិធីសារបន្ថែមនៃអនុសញ្ញា នៅក្នុងរាជកិច្ចដោយឥតបង្អង់តទៅទៀត និងបន្តពិនិត្យឡើងវិញលើនីតិកម្មរបស់ខ្លួន ដើម្បីដាក់បញ្ចូលបញ្ញត្តិទាំងអស់របស់អនុសញ្ញាទៅក្នុងច្បាប់ជាតិ។

៣៥.គ). ពិចារណាចូលជាសមាជិកនៃអនុសញ្ញា ILO លេខ១៨៩ ស្តីពី ការងារសមរម្យសម្រាប់អ្នកបម្រើការងារតាមផ្ទះ និងអនុសញ្ញាស្តីពីការការពារពលករទេសន្តរប្រវេសន៍គ្រប់រូប និងសមាជិកគ្រួសាររបស់ពួកគេ។

### *គណៈកម្មាធិការស្តីពីសិទ្ធិកុមារ* CRC/C/KHM/CO/2-3 (២០១១)

៨១. គណៈកម្មាធិការសូមអំពាវនាវឱ្យរដ្ឋភាគីធ្វើជាបន្ទាន់នូវរបាយការណ៍ដំបូងរបស់ខ្លួនស្តីពីពិធីសារបន្ថែមទាំងពីរនៃអនុសញ្ញាស្តីពីសិទ្ធិកុមារ។ ដើម្បីពង្រឹងបន្ថែមទៀតនូវការសម្រេចបាននូវសិទ្ធិកុមារ គណៈកម្មាធិការក៏សូមលើកទឹកចិត្តរដ្ឋភាគីឱ្យចូលជាសមាជិកនៃលិខិតុបករណ៍សិទ្ធិមនុស្សសំខាន់ៗទាំងអស់ រួមទាំងអនុសញ្ញាស្តីពីសិទ្ធិជនពិការ អនុសញ្ញាអន្តរជាតិស្តីពីការការពារសិទ្ធិកម្មករទេសន្តរប្រវេសន៍ និងសមាជិកគ្រួសារទាំងអស់របស់ពួកគេ និងអនុសញ្ញាអន្តរជាតិស្តីពីការការពារមនុស្សទាំងអស់ពីការបាត់ខ្លួនដោយបង្ខំ។

| |
|---|
| *គណៈកម្មាធិការប្រឆាំងទារុណកម្ម* CAT/C/KHM/CO/2 (២០១០) |
| ៣៤. គណៈកម្មាធិការស្នើសុំអញ្ជើញរដ្ឋភាគី ពិចារណាលើការផ្តល់សច្ចាប័នដល់សន្ធិសញ្ញាសិទ្ធិមនុស្សសំខាន់ៗរបស់អង្គការសហប្រជាជាតិដែលប្រទេសកម្ពុជាមិនទាន់ចូលជាភាគី ជាពិសេសអនុសញ្ញាអន្តរជាតិស្តីពីការការពារសិទ្ធិពលករទេសន្តរប្រវេសន៍គ្រប់រូប និងសមាជិកគ្រួសាររបស់ពួកគេ អនុសញ្ញាស្តីពីសិទ្ធិជនពិការ និងអនុសញ្ញាអន្តរជាតិស្តីពីការការពារមនុស្សទាំងអស់ពីការបាត់ខ្លួនដោយបង្ខំ។ |
| *គណៈកម្មាធិការលុបបំបាត់ការរើសអើងពូជសាសន៍* CERD/C/KHM/CO/8-13 (២០១០) |
| ២១. ដោយចងចាំអំពីអវិភាគភាពនៃសិទ្ធិមនុស្សទាំងអស់ គណៈកម្មាធិការជំរុញលើកទឹកចិត្តរដ្ឋភាគីឲ្យពិចារណាអំពីការផ្តល់សច្ចាប័នលើសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិទាំងឡាយ ដែលរដ្ឋភាគីនៅមិនទាន់បានផ្តល់សច្ចាប័ននៅឡើយ ជាពិសេស សន្ធិសញ្ញាដែលបញ្ញត្តិរបស់វាមានពាក់ព័ន្ធដោយផ្ទាល់នឹងការរើសអើងពូជសាសន៍ មានជាអាទិ៍ អនុសញ្ញាអន្តរជាតិស្តីពីការការពារសិទ្ធិពលករទេសន្តរប្រវេសន៍និងសមាជិកគ្រួសារទាំងអស់របស់ពួកគេ(១៩៩០) |
| *គណៈកម្មាធិការសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌* E/C.12/KHM/CO/1 (២០០៩) |
| ៤៤. គណៈកម្មាធិការជំរុញលើទឹកចិត្តដល់រដ្ឋភាគីឲ្យពិចារណាចុះហត្ថលេខា និងផ្តល់សច្ចាប័នលើពិធីសារបន្ថែមនៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌។<br>៤៥. គណៈកម្មាធិការជំរុញលើកទឹកចិត្តផងដែរដល់រដ្ឋភាគី ឲ្យពិចារណាផ្តល់សច្ចាប័នលើអនុសញ្ញារបស់អង្គការពលកម្មអន្តរជាតិ (ILO) លេខ៨១ស្តីពីអធិការកិច្ចការងារក្នុងវិស័យឧស្សាហកម្ម និងពាណិជ្ជកម្ម(១៩៤៧) និងអនុសញ្ញាលេខ១០២ស្តីពីបទដ្ឋានអប្បបរមានៃការធានារ៉ាប់រងផ្នែកសង្គម(របបសន្តិសុខសង្គម)(១៩៥២) |

## ខ. *កិច្ចសហប្រតិបត្តិការជាមួយយន្តការសិទ្ធិមនុស្ស និងស្ថាប័នសិទ្ធិមនុស្ស*

| |
|---|
| *អនុសាសន៍នៃការពិនិត្យជាសកលតាមកាលកំណត់* (២០១៤) |
| ១១៨. ៤៤. ពិចារណាសហប្រតិបត្តិបន្ថែមទៀតជាមួយយន្តការត្រួតពិនិត្យតាមដានសិទ្ធិមនុស្សអន្តរជាតិ រួមទាំងស្ថាប័នសន្ធិសញ្ញា និងនីតិវិធីពិសេសនៃក្រុមប្រឹក្សាសិទ្ធិមនុស្ស។ (ទួកមេនីស្ថាន) |
| *អនុសាសន៍នៃការពិនិត្យជាសកលតាមកាលកំណត់* (២០០៩) |
| ១៧. សូមដាក់របាយការណ៍ដែលមិនទាន់បានបញ្ជូនជូនស្ថាប័នសន្ធិសញ្ញាពាក់ព័ន្ធនានា។ (ប៉ាគីស្ថាន) |

### *គណៈកម្មាធិការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ* (២០១៣)

CEDAW/C/KHM/CO/4-5

៥០. គណៈកម្មាធិការស្នើឲ្យរដ្ឋភាគីផ្តល់ព័ត៌មានជាលាយលក្ខណ៍អក្សរអំពីវិធានការដែលត្រូវបានចាត់ឡើង ក្នុងការអនុវត្តអនុសាសន៍ក្នុងកថាខណ្ឌទី១៥ និងទី២១ ចំណុច(ក), (ខ) និង(គ) ក្នុងរយៈពេលពីរឆ្នាំ។

៥១. គណៈកម្មាធិការស្នើឲ្យរដ្ឋភាគីដាក់ជូនរបាយការណ៍គួបលើកទី៦ ក្នុងខែតុលា ឆ្នាំ២០១៧។

៥២. គណៈកម្មាធិការស្នើឲ្យរដ្ឋភាគីគោរពតាម "គោលការណ៍ណែនាំសុខុដុមនីយកម្មស្តីពីការធ្វើរបាយការណ៍តាមសន្ធិសញ្ញាសិទ្ធិមនុស្សជាក់លាក់ រាប់បញ្ចូលទាំងគោលការណ៍ណែនាំស្តីពីឯកសារគោលរួម និងឯកសារតាមសន្ធិសញ្ញានីមួយៗ" (HRI/MC/2006/3 និង Corr.1)។

### *គណៈកម្មាធិការស្តីពីសិទ្ធិកុមារ* CRC/C/KHM/CO/2-3 (២០១១)

៨៥. គណៈកម្មាធិការសូមអញ្ជើញរដ្ឋភាគីឱ្យធ្វើរបាយការណ៍បន្ទាប់របស់ខ្លួន ដោយដាក់បញ្ចូលគ្នាពីលើកទី៤ ទៅដល់លើកទី៦ ត្រឹមថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨។ គណៈកម្មាធិការសូមឱ្យយកចិត្តទុកដាក់ដល់គោលការណ៍ណែនាំសុខុដុមនីយកម្មស្តីពីការធ្វើរបាយការណ៍តាមសន្ធិសញ្ញាសិទ្ធិមនុស្សជាក់លាក់របស់ខ្លួន ដែលអនុម័តនៅថ្ងៃទី០១ ខែតុលា ឆ្នាំ២០១០ (CRC/C//58Rev.2) និងសូមរំលឹករដ្ឋភាគីថា របាយការណ៍អនាគតរបស់ខ្លួន ត្រូវស្របតាមគោលការណ៍ណែនាំនេះនិងមិនត្រូវលើសពី៦០ទំព័រឡើយ។ គណៈកម្មាធិការទទូចឱ្យរដ្ឋភាគីធ្វើរបាយការណ៍ស្របតាមគោលការណ៍ណែនាំនៃការធ្វើរបាយការណ៍នេះ។ ប្រសិនបើរបាយការណ៍លើសពីទំព័រដែលបានកម្រិតត្រូវបានផ្ញើទៅនោះ រដ្ឋភាគីនឹងត្រូវបានសំណូមពរឱ្យពិនិត្យឡើងវិញ និងត្រូវធ្វើរបាយការណ៍នេះ ស្របតាមគោលការណ៍ណែនាំខាងលើ។ គណៈកម្មាធិការសូមរំលឹករដ្ឋភាគីថា ប្រសិនបើខ្លួនមិនអាចពិនិត្យឡើងវិញទេនោះ ការបកប្រែរបាយការណ៍ទៅជាភាសាសហប្រជាជាតិ សំរាប់គោលដៅនៃការពិនិត្យដោយស្ថាប័នសន្ធិសញ្ញានោះ មិនអាចត្រូវបានធានាឡើយ។

### *គណៈកម្មាធិការលុបបំបាត់ការរើសអើងពូជសាសន៍* CERD/C/KHM/CO/8-13 (២០១០)

២៧. ដោយកត់សំគាល់ថា រដ្ឋភាគីបានដាក់ជូនឯកសារខ្លឹមសាររួមរបស់ខ្លួន ក្នុងឆ្នាំ១៩៩៨ រួចហើយ គណៈកម្មាធិការជំរុញលើកទឹកចិត្តរដ្ឋភាគីឲ្យដាក់ជូនសំណៅឯកសារដែលបានធ្វើបច្ចុប្បន្នភាពស្របតាមគោលការណ៍ណែនាំស្របគ្នាស្តីពីការធ្វើរបាយការណ៍ ក្រោមសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិ ជាពិសេស គោលការណ៍ណែនាំស្តីពីឯកសារខ្លឹមរួម [...]

២៨. អនុលោមតាមមាត្រា៩ កថាខ័ណ្ឌទី១ នៃអនុសញ្ញានេះ និងវិធាន៦៥ នៃនីតិវិធីដែលបានធ្វើវិសោធនកម្មរបស់ខ្លួន គណៈកម្មាធិការស្នើឲ្យរដ្ឋភាគី ផ្តល់ព័ត៌មានក្នុងអំឡុងពេលមួយឆ្នាំ ចាប់ពីថ្ងៃអនុម័តសេចក្តីសន្និដ្ឋាននេះ ស្តីពីការងារតាមដានបន្តដល់អនុសាសន៍ទាំងឡាយដែលមានចែងក្នុងកថាខ័ណ្ឌទី១៥, ១៦,១៧និង១៨ខាងលើ។

| |
|---|
| ២៩. គណៈកម្មាធិការមានបំណងផងដែរ ដើម្បីទាញចំណាប់អារម្មណ៍រដ្ឋភាគីទៅលើសារសំខាន់ជាក់លាក់នៃអនុសាសន៍លេខ១១, ១៣ និង២០ និងស្នើឲ្យរដ្ឋភាគីផ្តល់ព័ត៌មានលំអិតក្នុងរបាយការណ៍តាមកាលកំណត់លើកក្រោយរបស់ខ្លួនស្តីពីវិធានការជាក់ស្តែងដែលបានចាត់ ដើម្បីអនុវត្តន៍អនុសាសន៍ទាំងនេះ។<br>៣០. គណៈកម្មាធិការផ្តល់អនុសាសន៍ថារដ្ឋភាគីដាក់ជូនរបាយការណ៍តាមកាលកំណត់លើកទី១៤និងទី១៥ របស់ខ្លួន ក្នុងឯកសារតែមួយដែលត្រូវដល់ពេលកំណត់នៅថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១២ ដោយគិតអំពីគោលការណ៍ណែនាំសំរាប់ឯកសារជាក់លាក់ CERD ដែលបានអនុម័តដោយគណៈកម្មាធិការក្នុងសម័យប្រជុំលើកទី៧១ របស់ខ្លួន(CERD/C/2007/1) ហើយថា របាយការណ៍នោះត្រូវដោះស្រាយគ្រប់ចំណុចទាំងអស់ដែលបានលើកឡើងក្នុងសេចក្តីសង្កេតចុងក្រោយនេះ។ |
| *គណៈកម្មាធិការប្រឆាំងទារុណកម្ម* CAT/C/KHM/CO/2 (២០១០) |
| ៣៦. គណៈកម្មាធិការស្នើឲ្យរដ្ឋភាគី ផ្តល់ព័ត៌មានស្តីពីការឆ្លើយតបរបស់ខ្លួនទៅនឹងអនុសាសន៍នានារបស់គណៈកម្មាធិការ ដែលមាននៅក្នុងកថាខណ្ឌ១២ ១៤ ១៦ ២៦ និង២៧ ក្នុងរយៈពេលមួយឆ្នាំ។<br>៣៧. គណៈកម្មាធិការស្នើឲ្យរដ្ឋភាគីដាក់ជូននូវរបាយការណ៍បន្ទាប់តាមកាលកំណត់ អនុលោមតាមគោលការណ៍ស្តីពីការធ្វើរបាយការណ៍របស់ខ្លួន និងគោរពតាមការកំណត់ទំព័រចំនួន៤០ទំព័រ សម្រាប់ឯកសារជាក់លាក់តាមសន្ធិសញ្ញានីមួយៗ។ គណៈកម្មាធិការក៏ស្នើឲ្យរដ្ឋភាគី ដាក់ជូនឯកសារគោលរួមដែលធ្វើបច្ចុប្បន្នភាព ស្របតាមលក្ខខណ្ឌតម្រូវឯកសារគោលរួម ហើយ[...]គោរពតាមការកំណត់ទំព័រចំនួន៨០ទំព័រសម្រាប់ឯកសារគោលរួម។ ឯកសារជាក់លាក់តាមសន្ធិសញ្ញា និងឯកសារគោលរួមទាំងពីរនេះ បង្កើតឲ្យមានកាតព្វកិច្ចធ្វើរបាយការណ៍របស់រដ្ឋភាគី ដោយអនុលោមតាមអនុសញ្ញា។<br>៣៨. រដ្ឋភាគីត្រូវបានអញ្ជើញឲ្យដាក់ជូនរបាយការណ៍តាមពេលកំណត់លើកទីបីរបស់ខ្លួន នៅថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១៤។ |
| *គណៈកម្មាធិការសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌* E/C.12/KHM/CO/1 (២០០៩) |
| ៤៨. គណៈកម្មាធិការអញ្ជើញរដ្ឋភាគីឲ្យដាក់ស្នើឯកសារខ្លឹមសាររួមនៃរបាយការណ៍ស្របតាមគោលការណ៍ណែនាំទូទៅស្តីពីការធ្វើរបាយការណ៍សំរាប់ដាក់ជូនស្ថាប័នឃ្លាំមើលការអនុវត្តន៍សន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិ (HRI/GEN/2/Rev.5)<br>៤៩. គណៈកម្មាធិការស្នើឲ្យរដ្ឋភាគីដាក់ស្នើបញ្ចូលគ្នានូវរបាយការណ៍តាមកាលកំណត់លើកទីប្រាំ និងលើកទី៦ របស់ខ្លួន ស្របតាមគោលការណ៍ណែនាំស្តីពីការធ្វើរបាយការណ៍តាមសន្ធិសញ្ញាជាក់លាក់របស់គណៈកម្មាធិការ (E/C.12/2008/2) ត្រឹមថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១២។ |

| |
|---|
| ### *អ្នករាយការណ៍ពិសេស* |
| A/HRC/27/70 Para 81(o). ពិនិត្យឡើងវិញពីគោលជំហររបស់ខ្លួនលើអនុសាសន៍នានាដែលបានពីការពិនិត្យជាសកលតាមកាលកំណត់ដែលកម្ពុជាជាប់កាតព្វកិច្ចតាមផ្លូវច្បាប់ ដោយសារតែខ្លួនជារដ្ឋភាគីមួយនៃសន្ធិសញ្ញាអន្តរជាតិ និងត្រូវចាត់វិធានការអនុវត្តអនុសាសន៍ទាំងអស់នោះ ព្រមទាំងអនុសាសន៍ទាំងឡាយណាដែលបានទទួលយកយ៉ាងជាក់ច្បាស់ទាំងនៅក្នុងច្បាប់ទាំងការអនុវត្តន៍។<br>A/HRC/33/62, Para 61(a). ពិនិត្យឡើងវិញនូវអនុសាសន៍ដែលលេចធ្លោ ស្នើដោយអ្នករាយការណ៍ពិសេស ស្ថាប័នសន្ធិសញ្ញា និងរដ្ឋសមាជិកនានា (នៅក្នុងបរិបទនៃការពិនិត្យជាសកលតាមកាលកំណត់) ដើម្បីរៀបចំសេចក្ដីព្រាងស្ដីពីយុទ្ធសាស្ត្រអនុវត្ត ដោយមានកាលកំណត់ជាក់លាក់។<br>A/HRC/33/62 Para 61(v). រៀបចំ និងរក្សាកាលបរិច្ឆេទធ្វើការងារសំរាប់កាតព្វកិច្ចធ្វើរបាយការណ៍តាមសន្ធិសញ្ញាដែលរដ្ឋជាភាគី ខណៈដែលកំពុងបន្តរៀបចំយុទ្ធសាស្ត្រពិគ្រោះយោបល់ទូលំទូលាយ ដើម្បីផ្សព្វផ្សាយពីការរៀបចំធ្វើរបាយការណ៍។<br>A/HRC/33/62 Para 61(x). បង្កើយអនុស្សារណៈនៃការយោគយល់ជាមួយអង្គការសហប្រជាជាតិ ដើម្បីធានាពីដំណើរការបន្តទៀតនៃការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា។ |

## *គ. កិច្ចសហប្រតិបត្តិការជាមួយនីតិវិធីពិសេស*

| |
|---|
| ### *អនុសាសន៍នៃការពិនិត្យជាសកលតាមកាលកំណត់ (២០១៤)* |
| **១១៨.៤៥.** បន្តសហប្រតិបត្តិការជាមួយអាណត្តិរបស់អ្នករាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា និងអនុវត្តអនុសាសន៍របស់គាត់។ (អូទ្រីស)<br>**១១៨.៤៦.** ខិតខំរក្សាទំនាក់ទំនងការងារប្រកបដោយន័យស្ថាបនាជាមួយអ្នករាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិ មនុស្សនៅកម្ពុជាទាក់ទងនឹងឯករាជ្យភាពរបស់គាត់ និងរបស់ការិយាល័យ OHCHR។ (បែលហ្ស៊ិក)<br>**១១៨.៤៧.** [...] និងទទួលយកសំណើទស្សនកិច្ចដោយអ្នករាយការណ៍ពិសេសនានា។ (ស្វីស) |
| ### *អនុសាសន៍នៃការពិនិត្យជាសកលតាមកាលកំណត់ (២០០៩)* |
| **១៨.**សូមពិចារណាផ្តល់ការអញ្ជើញជាអចិន្ត្រៃយ៍ដល់នីតិវិធីពិសេសទទួលបន្ទុកសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ។ (សាធារណៈរដ្ឋឆែក)<br>សូមផ្តល់ និងអនុវត្តការអញ្ជើញជាអចិន្ត្រៃយ៍ដល់នីតិវិធីពិសេសទាំងអស់។ (ប្រេស៊ីល)<br>សូមផ្តល់ការអញ្ជើញជាអចិន្ត្រៃយ៍ដល់នីតិវិធីពិសេសទាំងអស់របស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស។ (ស្លូវ៉ាគី) |

១៩. សូមពិចារណាសំណើសុំធ្វើទស្សនៈកិច្ចរបស់អ្នកកាន់អាណត្តិតាមបញ្ហា។ (ណ័រវេស)

២០. សូមផ្តល់ការយល់ព្រមលើសំណើសុំធ្វើទស្សនៈកិច្ចរបស់អ្នករាយការណ៍ពិសេសស្តីពីការលក់កុមារ ពេស្យាចារកុមារ និងអាសអាភាសកុមារ។ សូមឆ្លើយតបជាវិជ្ជមានចំពោះសំណើសុំធ្វើទស្សនៈកិច្ចរបស់អ្នករាយការណ៍ពិសេសស្តីពីការលក់ដូរកុមារ។ (អេស្ប៉ាញ)

២១. ផ្តល់ការអនុញ្ញាតតាមសំណើសុំកាលពីឆ្នាំ២០០៦ ២០០៨ និង២០០៩ របស់អ្នករាយការណ៍ពិសេស ស្តីពីឯករាជ្យភាពរបស់ចៅក្រម និងមេធាវី ដើម្បីចុះធ្វើទស្សនៈកិច្ចមកកាន់ប្រទេស។ សូមផ្តល់ការយល់ព្រមលើសំណើចុះធ្វើទស្សនៈកិច្ចនេះ របស់អ្នករាយការណ៍ពិសេសស្តីពីឯករាជ្យភាពរបស់ចៅក្រម និងមេធាវី។ (ណ័រវេស)

### *អ្នករាយការណ៍ពិសេស*

A/HRC/21/63/Add.1/Rev.1.Para.238.ដើម្បីអាចត្រួតពិនិត្យបន្ថែមទៀតពីផលប៉ះពាល់សិទ្ធិមនុស្សនៃសម្បទានដីសេដ្ឋកិច្ច និងសម្បទានដីដទៃទៀត រាជរដ្ឋាភិបាលគួរចេញលិខិតអញ្ជើញជាអចិន្ត្រៃយ៍មួយដល់យន្តការនីតិវិធីពិសេសរបស់សហប្រជាជាតិ ឬយ៉ាងហោចណាស់អញ្ជើញអ្នកកាន់អាណត្តិពាក់ព័ន្ធដែលអាចផ្តល់ការវិភាគពិស្តារបាន។ និយាយដោយឡែក អ្នកដែលពាក់ព័ន្ធ គួរតែជាអ្នករាយការណ៍ពិសេសអំពីជនជាតិដើមភាគតិច ក្រុមការងារអំពីធុរកិច្ច និងសិទ្ធិមនុស្ស និងអ្នករាយការណ៍ពិសេសអំពីសិទ្ធិមានអាហារ លំនៅដ្ឋានសមរម្យ សិទ្ធិអប់រំ ទីទាល់ក្រ អនាម័យ និងសុវត្ថិភាពទឹកស្អាត និងសិទ្ធិវប្បធម៌។

## *ឃ. កិច្ចសហប្រតិបត្តិការអន្តរជាតិទូទៅលើវិស័យសិទ្ធិមនុស្ស*

### *អនុសាសន៍នៃការពិនិត្យជាសកលតាមកាលកំណត់* (២០១៨)

១១៨.៣៩. ធ្វើការពង្រឹងកិច្ចសហប្រតិបត្តិការអន្តរជាតិក្នុងវិស័យសិទ្ធិមនុស្ស។ (ទួកមេនីស្ថាន)

១១៨.៤០. ពង្រឹងកិច្ចសហប្រតិបត្តិការ និងកិច្ចសន្ទនាប្រកបដោយន័យស្ថាបនាផ្នែកសិទ្ធិមនុស្ស រួមទាំងតាមរយៈគណៈកម្មការសិទ្ធិមនុស្សអាស៊ាន និងជាមួយស្ថាប័ន និងយន្តការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិដែលពាក់ព័ន្ធ។ (វៀតណាម)

១១៨.៤១. ស្វែងរកការគាំទ្រពីសហគមន៍អន្តរជាតិក្នុងក្របខ័ណ្ឌជំនួយបច្ចេកទេសនិងហិរញ្ញវត្ថុ ដើម្បីពង្រឹងសមត្ថភាពរបស់ខ្លួន ក្នុងការអនុវត្តសកម្មភាពនានាដែលទាក់ទងនឹងសិទ្ធិមនុស្សឲ្យបានទាន់ពេលវេលា។ (អង់ហ្គោឡា)

១១៨.៤៧. សហការយ៉ាងពេញលេញជាមួយការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា។ (ស្វីស)

១១៨.៤៨. បន្តជំរុញកិច្ចសហប្រតិបត្តិរបស់ខ្លួនជាមួយការិយាល័យ OHCHR និងយន្តការនានារបស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស។ (កេនយ៉ា)

| |
|---|
| ***អនុសាសន៍នៃការពិនិត្យជាសកលតាមកាលកំណត់ (២០០៩)*** |
| ១៣. បន្តសហប្រតិបត្តិការជាមួយសហគមអន្តរជាតិ ក្នុងកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួន ដើម្បីធ្វើឲ្យសង្គមប្រជាធិបតេយ្យជឿនលឿនទៅមុខបន្ថែមទៀត និងដើម្បីពង្រឹងសិទ្ធិមនុស្ស និងសុខមាលភាពរបស់ប្រជាជនខ្លួន ស្របតាមអាទិភាពជាតិ ដូចបានកំណត់ក្នុងយុទ្ធសាស្ត្រអភិវឌ្ឍន៍ និងគោលនយោបាយផ្សេងៗរបស់ខ្លួន។ (ប៊ូថាន់)<br>៨២. បន្តស្វែងរកជំនួយបច្ចេកទេសក្នុងការរៀបចំសេចក្តីព្រាងនីតិកម្មក្នុងវិស័យកុមារ។ (ស្លូវីនៀ)<br>៩០.សូមបន្តកិច្ចសហប្រតិបត្តិការជាមួយអង្គការសហប្រជាជាតិនិងអង្គការអន្តរជាតិផ្សេងៗដើម្បីពង្រឹងសិទ្ធិមនុស្សនៅប្រទេសកម្ពុជា។ បង្កើតយន្តការមួយប្រកបដោយប្រសិទ្ធភាព ដើម្បីជួយសម្រួលកិច្ចសហប្រតិបត្តិការជាមួយស្ថាប័នពាក់ព័ន្ធរបស់អង្គការសហប្រជាជាតិ។ (ហុងគ្រី)<br>៩១. ក). សូមបន្តកិច្ចសហប្រតិបត្តិការ និងស្វែងរកជំនួយបច្ចេកទេស ប្រសិនបើ និងតាមការចាំបាច់ ក្នុងការពង្រឹងដល់លទ្ធិប្រជាធិបតេយ្យ និងធានាដល់ការការពារ និងការលើកស្ទួយសិទ្ធិមនុស្សជូនពលរដ្ឋកម្ពុជាគ្រប់រូប។ (ប៉ាគីស្ថាន)<br>ខ). សហការ និងស្វែងរកការគាំទ្រពីសហគមន៍អន្តរជាតិក្នុងការបង្កើតផែនការ និងយុទ្ធសាស្ត្ររបស់ខ្លួន និងក្នុងវិស័យកសាងសមត្ថភាព ដើម្បីអាចអនុវត្តផែនការ និងយុទ្ធសាស្ត្រទាំងនោះ។ ដោយមានជំនួយឧបត្ថមពីសហគមន៍អន្តរជាតិ សូមបន្តកិច្ចខិតខំប្រឹងប្រែងជាវិជ្ជមានរបស់ខ្លួន ក្នុងការប្រយុទ្ធប្រឆាំងនឹងភាពក្រីក្រ ជាពិសេសប្រទេសអភិវឌ្ឍន៍ផ្សេងៗ គួរតែសហការទ្វេដងបន្ថែមទៀតជាមួយប្រទេសកំពុងអភិវឌ្ឍន៍ដ៏តូចនេះ។ (អេហ្ស៊ីប)<br>គ). ដោយមានជំនួយឧបត្ថម្ភពីអន្តរជាតិ សូមបន្តបង្កើតកម្មវិធីប្រកបដោយប្រសិទ្ធភាព ក្នុងគោលបំណងកាត់បន្ថយភាពក្រីក្រ ជាពិសេស នៅតាមតំបន់ជនបទដែលមានប្រជាពលរដ្ឋ៨០%។ (គុយបា) |
| ***គណៈកម្មាធិការសិទ្ធិកុមារ៖ ពេស្យាចារកុមារ*** CRC/C/OPSC/KHM/CO/1 (២០១៥) |
| ៣២. តាមស្មារតីនៃមាត្រា១០ វាក្យខ័ណ្ឌ១ នៃពិធីសារបន្ថែមនេះ គណៈកម្មាធីការសូមលើកទឹកចិត្តរដ្ឋភាគី បន្តពង្រឹងកិច្ចសហប្រតិបត្តិការអន្តរជាតិ ទោះជាកិច្ចសម្រុះសម្រួលពហុភាគី ទ្វេភាគី ឬថ្នាក់តំបន់ ជាពិសេសជាមួយប្រទេសជិតខាង រួមទាំងតាមរយៈការពង្រឹងនីតិវិធីសំរាប់យន្តការសម្របសម្រួលដល់ការអនុវត្តកិច្ចសម្រុះសម្រួលនេះផងដើម្បីកែលំអដល់ការបង្ការ ការស៊ើបអង្កេត ការស៊ើបសួរ ការចោទប្រកាន់និងការផ្តន្ទាទោសអ្នកទាំងឡាយដែលទទួលខុសត្រូវចំពោះអំពើណាមួយដែលស្ថិតនៅក្រោមពិធីសារបន្ថែមនេះ។<br>៣៣. ក្នុងករណីនេះ គណៈកម្មាធិការសូមផ្តល់អនុសាសន៍ឱ្យរដ្ឋភាគីសហការជាមួយនិងស្វែងរកជំនួយបច្ចេកទេសជាអាទិ៍ ពីការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស និងអង្គការយូនីសេហ្វ។ |

| |
|---|
| *គណៈកម្មាធិការសិទ្ធិកុមារ៖ កុមារក្នុងជម្លោះប្រដាប់អាវុធ* (២០១៥)<br>CRC/C/OPAC/KHM/CO/1 |
| ២៦. គណៈកម្មាធិការ សូមផ្ដល់អនុសាសន៍ថា រដ្ឋភាគីបន្ត និងពង្រឹងកិច្ចសហប្រតិបត្តិការរបស់ខ្លួន ជាមួយគណៈកម្មាធិការកាកបាទក្រហមអន្តរជាតិ និងអ្នកតំណាងពិសេសរបស់អគ្គលេខាធិការសំរាប់កុមារ និងជម្លោះប្រដាប់អាវុធ និងថារដ្ឋភាគីស្វះស្វែងបង្កើនកិច្ចសហការជាមួយអង្គការយូនីសេហ្វ ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស និងស្ថាប័នសហប្រជាជាតិដទៃទៀត ក្នុងការអនុវត្តពិធីសារបន្ថែមនេះ។ |
| *គណៈកម្មាធិការស្ដីពីសិទ្ធិកុមារ* CRC/C/KHM/CO/2-3 (២០១១) |
| ៨២. គណៈកម្មាធិការផ្ដល់អនុសាសន៍ថា រដ្ឋភាគីសហការជាមួយគណៈកម្មការស្ត្រី និងកុមាររបស់អាស៊ានសំដៅដល់ការអនុវត្តន៍អនុសញ្ញាសិទ្ធិកុមារ និងលិខិតុបករណ៍សិទ្ធិមនុស្សដទៃទៀត ទាំងនៅក្នុងរដ្ឋភាគី ទាំងនៅក្នុងរដ្ឋសមាជិកអាស៊ានដទៃទៀត។ |
| *អ្នករាយការណ៍ពិសេស* |
| A/HRC/21/63/Add.1/Rev.1.Para.236. ការប្រើនីតិវិធី និងយន្តការបណ្ដឹងអន្តរជាតិ ព្រមទាំងស្ថាប័នសិទ្ធិមនុស្សជាតិនៅក្រៅប្រទេស គួរតែត្រូវបានស្វះស្វែងរកបន្ថែមទៀតដោយតួអង្គសង្គមស៊ីវិល ដើម្បីដាក់បណ្ដឹងប្រឆាំងនឹងការរំលោភបំពានសិទ្ធិមនុស្សដោយក្រុមហ៊ុនធុរកិច្ចដែលមានម្ចាស់ហ៊ុនជាជនបរទេស ដែលមានការពាក់ព័ន្ធនឹងការរំលោភបំពានសិទ្ធិមនុស្សនៅកម្ពុជា (មិនគិតថាធុរកិច្ចនេះ មានម្ចាស់ហ៊ុនធំឬតូច ឱ្យតែជាជនបរទេស)។ តួនាទីដែលអាចមានរបស់គណៈកម្មការសិទ្ធិមនុស្សអន្តររដ្ឋាភិបាលរបស់អាស៊ាន ក៏អាចត្រូវបានយកមកពិនិត្យបន្ថែមទៀតផងដែរ។ |

## ង. *យន្តការបង្ការថ្នាក់ជាតិ៖ កាតព្វកិច្ចតាមពិធីសារបន្ថែមនៃអនុសញ្ញាប្រឆាំងទារុណកម្ម*

| |
|---|
| *អនុសាសន៍នៃការពិនិត្យជាសកលតាមកាលកំណត់* (២០១៨) |
| ១១៨.១៣. [...]និងដើម្បីបង្កើតយន្តការបង្ការថ្នាក់ជាតិមួយ ដែលឯករាជ្យ និងមានធនធានគ្រប់គ្រាន់ យោងតាមលក្ខខណ្ឌតម្រូវនៃពិធីសារបន្ថែមលើអនុសញ្ញាប្រឆាំងទារុណកម្ម។ (អាល្លឺម៉ង់) |

| *អនុសាសន៍នៃការពិនិត្យជាសកលតាមកាលកំណត់* (២០០៩) |
| --- |
| ៨. ពង្រឹងភាពជឿនលឿនឆ្ពោះទៅកាន់ការបង្កើតយន្តការបង្ការថ្នាក់ជាតិឯករាជ្យមួយដែលមានអាណត្តិ និងធនធានចាំបាច់ ដើម្បីអនុវត្តតាមកាតព្វកិច្ច ក្រោមពិធីសារបន្ថែមនៃអនុសញ្ញាប្រឆាំងទារុណកម្ម និងការប្រព្រឹត្ត ឬទណ្ឌកម្មឯទៀតដែលឃោរឃៅ អមនុស្សធម៌ ឬបន្ទាបបន្ថោក។ (ដាណឺម៉ាក) |
| *គណៈកម្មាធិការសិទ្ធិមនុស្ស* (CCPR/C/SR.3157) (២០១៥) |
| ១៣. រដ្ឋភាគីគួរបង្កើតយន្តការឯករាជ្យមួយសម្រាប់ទទួលពាក្យបណ្តឹង ដែលមានអំណាចស៊ើបអង្កេតរាល់ការចោទប្រកាន់ និងបណ្តឹងទាំងអស់ទាក់ទងនឹងការធ្វើទារុណកម្ម និងការប្រព្រឹត្តមិនគប្បី។ [...]ម្យ៉ាងវិញទៀត រដ្ឋភាគីគួរបង្កើតឲ្យបានឆាប់រហ័ស ឬដាក់ឲ្យអនុវត្តយន្តការបង្ការថ្នាក់ជាតិសម្រាប់បង្ការទារុណកម្មដូចមានចែងក្នុងពិធីសារបន្ថែមនៃអនុសញ្ញាប្រឆាំងទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀត ដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប។ |
| *គណៈកម្មាធិការប្រឆាំងទារុណកម្ម* CAT/C/KHM/CO/2 (២០១០) |
| ៣០. រដ្ឋភាគីគួរចាត់វិធានការចាំបាច់ទាំងអស់ ដើម្បីធានាថាយន្តការបង្ការទារុណកម្មថ្នាក់ជាតិនឹងត្រូវបង្កើតឡើងដោយគោរពទៅតាមពិធីសារបន្ថែមនៃអនុសញ្ញាប្រឆាំងទារុណកម្ម។ ដើម្បីសម្រេចគោលបំណងនេះ រដ្ឋភាគីគួរធានាថា យន្តការបង្ការទារុណកម្មថ្នាក់ជាតិនេះនឹងត្រូវបង្កើតឡើងតាមរយៈការធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញ ឬតាមច្បាប់រៀបចំអង្គការ ហើយយន្តការនេះត្រូវតែជាយន្តការដែលមានវិជ្ជាជីវៈ និងឯករាជ្យទាំងខាងស្ថាប័ន ទាំងហិរញ្ញវត្ថុ។ រដ្ឋភាគីគួរធានាផងដែរថាច្បាប់ដែលបង្កើតយន្តការបង្ការទារុណកម្មថ្នាក់ជាតិ នឹងត្រូវកំណត់ឲ្យបានច្បាស់លាស់ថាយន្តការនេះនឹងត្រូវមានសមត្ថភាពធ្វើទស្សនកិច្ចត្រួតពិនិត្យដោយមិនប្រកាសឲ្យដឹងជាមុន ទៅគ្រប់ទីកន្លែងទាំងអស់ដែលមនុស្សនៅទីកន្លែងទាំងនោះត្រូវបានឬអាចត្រូវបានគេដកហូតសិទ្ធិសេរីភាព និងធ្វើបទសម្ភាសជាសម្ងាត់ជាមួយអ្នកទាំងនោះ ហើយច្បាប់នេះនឹងមានចែងអំពីនីតិវិធីជ្រើសរើសដោយតម្លាភាព ក្នុងគោលដៅតែងតាំងសមាជិកឯករាជ្យសម្រាប់ស្ថាប័ននេះ។ គណៈកម្មាធិការជំរុញឲ្យរដ្ឋភាគីពិចារណាលើការចេញផ្សាយរបាយការណ៍របស់អនុគណៈកម្មាធិការបង្ការទារុណកម្មបន្ទាប់ពីបានបំពេញទស្សនកិច្ចត្រួតពិនិត្យរបស់ខ្លួននៅខែធ្នូ ឆ្នាំ២០០៩។ |

## ច. *ការអប់រំជាទូទៅអំពីសិទ្ធិមនុស្ស និងសន្ធិសញ្ញាសិទ្ធិមនុស្ស*

| *អនុសាសន៍នៃការពិនិត្យជាសកលតាមកាលកំណត់* (២០១៤) |
| --- |
| ១១៨.៤២. បន្តកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួនដល់ការអប់រំ និងការបណ្តុះបណ្តាលសិទ្ធិមនុស្សនៅគ្រប់កម្រិត រួមទាំងមន្ត្រីរដ្ឋាភិបាលផង។ (ប៉ាគីស្ថាន) |

| |
|---|
| *អនុសាសន៍នៃការពិនិត្យជាសកលតាមកាលកំណត់* (២០០៩) |
| ១៥. លើកកម្ពស់ការអប់រំនិងការបណ្តុះបណ្តាលសិទ្ធិមនុស្សនៅគ្រប់ជាន់ថ្នាក់ រាប់បញ្ចូលទាំងសំរាប់មន្ត្រីរដ្ឋាភិបាល ដើម្បីលើកកំពស់ការយល់ដឹងអំពីសិទ្ធិមនុស្សសំរាប់ជនគ្រប់រូប។ (រាជាណាចក្រថៃ) |
| *គណៈកម្មាធិការសិទ្ធិមនុស្ស* (CCPR/C/SR.3157) (២០១៥) |
| ៥. រដ្ឋភាគី គួរចាត់វិធានការសមស្រប ដើម្បីលើកកម្ពស់ការយល់ដឹងអំពីកតិកាសញ្ញានេះ ក្នុងចំណោមចៅក្រម ព្រះរាជអាជ្ញា មេធាវី និងសាធារណៈជនទូទៅ ដើម្បីធានាថា បទប្បញ្ញត្តិនៃកតិកាសញ្ញានេះ ត្រូវបានយកមកពិចារណានៅចំពោះមុខតុលាការជាតិ។ […]<br><br>២៩. រដ្ឋភាគី គួរតែផ្សព្វផ្សាយកតិកាសញ្ញានេះឲ្យបានទូលំទូលាយ អត្ថបទនៃរបាយការណ៍តាមកាលកំណត់លើកទីពីររបស់ខ្លួន ការឆ្លើយតបជាលាយលក្ខណ៍អក្សរទៅនឹងបញ្ជីសំណួរដែលបានធ្វើឡើងដោយគណៈកម្មាធិការ និងការពិនិត្យផ្ទៀងផ្ទាត់ចុងក្រោយ ក្នុងចំណោមអាជ្ញាធរតុលាការ អាជ្ញាធរច្បាប់ និងអាជ្ញាធររដ្ឋបាល សង្គមស៊ីវិល និងអង្គការមិនមែនរដ្ឋាភិបាលនានា ដែលប្រតិបត្តិការនៅក្នុងប្រទេសកម្ពុជា ក៏ដូចជាសាធារណជន។ |
| *គណៈកម្មាធិការសិទ្ធិកុមារ៖ កុមារក្នុងជម្លោះប្រដាប់អាវុធ* (២០១៥)<br>CRC/C/OPAC/KHM/CO/1 |
| ១១. គណៈកម្មាធិការសូមផ្តល់អនុសាសន៍ថា រដ្ឋភាគីលើកកំពស់កិច្ចខិតខំប្រឹងប្រែងផ្សព្វផ្សាយរបស់ខ្លួនដើម្បីធ្វើឱ្យគោលការណ៍ និងបទប្បញ្ញត្តិនៃពិធីសារបន្ថែមនេះ បានជ្រួតជ្រាបល្អដល់មន្ត្រីរដ្ឋាភិបាល និងមន្ត្រីប្រតិបត្តិច្បាប់ រួមទាំងនៅកំរិតខេត្ត និងបង្កើតយុទ្ធនាការព័ត៌មានជាក់លាក់ ដើម្បីលើកកំពស់ការយល់ដឹងដល់មាតា-បិតា គ្រូបង្រៀន សិស្ស កុមារ និងតួអង្គសង្គមស៊ីវិល។ គណៈកម្មាធិការក៏សូមផ្តល់អនុសាសន៍ផងដែរថា រដ្ឋភាគីពង្រឹងសកម្មភាពបណ្តុះបណ្តាលរបស់ខ្លួន ដោយរួមទាំងកម្មវិធីអប់រំជាប្រព័ន្ធ និងទូលំទូលាយអំពីបទប្បញ្ញត្តិនៃពិធីសារបន្ថែម និងច្បាប់មនុស្សធម៌អន្តរជាតិ ដល់ក្រុមវិជ្ជាជីវៈដែលពាក់ព័ន្ធ បណ្ឌិតសភានគរបាល និងបុគ្គលិកយោធិនរបស់ខ្លួន រួមទាំងបុគ្គលិកយោធិនដែលចូលរួមក្នុងបេសកកម្មរក្សាសន្តិភាពអន្តរជាតិផង។<br><br>២៥. គណៈកម្មាធិការសូមផ្តល់អនុសាសន៍ថា រដ្ឋភាគីពង្រឹងកម្មវិធីលើកកំពស់ការយល់ដឹងអំពីមីន និងសកម្មភាពដោះមីន ដើម្បីការពារកុមារពីគ្រោះថ្នាក់ដោយសារមីន និងគ្រឿងផ្ទុះដែលសល់ពីសង្គ្រាម។ គណៈកម្មាធិការក៏សូមផ្តល់អនុសាសន៍ថា រដ្ឋភាគីពិចារណាបង្កើតកម្មវិធីកុមារមេត្រីដើម្បីធានាពីការផ្តល់សេវាគ្រប់គ្រាន់ដោយកែសម្រួលឱ្យស្របតាមតម្រូវការជាក់លាក់របស់កុមាររងគ្រោះ ជាពិសេស កុមារពិការដោយសារសំណល់មីន និងគ្រឿងផ្ទុះដែលសល់ពីសង្គ្រាម និងផ្តល់ឱ្យពួកគេនូវការស្តារកាយសម្បទា និងផ្លូវចិត្ត ព្រមទាំងជំនួយសង្គម។ |

## *គណៈកម្មាធិការសិទ្ធិកុមារ៖ ពេស្យាចារកុមារ* CRC/C/OPSC/KHM/CO/1 (២០១៥)

**១៣.** គណៈកម្មាធិការជំរុញរដ្ឋភាគី ឱ្យចាត់គ្រប់វិធានការចាំបាច់ ដើម្បីធ្វើឱ្យបទប្បញ្ញត្តិនៃពិធីសារបន្ថែមបានជ្រួតជ្រាបយ៉ាងទូលំទូលាយ។ ដើម្បីសម្រេចបានគោលដៅនេះ ជាពិសេស៖

(ក). ដោយពិគ្រោះយោបល់ជាមួយសហគមន៍ អង្គការសង្គមស៊ីវិល និងកុមារ រដ្ឋភាគីគួរបង្កើត និងរៀបចំកម្មវិធីអប់រំរយៈពេលវែង និងការលើកកំពស់ការយល់ដឹងអំពីវិធានការបង្ការ និងផលប៉ះពាល់ដែលគ្រោះថ្នាក់ពីគ្រប់បទល្មើសដែលគ្របដណ្តប់ដោយពិធីសារបន្ថែមនេះ រួមទាំងយន្តការរាយការណ៍ និងជំនួយ ដែលបង្កើតឡើងដើម្បីការពារកុមារកុំឱ្យធ្លាក់ទៅជាជនរងគ្រោះពីបទល្មើសនានាដែលមាននៅក្នុងពិធីសារបន្ថែមនេះ។

(ខ). រដ្ឋភាគីគួរផ្សព្វផ្សាយជាប្រព័ន្ធនូវពិធីសារបន្ថែមនេះ ដល់មន្ត្រីរដ្ឋាភិបាលនៅថ្នាក់ជាតិ ថ្នាក់ខេត្ត និងថ្នាក់ស្រុក ព្រមទាំងដល់ក្រុមវិជ្ជាជីវៈពាក់ព័ន្ធទាំងអស់ ជាពិសេសមន្ត្រីប៉ូលីស ចៅក្រម និងព្រះរាជអាជ្ញា។

(គ). រដ្ឋភាគីគួរពិចារណាដាក់បញ្ចូលបញ្ហានានាពាក់ព័ន្ធនឹងពិធីសារបន្ថែមនេះ ទៅក្នុងកម្មវិធីសិក្សានៅសាលាបឋមសិក្សា និងមធ្យមសិក្សា។

**១៥.** គណៈកម្មាធិការសូមផ្តល់អនុសាសន៍ថា រដ្ឋភាគី

(ក). ផ្តល់ធនធានគ្រប់គ្រាន់ដើម្បីធានាពីការបណ្តុះបណ្តាលជាប្រព័ន្ធ និងចំទិសដៅ ជាពិសេស អំពីបទប្បញ្ញត្តិនៃពិធីសារបន្ថែមនេះ និងការអនុវត្តបទប្បញ្ញត្តិទាំងនោះដល់ក្រុមវិជ្ជាជីវៈពាក់ព័ន្ធទាំងអស់ ដែលធ្វើការជាមួយ និងដើម្បីកុមារ ព្រមទាំងចៅក្រម ព្រះរាជអាជ្ញា មន្ត្រីប៉ូលីស និងមន្ត្រីរាជការ រួមទាំងនៅថ្នាក់ជាតិ និងនៅថ្នាក់ខេត្ត។

(ខ). ធានាថាការបណ្តុះបណ្តាលបែបនេះ រួមមានកម្មវិធីបណ្តុះបណ្តាលពហុជំនាញ ដែលបង្កើតឡើងដោយមានការពិគ្រោះយោបល់ជាមួយសហគមន៍ អង្គការសង្គមស៊ីវិល និងកុមាររងគ្រោះ។

(គ). រៀបចំការវាយតំលៃជាទៀងទាត់អំពីសកម្មភាពបណ្តុះបណ្តាលនានាដើម្បីធានាថា ចំណេះដឹងនិងជំនាញដែលទទួលបាន ឆ្លើយតបនឹងការអនុវត្តជាក់ស្តែង ដើម្បីកំណត់ជនរងគ្រោះ និងការពារកុមារប្រកបដោយប្រសិទ្ធភាពពីបទល្មើសនានាដែលគ្របដណ្តប់ដោយពិធីសារបន្ថែមនេះ។

(ឃ). ពង្រឹងកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួន ដើម្បីជ្រើសរើស និងបណ្តុះបណ្តាលបុគ្គលិកសង្គមកិច្ចនៅថ្នាក់ឃុំ និងផ្តល់មូលនិធិគ្រប់គ្រាន់ដល់ពួកគេក្នុងការបំពេញតួនាទីការងាររបស់ពួកគេ។

## *គណៈកម្មាធិការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ* (២០១៣) CEDAW/C/KHM/CO/4-5

គណៈកម្មាធិការ បញ្ជាក់ឡើងវិញលើអនុសាសន៍លើកមុនរបស់ខ្លួន (CEDAW/C/KHM/CO/3 កថាខណ្ឌទី១០) ដែលស្នើឲ្យរដ្ឋភាគីពង្រឹងវិធានការរបស់ខ្លួនក្នុងការបង្កើនការយល់ដឹងអំពីអនុសញ្ញា និងពិធីសារបន្ថែមដល់ចៅក្រម ព្រះរាជអាជ្ញា និងមេធាវី និងបន្តបញ្ចូលការបណ្តុះបណ្តាលអនុសញ្ញា ក្នុងកម្មវិធីអប់រំពាក់ព័ន្ធ សម្រាប់មន្ត្រីរាជការ មន្ត្រីតុលាការ និងអ្នកដែលបានប្រើប្រាស់ក្នុងប្រព័ន្ធអប់រំ។

| |
|---|
| *គណៈកម្មាធិការស្តីពីសិទ្ធិកុមារ* CRC/C/KHM/CO/2-3 (២០១១) |
| ២១. គណៈកម្មាធិការសូមស្នើឱ្យរដ្ឋភាគី ធ្វើការពង្រឹងកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួន ក្នុងការផ្សព្វផ្សាយអនុសញ្ញានៅពាសពេញប្រទេស ដើម្បីលើកកម្ពស់ការយល់ដឹងរបស់សាធារណៈ រួមទាំងកុមារខ្លួនឯង និងមាតាបិតា ព្រមទាំងផ្សព្វផ្សាយព័ត៌មានអំពីគោលការណ៍ និងបទប្បញ្ញត្តិរបស់អនុសញ្ញា។ |
| *គណៈកម្មាធិការប្រឆាំងទារុណកម្ម* CAT/C/KHM/CO/2 (២០១០) |
| ១០. រដ្ឋភាគី គួរចាត់វិធានការសមស្រប ដើម្បីធានាឲ្យមានការអនុវត្តបទប្បញ្ញត្តិពេញលេញនៃអនុសញ្ញា នៅក្នុងឋានានុក្រមច្បាប់ជាតិរបស់ខ្លួន។ វិធានការទាំងនេះ រួមមានការបណ្តុះបណ្តាលឲ្យបានទូលំទូលាយស្តីពីបទប្បញ្ញត្តិនៃសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិ រួមទាំង អនុសញ្ញានេះ សម្រាប់មន្ត្រីរាជការ មន្ត្រីប្រតិបត្តិច្បាប់ និងមន្ត្រីពាក់ព័ន្ធផ្សេងៗ ក៏ដូចជាចៅក្រម ព្រះរាជអាជ្ញា និងមេធាវីផងដែរ។ គណៈកម្មាធិការក៏ស្នើឲ្យរដ្ឋភាគី ធ្វើរបាយការណ៍បញ្ជូនត្រឡប់មកវិញស្តីពីភាពជឿនលឿនក្នុងបរិបទនេះ និងលើសេចក្តីសម្រេចរបស់តុលាការជាតិ ឬសាលា ជំរះក្តី និងអាជ្ញាធររដ្ឋបាល ដោយអនុវត្តឲ្យមានប្រសិទ្ធភាពនូវសិទ្ធិទាំងឡាយដែលបានតំកល់ទុកក្នុងអនុសញ្ញានេះ។ |
| *គណៈកម្មាធិការលុបបំបាត់ការរើសអើងពូជសាសន៍* CERD/C/KHM/CO/8-13 (២០១០) |
| ១១. គណៈកម្មាធិការផ្តល់អនុសាសន៍ថែមទៀតថា រដ្ឋភាគីត្រូវធានាថាបញ្ញត្តិទាំងអស់នេះ ត្រូវបានផ្សព្វផ្សាយឲ្យសាធារណៈជនបានយល់ដឹងទាំងស្រុង និងត្រូវបានដាក់ឲ្យអនុវត្ត។ |
| *គណៈកម្មាធិការសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌* E/C.12/KHM/CO/1 (២០០៩) |
| ១២. គណៈកម្មាធិការសូមទាញចំណាប់អារម្មណ៍របស់រដ្ឋភាគីចំពោះសេចក្តីពន្យល់ទូទៅរបស់ខ្លួនលេខ៩(១៩៩៨) ស្តីពីការអនុវត្តន៍ក្នុងស្រុកនៃកតិកាសញ្ញានេះ និងសូមផ្តល់ជាអនុសាសន៍ថា រដ្ឋភាគីចាត់រាល់វិធានការសមស្រប ដើម្បីធានាការអនុវត្តន៍ដោយផ្ទាល់នូវបទប្បញ្ញត្តិនៃកតិកាសញ្ញានេះ នៅក្នុងឋានានុក្រមច្បាប់ជាតិរបស់ខ្លួន ដោយរួមទាំង ការរៀបចំឲ្យមានកម្មវិធីបណ្តុះបណ្តាលចៅក្រម មេធាវី និងមន្ត្រីសាធារណៈនានា។ |
| *អ្នករាយការណ៍ពិសេស* |
| A/HRC/15/46, para. 100. ចៅក្រម និងព្រះរាជអាជ្ញា គួរទទួលបានការបណ្តុះបណ្តាលគ្រប់គ្រាន់អំពីច្បាប់សិទ្ធិមនុស្ស និងការបកស្រាយច្បាប់ជាតិ ស្របតាមបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ ក្រោមសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិ ដែលកម្ពុជាគឺជារដ្ឋភាគី។ |

## II. កំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ និងនីតិរដ្ឋ

### *ក. កំណែទម្រង់ច្បាប់ទូទៅ*

| *អនុសាសន៍នៃការពិនិត្យជាសកលតាមកាលកំណត់* (២០១៤) |
|---|
| **១១៨.២៧.** បន្តកំណែទម្រង់ច្បាប់ និងស្ថាប័នដើម្បីលើកស្ទួយ និងការពារសិទ្ធិមនុស្ស។ (នេប៉ាល់)<br><br>**១១៨.៨០.** ធានាថា កិច្ចខិតខំប្រឹងប្រែងអំពីកំណែទម្រង់ច្បាប់ ត្រូវបន្តដោយគ្មានការរារាំង។ (ស៊ុយអែត)<br><br>**១១៨.៨១.** បន្តកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួនដើម្បីលើកកម្ពស់នីតិរដ្ឋដូចមានចែងក្នុងរដ្ឋធម្មនុញ្ញរបស់ខ្លួន។(សឹង្ហបូរី)<br><br>**១១៨.១៣៣.** បន្តជំរុញវឌ្ឍនភាពទៅលើបញ្ហាសំខាន់ៗ សម្រាប់ការលើកស្ទួយសិទ្ធិមនុស្ស និងប្រជាធិបតេយ្យភាវូបនីយកម្មរបស់ខ្លួន ជាពិសេសនៅក្នុងកំណែទម្រង់តុលាការនិងវិធានការនានាដើម្បីដោះស្រាយបញ្ហាដីធ្លី។(ជប៉ុន) |
| *អនុសាសន៍នៃការពិនិត្យជាសកលតាមកាលកំណត់* (២០០៩) |
| **៥.** បន្តកំណែទម្រង់ប្រព័ន្ធយុត្តិធម៌និងច្បាប់ និងធ្វើឲ្យច្បាប់នានាស៊ីសង្វាក់គ្នាទៅនឹងលិខិតុបករណ៍សិទ្ធិមនុស្សអន្តរជាតិ។ (ម៉ូរុកកូ)<br><br>**៦.** ពង្រីកដំណើរការពិគ្រោះយោបល់ស្តីពីការបង្កើតគោលនយោបាយច្បាប់ និងបទបញ្ញានានា ដើម្បីធានាថាលិខិតុបករណ៍ច្បាប់ទាំងអស់ ត្រូវបានវាយតម្លៃទាក់ទងនឹងផលប៉ះពាល់ជាវិជ្ជមាន និងអវិជ្ជមានទៅលើសិទ្ធិមនុស្ស។ (ចក្រភពអង់គ្លេស)<br><br>**១០.** បន្តពង្រឹងកម្មវិធីកំណែទម្រង់របស់ខ្លួនលើវិស័យទាំងអស់ ដើម្បីធានាការពារសិទ្ធិមនុស្ស និងសេរីភាពផ្សេងៗដែលមានចែងក្នុងរដ្ឋធម្មនុញ្ញនៃប្រទេសកម្ពុជា។ (ប្រុយណេ)<br><br>**៣៤.** សូមបន្តកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួនបន្តទៀត ដើម្បីលើកស្ទួយនិងការពារសិទ្ធិមនុស្ស និងពង្រឹងអភិបាលកិច្ចល្អនិងការគោរពនីតិរដ្ឋ បន្តពង្រឹងនីតិរដ្ឋនិងអភិបាលកិច្ចល្អ ទុកជាមធ្យោបាយមួយដើម្បីជួយពង្រឹងការលើកស្ទួយ និងការការពារសិទ្ធិមនុស្សនៅក្នុងប្រទេស។ (រាជាណាចក្រថៃ)<br><br>**៧៧.** ពង្រឹងកំណែទម្រង់ច្បាប់ និងគោលនយោបាយបន្ថែមទៀត ក្នុងគោលបំណងការពារសិទ្ធិរបស់ប្រជាជន និងធ្វើឲ្យប្រសើរឡើងដល់ប្រជាពលរដ្ឋក្រីក្រ និងក្រុមដែលមិនបានទទួលផលប្រយោជន៍ផ្សេងទៀត។ (វៀតណាម) |

### *គណៈកម្មាធិការសិទ្ធិកុមារៈកុមារក្នុងជម្លោះប្រដាប់អាវុធ* (២០១៥)

CRC/C/OPAC/KHM/CO/1

**១៧**. គណៈកម្មាធិការសូមផ្តល់អនុសាសន៍ថា រដ្ឋភាគីកែសម្រួលក្រមព្រហ្មទណ្ឌរបស់ខ្លួន ដោយដាក់បទប្បញ្ញត្តិនានាដែលដាក់ទោសយ៉ាងជាក់ស្តែងដល់ការជ្រើសរើស និងការប្រើប្រាស់កុមារអាយុក្រោម១៨ឆ្នាំ នៅក្នុងកងយោធពលខេមរភូមិន្ទ នៅក្នុងក្រុមប្រដាប់អាវុធមិនមែនរបស់រដ្ឋ និងសេវាកម្មឬក្រុមហ៊ុនសន្តិសុខឯកជន ព្រមទាំងនិយមន័យនៃការចូលរួមផ្ទាល់ក្នុងអរិភាព។

### *គណៈកម្មាធិការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ* (២០១៣)

CEDAW/C/KHM/CO/4-5

**៧**. ខណៈដែលអះអាងជាថ្មីទៀតថា រាជរដ្ឋាភិបាលមានការទទួលខុសត្រូវជាចម្បង និងជាពិសេស ទទួលខុសត្រូវចំពោះការអនុវត្តដ៏ពេញលេញនូវកាតព្វកិច្ចរបស់រដ្ឋភាគីក្រោមអនុសញ្ញានេះ គណៈកម្មាធិការសង្កត់ធ្ងន់ថា អនុសញ្ញានេះភ្ជាប់កាតព្វកិច្ចចំពោះស្ថាប័នទាំងអស់របស់រាជរដ្ឋាភិបាល និងស្នើឲ្យរដ្ឋភាគីជំរុញសភារបស់ខ្លួនចាត់វិធានការចាំបាច់ស្របតាមនីតិវិធី និងក្នុងករណីសមស្រប ទាក់ទងនឹងការអនុវត្តសេចក្តីសង្កេតសន្និដ្ឋានក្នុងអំឡុងពេលនេះ និងរយៈពេលរាយការណ៍បន្ទាប់ ស្របតាមអនុសញ្ញានេះ។

**៩**. គណៈកម្មាធិការបញ្ជាក់ឡើងវិញលើអនុសាសន៍មុនៗរបស់ខ្លួន(CEDAW/C/KHM/CO/3 កថាខណ្ឌទី១០) និងផ្តល់អនុសាសន៍ឲ្យរដ្ឋភាគីបោះពុម្ពផ្សាយអនុសញ្ញា និងពិធីសារបន្ថែម ក្នុងព្រះរាជកិច្ចដោយឥតបង្អង់តទៅទៀត និងបន្តពិនិត្យឡើងវិញលើនីតិកម្មដើម្បីបញ្ចូលបញ្ញត្តិទាំងអស់របស់អនុសញ្ញាទៅក្នុងច្បាប់ជាតិ។

**១១**. គណៈកម្មាធិការបញ្ជាក់ឡើងវិញលើអនុសាសន៍មុនៗរបស់ខ្លួន (CEDAW/C/KHM/CO/3 កថាខណ្ឌទី១២) និងផ្តល់អនុសាសន៍ឲ្យរដ្ឋភាគីពិចារណាលើការអនុម័តច្បាប់ទូលាយគ្រប់គ្រងសមភាពយេនឌ័រ ដែលគួរតែបញ្ចូលនិយមន័យនៃការរើសអើងប្រឆាំងស្ត្រី ដែលគ្របដណ្តប់លើការរើសអើងដោយផ្ទាល់ និងដោយប្រយោល ស្របតាមមាត្រា១ នៃអនុសញ្ញា។ គណៈកម្មាធិការលើកទឹកចិត្តដល់រដ្ឋភាគីឱ្យស្វែងរកជំនួយបច្ចេកទេសពីការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅក្នុងរដ្ឋភាគីនោះ និងទីភ្នាក់ងារសហប្រជាជាតិពាក់ព័ន្ធនានាក្នុងការកសាងច្បាប់នេះ។

### *គណៈកម្មាធិការស្តីពីសិទ្ធិកុមារ* CRC/C/KHM/CO/2-3 (២០១១)

**៩**. គណៈកម្មាធិការសូមទទូចឱ្យរដ្ឋភាគីចាត់រាល់វិធានការដ៏សមស្របទាំងអស់ ដើម្បីធានានូវការអនុវត្តដ៏ពេញលេញនូវគោលការណ៍និងបទប្បញ្ញត្តិទាំងឡាយរបស់អនុសញ្ញា ទៅតាមលំដាប់លំដោយនៃច្បាប់ក្នុងស្រុករបស់

ខ្លួន រួមទាំងការបង្កើតនូវយន្តការ ក្របខណ្ឌ និងប្រព័ន្ធដែលមានលក្ខណៈគ្រប់គ្រាន់ សម្រាប់អនុវត្តច្បាប់ទាំងឡាយដែលពាក់ព័ន្ធជាមួយកុមារនៅថ្នាក់ជាតិ ខេត្ត និងក្រុង។ គណៈកម្មាធិការក៏សូមស្នើផងដែរ ឱ្យរដ្ឋភាគីធ្វើរបាយការណ៍អំពីវឌ្ឍនភាពទាក់ទងនឹងការទទូចចង់បាននេះ និងទាក់ទងនឹងសេចក្ដីសម្រេចរបស់តុលាការ សាលាក្ដី ឬអាជ្ញាធររដ្ឋបាលជាតិដើម្បីធ្វើឱ្យមានប្រសិទ្ធភាពដល់សិទ្ធិទាំងឡាយដែលមានចែងនៅក្នុងអនុសញ្ញា។

៣១. គណៈកម្មាធិការសូមទទូចឱ្យរដ្ឋភាគីធ្វើការពង្រឹងកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួន ក្នុងការធានាថាគោលការណ៍នៃឧត្តមប្រយោជន៍របស់កុមារត្រូវបានបញ្ចូលយ៉ាងសមស្រប និងត្រូវបានអនុវត្តស៊ីសង្វាក់គ្នានៅក្នុងកិច្ចដំណើរការនីតិវិធី ច្បាប់ រដ្ឋបាល និងតុលាការ ក៏ដូចជានៅក្នុងគោលនយោបាយ កម្មវិធី និងគម្រោងទាំងឡាយដែលពាក់ព័ន្ធជាមួយផលប៉ះពាល់លើកុមារ។ រាល់ការផ្ដល់ហេតុផលផ្លូវច្បាប់នៃសេចក្ដីវិនិច្ឆ័យ ព្រមទាំងសេចក្ដីសម្រេចរបស់តុលាការ និងរដ្ឋបាលគួរតែផ្អែកទៅលើគោលការណ៍នេះ។

៧៨. តាមរយៈបទប្បញ្ញត្តិ និងបទបញ្ជាផ្លូវច្បាប់ដែលមានគ្រប់គ្រាន់ គណៈកម្មាធិការក៏សូមស្នើឱ្យរដ្ឋភាគីធ្វើការធានាថា កុមាររងគ្រោះទាំងអស់ និង/ឬសាក្សីនៃបទល្មើស ឧទា. កុមាររងគ្រោះពីការរំលោភបំពានពីអំពើហិង្សាក្នុងគ្រួសារ ពីការកេងប្រវ័ញ្ចផ្លូវភេទ និងផ្លូវសេដ្ឋកិច្ច ការចាប់ពង្រត់ និងអំពើជួញដូរមនុស្សត្រូវបានផ្ដល់នូវកិច្ចការពារដែលតម្រូវដោយអនុសញ្ញា និងស្នើសុំឱ្យរដ្ឋភាគី ធ្វើការគិតគូរឱ្យបានពេញលេញនូវគោលការណ៍សហប្រជាជាតិស្ដីពីយុត្តិធម៌ ដែលមានបញ្ហាទាក់ទងនឹងកុមារជាជនរងគ្រោះ និងសាក្សី នៅក្នុងបទល្មើស (ឧបសម្ព័ន្ធភ្ជាប់ទៅនឹងសេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គមកិច្ចលេខ២០/២០០៥)។

### *គណៈកម្មាធិការប្រឆាំងទារុណកម្ម* CAT/C/KHM/CO/2 (២០១០)

១០. រដ្ឋភាគីគួរចាត់វិធានការសមស្រប ដើម្បីធានាឲ្យមានការអនុវត្តបទប្បញ្ញត្តិពេញលេញនៃអនុសញ្ញា នៅក្នុងឋានានុក្រមច្បាប់ជាតិរបស់ខ្លួន។ [...]

គណៈកម្មាធិការក៏ស្នើឲ្យរដ្ឋភាគីធ្វើរបាយការណ៍បញ្ជូនត្រឡប់មកវិញស្ដីពីភាពជឿនលឿនក្នុងបរិបទនេះ និងលើសេចក្ដីសម្រេចរបស់តុលាការជាតិ ឬសាលាជំរះក្ដី និងអាជ្ញាធររដ្ឋបាលដោយអនុវត្តឲ្យមានប្រសិទ្ធភាពនូវសិទ្ធិទាំងឡាយដែលបានដំកល់ទុកក្នុងអនុសញ្ញានេះ។

### *គណៈកម្មាធិការលុបបំបាត់ការរើសអើងពូជសាសន៍* CERD/C/KHM/CO/8-13 (២០១០)

១១. គណៈកម្មាធិការផ្ដល់អនុសាសន៍ថា ច្បាប់នេះគួរតែបានបំពេញបង្គ្រប់ ដើម្បីធានាឲ្យមាននិយមន័យច្បាស់លាស់ចំពោះការរើសអើងពូជសាសន៍ ស្របតាមមាត្រា១នៃអនុសញ្ញានេះ និងសិទ្ធិបុគ្គលគ្រប់រូបមិនត្រូវបានគេរើសអើងប្រឆាំង ក្នុងការអាស្រ័យផលនូវសិទ្ធិទាំងអស់ដែលមានចែងក្នុងមាត្រា៥ នៃអនុសញ្ញានេះ។ គណៈកម្មាធិការផ្ដល់អនុសាសន៍ថែមទៀតថា រដ្ឋភាគីត្រូវធានាថា បញ្ញត្តិទាំងអស់នេះត្រូវបានផ្សព្វផ្សាយឲ្យសាធារណៈជនបានយល់ដឹងទាំងស្រុង និងត្រូវបានដាក់ឲ្យអនុវត្ត។

## *គណៈកម្មាធិការសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌* E/C.12/KHM/CO/1 (២០០៩)

**១២**. គណៈកម្មាធិការសូមទាញចំណាប់អារម្មណ៍របស់រដ្ឋភាគីចំពោះសេចក្តីពន្យល់ទូទៅរបស់ខ្លួនលេខ៩(១៩៩៨) ស្តីពីការអនុវត្តន៍ក្នុងស្រុកនៃកតិកាសញ្ញានេះ និងសូមផ្តល់ជាអនុសាសន៍ថា រដ្ឋភាគីចាត់វាល់វិធានការសមស្រប ដើម្បីធានាការអនុវត្តន៍ដោយផ្ទាល់នូវបទបញ្ញត្តិនៃកតិកាសញ្ញានេះ នៅក្នុងឋានានុក្រមច្បាប់ជាតិរបស់ខ្លួន។ [...]

គណៈកម្មាធិការស្នើផងដែរឲ្យរដ្ឋភាគី ដាក់បញ្ចូលទៅក្នុងរបាយការណ៍តាមកាលកំណត់លើកក្រោយរបស់ខ្លួននូវព័ត៌មានលំអិតស្តីពីការរីកចំរើនដែលបានធ្វើឡើងពាក់ព័ន្ធនឹងបញ្ហាទាំងនេះ និងអំពីសេចក្តីសំរេចនានារបស់តុលាការជាតិ សាលាក្តី ឬអាជ្ញាធរសាធារណៈ ដែលផ្តល់អានុភាពដល់សិទ្ធិទាំងឡាយដែលមានចែងក្នុងកតិកាសញ្ញានេះ។

## *អ្នករាយការណ៍ពិសេស*

A/HRC/7/42, para.101. រដ្ឋាភិបាលត្រូវលើកស្ទួយការគោរពនិតិរដ្ឋនៅក្នុងរដ្ឋ និងសង្គម។ ជាឧទាហរណ៍ រដ្ឋាភិបាលត្រូវកំណត់ថាជាអ្នកការពាររដ្ឋធម្មនុញ្ញ និងច្បាប់។ ច្បាប់ត្រូវយកមកអនុវត្តយ៉ាងត្រឹមត្រូវ និងពេញលេញ និងត្រូវធានាឱ្យមានដំណោះស្រាយដ៏មានប្រសិទ្ធភាពដល់ការរំលោភបំពានសិទ្ធិនានា ប្រសិនបើចង់ឱ្យប្រជាជនជឿជាក់លើសញ្ញាណនៃនីតិរដ្ឋ។

A/HR/15/46.Para.83រដ្ឋាភិបាលគួរពន្លឿនដំណើរការនៃការធ្វើសេចក្តីព្រាងក្រមរដ្ឋបាលនិងក្រមនីតិវិធីរដ្ឋបាល។

អនុសាសន៍ខាងក្រោមនេះ ដកស្រង់ចេញពី**A/HRC/18/46** រហូតដល់មានការបង្ហាញផ្សេងពីនេះ៖
**៦៦**. គណៈកម្មការសិទ្ធិមនុស្សក្នុងសភាគួរតែធ្វើការបញ្ជ្រៀបសិទ្ធិមនុស្សជាបញ្ហាពហុវិស័យមួយនិងធ្វើការឆ្ពោះទៅធានាការអនុវត្តន៍ច្បាប់ជាតិឲ្យស្របតាមបទដ្ឋានអន្តរជាតិ។

**៧៤**. សេចក្តីព្រាងច្បាប់គួរតែបានបោះពុម្ពផ្សាយ សំរាប់ឲ្យមានការពិគ្រោះយោបល់ជាសាធារណៈ ជាពិសេស ជាសៀវភៅផ្សេងៗ មានដូចជា រាជកិច្ចជាដើម។ រាជកិច្ចទាំងនេះ គួរតែរក្សាឲ្យមានសំរាប់សាធារណជនអាចទាក់ទងរកបាន។

**៧៥**. ច្បាប់មិនគួរត្រូវបានដាក់ឲ្យអនុវត្តឡើយ រហូតទាល់តែច្បាប់ទាំងនោះត្រូវបានចុះផ្សាយក្នុងរាជកិច្ច។

**៧៦**. គណៈកម្មការសភាផ្សេងៗ គួរតែពិនិត្យឡើងវិញនូវរាល់បទបញ្ជាអនុវត្តន៍ច្បាប់ ឬសេចក្តីណែនាំផ្សេងៗដែលអនុម័តដោយរដ្ឋាភិបាល ដើម្បីធ្វើឲ្យប្រាកដថា បទបញ្ជា ឬសេចក្តីណែនាំទាំងនោះ មិនចែងហួសវិសាលភាពនៃបញ្ញត្តិច្បាប់ដើមរបស់វាឡើយ។

**៨១**. ក្រុមប្រឹក្សាធម្មនុញ្ញគួរតែពិនិត្យ មិនត្រឹមតែច្បាប់ទាំងឡាយដែលសភាបានអនុម័តប៉ុណ្ណោះទេ ប៉ុន្តែក្រុមប្រឹក្សាក៏គួរតែពិនិត្យផងដែរនូវបទបញ្ជាផ្ទៃក្នុងរបស់សភាជាទូទៅ ជាពិសេស បទបញ្ជាផ្ទៃក្នុងរបស់រដ្ឋសភា ដើម្បីធ្វើឱ្យប្រាកដថា បញ្ញត្តិទាំងអស់ពិតជាស្របតាមស្មារតីនៃរដ្ឋធម្មនុញ្ញ បទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ និងគោលការណ៍នីតិរដ្ឋ រាប់ទាំងគោលការណ៍យុត្តិធម៌ធម្មជាតិផងដែរ។

៨២. ច្បាប់ណាក៏ដោយដែលសភាបានអនុម័ត ហើយដែលច្បាប់នោះមានជាប់ជំពាក់ដោយផ្ទាល់ដល់សិទ្ធិមនុស្ស គួរតែត្រូវបានបញ្ជូនដោយស្វ័យប្រវត្តិទៅក្រុមប្រឹក្សាធម្មនុញ្ញ ដើម្បីពិនិត្យសិន មុននឹងដាក់ស្នើទៅព្រះមហាក្សត្រ ដើម្បីឡាយព្រះហស្តលេខាប្រកាសឲ្យប្រើ។

A/HRC/27/70, para.81(g). ផ្តល់ប្រសិទ្ធភាពដល់សិទ្ធិចូលរួមក្នុងជីវភាពសាធារណៈ ដោយធ្វើការណែនាំដល់ក្រសួងទាំងអស់ និងស្ថាប័នរដ្ឋដទៃទៀត ឱ្យរៀបចំកិច្ចពិគ្រោះយោបល់ជាសាធារណៈលើសេចក្តីព្រាងច្បាប់ និងផ្សព្វផ្សាយសេចក្តីព្រាងនេះជាសាធារណៈ ដោយទទួលយកយោបល់ពីសមាជិកសាធារណៈដែលមានប្រយោជន៍ មុននឹងដាក់ជូនគណៈរដ្ឋមន្ត្រី។ ជាពិសេស ការធ្វើបែបនេះត្រូវយកមកអនុវត្តចំពោះសេចក្តីព្រាងច្បាប់ដែលតាមដឹងកំពុងតែរៀបរៀង គឺសេចក្តីព្រាងច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល និងសេចក្តីព្រាងឧក្រិដ្ឋកម្មតាមអ៊ិនធឺណែត ព្រមទាំងសេចក្តីព្រាងច្បាប់ដទៃទៀតដែលពាក់ព័ន្ធដល់ការទទួលបានសិទ្ធិមនុស្ស។

A/HRC/27/70,para.81(h). ធ្វើការកែទម្រង់សភាដើម្បីបង្កើនតម្លាភាពនៅក្នុងដំណើរការនីតិកម្ម និងធានាឱ្យសេចក្តីព្រាងច្បាប់ទាំងអស់ដែលមានពាក់ព័ន្ធនឹងសិទ្ធិមនុស្ស ស្របជាមួយនឹងបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ។

A/HRC/33/62,para.61(k). ផ្សព្វផ្សាយជាសាធារណៈនូវសេចក្តីព្រាងច្បាប់នៅតំណាក់កាលដំបូងបំផុត ដើម្បីសម្រួលដល់កិច្ចពិគ្រោះយោបល់ដ៏មានអត្ថន័យទៅលើសេចក្តីព្រាងទាំងនេះ និងអំពីភាពស្របតាមសិទ្ធិមនុស្សនៃសេចក្តីព្រាងច្បាប់ទាំងនេះ។

A/HRC/33/62,para.61(i). អនុវត្តបទប្បញ្ញត្តិពាក់ព័ន្ធនៃក្រមព្រហ្មទណ្ឌ នៅពេលស្ត្រីត្រូវបានគូសវាសព៌ណនាតាមលក្ខណៈជារូបភាព ជាពិសេស ជនរងគ្រោះពីអំពើបៀតបៀនកេរ្តិ៍ខ្មាស់ ឬអំពើហិង្សា។

## ខ. ប្រព័ន្ធយុត្តិធម៌ និងតុលាការដែលមានប្រសិទ្ធភាព និងឯករាជ្យ

*អនុសាសន៍នៃការពិនិត្យជាសកលតាមកាលកំណត់ (២០១៤)*

១១៨.២៤. អនុវត្តសេចក្តីព្រាងច្បាប់ចំនួនបី ដែលមានគោលបំណងលើកកម្ពស់ឯករាជ្យភាព និងប្រសិទ្ធភាពនៃប្រព័ន្ធតុលាការ នៅពេលអនុម័តរួច។ (ព័រទុយហ្គាល់)

១១៨.៧៩. អនុវត្តដោយពេញលេញ នូវក្របខ័ណ្ឌសម្រាប់កំណែទម្រង់ប្រព័ន្ធយុត្តិធម៌ ដែលបានកំណត់នៅក្នុងរបាយការណ៍ខែកញ្ញា ឆ្នាំ២០១០ ដោយអ្នករាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា។(អេស្ប៉ាញ)

១១៨.៨១. បង្កើនកិច្ចខិតខំប្រឹងប្រែង សំដៅពង្រឹងឯករាជ្យភាពតុលាការ និងប្រព័ន្ធផ្សព្វផ្សាយ។ (អ៊ីតាលី)

១១៨.៨២. ចាត់វិធានការចាំបាច់ទាំងអស់ដើម្បីធានាឯករាជ្យភាពតុលាការ ដោយគ្មានការត្រួតត្រា ឬការជ្រៀតជ្រែកនយោបាយ។ (ស្វីស)

១១៨.៨៣. បង្កើតកំណែទម្រង់ប្រព័ន្ធយុត្តិធម៌ដែលផ្តល់យន្តការធានាឯករាជ្យប្រព័ន្ធយុត្តិធម៌ [...] (បែលហ្ស៊ិក)

| |
|---|
| ១១៨.៨៤. បន្តដំណើរការកំណែទម្រង់ប្រព័ន្ធយុត្តិធម៌ រួមទាំងការអនុវត្តវិធានការនានា ដើម្បីពង្រឹងស្ថាប័ន និងធានាឯករាជ្យភាពរបស់ស្ថាប័នទាំងនោះ។ (ឈីលី)<br>១១៨.៨៥. ចាត់វិធានការនានាដែលលើកកម្ពស់ឯករាជ្យភាពតុលាការទាំងតាមច្បាប់ ទាំងតាមការអនុវត្តជាក់ស្តែង (បុតស្វានណា)<br>១១៨.៨៦. ពង្រឹងស្ថាប័នតុលាការបន្ថែមទៀត និង[...] ដើម្បីធានាឯករាជ្យភាពនៃស្ថាប័នទាំងនេះឲ្យមានប្រសិទ្ធភាព។ (កេនយ៉ា)<br>១១៨.៨៧. អនុវត្តកំណែទម្រង់ដែលពាក់ព័ន្ធនានាដែលធានាឯករាជ្យភាព និងភាពមិនលំអៀងនៃតុលាការ និងធានាថា ស្ថាប័ននេះមិនស្ថិតក្រោមការត្រួតត្រា និងការជ្រៀតជ្រែកនយោបាយ។ (ប៉ូឡូញ)<br>១១៨.៨៨. អនុម័ត និងអនុវត្តច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា ច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃតុលាការ និងច្បាប់ស្តីពីឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ដើម្បីធានាឯករាជ្យភាពនៃប្រព័ន្ធតុលាការ។ (បារាំង)<br>១១៨.៨៩. អនុម័តគ្រប់វិធានការចាំបាច់ ដើម្បីធានាពីឯករាជ្យភាពតុលាការ រួមទាំង តាមរយៈការអនុវត្តដោយប្រសិទ្ធភាពនៃកំណែទម្រង់ប្រព័ន្ធយុត្តិធម៌។ (ស្លូវ៉ាគី)<br>១១៨.៩០. ពន្លឿនដំណើរការកំណែទម្រង់ប្រព័ន្ធយុត្តិធម៌ ដើម្បីពង្រឹង និងធានាឯករាជ្យភាពតុលាការ ព្រមទាំងដើម្បីដោះស្រាយបញ្ហាពុករលួយនៅក្នុងប្រព័ន្ធតុលាការ ដោយអនុម័តច្បាប់ពាក់ព័ន្ធនានានៃកំណែទម្រង់។ (សាធារណរដ្ឋកូរ៉េ) |
| *អនុសាសន៍នៃការពិនិត្យជាសកលតាមកាលកំណត់ (២០០៩)* |
| ៩០- (ក). ធានាឯករាជ្យភាព និងអនាគតិនៃប្រព័ន្ធតុលាការ។ (ស៊ុយអែត)<br>(ខ). ធានាឯករាជ្យភាពនៃប្រព័ន្ធតុលាការ ដោយគ្មានការជ្រៀតជ្រែកខាងនយោបាយ។ (ស្វីស)<br>(គ). ពង្រឹងយន្តការនានា ដែលធានាដល់ឯករាជ្យភាពរបស់តុលាការ រាប់បញ្ចូលទាំងការផ្តល់អំណាចពេញលេញទៅឲ្យអង្គភាពប្រឆាំងអំពើពុករលួយរបស់រដ្ឋាភិបាល ដើម្បីប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ នៅក្នុងប្រព័ន្ធតុលាការ។ (ណូវែលហ្សេឡង់)<br>(ឃ). បង្កើនកិច្ចខំប្រឹងប្រែងរបស់ខ្លួន ឆ្ពោះទៅរកការបង្កើតប្រព័ន្ធតុលាការមួយ ដែលឯករាជ្យ អនាគតិ និងអព្យាក្រិតពេញលេញ ដោយគ្មានអំពើពុករលួយ ស្របតាមបទដ្ឋានអន្តរជាតិនានា ដោយធានាថា ជនល្មើសដែលប្រព្រឹត្តអំពើរំលោភសិទ្ធិមនុស្សទាំងអស់ ត្រូវចាប់ខ្លួនឲ្យទទួលខុសត្រូវ ហើយគ្មានជនណាមួយរួចផុតពីទណ្ឌកម្មឡើយ។ (ស្លូវ៉ាគី)<br>(ង). ស្វែងរកមធ្យោបាយ ដើម្បីធ្វើឲ្យប្រសើរឡើងដល់ប្រព័ន្ធបៀវត្សរ៍សំរាប់ចៅក្រម ក្នុងការផ្តល់កិច្ចធានាឲ្យកាន់តែប្រសើរឡើងដល់ឯករាជ្យភាព។ (អេស្ប៉ាញ) |

| |
|---|
| ៤២. អនុម័តច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងច្បាប់វិសោធនកម្មស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម និងច្បាប់ប្រឆាំងអំពើពុករលួយ ស្របតាមអនុសាសន៍ជាបន្តបន្ទាប់ដែលធ្វើដោយអ្នកតំណាងពិសេសនៃអគ្គលេខាធិការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា ក្របខ័ណ្ឌជំនួយអភិវឌ្ឍន៍សហប្រជាជាតិ និងគណៈកម្មាធិការសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ហើយត្រូវបង្កើត និងអនុម័តក្រមសីលធម៌សំរាប់ចៅក្រម និងព្រះរាជអាជ្ញា និងក្រុមប្រឹក្សាវិន័យ រួមទាំងបញ្ញត្តបទវិន័យផង។ (អ៊ីស្រាអែល) |
| *គណៈកម្មាធិការសិទ្ធិមនុស្ស* (CCPR/C/SR.3157) (២០១៥) |
| ២០. រដ្ឋភាគីគួរចាត់វិធានការបន្ទាន់នានា ដើម្បីធានា និងការពារឯករាជ្យភាពពេញលេញ និងភាពមិនលំអៀង នៃប្រព័ន្ធតុលាការ និងធានាថា ប្រព័ន្ធតុលាការនេះ ដំណើរការដោយសេរី ដោយគ្មានការដាក់សម្ពាធ និងការជ្រៀតជ្រែកពីអង្គនីតិប្រតិបត្តិ។ រដ្ឋភាគីគួរធ្វើការពិនិត្យឡើងវិញនូវច្បាប់ស្តីពីប្រព័ន្ធតុលាការ ដើម្បីកាត់បន្ថយសមត្ថកិច្ចរបស់ក្រសួងយុត្តិធម៌ និងពង្រឹងឯករាជ្យភាពរបស់តុលាការ។ |
| *គណៈកម្មាធិការប្រឆាំងទារុណកម្ម* CAT/C/KHM/CO/2 (២០១០) |
| ១៣. រដ្ឋភាគីគួរបង្កើនកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួន ដើម្បីបង្កើត និងធានាឲ្យមានតុលាការមួយ ដែលមានឯករាជ្យពេញលេញ និងមានវិជ្ជាជីវៈ ស្របតាមបទដ្ឋានអន្តរជាតិនានា និងធានាថា តុលាការមិនមានការជ្រៀតជ្រែកផ្នែកនយោបាយ។ កិច្ចខិតខំប្រឹងប្រែងទាំងនេះគួររាប់បញ្ចូលទាំងការអនុម័តជាបន្ទាន់នូវច្បាប់ទាំងអស់ពាក់ព័ន្ធនឹងការកែទម្រង់ ជាពិសេសច្បាប់រៀបចំអង្គការស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់តុលាការ ច្បាប់ស្តីពីវិសោធនកម្មចំពោះឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម និងច្បាប់ស្តីពីលក្ខន្តិកៈនៃអង្គចៅក្រម និងព្រះរាជអាជ្ញា។ រដ្ឋភាគីគួរធានាថា បុគ្គលទាំងឡាយណាដែលជាប់ពាក់ព័ន្ធនឹងការដាក់ និងអនុវត្តតាមសម្ពាធមិនត្រឹមត្រូវទៅលើប្រព័ន្ធតុលាការ ត្រូវធ្វើការស៊ើបអង្កេត ចោទប្រកាន់និងផ្តន្ទាទោស ហើយផ្តល់ឧទាហរណ៍នៃសំណុំរឿងទាំងនេះ។ លើសពីនេះ រដ្ឋភាគីគួរចាត់វិធានការចាំបាច់នានា ដើម្បីធានាថា គណៈមេធាវីមានឯករាជ្យភាព តម្លាភាព និងបង្កលក្ខណៈទទួលយកមេធាវីឱ្យមានចំនួនគ្រប់គ្រាន់។ លើសពីនេះទៅទៀត គណៈកម្មាធិការស្នើឱ្យរដ្ឋភាគីផ្តល់ព័ត៌មានស្តីពីបទប្បញ្ញត្តិនៃច្បាប់ប្រឆាំងអំពើពុករលួយដែលលើកឡើងពីឯករាជ្យភាពតុលាការ។ |
| *គណៈកម្មាធិការលុបបំបាត់ការរើសអើងពូជសាសន៍* CERD/C/KHM/CO/8-13 (២០១០) |
| ១៣. គណៈកម្មាធិការផ្តល់អនុសាសន៍ថា រដ្ឋភាគីបន្ត និងបង្កើនកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួន ដើម្បីពង្រឹង និងធានាឯករាជ្យភាពតុលាការ ហើយធានាថា ស្ថាប័ននេះមិនត្រូវបានត្រួតត្រានិងជ្រៀតជ្រែកខាងនយោបាយ តាមរយៈការអនុម័តឲ្យបានឆាប់រហ័សនូវច្បាប់ទាំងអស់ដែលពាក់ព័ន្ធដល់ការធ្វើកំណែទម្រង់។គណៈកម្មាធិការផ្តល់អនុសាសន៍ទៀតថា រដ្ឋភាគីចាត់វិធានការ ដើម្បីបង្កើនសមត្ថភាពរបស់ខ្លួន ក្នុងការស៊ើបអង្កេត និងចាត់វិធានការដាក់វិន័យ ក្នុងករណីអសមត្ថភាព និងអំពើពុករលួយ។ |

## *អ្នករាយការណ៍ពិសេស*

អនុសាសន៍ខាងក្រោមនេះ ដកស្រង់ចេញពីA/HRC/15/46 រហូតដល់មានការបង្ហាញផ្សេងពីនេះ៖

**៦៦.** កម្ពុជាគួរតែអនុម័ត និងដាក់ឱ្យចូលជាធរមាននូវច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា និងច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃតុលាការដោយគ្មានការពន្យាពេល។ ច្បាប់ទាំងនេះគួរតែត្រូវបានបង្កើតឡើង ដើម្បីធានាឯករាជ្យភាពទាំងស្ថាប័ន និងបុគ្គលនានា នៅក្នុងប្រព័ន្ធតុលាការ ក៏ដូចជាចាត់វិធានការខាងវិន័យ ប្រឆាំងនឹងការប្រព្រឹត្តមិនត្រឹមត្រូវនានារបស់តុលាការ និងចៅក្រមពុករលួយ និងអសមត្ថភាពនានា។ រដ្ឋធម្មនុញ្ញតម្រូវឱ្យអនុម័តច្បាប់ទាំងនេះ ដែលអវត្តមានអស់រយៈពេលជាង១៧ឆ្នាំមកហើយ។ ច្បាប់ទាំងនេះ នឹងរួមចំណែកការពារមុខតំណែងរបស់ចៅក្រម និងការពារលក្ខខណ្ឌនៃការងាររបស់ពួកគេ ដោយផ្អែកលើក្រមសីលធម៌សម្រាប់ចៅក្រម និងព្រះរាជអាជ្ញា។

**៦៧.** ច្បាប់ថ្មីទាំងនេះ គួរតែហាមឃាត់សមាជិកសកម្មនៃគណៈបក្សនយោបាយនានា មិនឱ្យកាន់តំណែងនានាក្នុងវិស័យតុលាការ ព្រមទាំងហាមឃាត់ចៅក្រម និងព្រះរាជអាជ្ញានានា មិនឱ្យបំពេញមុខងារជាទីប្រឹក្សានានារបស់អ្នកដឹកនាំនយោបាយ ឬរដ្ឋមន្ត្រីនានា។ ចៅក្រម និងព្រះរាជអាជ្ញានានា អាចជាសមាជិកនៃគណៈបក្សនយោបាយណាមួយ មុនពេលការតែងតាំងរបស់ខ្លួន។ យ៉ាងណាមិញ នៅពេលដែលពួកគេត្រូវបានតែងតាំងទៅកាន់តំណែងនានាក្នុងវិស័យតុលាការ ពួកគេគួរតែបញ្ឈប់មុខងារជាសមាជិកសកម្មក្នុងគណៈបក្សនយោបាយណាមួយនោះ ឬឈប់ដើរតួនាទីណាមួយ នៅក្នុងសកម្មភាពនានារបស់គណៈបក្សនយោបាយណាមួយនោះតទៅទៀត។

**៦៨.** ចៅក្រម និងព្រះរាជអាជ្ញានានា គួរតែទទួលកម្រៃតបស្នងគ្រប់គ្រាន់ តម្រូវឱ្យធ្វើការពេញម៉ោង និងហាមឃាត់មិនឱ្យបំពេញមុខងារក្រៅវិស័យតុលាការ។ ចៅក្រម និងព្រះរាជអាជ្ញា គួរតែទទួលបានប្រាក់ខែ និងប្រាក់ឧបត្ថម្ភផ្សេងៗទៀត មកពីប្រភពតែមួយគត់ ឧទាះ មកពីក្រសួងយុត្តិធម៌។ នាពេលបច្ចុប្បន្ន ចៅក្រមទទួលបានប្រាក់ខែពីក្រសួងយុត្តិធម៌ និងប្រាក់បំណាច់មុខងារដោយឡែកពីគណៈរដ្ឋមន្ត្រី។ ការអនុវត្តន៍បែបនេះ ពុំអាចធ្វើឱ្យតុលាការឯករាជ្យ ចេញពីអង្គនីតិប្រតិបត្តិនោះទេ។

**៦៩.** តុលាការកំពូល គួរមានការទទួលខុសត្រូវទាំងមូល ចំពោះការគ្រប់គ្រងតុលាការជាន់ទាបនានា គឺមិនមែនក្រសួងយុត្តិធម៌នោះទេ។

**៧០.** ព្រះរាជអាជ្ញាពុំគួរស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងយុត្តិធម៌នោះទេ ប៉ុន្តែគួរស្ថិតក្រោមឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។

**៧១.** គួរតែមានការិយាល័យដាច់ដោយឡែក និងឯករាជ្យមួយសម្រាប់អគ្គព្រះរាជអាជ្ញាដែលមានអំណាចគ្រប់គ្រងលើព្រះរាជអាជ្ញានៅគ្រប់ជាន់ថ្នាក់ ហើយព្រះរាជអាជ្ញាទាំងអស់ គួរស្ថិតក្រោមការិយាល័យឯករាជ្យមួយ ជាជាងនៅអមតាមសាលាដំបូងសាមីនានា។

**៧២**. ច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម គួរធ្វើវិសោធនកម្មដើម្បីធ្វើឱ្យស្ថាប័ននេះមានឯករាជភាពយ៉ាងពិតប្រាកដ។ [...] ធ្វើដូច្នេះបាននឹងពង្រឹងឯករាជភាពនៃប្រព័ន្ធតុលាការ ដោយដកចេញនូវការគ្រប់គ្រងបច្ចុប្បន្នរបស់អង្គនីតិប្រតិបត្តិ ហើយនឹងបង្កើតនូវនីតិវិធីបែបប្រជាធិបតេយ្យ និងប្រកបដោយតម្លាភាពមួយក្នុងការជ្រើសរើស និងការតែងតាំងសមាជិកនានា។ [...]

**៧៣**. សមាជិកនានារបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម គួរតែឈប់បំពេញមុខងារជាចៅក្រមសកម្ម កំឡុងពេលដែលពួកគេកំពុងបម្រើការជាសមាជិកនៃឧត្តមក្រុមប្រឹក្សា ហើយពុំគួរធ្វើជាសមាជិកនៃគណៈបក្សនយោបាយណាមួយនោះឡើយ។ [...]

**៧៧**. រដ្ឋាភិបាលគួរតែគោរពឯករាជភាពរបស់មេធាវី។ ច្បាប់ស្ដីពីលក្ខន្តិកៈមេធាវី ក៏គួរតែធ្វើវិសោធនកម្មទៅតាមនោះផងដែរ។

**៧៨**. គណៈមេធាវីផ្ទាល់ក៏ពុំគួរជ្រៀតជ្រែកក្នុងការងាររបស់មេធាវីនានានោះដែរ។ មេធាវីនានា គួរមានសេរីភាពក្នុងការសម្រេចចិត្តផ្ដល់សេវាផ្នែកច្បាប់របស់ពួកគេដល់អ្នកណាម្នាក់។ មានតែលក្ខន្តិកៈមេធាវីទេ ទើបអាចកំណត់ពីលក្ខណៈនៃការផ្ដល់សេវាផ្នែកច្បាប់នោះបាន ដើម្បីរក្សាបាននូវបទដ្ឋាននៃក្រមសីលធម៌វិជ្ជាជីវៈ។ ក្រមសីលធម៌មេធាវី គួរធ្វើវិសោធនកម្មទៅតាមនោះផងដែរ។

**៨២**. ដំណើរការនៃការទទួលឲ្យចូលរៀននៅសាលាបណ្ដុះបណ្ដាលឲ្យក្លាយជាចៅក្រមនិងព្រះរាជអាជ្ញា គួរតែមានតម្លាភាព និងប្រកួតប្រជែងជាងនេះ (គួរតែតាមរយៈការប្រលងចូល) ហើយត្រូវស្ថិតក្រោមការត្រួតពិនិត្យរបស់អង្គភាពឯករាជ្យពីខាងក្រៅដែលមានសមាសភាពតំណាងនានាមកពីវិស័យតុលាការ គណៈមេធាវី និងមហាវិទ្យាល័យច្បាប់នានានៅកម្ពុជា។ គួរតែមានការផ្ដល់អាហារូបករណ៍សម្រាប់អ្នកដែលមកពីក្រុមទន់ខ្សោយនានា ដោយឈរលើគោលការណ៍ដើម្បីផ្ដល់លទ្ធភាពឲ្យពួកគេអាចចូលរួមក្នុងវិជ្ជាជីវៈច្បាប់។

**៨៧**. រដ្ឋាភិបាលគួរមានគោលនយោបាយល្អៗ និងច្បាស់លាស់ជាងនេះ និងមានយន្តការរឹងមាំរួចជាស្រេចមួយដើម្បីជួយដល់ប្រព័ន្ធតុលាការ។ គោលនយោបាយបែបនេះ គួរត្រូវបង្កើតឡើង ដើម្បីបញ្ចៀសការបំពេញតួនាទីទ្វេរបស់ស្ថាប័នរដ្ឋាភិបាលនានានៅក្នុងបញ្ហានេះ។ សម្រាប់កិច្ចការនេះ តួនាទីរបស់ក្រសួងយុត្តិធម៌គួរត្រូវបានពង្រឹង ហើយក្រសួងនេះគួរទទួលបានធនធានកាន់តែច្រើនឡើងនៅក្នុងកិច្ចការជួយដល់ប្រព័ន្ធតុលាការ។ ស្ថាប័នរដ្ឋាភិបាលនានាឬបណ្ដារដ្ឋមន្ត្រី ពុំគួរមានតួនាទីណាមួយនៅក្នុងការគ្រប់គ្រង និងមានឥទ្ធិពលលើការងាររបស់តុលាការនោះទេ។

**៨៨**. ក្រឡាបញ្ជី និងមន្ត្រីតុលាការផ្សេងៗ គួរស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់ពីតុលាការសាមី ជាជាងស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងយុត្តិធម៌។

A/HRC/24/36 Para 66. រាជរដ្ឋាភិបាល គួរតែពន្លឿនការអនុវត្តនៃរបៀបវារៈកំណែទម្រង់ស្ថាប័នរដ្ឋ ទទួលបន្ទុកលើកកំពស់សិទ្ធិរបស់ប្រជាពលរដ្ឋ រួមទាំងការអនុម័តច្បាប់គ្រឹះទាំងបីទាក់ទងនឹងការពង្រឹងឯករាជ្យភាព និងសមត្ថភាពរបស់ស្ថាប័នតុលាការ តាមការសន្យារបស់រាជរដ្ឋាភិបាល។

| |
|---|
| A/HRC/21/63/Add.1/Rev.1 Para 234. គួរតែខិតខំប្រឹងប្រែងថែមទៀត ដើម្បីពង្រឹងសមត្ថភាពរដ្ឋបាលនៃយន្តការដោះស្រាយវិវាទដីធ្លី និងប្រព័ន្ធតុលាការ ដើម្បីធ្វើឲ្យកាន់តែប្រសើរដល់ការទទួលបានដំណោះស្រាយរបស់សហគមន៍ពាក់ព័ន្ធនឹងដីធ្លី។ សមត្ថភាព និងឯករាជភាពនៃប្រព័ន្ធតុលាការ គួរត្រូវបានលើកកំពស់ ធ្វើដូច្នេះបានអាចទទួលបានការគោរព និងការជឿទុកចិត្តពីប្រជាពលរដ្ឋ។ ប្រព័ន្ធតុលាការមិនគួរត្រូវយកមកប្រើជាយន្តការមួយដើម្បីដាក់ទោសដល់សកម្មជនដីធ្លី បុគ្គលទាំងឡាយណាដែលទាមទារថាជាដីរបស់ពួកគាត់ អ្នកការពារសិទ្ធិមនុស្ស និងអាជ្ញាធរមូលដ្ឋាននោះទេ។<br><br>A/HRC/33/62 Para 61 (q). ដោយឈរលើមូលដ្ឋាននៃអនុសាសន៍ដែលស្នើដោយអ្នកកាន់អាណត្តិមុនៗ (សូមមើលA/HRC/18/46) ចាប់ផ្តើមកម្មវិធីពង្រឹងឯករាជភាពតុលាការនៅតុលាការគ្រប់កំរិត និងញែកឱ្យដាច់តួនាទីរបស់នីតិប្រតិបត្តិនៅក្នុងដំណើរការតុលាការ និងក្នុងការបណ្តុះបណ្តាល និងកាដាក់វិន័យដល់សមាជិកតុលាការ។ |

## គ. កំណែទម្រង់ប្រព័ន្ធយុត្តិធម៌ និងការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ

| *អនុសាសន៍នៃការពិនិត្យជាសកលតាមកាលកំណត់ (២០១៤)* |
|---|
| **១១៨.៨៣**. បង្កើតកំណែទម្រង់ប្រព័ន្ធយុត្តិធម៌ ដែលផ្តល់យន្តការធានាឯករាជ្យប្រព័ន្ធយុត្តិធម៌ និងប្រសិទ្ធភាពនៃស្ថាប័នដែលទទួលខុសត្រូវក្នុងការប្រយុទ្ធប្រឆាំងអំពើពុករលួយ។ (បែលហ្សិក)<br><br>**១១៨.៩០**. ពន្លឿនដំណើរការកំណែទម្រង់ប្រព័ន្ធយុត្តិធម៌ ដើម្បីពង្រឹង និងធានាឯករាជ្យភាពតុលាការ ព្រមទាំងដើម្បីដោះស្រាយបញ្ហាពុករលួយនៅក្នុងប្រព័ន្ធតុលាការ ដោយអនុម័តច្បាប់ពាក់ព័ន្ធនានានៃកំណែទម្រង់។ (សាធារណរដ្ឋកូរ៉េ) |
| *អនុសាសន៍នៃការពិនិត្យជាសកលតាមកាលកំណត់ (២០០៩)* |
| **៣៥**. អនុម័តច្បាប់ប្រឆាំងអំពើពុករលួយ។ (ស្វីស)<br><br>**៣៦**. ពិនិត្យឡើងវិញ និងអនុម័តជាបន្ទាន់ នូវច្បាប់ប្រឆាំងអំពើពុករលួយ ដែលនឹងដាក់បញ្ចូលទោសទណ្ឌឲ្យបានតឹងរឹងចំពោះអំពើពុករលួយរបស់រដ្ឋាភិបាលហើយតម្រូវឲ្យមន្ត្រីសាធារណៈប្រកាសអំពីធនធានហិរញ្ញវត្ថុរបស់ខ្លួន។ (សហរដ្ឋអាមេរិក)<br><br>**៣៧**. អនុវត្តច្បាប់ប្រឆាំងអំពើពុករលួយ តាមរយៈគណៈកម្មការប្រឆាំងអំពើពុករលួយ មិនបក្សពួក និងឯករាជ្យ។ (អៀកឡង់)<br><br>**៣៨**. ចាត់វិធានការបន្ថែមទៀត ដើម្បីបន្តដំណើរកំណែទម្រង់ប្រព័ន្ធយុត្តិធម៌របស់ខ្លួន ដើម្បីដោះស្រាយបញ្ហាដីធ្លី និងដើម្បីប្រយុទ្ធប្រឆាំងអំពើពុករលួយ ពីព្រោះវិធានការទាំងនេះ មានសារៈសំខាន់សំរាប់ការលើកស្ទួយ និងការការពារសិទ្ធិមនុស្ស ព្រមទាំងសំរាប់ពង្រឹងដល់លទ្ធិប្រជាធិបតេយ្យ។ (ជប៉ុន) |

| |
|---|
| ៤១. សូមបញ្ជាប់នូវដំណើរការកំណែទម្រង់តុលាការ និងអនុម័តច្បាប់សំខាន់ៗ ដូចជាក្រមព្រហ្មទណ្ឌថ្មី ច្បាប់ប្រឆាំងអំពើពុករលួយ ច្បាប់ធានានិងការពារឯករាជ្យភាព និងភាពអនាគតិរបស់ប្រព័ន្ធតុលាការ មន្ត្រីតុលាការ និងចៅក្រម ស្របតាមបទដ្ឋានអន្តរជាតិ។ (ណ័រវេស) |
| *គណៈកម្មាធិការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ* (២០១៣) CEDAW/C/KHM/CO/4-5 |
| ១៣. គណៈកម្មាធិការសូមទទូចឲ្យរដ្ឋភាគី៖ [...] (គ). បន្តស៊ើបអង្កេត និងចោទប្រកាន់លើករណីពុករលួយក្នុងតុលាការ និងប្រសិនបើអាចអនុវត្តបាន ផ្តន្ទាទោសអ្នកប្រព្រឹត្ត។ |
| *គណៈកម្មាធិការប្រឆាំងទារុណកម្ម* CAT/C/KHM/CO/2 (២០១០) |
| ១២. រដ្ឋភាគីគួរចាត់វិធានការជាបន្ទាន់និងភ្លាមៗ ដើម្បីលុបបំបាត់អំពើពុករលួយនៅទូទាំងប្រទេសដែលជាឧបសគ្គមួយក្នុងចំណោមឧបសគ្គដ៏ធ្ងន់ធ្ងរបំផុតទាំងឡាយដល់នីតិរដ្ឋ និងដល់ការអនុវត្តអនុសញ្ញា។ វិធានការទាំងនេះ រួមមានការអនុវត្តច្បាប់ប្រឆាំងអំពើពុករលួយឲ្យមានប្រសិទ្ធភាព និងការដាក់ឲ្យដំណើរការនូវអង្គភាពប្រឆាំងអំពើពុករលួយឲ្យបានឆាប់រហ័ស ដែលត្រូវមានសមាជិកនានាឯករាជ្យ។ រដ្ឋភាគីគួរបង្កើនសមត្ថភាពរបស់ខ្លួនក្នុងការស៊ើបអង្កេត និងជំនុំជម្រះសំណុំរឿងអំពើពុករលួយផងដែរ។ រដ្ឋភាគីគួរបង្កើតកម្មវិធីការពារសាក្សី និងអ្នករិះគន់តតសំថៃមាត់ដើម្បីជួយធានាដល់ការរក្សាការសម្ងាត់ និងការពារអ្នកដែលចេញមុខដាក់ពាក្យបណ្តឹងពីបទពុករលួយ ហើយធានាឲ្យមានការបែងចែកថវិកាគ្រប់គ្រាន់សម្រាប់បំពេញមុខងាររបស់ខ្លួនឲ្យមានប្រសិទ្ធភាព។ លើសពីនេះ រដ្ឋភាគីគួររៀបចំកម្មវិធីបណ្តុះបណ្តាល និងកសាងសមត្ថភាពដល់មន្ត្រីនគរបាលនិងមន្ត្រីប្រតិបត្តិច្បាប់ ព្រះរាជអាជ្ញា និងចៅក្រមស្តីពីការអនុវត្តយ៉ាងតឹងរ៉ឹងនូវច្បាប់ប្រឆាំងអំពើពុករលួយ ព្រមទាំងក្រមសីលធម៌វិជ្ជាជីវៈពាក់ព័ន្ធនិងអនុម័តយន្តការដែលមានប្រសិទ្ធភាពដើម្បីធានាឲ្យមានតម្លាភាពក្នុងការប្រព្រឹត្តទៅរបស់មន្ត្រីសាធារណៈ ទាំងនៅក្នុងផ្នែកខ្លឹមសារច្បាប់ និងទាំងការអនុវត្តការងារជាក់ស្តែង។ គណៈកម្មាធិការស្នើឲ្យរដ្ឋភាគីធ្វើរបាយការណ៍ស្តីពីវឌ្ឍនភាពដែលទទួលបានជោគជ័យ និងការលំបាកទាំងឡាយ ដែលជួបប្រទះក្នុងការប្រយុទ្ធប្រឆាំងអំពើពុករលួយ។ គណៈកម្មាធិការសូមស្នើឲ្យរដ្ឋភាគីផ្តល់ព័ត៌មានស្តីពីចំនួនមន្ត្រី រួមទាំងមន្ត្រីជាន់ខ្ពស់ដែលត្រូវបានជំនុំជម្រះ និងដាក់ទោសពីបទប្រព្រឹត្តអំពើពុករលួយ។ |

## *គណៈកម្មាធិការសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌* E/C.12/KHM/CO/1 (២០០៩)

១៤. គណៈកម្មាធិការស្នើយ៉ាងទទូចដល់រដ្ឋភាគីឲ្យអនុម័តសេចក្តីព្រាងច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ ដោយគ្មានការអូសបន្លាយពេលវេលា និងពង្រឹងកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួនដើម្បីធ្វើទំនើបកម្មនិងធ្វើឲ្យប្រសើរឡើងថែមទៀតនូវការងាររបស់តុលាការ រួមទាំងតាមរយៈគំរោងថ្មីសំរាប់កំណែទម្រង់ប្រព័ន្ធយុត្តិធម៌។ គណៈកម្មាធិការផ្តល់ជាអនុសាសន៍ថា រដ្ឋភាគីពង្រឹងកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួន ក្នុងការផ្តន្ទាទោសករណីនៃអំពើពុករលួយ និងពិនិត្យឡើងវិញនូវគោលនយោបាយរបស់ខ្លួន ស្តីពីការកាត់ទោសបទល្មើសពាក់ព័ន្ធនឹងអំពើពុករលួយ។ គណៈកម្មាធិការផ្តល់ជាអនុសាសន៍ផងដែរថា រដ្ឋភាគីគួររៀបចំបង្កើតកម្មវិធីបណ្តុះបណ្តាល និងកសាងសមត្ថភាពដល់នគរបាល និងមន្ត្រីប្រតិបត្តិច្បាប់ ព្រះរាជអាជ្ញា និងចៅក្រម អំពីការអនុវត្តន៍យ៉ាងម៉ឺងម៉ាត់នូវវិធានការ និងច្បាប់ប្រឆាំងអំពើពុករលួយ និងអនុម័តយន្តការមានប្រសិទ្ធភាព ដើម្បីធានាតម្លាភាពក្នុងដំណើរការរបស់អាជ្ញាធរសាធារណៈ ទាំងក្នុងការអនុវត្តន៍ច្បាប់ ទាំងក្នុងការអនុវត្តន៍ជាក់ស្តែង។ គណៈកម្មាធិការស្នើឲ្យរដ្ឋភាគី ផ្តល់ក្នុងរបាយការណ៍តាមកាលកំណត់លើកក្រោយរបស់ខ្លួន នូវព័ត៌មានលំអិតទាក់ទងនឹងសមិទ្ធិផលដែលសំរេចបាន និងការលំបាកផ្សេងៗដែលរដ្ឋភាគីបានជួបប្រទះ ក្នុងការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ។

## *អ្នករាយការណ៍ពិសេស*

A/HRC/7/42.Para.101. រដ្ឋាភិបាល ត្រូវអនុម័តច្បាប់ស្តីពីការធ្វើបាតុកម្ម និងច្បាប់ប្រឆាំងអំពើពុករលួយឲ្យបានឆាប់ ដោយធានាថា ច្បាប់ទាំងនេះស្របតាមរដ្ឋធម្មនុញ្ញ និងបទដ្ឋានសិទ្ធិមនុស្ស។

A/HRC/21/63/Add.1/Rev.1.Para.235. ត្រូវធ្វើការប្រឹងប្រែងឲ្យអស់ពីសមត្ថភាពក្នុងការតាមឃ្លាំមើលករណីវិវាទដីធ្លីនៅតាមយន្តការដោះស្រាយវិវាទដីធ្លី និងនៅតាមតុលាការ ជាតួយ៉ាង ឃ្លាំមើលពីទំនាស់ផលប្រយោជន៍ ការជ្រៀតជ្រែកនយោបាយ ឬអំពើពុករលួយពាក់ព័ន្ធនឹងក្រុមហ៊ុនសម្បទាន។ មន្ត្រីរដ្ឋបាល ឬមន្ត្រីតុលាការដែលចេញសេចក្តីសម្រេចដោយផ្អែកលើការលើកទឹកចិត្តជាឯកជន គួរត្រូវបានហាមឃាត់ពីតួនាទីណាមួយក្នុងការជម្រះក្តី។

A/HRC/27/70, Para 81(f). បន្តកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួន សំដៅកែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ជាពិសេសអំពីការធ្វើឱ្យកាន់តែប្រសើរដល់ឯករាជភាពតុលាការ និងសមត្ថភាពរបស់តុលាការក្នុងការដោះស្រាយសំណុំរឿងតាមលក្ខណៈមួយឆាប់រហ័ស និងយុត្តិធម៌ ហើយក្នុងករណីនេះ គួរចាប់ផ្តើមភ្លាមៗនូវការធ្វើវិសោធនកម្មច្បាប់មូលដ្ឋានទាំងបីពាក់ព័ន្ធនឹងតុលាការ ដើម្បីសម្រេចបានគោលបំណងនេះ។

A/HRC/33/62, Para 61(r). ធានាថាបញ្ជីនៃកម្រៃដែលត្រូវចំនាយក្នុងរឿងក្តីនៅតុលាការ ត្រូវបានដាក់ផ្សាយជាសាធារណៈនៅគ្រប់តុលាការ ហើយតម្លៃបន្ថែមណាមួយដែលក្រឡាបញ្ជីអាចទាមទារឱ្យបង់ត្រឹមត្រូវតាមច្បាប់ ត្រូវបានផ្ទៀងផ្ទាត់នឹងបញ្ជីដែលដាក់ផ្សាយជាសាធារណៈនោះ។

## ឃ. មធ្យោបាយសំរាប់ប្រព័ន្ធយុត្តិធម៌ និងការទទួលបានសេវាកម្មច្បាប់/ជំនួយផ្នែកច្បាប់ដល់ជនក្រីក្រដែលកាន់តែប្រសើរឡើង

| *អនុសាសន៍នៃការពិនិត្យជាសកលតាមកាលកំណត់* (២០១៤) |
| --- |
| **១១៨.៩៤.** អនុម័តវិធានការចាំបាច់នានា ដើម្បីធានាពីការទទួលបានសេវាយុត្តិធម៌សម្រាប់ស្ត្រី។ (អេស្ប៉ាញ) <br> **១១៨.៩៥.** ពង្រឹងមធ្យោបាយនានាតាមការប្រើប្រាស់ប្រព័ន្ធយុត្តិធម៌ និងធ្វើឲ្យប្រព័ន្ធនេះកាន់តែងាយទទួលបានដល់អ្នកក្រីក្រ។ (សេណេហ្គាល់) |
| *អនុសាសន៍នៃការពិនិត្យជាសកលតាមកាលកំណត់* (២០០៩) |
| **៣៩.** ចាត់វិធានការដើម្បីធានាដល់សិទ្ធិរបស់ជនគ្រប់រូប ក្នុងការប្រើប្រាស់ប្រព័ន្ធយុត្តិធម៌ឲ្យបានស្មើៗគ្នា ស្របតាមបទដ្ឋានអន្តរជាតិ។ (ស៊ុយអែត) |
| *គណៈកម្មាធិការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ* (២០១៣) <br> CEDAW/C/KHM/CO/4-5 |
| **១៣.** គណៈកម្មាធិការសូមទទូចឲ្យរដ្ឋភាគីៈ <br> (ក). បង្កើតគម្រោងជំនួយផ្នែកច្បាប់គ្រប់ជ្រុងជ្រោយដើម្បីធានាថាស្ត្រីទទួលបានសេវាប្រកបដោយប្រសិទ្ធភាពពីតុលាការនិងសាលាជម្រះក្តី ស្របតាមគោលការណ៍និងការណែនាំរបស់អង្គការសហប្រជាជាតិស្តីពីការទទួលបានជំនួយផ្នែកច្បាប់ក្នុងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ (សេចក្តីសម្រេចលេខ៦៧/១៨៧ របស់មហាសន្និបាតអង្គការសហប្រជាជាតិ) ជាពិសេសគោលការណ៍ណែនាំទី៩ស្តីពីការអនុវត្តសិទ្ធិរបស់ស្ត្រី ក្នុងការទទួលបានជំនួយផ្នែកច្បាប់។ <br> (ខ). ផ្តល់ថវិកាគ្រប់គ្រាន់ដល់គណៈមេធាវី និងអង្គការរបស់ស្ត្រី ដែលផ្តល់ការប្រឹក្សាផ្នែកច្បាប់ដោយឥតគិតថ្លៃ ដើម្បីធានាបាននូវការទទួលបានយុត្តិធម៌ប្រកបដោយប្រសិទ្ធភាពសម្រាប់ស្ត្រី និង [...] |
| *គណៈកម្មាធិការប្រឆាំងទារុណកម្ម* CAT/C/KHM/CO/2 (២០១០) |
| **១៤.** រដ្ឋភាគីគួរអនុវត្តវិធានការឲ្យបានទាន់ពេលវេលា និងមានប្រសិទ្ធភាព ដើម្បីធានាថា ជនជាប់ឃុំទាំងអស់ ត្រូវទទួលបានកិច្ចធានាការពារតាមផ្លូវច្បាប់ជាមូលដ្ឋាន ចាប់ពីពេលឃាត់ខ្លួន/ឃុំខ្លួនលើកដំបូង។ ដើម្បីសម្រេចគោលបំណងនេះ រដ្ឋភាគីគួរធ្វើវិសោធនកម្មក្រមនីតិវិធីព្រហ្មទណ្ឌ ដើម្បីធានាថា ជនជាប់ឃុំមានសិទ្ធិទទួលបានមេធាវីជាបន្ទាន់ ចាប់ពីពេលដែលពួកគេត្រូវបានដកហូតសេរីភាព រហូតដល់ដំណាក់កាលស៊ើបអង្កេត ដំណើរការកាត់ទោសទាំងមូល និងអំឡុងពេលប្តឹងឧទ្ធរណ៍ ព្រមទាំងមានសិទ្ធិទទួលបានការត្រួតពិនិត្យសុខភាពដោយឯករាជ្យ |

| |
|---|
| ដោយជ្រើសរើសគ្រូពេទ្យដោយខ្លួនឯង ការផ្ដល់ដំណឹងដល់សាច់ញាតិ និងត្រូវបានគេប្រាប់ឲ្យដឹងពីសិទ្ធិទាំងឡាយនៅពេលឃាត់ខ្លួន/ជាប់ឃុំ រាប់ទាំងការចោទប្រកាន់មកលើខ្លួន និងសិទ្ធិបង្ហាញខ្លួនភ្លាមនៅចំពោះមុខចៅក្រមជាដើម។ ដោយចាត់ទុកជាបញ្ហាបន្ទាន់ រដ្ឋភាគីគួរបង្កើនចំនួនមេធាវីការពារក្ដី ដូចជាមេធាវីការពារក្ដី ជំនួយផ្នែកច្បាប់ក្នុងប្រទេស និងដកចេញនូវរាល់ឧបសគ្គដែលមិនតាមយុត្តិកម្ម ដើម្បីឲ្យបុគ្គលទាំងឡាយអាចចូលជាសមាជិកមេធាវីតាមបំណងរបស់ពួកគេ។ រដ្ឋភាគីគួរធានាឲ្យមានការចុះបញ្ជីឲ្យបានទាន់ពេលវេលា ចំពោះជនដែលត្រូវបានដកហូតសេរីភាព ហើយធានាថា ត្រូវមានការត្រួតពិនិត្យកំណត់ហេតុឃុំខ្លួន/ឃាត់ខ្លួនតាមពេលកំណត់ នៅស្ថានីយ៍នគរបាល និងពន្ធនាគារ ដើម្បីធ្វើឱ្យប្រាកដថា កំណត់ហេតុទាំងនេះត្រូវរក្សាទុកស្របទៅតាមនីតិវិធីទាំងឡាយដែលកំណត់ដោយច្បាប់។ |
| *គណៈកម្មាធិការលុបបំបាត់ការរើសអើងពូជសាសន៍* CERD/C/KHM/CO/8-13 (២០១០) |
| **១៧.** [...] ក្នុងកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួនដើម្បីពង្រឹងប្រព័ន្ធយុត្តិធម៌ រដ្ឋភាគីគួរធានាប្រសិទ្ធភាពថែមទៀតដល់ប្រព័ន្ធយុត្តិធម៌ដើម្បីធានាសិទ្ធិស្មើគ្នាក្នុងការស្វែងរកយុត្តិធម៌សំរាប់មនុស្សគ្រប់រូប រាប់ទាំងជនភាគតិច និងជនជាតិដើមភាគតិច។ អនុលោមតាមសេចក្ដីពន្យល់ទូទៅលេខ៣១(២០០៥) របស់គណៈកម្មាធិការប្រឆាំងនឹងការរើសអើងពូជសាសន៍ ក្នុងការគ្រប់គ្រង និងការប្រព្រឹត្តទៅនៃប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ។ |
| *អ្នករាយការណ៍ពិសេស* |
| A/HRC/7/42, Para. 101. រដ្ឋាភិបាលត្រូវលះបង់ធនធានបន្ថែមទៀតដល់វិស័យយុត្តិធម៌។ កិច្ចខិតខំប្រឹងប្រែងបណ្ដុះបណ្ដាលមេធាវី និងជ្រើសរើសចៅក្រម/ព្រះរាជអាជ្ញា គួរបន្ត ហើយគោលដៅគួរតែសំរាប់ទាំងអស់គ្នា ងាយស្រួយទទួលបានសេវាតុលាការ ហើយការពន្យាពេលក្នុងនីតិវិធី ត្រូវបានបង្រួញ។<br>អនុសាសន៍ខាងក្រោមនេះ ដកស្រង់ចេញពីA/HRC/15/46<br>**៧៥.** ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមគួរតែមានលេខាធិការដ្ឋានផ្ទាល់របស់ខ្លួន [...]។ លេខាធិការដ្ឋានដ៏រឹងមាំមួយបូករួមនឹងសមាជិកដែលបំពេញមុខងារពេញម៉ោង នឹងបង្កើនសមត្ថភាពការងាររបស់ក្រុមប្រឹក្សានេះ [...]។<br>**៧៦.** សមត្ថភាពរបស់សាលាឧទ្ធរណ៍ គួរតែត្រូវបានធ្វើឲ្យប្រសើរឡើងយ៉ាងប្រាកដប្រជា ដើម្បីផ្ដល់លទ្ធភាពឲ្យស្ថាប័ននេះ ដោះស្រាយលើសំណុំរឿងដែលកកស្ទះយ៉ាងច្រើនរបស់ខ្លួន ហើយអាចចាត់ចែងសំណុំរឿងថ្មីៗឲ្យបានត្រឹមត្រូវ ទាន់ពេលវេលា និងមានសណ្ដាប់ធ្នាប់។ គួរពិចារណាផងដែរពីការបង្កើតសាលាឧទ្ធរណ៍បន្ថែមមួយចំនួនដែលមានវិសាលភាពគ្របដណ្ដប់ខេត្តមួយ ឬច្រើន។ សាលាឧទ្ធរណ៍នៅរាជធានីភ្នំពេញគួរមានបន្ទប់សវនាការ និងធនធានច្រើនបន្ថែមទៀត ដើម្បីគាំទ្រដល់សកម្មភាពនានារបស់ខ្លួន។<br>**៧៩.** គណៈមេធាវីគួរតែគាំពារ និងការពារមេធាវីដែលធ្វើការដើម្បីប្រយោជន៍សាធារណៈ ដែលតួនាទីរបស់មេធាវីទាំងនេះ មានសារៈសំខាន់ណាស់ក្នុងការលើកស្ទួយយុត្តិធម៌នៅកម្ពុជា។ |

៨០. ដៃគូអភិវឌ្ឍន៍អន្តរជាតិនានារបស់កម្ពុជាគួរតែបង្កើនការគាំទ្រខាងហិរញ្ញវត្ថុដល់កំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ និងជួយដល់គណៈមេធាវី ដើម្បីផ្តល់ជំនួយផ្នែកច្បាប់ដល់ជនក្រីក្រ។

៨១. គួរតែបង្កើនថវិកាឲ្យបានគ្រប់គ្រាន់ដល់វិស័យយុត្តិធម៌។ រាជរដ្ឋាភិបាល គួរតែឧបត្ថម្ភហិរញ្ញវត្ថុដល់ការអប់រំច្បាប់សម្រាប់ប្រជាពលរដ្ឋ ឲ្យកាន់តែច្រើនឡើងថែមទៀត ជាពិសេសដល់ជនក្រីក្រ និងជនងាយរងគ្រោះ។

៨៤. គួរតែផ្តល់ការអប់រំ និងការបណ្តុះបណ្តាលផ្នែកច្បាប់ដល់មន្ត្រីនគរបាលយុត្តិធម៌ដែលជាអ្នកដើរតួយ៉ាងសំខាន់ក្នុងដំណើរការស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌ។

៨៥. រដ្ឋាភិបាលគួរធានាថា បុគ្គលទាំងអស់ដែលត្រូវបានឃាត់ខ្លួននិងឃុំខ្លួនត្រូវមានអ្នកតំណាងផ្នែកច្បាប់ត្រឹមត្រូវ និងទទួលបានមេធាវីយ៉ាងឆាប់រហ័សបំផុត។ គួរធ្វើវិសោធនកម្មក្រមនីតិវិធីព្រហ្មទណ្ឌដើម្បីធានាថា បុគ្គលដែលត្រូវ បានចោទប្រកាន់ពីការប្រព្រឹត្តបទល្មើសណាមួយ គួរមានវត្តមានរបស់អ្នកតំណាងផ្នែកច្បាប់នៅជាមួយ ក្នុងកំឡុង ពេលនៃការសាកសួររបស់នគរបាល។

៨៦. កម្ពុជាគួរផ្តល់ការការពារពិសេសដល់ក្រុមមនុស្សដែលស្ថិតក្នុងក្រុមពិសេសណាមួយ ដូចជា ប្រព័ន្ធយុត្តិធម៌អនីតិជនដាច់ដោយឡែកមួយ ហើយគួរបង្កើតឲ្យមានតុលាការគ្រួសារផងដែរ។

៨៩. គួរផ្តល់ការបណ្តុះបណ្តាលត្រឹមត្រូវអំពីវិទ្យាសាស្ត្រកោសល្យវិច័យដល់មន្ត្រីនគរបាលយុត្តិធម៌ ព្រះរាជអាជ្ញា និងចៅក្រមស៊ើបសួរនានា។

៩០. គួរមានការផ្តល់ជំនួយផ្នែកច្បាប់ពីសំណាក់រដ្ឋ ដល់ជនក្រីក្របំផុត និងបុគ្គលផ្សេងទៀតដែលស្ថិតក្នុងក្រុមមនុស្សងាយរងគ្រោះ និងក្រុមដែលត្រូវគេផាត់ចេញពីសង្គម។

៩១. ទស្សនៈស្តីពីតុលាការគំរូគួរត្រូវបានពង្រីកឲ្យទូលំទូលាយឡើង ហើយតុលាការទាំងនោះគួរត្រូវបានផ្តល់ឲ្យនូវធនធានកាន់តែច្រើនឡើង ដើម្បីផ្តល់លទ្ធភាពឲ្យពួកគេដំណើរការជាតុលាការគំរូដ៏ពិតប្រាកដ។

៩២. តុលាការនីមួយៗគួរមានអ្នកកាន់បញ្ជីរៀងខ្លួន ព្រមទាំងមានប្រព័ន្ធរក្សាសំណុំរឿង និងសំណុំលិខិតបានត្រឹមត្រូវ។ ចៅក្រមពុំគួររក្សាទុកសំណុំរឿងក្តីនៅជាមួយខ្លួននោះទេ ហើយក៏ពុំគួរនាំសំណុំរឿងទាំងនោះទៅជាមួយ នៅពេលខ្លួនផ្លាស់ប្តូរទៅតុលាការផ្សេងនោះដែរ។

៩៣. តុលាការនានាគួរប្រកាន់យកគោលនយោបាយដែលកាន់តែមានតម្លាភាពឡើង ក្នុងការបញ្ចេញច្បាប់ចម្លងនៃសាលក្រមនានា និងឯកសារតុលាការផ្សេងៗទៀតទៅដល់ភាគីពាក់ព័ន្ធនានា។

A/HRC/33/62 Para 61(g). ពង្រឹងយន្តការតុលាការការពារជនរងគ្រោះពីអំពើហិង្សាក្នុងគ្រួសារ និងការជួញដូរជំរុញកិច្ចខិតខំប្រឹងប្រែងបណ្តុះបណ្តាលមន្ត្រីតុលាការនិងមន្ត្រីអនុវត្តច្បាប់អំពីច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ ដើម្បីធានាឱ្យមានការចោទប្រកាន់ដ៏មានប្រសិទ្ធភាព ជាជាងតាមរយៈការសម្រុះសម្រួល និងធានាថាការសម្រុះសម្រួល និងយន្តការក្រៅផ្លូវការ ត្រូវបានប្រើសំរាប់តែរឿងក្តីមិនមែនព្រហ្មទណ្ឌប៉ុណ្ណោះ។

A/HRC/33/62 Para 61(s). បង្កើនកិច្ចខិតខំប្រឹងប្រែងឱ្យមានកំណត់ត្រា និងរបាយការណ៍រឿងក្តីជាប្រព័ន្ធ ដោយមានសេចក្តីសង្ខេបពីមូលហេតុនៃការសម្រេចរបស់ខ្លួនផង។

## ង. យុត្តិធម៌អនីតិជន

| |
|---|
| *អនុសាសន៍នៃការពិនិត្យជាសកលតាមកាលកំណត់* (២០១៤) |
| **១១៨.៩៣.** ដាក់ឲ្យអនុវត្តនូវប្រព័ន្ធយុត្តិធម៌អនីតិជន ដែលសម្របទៅតាមតម្រូវការរបស់ជនល្មើសជាអនីតិជន ជាពិសេស ដើម្បីធានាថា អនីតិជនមិនត្រូវបានឃុំខ្លួនជាមួយមនុស្សពេញវ័យ។ (ឌ្យីប៊ូទី) |
| *អនុសាសន៍នៃការពិនិត្យជាសកលតាមកាលកំណត់* (២០០៩) |
| **៨១.** ដាក់បញ្ចូលនិយមន័យស្របច្បាប់អំពីកុមារ អាយុអប្បបរិមាសំរាប់ទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ និងការព្រមព្រៀងខាងផ្លូវភេទ និងសូមពង្រឹងច្បាប់ស្តីពីអាយុអប្បបរិមាសំរាប់រៀបអាពាហ៍ពិពាហ៍ ដូចគណៈកម្មាធិការស្តីពីសិទ្ធិកុមារបានផ្តល់អនុសាសន៍ ព្រមទាំង សូមបង្កើត និងអនុវត្តច្បាប់ជាតិដែលកំណត់ជាបទឧក្រិដ្ឋ និងផ្តន្ទាទោសអំពើចែកចាយ លក់ដូរ និងអំពើឬសំភារៈអាសអាភាសកុមារ។ (អ៊ីស្រាអែល) |
| *គណៈកម្មាធិការសិទ្ធិមនុស្ស* (CCPR/C/SR.3157) (២០១៥) |
| **១៥.** រដ្ឋភាគីគួរតែចាត់វិធានការដើម្បីបង្កើតប្រព័ន្ធយុត្តិធម៌អនីតិជន ក្នុងគោលបំណងធានាថា អនីតិជនត្រូវបានប្រព្រឹត្តិមកលើក្នុងរបៀបមួយសមស្របតាមអាយុរបស់ពួកគេ។ រដ្ឋភាគីគួរធានាផងដែរនូវការដាក់អនីតិជន និងនីតិជនឲ្យនៅដាច់ដោយឡែកពីគ្នានៅកន្លែងឃុំខ្លួន ដោយអនុលោមតាមបទដ្ឋានអន្តរជាតិ។ |
| *គណៈកម្មាធិការសិទ្ធិកុមារ៖ ពេស្យាចារកុមារ* CRC/C/OPSC/KHM/CO/1 (២០១៥) |
| **២៩.** យោងតាមមាត្រា៨ វក្យខ័ណ្ឌ១ នៃពិធីសារបន្ថែម និងគោលការណ៍ណែនាំស្តីពីយុត្តិធម៌ក្នុងបញ្ហាពាក់ព័ន្ធនឹងកុមារជាជនរងគ្រោះ និងជាសាក្សីនៃបទឧក្រិដ្ឋ (ក្រុមប្រឹក្សាសេដ្ឋកិច្ចនិងសង្គម សេចក្តីសម្រេចលេខ២០០៥/២០ ឧបសម្ព័ន្ធ) គណៈកម្មាធិការទទូចឱ្យរដ្ឋភាគីធានាថា តាមរយៈបទប្បញ្ញត្តិ និងបទបញ្ជាគ្រប់គ្រាន់ កុមារជាជនរងគ្រោះ និងជាសាក្សីទាំងអស់នៃបទឧក្រិដ្ឋ ក្រោមពិធីសារបន្ថែមនេះ ត្រូវប្រព្រឹត្តិលើតាមវិធីគិតគូរពិសេសលើកុមារដោយប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ចាប់តាំងពីដំណាក់ការស៊ើបសួរ រហូតដល់ដំណើរការសវនាការ និងត្រូវផ្តល់ជូននូវការគាំពារគ្រប់គ្រាន់។ ជាពិសេស រដ្ឋភាគី ត្រូវបានស្នើឱ្យ៖<br>(ក). បង្កើតនីតិវិធីនិងបទដ្ឋានគិតគូរកុមារឱ្យបានច្បាស់លាស់ចំពោះការផ្តល់ការគាំពារបែបនេះនៅគ្រប់ដំណាក់កាលនៃដំណើរការព្រហ្មទណ្ឌ និងតាមផ្លូវតុលាការ។<br>(ខ). ធានាថា តុលាការត្រូវមានរបាំងឡប់ឡែចំពោះកុមារ និងមានកម្មវិធីភ្ជាប់ជាវីដេអូនៅតាមគ្រប់តុលាការ។ |

| |
|---|
| (គ). ផ្តល់ឱ្យកុមាររងគ្រោះនូវសេវាជំនួយផ្នែកច្បាប់ដោយឥតគិតថ្លៃ ឬសេវាច្បាប់ដោយឧបត្ថម្ភធន រួមជាមួយការគាំពារកុមារពីអ្នកចិត្តវិទ្យា និងមន្ត្រីសង្គមកិច្ច។<br><br>(ឃ). ធានាថា កុមាររងគ្រោះពីបទល្មើសនានាក្រោមពិធីសារបន្ថែមនេះ មិនត្រូវទុកជាជនល្មើសនៅក្នុងការអនុវត្តឡើយ ហើយថាមន្ត្រីប្រតិបត្តិច្បាប់ត្រូវតែជ្រួតជ្រាបពីច្បាប់ជាតិរបស់ខ្លួននៅក្នុងករណីនេះ។<br><br>**៣១.** គណៈកម្មាធិការសូមផ្តល់អនុសាសន៍ថា រដ្ឋភាគីចាត់វិធានការចាំបាច់ទាំងអស់ ដើម្បីធានាថា កុមាររងគ្រោះពីបទល្មើសនានាក្រោមពិធីសារបន្ថែមនេះ ត្រូវបានផ្តល់នូវការគាំពារសមរម្យ រួមទាំងការស្តារផ្លូវកាយ និងផ្លូវចិត្តឡើងវិញ និងការធ្វើសមោហរណកម្មពេញលេញទៅក្នុងសង្គម ជាពិសេសនៅថ្នាក់ឃុំ។ ក្នុងករណីនេះ គណៈកម្មាធិការអំពាវនាវឱ្យរដ្ឋភាគីទទួលខុសត្រូវពេញលេញចំពោះកិច្ចខិតខំប្រឹងប្រែងបែបនេះ តាមរយៈការបង្កើនសេវាកម្មសង្គមកិច្ចរបស់រដ្ឋ និងការពង្រឹងសមត្ថភាពរបស់ទីភ្នាក់ងាររដ្ឋាភិបាល ដើម្បីគាំទ្រ និងសម្របសម្រួលដល់កិច្ចគាំពារកុមាររងគ្រោះពីបទល្មើសនានាក្រោមពិធីសារបន្ថែមនេះ។ រដ្ឋភាគីគួរធានាផងដែរឱ្យមានការចូលរួមពីកុមារនៅក្នុងការអភិវឌ្ឍន៍គោលនយោបាយ និងកម្មវិធីសំរាប់ការស្តារឡើងវិញ និងការធ្វើសមោហរណកម្មឡើងវិញ។ |
| *គណៈកម្មាធិការស្តីពីសិទ្ធិកុមារ* CRC/C/KHM/CO/2-3 (២០១១) |
| **៧.** គណៈកម្មាធិការសូមទទូចឱ្យរដ្ឋភាគីចាត់រាល់វិធានការចាំបាច់ ដើម្បីអនុវត្តតាមអនុសាសន៍នានាដែលបានដាក់ចេញនៅក្នុងសេចក្តីសង្កេតសន្និដ្ឋានលើរបាយការណ៍ដើម ដែលមិនទាន់បានអនុវត្តនៅឡើយ ឬត្រូវបានអនុវត្តមិនបានគ្រប់ជ្រុងជ្រោយ ជាពិសេស ទាក់ទងនឹងការមិនរើសអើងកុមារពិការ សុខភាពយុវវ័យ និងយុត្តិធម៌អនីតិជន។<br><br>**៩.** គណៈកម្មាធិការក៏សូមទទូចបន្ថែមទៀត ឱ្យរដ្ឋភាគីបង្កើនល្បឿនក្នុងការធ្វើច្បាប់ស្តីពីកិច្ចការពារកុមារ ដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយមួយ ដែលគ្របដណ្តប់រាល់គោលការណ៍ និងបទប្បញ្ញត្តិទាំងអស់នៃអនុសញ្ញា និងធានាថា ច្បាប់ស្តីពីយុត្តិធម៌អនីតិជនដែលកំពុងបានធ្វើសេចក្តីព្រាងនាពេលបច្ចុប្បន្ន ត្រូវបានបញ្ចូលយ៉ាងពេញលេញទៅក្នុងច្បាប់នេះ។<br><br>**៧៧.** គណៈកម្មាធិការសូមស្នើឱ្យរដ្ឋភាគីអនុវត្តប្រព័ន្ធយុត្តិធម៌អនីតិជនយ៉ាងពេញលេញឱ្យស្របជាមួយអនុសញ្ញា ជាពិសេសមាត្រា៣៧ មាត្រា៣៩និងមាត្រា៤០ ព្រមទាំងស្របជាមួយបទដ្ឋានពាក់ព័ន្ធផ្សេងទៀត រួមទាំងវិធានបទដ្ឋានអប្បបរមាសម្រាប់គ្រប់គ្រងយុត្តិធម៌អនីតិជន (វិធានក្រុងប៉េកាំង) គោលការណ៍ណែនាំសម្រាប់បង្ការយុវទោសកម្ម (គោលការណ៍ទីក្រុងរីយ៉ាដ) វិធានសម្រាប់ការពារអនីតិជនដែលត្រូវបានដកហូតសេរីភាព (វិធានទីក្រុងឡាហាវ៉ាន់) គោលការណ៍ក្រុងវីយែនសម្រាប់កុមារនៅក្នុងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ និងសេចក្តីពន្យល់ទូទៅលេខ១០(២០០៧) របស់គណៈកម្មាធិការស្តីពីសិទ្ធិកុមារនៅក្នុងយុត្តិធម៌អនីតិជន។ ជាពិសេស គណៈកម្មាធិការសូមទទូចឱ្យរដ្ឋភាគី៖<br><br>**ក.** បង្កើតនូវតុលាការអនីតិជនជំនាញនៅពាសពេញប្រទេស។<br><br>**ខ.** ធានាមិនឱ្យមានកុមារណាម្នាក់ទទួលរងការរំលោភបំពាន និងការធ្វើទារុណកម្មនៅពេលពួកគេមានទំនាក់ទំនង ឬមានទំនាស់ជាមួយច្បាប់ ជាពិសេស ក្នុងអំឡុងពេលនៃដំណាក់កាលចាប់ខ្លួន និងស៊ើបសួរ។ |

| |
|---|
| គ. ផ្តល់ដល់កុមារទាំងជនរងគ្រោះ និងជនជាប់ចោទនូវជំនួយផ្លូវច្បាប់ និងជំនួយផ្សេងទៀតឱ្យបានគ្រប់គ្រាន់ នៅដំណាក់កាលដំបូងនៃនីតិវិធី និងនៅក្នុងគ្រប់កិច្ចដំណើរការផ្លូវច្បាប់ទាំងឡាយ។<br>ឃ. ធានាថាកុមារដែលត្រូវបានដកហូតសេរីភាព ឬស្ថិតនៅក្នុងមណ្ឌលស្តារនីតិសម្បទា ឬនៅក្នុងមណ្ឌលឃុំខ្លួន មិនត្រូវបានទុកដាក់នៅជាមួយនីតិជននោះឡើយ និងត្រូវធានាថា កុមារទាំងនោះមានបរិស្ថានដ៏មានសុវត្ថិភាព មានលក្ខណៈគិតគូរយ៉ាងដិតដល់ចំពោះកុមារ និងត្រូវធានាថា ពួកគេអាចរក្សាទំនាក់ទំនងជាទៀងទាត់ជាមួយគ្រួសាររបស់ពួកគេ និងទទួលបាននូវអាហារ ការអប់រំ និងការបណ្តុះបណ្តាលវិជ្ជាជីវៈ។<br>ង. ត្រូវផ្តល់ដល់កុមារដែលត្រូវបានដកហូតសេរីភាពនូវទម្រង់ណាមួយនៃសិទ្ធិក្នុងការពិនិត្យឡើងវិញនូវសេចក្តីសម្រេចនៃការទុកដាក់កុមារ។ |
| *គណៈកម្មាធិការប្រឆាំងទារុណកម្ម* CAT/C/KHM/CO/2 (២០១០) |
| **២៣.** ដោយចាត់ទុកជាបញ្ហាបន្ទាន់ រដ្ឋភាគីគួរបង្កើតប្រព័ន្ធយុត្តិធម៌សម្រាប់អនីតិជនដាច់ដោយឡែក សមស្របតាមតម្រូវការ ស្ថានភាព និងលក្ខខណ្ឌតម្រូវពិសេសរបស់អនីតិជន។ ដើម្បីសម្រេចគោលបំណងនេះ រដ្ឋភាគីគួរអនុម័តសេចក្តីព្រាងច្បាប់ស្តីពីយុត្តិធម៌របស់អនីតិជនឲ្យបានឆាប់រហ័ស និងធានាថាសេចក្តីព្រាងច្បាប់នេះ មានភាពសមស្របតាមបទដ្ឋានអន្តរជាតិ និងគួរបង្កើតគោលការណ៍ណែនាំ និងសារាចរណែនាំដែលស៊ីសង្វាក់គ្នាស្តីពីទស្សនៈប្រព័ន្ធយុត្តិធម៌កុមារមេត្រី សម្រាប់ចៅក្រម ព្រះរាជអាជ្ញា និងនគរបាលយុត្តិធម៌។ រដ្ឋភាគីគួរបន្តចាត់វិធានការចាំបាច់ទាំងអស់ដើម្បីបង្កើត និងអនុវត្តប្រព័ន្ធដ៏ទូលំទូលាយមួយនៃវិធានការជំនួសការដាក់ពន្ធនាគារ ដើម្បីធានាថាការដកហូតសិទ្ធិសេរីភាពរបស់អនីតិជន អាចអនុវត្តសម្រាប់តែជាជម្រើសចុងក្រោយក្នុងរយៈវេលាដ៏ខ្លីបំផុតតាមដែលអាចធ្វើទៅបាន និងក្នុងលក្ខខណ្ឌសមស្រប។ លើសពីនេះរដ្ឋភាគីគួរចាត់វិធានការចាំបាច់ ដើម្បីធានាថាអនីតិជនដែលមានអាយុក្រោម១៨ឆ្នាំ មិនត្រូវឃុំខ្លួនជាមួយមនុស្សពេញវ័យឡើយ។ |

## ច. ការមិនបញ្ជូនត្រឡប់

| |
|---|
| *គណៈកម្មាធិការសិទ្ធិកុមារ៖ ពេស្យាចារកុមារ* CRC/C/OPSC/KHM/CO/1 (២០១៥) |
| **២៥.** គណៈកម្មាធិការសូមផ្តល់អនុសាសន៍ថា រដ្ឋភាគីចាត់វិធានការចាំបាច់ដើម្បីលុបចោលតម្រូវការដាក់ទោសទណ្ឌទ្វេដល់ការធ្វើបត្យាប័នចំពោះបទល្មើសនានាដែលគ្របដណ្តប់ដោយពិធីសារបន្ថែមនេះ នៅពេលដែលបទល្មើសទាំងនេះត្រូវបានប្រព្រឹត្តិនៅក្រៅដែនដីរបស់ខ្លួន និងក្នុងករណីមិនមានកិច្ចព្រមព្រៀងបត្យាប័នទ្វេភាគីឬពហុភាគី ឱ្យពិចារណាយកពិធីសារបន្ថែមនេះមកប្រើជាមូលដ្ឋានច្បាប់សំរាប់ការធ្វើបត្យាប័ន ស្របតាមមាត្រា៥ នៃពិធីសារបន្ថែម។ |

### *គណៈកម្មាធិការសិទ្ធិកុមារ៖ កុមារក្នុងជម្លោះប្រដាប់អាវុធ* (២០១៥)

CRC/C/OPAC/KHM/CO/1

**១៩.** គណៈកម្មាធិការសូមផ្តល់អនុសាសន៍ថា រដ្ឋភាគីចាត់វាល់វិធានការច្បាប់ និងវិធានការជាក់ស្តែងចាំបាច់ ដើម្បីធានាថាច្បាប់ជាតិរបស់ខ្លួនអនុញ្ញាតិឱ្យបង្កើត និងអនុវត្តយុត្តាធិការក្រៅដែនដីទៅលើបទល្មើសទាំងអស់ដែលគ្របដណ្តប់ដោយពិធីសារបន្ថែម រួមទាំងកុមារជាប់កំណែន ឬកុមារចូលធ្វើទាហាន ក្នុងកងកំលាំងប្រដាប់អាវុធ ឬក្រុមប្រដាប់អាវុធ ឬប្រើប្រាស់កុមារឱ្យចូលរួមយ៉ាងសកម្មក្នុងអរិភាព ប្រសិនបើបទល្មើសបែបនេះត្រូវបានប្រព្រឹត្តិដោយ ឬប្រឆាំងនឹងជនជាតិកម្ពុជា ឬជនណាម្នាក់ដែលស្នាក់នៅក្នុងរដ្ឋភាគី។ គណៈកម្មាធិការសូមផ្តល់អនុសាសន៍បន្ថែមទៀតថា រដ្ឋភាគីលប់ចោលតម្រូវការដាក់ទោសទណ្ឌទ្វេដល់ការធ្វើបត្យាប័នចំពោះបទល្មើសនានាដែលស្ថិតក្រោមពិធីសារបន្ថែមនេះ។

### *គណៈកម្មាធិការស្តីពីសិទ្ធិកុមារ* CRC/C/KHM/CO/2-3 (២០១១)

**៧៥.** ដោយចូលរួមកង្វល់ដែលបានលើកឡើង ជាពិសេសដោយគណៈកម្មាធិការប្រឆាំងទារុណកម្ម (CAT/C/KHM/CO/២ កថាខណ្ឌ២៤) អំពីការបញ្ជូនត្រឡប់ដោយបង្ខំ ទៅប្រទេសចិន នូវជនសុំសិទ្ធិជ្រកកោនអ៊ុយហ្គឺរចំនួន២០នាក់ រួមទាំងកុមារ២នាក់ ក្នុងឆ្នាំ២០០៩ គណៈកម្មាធិការសូមទទូចឱ្យរដ្ឋភាគីលើកកម្ពស់គោលការណ៍ការពារជនភៀសខ្លួន មិនឱ្យបញ្ជូនត្រឡប់ទៅប្រទេសដើមវិញ ស្របតាមច្បាប់ជនភៀសខ្លួនអន្តរជាតិ និងសិទ្ធិមនុស្ស រួមទាំងអនុសញ្ញាផងដែរ។

### *គណៈកម្មាធិការប្រឆាំងទារុណកម្ម* CAT/C/KHM/CO/2 (២០១០)

**២៤.** រដ្ឋភាគីគួរបង្កើត និងអនុម័តច្បាប់ជាតិស្តីពីការធានាសិទ្ធិរបស់ជនភៀសខ្លួន និងអ្នកសុំសិទ្ធិជ្រកកោន រួមទាំងកុមារកំព្រាដែលត្រូវការការពារពីអន្តរជាតិផងដែរ។ រដ្ឋភាគីគួរបង្កើត និងអនុម័តបទប្បញ្ញត្តិច្បាប់ដើម្បីអនុវត្តមាត្រា៣នៃអនុសញ្ញានេះដើម្បីដាក់បញ្ចូលទៅក្នុងច្បាប់ជាតិ។ ទោះក្នុងកាលៈទេសៈណាក៏ដោយ រដ្ឋជាតីមិនត្រូវបណ្តេញចេញ បញ្ជូនត្រឡប់ ឬធ្វើបត្យាប័នបុគ្គលណាមួយទៅកាន់រដ្ឋមួយផ្សេងទៀត នៅពេលមានមូលដ្ឋានគ្រប់គ្រាន់អាចជឿជាក់បានថា ជននោះនឹងស្ថិតក្នុងគ្រោះថ្នាក់នៃការធ្វើទារុណកម្ម ឬប្រព្រឹត្តកម្មមិនគប្បីមកលើខ្លួន។ គណៈកម្មាធិការស្នើសុំឲ្យរដ្ឋភាគី ធានាឲ្យមានការតាមដានសមស្រប ពាក់ព័ន្ធនឹងស្ថានភាពនៃអ្នកសុំសិទ្ធិជ្រកកោន ជាម៉ុងតាញ៉ាចំនួន៦៧៤នាក់ និងអ្នកសុំសិទ្ធិជ្រកកោនជនជាតិអ៊ុយហ្គឺចំនួន២០នាក់ និងផ្តល់ព័ត៌មានពីករណីទាំងនេះដល់ គណៈកម្មាធិការ។

| |
|---|
| *គណៈកម្មាធិការលុបបំបាត់ការរើសអើងពូជសាសន៍* CERD/C/KHM/CO/8-13 (២០១០) |
| ១៤. គណៈកម្មាធិការស្នើឲ្យរដ្ឋភាគីធានាថា ច្បាប់ដែលបានអនុម័តហើយ រាប់ទាំងច្បាប់ស្តីពីសិទ្ធិជ្រកកោន ត្រូវតែបានអនុវត្តយ៉ាងពេញលេញ និងសុទ្ធចិត្ត ដើម្បីផ្តល់ការការពារទាំងស្រុងតាមផ្លូវច្បាប់ ការគោរពគោលការណ៍ស្តីពី "ការមិនបញ្ជូនត្រឡប់វិញ" និងការទទួលបានដូចគ្នានូវសិទ្ធិ និងអត្ថប្រយោជន៍ស្មើភាពគ្នា។ |
| *អ្នករាយការណ៍ពិសេស* |
| A/HRC/27/70 Para 84. ជាទីបញ្ចប់ អ្នករាយការណ៍ពិសេស សូមផ្តល់អនុសាសន៍ថា រដ្ឋាភិបាលកម្ពុជា និងរដ្ឋាភិបាលអូស្ត្រាលី ដែលជារដ្ឋភាគីនៃអនុសញ្ញាស្តីពីឋានៈជនភៀសខ្លួនឆ្នាំ១៩៥១ ចាត់វិធានការចាំបាច់នានាដើម្បីធានាថា កម្ពុជាត្រូវរៀបចំខ្លួនឱ្យបានពេញលេញ ដើម្បីផ្តល់ឱ្យជនភៀសខ្លួននូវឱកាសកសាងជីវិតរបស់ពួកគេឡើងវិញដោយសុវត្ថិភាព និងកិត្តិយស ស្របតាមបទដ្ឋានអន្តរជាតិ មុននឹងកិច្ចព្រមព្រៀងនេះត្រូវបានចុះហត្ថលេខា ហើយជនភៀសខ្លួនត្រូវបានបញ្ជូនមកកម្ពុជា។ |

## III. សេរីភាពនៃការបញ្ចេញមតិ (រួមទាំងសេរីភាពព័ត៌មាន) សេរីភាពសមាគម និងសេរីភាពនៃការប្រមូលផ្តុំ

### *ក. សេរីភាពនៃការបញ្ចេញមតិ និងកំណែទម្រង់ច្បាប់*

| *អនុសាសន៍នៃការពិនិត្យជាសកលតាមកាលកំណត់* (២០១៨) |
|---|
| **១១៨.១៤.** ធានាការអនុវត្តដោយពេញលេញនូវបទប្បញ្ញត្តិដែលបានអនុម័តនាពេលថ្មីៗ ទាក់ទងនឹងក្រមព្រហ្មទណ្ឌ។ (ម៉ុងតេណេក្រូ) |
| **១១៨.១៥.** ពិនិត្យក្រមព្រហ្មទណ្ឌឡើងវិញដើម្បីធានាថា ក្រមនេះស្របគ្នានឹងកាតព្វកិច្ចរបស់កម្ពុជា ក្រោមកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ ទាក់ទងនឹងសេរីភាពនៃការបញ្ចេញមតិ និងចាត់វិធានការចាំបាច់នានាដើម្បីធ្វើវិសោធនកម្ម ឬលុបចោលមាត្រាណាដែលមិនឆ្លើយតបនឹងកាតព្វកិច្ចទាំងនេះ។ (កាណាដា) |
| **១១៨.១៦.** កែសម្រួលក្រមព្រហ្មទណ្ឌ ដើម្បីធ្វើឲ្យវាស្របនឹងស្តង់ដារអន្តរជាតិ និងកាតព្វកិច្ចរបស់កម្ពុជា ក្រោមកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។ (បែលហ្ស៊ិក) |
| **១១៨.១៨.** អនុម័តវិធានការច្បាប់ និងវិធានការដទៃទៀត ដែលលើកកម្ពស់ការទទួលបានសេរីភាពនៃការបញ្ចេញមតិ។ (បុតស្វាណា) |
| **១១៨.១៩.** ចាត់វិធានការដើម្បីធានាថា ច្បាប់កម្ពុជាអនុញ្ញាតឲ្យគណបក្សនយោបាយទាំងអស់ សហជីព និងក្រុមសង្គមស៊ីវិលដទៃទៀត ប្រើប្រាស់សិទ្ធិរបស់ខ្លួន ដើម្បីទទួលបានសេរីភាពនៃការបញ្ចេញមតិ មានសមាគម និងការប្រមូលផ្តុំដោយសន្តិវិធី ហើយថាបាតុកម្មដោយសន្តិវិធី អាចកើតឡើងដោយសុវត្ថិភាព និងដោយគ្មានការភ័យខ្លាចពីការបំភិតបំភ័យ ឬការប្រើកម្លាំងហួសហេតុពីខាងភាគីអាជ្ញាធរកម្ពុជា។ (កាណាដា) |
| **១១៨.២០.** កែសម្រួលក្រមព្រហ្មទណ្ឌ ក៏ដូចជាច្បាប់ដទៃទៀត ដើម្បីឲ្យច្បាប់ទាំងនេះ ស្របតាមស្តង់ដាសេរីភាពនៃការបញ្ចេញមតិជាអន្តរជាតិ និងទប់ស្កាត់ការយាយីដល់អ្នកការពារសិទ្ធិមនុស្ស អ្នកសារព័ត៌មាន និងអង្គការក្រៅរដ្ឋាភិបាល។ (សាធារណរដ្ឋឆេក) |
| **១១៨.១០២.** ធានាថា ទស្សនៈនៃការបរិហារកេរ្តិ៍ និងការរំខានដល់សណ្តាប់ធ្នាប់សាធារណៈ ត្រូវស្របគ្នានឹងសិទ្ធិមនុស្សក្នុងការទទួលបានសេរីភាពនៃការបញ្ចេញមតិទាំងនៅក្នុងច្បាប់ទាំងនៅក្នុងការអនុវត្តជាក់ស្តែង។(អាល្លឺម៉ង់) |
| *អនុសាសន៍នៃការពិនិត្យជាសកលតាមកាលកំណត់* (២០០៩) |
| ៤៦-(ក). សូមធានាថា សេរីភាពនៃការបញ្ចេញមតិ និងសារព័ត៌មាន ដូចបានធានាក្នុងច្បាប់រដ្ឋធម្មនុញ្ញ ត្រូវបានគោរពប្រកបដោយប្រសិទ្ធភាព។ (ស្វីស) |

ខ). សូមពិនិត្យក្រមព្រហ្មទណ្ឌដែលទើបអនុម័តថ្មីៗឡើងវិញ ក្នុងគោលបំណងធានាថាច្បាប់នេះស្របតាមការដាក់កំហិតដែលអនុញ្ញាតលើសេរីភាពនៃការបញ្ចេញមតិ ដូចមានចែងក្នុង ICCPR។ (ឆេក)

គ). សូមចាត់វិធានការប្រកបដោយប្រសិទ្ធភាព ដើម្បីធានាឲ្យមានសេរីភាពនៃការបញ្ចេញមតិ និងគំនិតដោយការធ្វើវិសោធនកម្មច្បាប់ស្តីពីរបបសារព័ត៌មាន ដែលបង្កឲ្យមានការបកស្រាយយ៉ាងទូលំទូលាយទៅលើពាក្យមិនច្បាស់លាស់ "អំពើជេរប្រមាថស្ថាប័នជាតិ" ហើយដែលអនុញ្ញាតឲ្យមានការពិនិត្យចាប់ពិរុទ្ធ ការព្យួរការបោះពុម្ពផ្សាយ និងការជាប់ពន្ធនាគារ ក្រោមលេសថា សន្តិសុខជាតិ និងស្ថេរភាពនយោបាយ។ (អ៊ីស្រាអែល)

ឃ). អនុម័តវិធានការផ្លូវច្បាប់ដែលចាំបាច់ ដើម្បីកុំឲ្យគេធ្វើទុក្ខបុកម្នេញអ្នកសារព័ត៌មាន នៅពេលដែលពួកគេអនុវត្តវិជ្ជាជីវៈរបស់ខ្លួន ហើយការរំលោភលើការដាក់កំហិតលើសេរីភាពនៃការបញ្ចេញមតិ មិនត្រូវបានគេដាក់ទោសតាមបែបព្រហ្មទណ្ឌឡើយ។ (ម៉ិចស៊ីកូ)

ង). សូមកំណត់អំពីទំហំនៃបទបរិហារកេរ្តិ៍ និងបទផ្សាយព័ត៌មានមិនពិត ដើម្បីធានាថា បទចោទប្រកាន់ទាំងនេះមិនរំលោភលើសេរីភាពនៃការបញ្ចេញមតិ ព្រមទាំងផ្តល់ការណែនាំឲ្យបានច្បាស់លាស់ដល់មន្ត្រីតុលាការ ដើម្បីឲ្យបទប្បញ្ញត្តិទាំងនេះ មិនបង្កឲ្យមានករណីយ៉ាងច្រើន ដោយសារតែការចោទប្រកាន់មិនត្រឹមត្រូវនោះឡើយ។ (ចក្រភពអង់គ្លេស)

### *គណៈកម្មាធិការសិទ្ធិមនុស្ស* (CCPR/C/SR.3157) (២០១៥)

២១. រដ្ឋភាគីគួរធានា [...]

(គ). ចូរពិចារណាកុំដាក់បទបរិហាកេរ្តិ៍ ជាទោសព្រហ្មទណ្ឌ និងលើកយកនូវបទប្បញ្ញត្តិពាក់ព័ន្ធណាមួយផ្សេងទៀតនៃក្រមព្រហ្មទណ្ឌ ឲ្យស្របទៅនឹងមាត្រា១៩ នៃកតិកាសញ្ញានេះ។

(ឃ). ពិនិត្យឡើងវិញនូវច្បាប់បច្ចុប្បន្ន និងច្បាប់មិនទាន់តាក់តែងរបស់ខ្លួន រាប់ទាំងសេចក្តីព្រាងច្បាប់ស្តីពីឧក្រិដ្ឋកម្មតាមអ៊ីនធឺណិត និងច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ដើម្បីបញ្ចៀសនូវការប្រើប្រាស់វាក្យសព្ទមិនច្បាស់លាស់ និងការរឹតត្បិតហួសហេតុ ដើម្បីធានាថា ការរឹតត្បិតណាមួយលើការអនុវត្តសេរីភាពនៃការបញ្ចេញមតិ និងការបង្កើតសមាគម ពិតជាអនុលោមតាមលក្ខខណ្ឌតម្រូវនៃមាត្រា១៩ កថាខ័ណ្ឌទី៣ និង២២ នៃកតិកាសញ្ញានេះ។

### *អ្នករាយការណ៍ពិសេស*

A/HRC/15/46. Para .95. រដ្ឋាភិបាលគួរពិនិត្យក្រមព្រហ្មទណ្ឌថ្មីឡើងវិញ ដើម្បីធានាថា ក្រមនេះពិតជាអនុលោមតាមកំរិតនៃការរិតត្បិត ដែលអាចអនុញ្ញាតឲ្យធ្វើបានលើសេរីភាពនៃការបញ្ចេញមតិ ដូចដែលបានចែងនៅក្នុងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយឆ្នាំ១៩៦៦។

A/HRC/15/46.Para.96. តុលាការគួរអនុវត្តច្បាប់សារព័ត៌មានចំពោះបញ្ហាដែលទាក់ទងនឹងអ្នកសារព័ត៌មាន ព្រមទាំងអនុញ្ញាតឲ្យមានការដកអត្ថបទចេញ ការកែតម្រូវ និងសិទ្ធិនៃការឆ្លើយតប មុនពេលឈានទៅដល់ការដាក់បណ្តឹងប្រឆាំងនឹងអ្នកសារព័ត៌មាននានា ចំពោះការបោះពុម្ពផ្សាយព័ត៌មានដែលត្រូវបានចាត់ទុកថាមិនត្រឹមត្រូវ ឬប៉ះពាល់ដល់កិត្តិយសរបស់បុគ្គលនានាឬសូម្បីតែការគម្រាមកំហែងដល់សន្តិសុខជាតិឬសណ្តាប់ធ្នាប់សាធារណៈ។ នីតិវិធីផ្លូវច្បាប់នៅក្នុងករណីនេះ គួរតែជាបណ្តឹងរដ្ឋប្បវេណី ហើយមិនមែនជាបណ្តឹងអាជ្ញានោះទេ។

A/HRC/15/46. Para. 97. បុគ្គលសាធារណៈនានាគួរត្រៀមខ្លួនអត់ទ្រាំនឹងការរិះគន់ ហើយជៀសវាងប្រើប្រាស់តុលាការ ដើម្បីបំបិទការរិះគន់ ព្រោះការរិះគន់ ជាផ្នែកមួយជួយធ្វើឲ្យលទ្ធិប្រជាធិបតេយ្យ ដំណើរការបានដោយរលូន។ ជាការប្រសើរជាងដែលយកសេចក្តីពិតទៅតបតនឹងសេចក្តីមិនពិត ជាជាងប្រើប្រាស់ការបំភិតបំភ័យតាមផ្លូវតុលាការ។ ស្ថាប័នរដ្ឋាភិបាលនានាគួរតែរៀបចំឲ្យមានអ្នកនាំពាក្យរៀងៗខ្លួន ដើម្បីប្រឆាំងទៅនឹងការរិះគន់នានាលើគោលនយោបាយរបស់រដ្ឋាភិបាល ឬប្រតិកម្មចំពោះអត្ថបទសារព័ត៌មានណាមួយ ដែលមានលក្ខណៈរសើបចំពោះបុគ្គលនៅក្នុងតំណែងសាធារណៈនានា ជាជាងជ្រើសរើសផ្លូវទៅប្រើបណ្តឹងអាជ្ញានោះ។

A/HRC/15/46. Para.98. បទបរិហារកេរ្តិ៍ និងបទផ្សាយព័ត៌មានមិនពិត គួរតែដកចេញពីបទល្មើសព្រហ្មទណ្ឌទាំងស្រុង។ សេចក្តីថ្លែងការណ៍ដែលត្រូវបានចាត់ទុកថាជាការគម្រាមកំហែងដល់សន្តិសុខជាតិត្រូវតែទទួលបានការបកស្រាយឲ្យស្របតាមកាតព្វកិច្ចនានាក្រោមកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយរបស់កម្ពុជា។

A/HRC/18/46.Para.86. សភាគួរតែពិនិត្យឡើងវិញនូវបញ្ញត្តិក្រមព្រហ្មទណ្ឌថ្មី ក្នុងគោលដៅធ្វើឲ្យប្រាកដថា ក្រមនេះស្របតាមកំហិតដែលបានអនុញ្ញាតឲ្យដាក់ចំពោះសេរីភាពនៃការបញ្ចេញមតិក្រោមច្បាប់សិទ្ធិមនុស្សអន្តរជាតិ។

A/HRC/18/46. Para. 87. សភាគួរតែធានាការពារសិទ្ធិសេរីភាពនៃការបញ្ចេញមតិរបស់សមាជិករបស់ខ្លួនផ្ទាល់ និងការពារអភ័យឯកសិទ្ធិសភារបស់ពួកគាត់។

A/HRC/18/46. Para. 88. អង្គតុលាការគួរធ្វើការបកស្រាយបញ្ញត្តិនៃក្រមព្រហ្មទណ្ឌ ស្របតាមបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិស្តីពីសេរីភាពនៃការបញ្ចេញមតិ។ ក្រសួងយុត្តិធម៌គួរតែពឹងពាក់លើសហគមន៍អន្តរជាតិ រាប់ទាំងការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា ដើម្បីផ្តល់វគ្គបណ្តុះបណ្តាលផ្សេងៗដល់ចៅក្រម ព្រះរាជអាជ្ញា និងមេធាវី ក្នុងបញ្ហានេះ។

A/HRC/24/36. Para. 68. សេរីភាពនៃការបញ្ចេញមតិរបស់ភាគីពាក់ព័ន្ធទាំងអស់នៅក្នុងសង្គមកម្ពុជា គួរត្រូវបានគោរពគ្រប់ពេលទាំងអស់ រួមទាំងមុនពេល ក្នុងអំឡុងពេល និងក្រោយពេលបោះឆ្នោត។

A/HRC/27/70 Para 81(d). គោរពយ៉ាងពេញលេញនូវសេរីភាពនៃការសម្តែងមតិរបស់អ្នកពាក់ទាំងអស់ នៅក្នុងសង្គមកម្ពុជា និងសេរីភាពនៃការជួបប្រជុំដោយសន្តិវិធីនៅគ្រប់ពេល ព្យាយាមទប់មិនឱ្យមានការព្យួរសិទ្ធិទាំងនេះតាមទំនើងចិត្តហើយក្នុងករណីនេះត្រូវលើកចោលជាផ្លូវការនូវបំរាមការធ្វើបាតុកម្មទាំងក្នុងច្បាប់ទាំងក្នុងការអនុវត្ត។

A/HRC/33/62 Para 61(m). ពិចារណាឡើងវិញនូវបទប្បញ្ញត្តិនៃក្រមព្រហ្មទណ្ឌ ដែលអាចត្រូវបានយកមកប្រើដើម្បីដាក់កំហិតលើសេរីភាពនៃការសម្តែងមតិ ដើម្បីសម្រេចឱ្យកាន់តែស្របនឹងបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ ដាក់ឱ្យទៅជាមិនមែនបទល្មើសព្រហ្មទណ្ឌតាមការចាំបាច់។

## ខ. សេរីភាពនៃការប្រមូលផ្តុំ

| *អនុសាសន៍នៃការពិនិត្យជាសកលតាមកាលកំណត់* (២០១៤) |
|---|
| **១១៨.១០៤.** លើកកម្ពស់បរិយាកាសអំណោយផល និងមានសុវត្ថិភាពមួយដែលអនុញ្ញាតឲ្យបុគ្គល និងក្រុមនានាប្រើប្រាស់សេរីភាពនៃការបញ្ចេញមតិ សេរីភាពមានសមាគម និងសេរីភាពនៃការប្រមូលផ្តុំដោយសន្តិវិធី ហើយត្រូវបញ្ចប់ការឃាយី ការបំភិតបំភ័យ ការចាប់ខ្លួនតាមទំនើងចិត្ត និងការវាយប្រហារលើរាងកាយ ជាពិសេសក្នុងបរិបទនៃការធ្វើបាតុកម្មដោយសន្តិវិធី។ (ស្វីស)<br><br>**១១៨.១០៦.** ធានាសិទ្ធិរបស់បុគ្គល និងអង្គការការពារ និងលើកស្ទួយសិទ្ធិមនុស្ស រួមទាំងការការពារ និងការលើកស្ទួយសិទ្ធិមានសេរីភាពនៃការបញ្ចេញមតិ ការប្រមូលផ្តុំ និងសេរីភាពមានសមាគម។ (កូឡុំប៊ី)<br><br>**១១៨.១០៧.** ធានាការការពារកម្មករដែលប្រើសិទ្ធិមានសេរីភាពនៃការប្រមូលផ្តុំដោយសន្តិវិធី និងមានសមាគម និងអនុញ្ញាតឲ្យមានការអនុវត្តដោយពេញលេញនូវសិទ្ធិមានសេរីភាពក្នុងការបញ្ចេញមតិនៅក្នុងប្រទេស។(ក្រូអាត)<br><br>**១១៨.១០៨.** ការពារយ៉ាងសកម្មដល់សិទ្ធិមានសេរីភាពក្នុងការបញ្ចេញមតិ និងការប្រមូលផ្តុំដោយសន្តិវិធី ដោយធានាថា ការរឹតត្បិតណាមួយទៅលើសិទ្ធិទាំងនេះ ត្រូវធ្វើឡើងត្រឹមត្រូវតាមច្បាប់ ចាំបាច់ និងសមាមាត្រ។ (ណូវ៉ែលហ្សេឡង់ដ៍)<br><br>**១១៨.១០៩.** អនុម័ត និងអនុវត្តវិធានការប្រកបដោយប្រសិទ្ធភាព ដើម្បីទប់ស្កាត់ការប្រើអំពើហិង្សាទៅលើបាតុករស្របតាមច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធី និងអនុញ្ញាតឲ្យក្រុមទាំងអស់ រួមទាំង ក្រុមដែលមានទស្សនៈប្រឆាំង មានសិទ្ធិពេញលេញឡើងវិញនូវសេរីភាពនៃការប្រមូលផ្តុំដោយសន្តិវិធី និងសមាគម។(សាធារណរដ្ឋឆែក) |
| *អនុសាសន៍នៃការពិនិត្យជាសកលតាមកាលកំណត់* (២០០៩) |
| **៥១.** សូមពង្រឹងកិច្ចខិតខំប្រឹងប្រែងក្នុងការការពារដល់សេរីភាពនៃការបញ្ចេញមតិ និងសិទ្ធិរបស់អ្នកការពារសិទ្ធិមនុស្សទាំងអស់ រាប់បញ្ចូល អ្នកទាំងនោះដែលធ្វើការលើបញ្ហាដីធ្លីដើម្បីពួកគេអាចធ្វើសកម្មភាពការងារដោយគ្មានឧបសគ្គឬការបំភិតបំភ័យ រាប់បញ្ចូលទាំងការការពារដល់សេរីភាពនៃការជួបប្រជុំនិងសមាគមផងដែរ។(ស៊ុយអែត) |
| *គណៈកម្មាធិការសិទ្ធិមនុស្ស* (CCPR/C/SR.3157) (២០១៥) |
| **២២.** រដ្ឋភាគីគួរធានាថា ច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធី ត្រូវបានអនុវត្ត អនុលោមតាមកតិកាសញ្ញានេះ។ រដ្ឋភាគីក៏គួរតែធានាផងដែរថា ការអនុវត្តសិទ្ធិនៃការជួបប្រជុំដោយសន្តិវិធីមិនត្រូវមានការរឹតត្បិតផ្សេងៗ ក្រៅពីការរឹតត្បិតដែលអនុញ្ញាតឲ្យមាន ក្រោមកតិកាសញ្ញានេះឡើយ។ |

| *អ្នកពាយការណ៍ពិសេស* |
|---|
| A/HRC/15/46.Para.99. ទស្សនទាននៃ "ការគម្រាមកំហែងដល់សណ្ដាប់ធ្នាប់សាធារណៈ" គួរត្រូវបានផ្ដល់និយមន័យដោយច្បាប់ និងតុលាការនានា នៅក្នុងអត្ថន័យដ៏ចង្អៀតបំផុតតាមដែលអាចធ្វើទៅបាន ដើម្បីលើកកំពស់ដល់សេរីភាពនៃការបញ្ចេញមតិ។ នៅក្នុងសេចក្ដីសម្រេចរបស់ខ្លួន ចៅក្រមនានាគួរបង្ហាញនៅក្នុងវាក្យស័ព្ទជាក់លាក់នានាថាតើសេចក្ដីថ្លែងការណ៍ ឬការបញ្ចេញមតិដោយឡែកណាមួយ បាន ឬនឹងគម្រាមកំហែងដល់សណ្ដាប់ធ្នាប់សាធារណៈតាមរបៀណា។ តុលាការពុំគួរយកការពោលអះអាងណាមួយ ដែលត្រូវបានធ្វើឡើងដោយអរូបី មកពិចារណានោះទេ។<br><br>A/HRC/7/42, Para. 101. រដ្ឋាភិបាលត្រូវអនុម័តច្បាប់ស្ដីពីការធ្វើបាតុកម្មឲ្យបានឆាប់ [...], ដោយធានាថា ច្បាប់នេះត្រូវស្របតាមរដ្ឋធម្មនុញ្ញ និងបទដ្ឋានសិទ្ធិមនុស្ស។<br><br>A/HRC/21/63/Add.1/Rev.1. Para. 240. ដោយសារការរំលោភបំពានសិទ្ធិមានសេរីភាពនៃការបញ្ចេញមតិ និងការប្រមូលផ្ដុំកាន់តែកើនឡើង រដ្ឋាភិបាលគួរចាត់វិធានការអនុវត្តបន្ថែមទៀតនូវច្បាប់ស្ដីពីការធ្វើបាតុកម្មដោយសន្តិវិធី រួមទាំងតាមការផ្សព្វផ្សាយ ការបណ្ដុះបណ្ដាលអំពីគោលការណ៍ណែនាំអនុវត្តច្បាប់នេះផង។ ក្រសួងមហាផ្ទៃគួរបន្តផ្ដល់ការណែនាំ និងលើកកំពស់ការយល់ដឹងដល់អាជ្ញាធរនៅកំរិតខេត្ត-រាជធានី រួមទាំងមន្ត្រីប្រតិបត្តិច្បាប់អំពីរបៀបអនុវត្តច្បាប់ស្ដីពីការធ្វើបាតុកម្មដោយសន្តិវិធី ក្នុងលក្ខណៈមួយស្របតាមកាតព្វកិច្ចសិទ្ធិមនុស្សជាអន្តរជាតិរបស់កម្ពុជា។<br><br>A/HRC/27/70 Para 81(d). គោរពយ៉ាងពេញលេញនូវសេរីភាពនៃការសម្ដែងមតិរបស់អ្នកពាក់ទាំងអស់ នៅក្នុងសង្គមកម្ពុជា និងសេរីភាពនៃការជួបប្រជុំដោយសន្តិវិធីនៅគ្រប់ពេល ព្យាយាមទប់មិនឱ្យមានការព្យួរសិទ្ធិទាំងនេះតាមទំនើងចិត្តហើយក្នុងករណីនេះត្រូវលើកចោលជាផ្លូវការនូវបំរាមការធ្វើបាតុកម្មទាំងក្នុងច្បាប់ទាំងក្នុងការអនុវត្ត។ |

## *គ. សេរីភាពសមាគម រួមទាំងសហជីព*

| *អនុសាសន៍នៃការពិនិត្យជាសកលតាមកាលកំណត់ (២០១៨)* |
|---|
| **១១៨.១១០.** ធានាសេរីភាពនៃការប្រមូលផ្ដុំ និងមានសមាគម ហើយត្រូវទទួលស្គាល់សារៈសំខាន់របស់សហជីព និងសង្គមស៊ីវិលផ្សេងៗ នៅក្នុងសង្គមប្រជាធិបតេយ្យ។ (ហូឡង់ដ៍)<br><br>**១១៨.១១១.** ទាំងក្នុងច្បាប់ ទាំងក្នុងការអនុវត្តជាក់ស្ដែង ធានាការគោរពដោយពេញលេញនូវសេរីភាពនៃការជួបប្រជុំដោយសន្តិវិធី និងមានសមាគម ស្របតាមច្បាប់អន្តរជាតិ។ (អូស្ត្រាលី) |

| |
|---|
| ***អនុសាសន៍នៃការពិនិត្យជាសកលតាមកាលកំណត់*** (២០០៩) |
| **៥៦.** ត្រូវធានាថា សេចក្តីព្រាងច្បាប់ស្តីពីអង្គការក្រៅរដ្ឋាភិបាលនឹងមិនធ្វើឲ្យលក្ខខណ្ឌការងាររបស់អង្គការក្រៅរដ្ឋាភិបាលកាន់តែមានការលំបាកឡើយ ហើយត្រូវគោរពសេរីភាពនៃការបញ្ចេញមតិនិងការបង្កើតសមាគម។ (បារាំង)<br>**៥៨.** ចាត់វិធានការចាំបាច់នានាដើម្បីធានាថា សិទ្ធិចូលរួមសហជីពរបស់កម្មករនៅកម្ពុជា ត្រូវបានគោរពទាំងស្រុង និងថាសកម្មជនសហជីពអាចអនុវត្តសកម្មភាពរបស់ពួកគេដោយគ្មានការបំភិតបំភ័យ និងគ្មានគ្រោះថ្នាក់ដល់សន្តិសុខផ្ទាល់ខ្លួន និងជីវិតរបស់ពួកគេ។ (សហរដ្ឋអាមេរិច)<br>**៥៩.** សូមបង្កើតតុលាការការងារក្នុងកិច្ចខិតខំប្រឹងប្រែងមួយ ធានាដល់ការគោរពសិទ្ធិកម្មករ និងដើម្បីផ្តល់ដំណោះស្រាយតាមផ្លូវច្បាប់ និងប្រកបដោយប្រសិទ្ធភាពសំរាប់វិវាទការងារ និងសូមពិនិត្យច្បាប់ស្តីពីសហជីពឡើងវិញ។ (សហរដ្ឋអាមេរិច) |
| ***គណៈកម្មាធិការសិទ្ធិមនុស្ស*** (CCPR/C/SR.3157) (២០១៥) |
| **២១.** រដ្ឋភាគីគួរធានាថា បុគ្គលគ្រប់រូបអាចអនុវត្តដោយសេរីនូវសិទ្ធិសេរីភាពបញ្ចេញមតិ និងការបង្កើតសមាគមរបស់ពួកគេ អនុលោមតាមមាត្រា១៩ និង២២ នៃកតិកាសញ្ញា និងសេចក្តីពន្យល់ទូទៅលេខ៣៤ (២០១១) របស់គណៈកម្មាធិការនេះ ស្តីពីសេរីភាពនៃគំនិត និងការសម្តែងមតិ។ [...] |
| ***គណៈកម្មាធិការប្រឆាំងទារុណកម្ម*** CAT/C/KHM/CO/2 (២០១០) |
| **៣១.** រដ្ឋភាគីគួរធានាថា អង្គការសង្គមស៊ីវិល រួមមានអង្គការមិនមែនរដ្ឋាភិបាលមិនត្រូវទទួលរងការដាក់កំហិតពាក់ព័ន្ធនឹងការបង្កើត និងដំណើរការរបស់ពួកគេទេ ហើយអង្គការទាំងនេះអាចដំណើរការដោយឯករាជ្យពីរដ្ឋាភិបាល។ ជាពិសេស គណៈកម្មាធិការជំរុញឲ្យរដ្ឋភាគីផ្តល់បរិយាកាសអំណោយផលសម្រាប់ការបង្កើត និងការចូលរួមយ៉ាងសកម្មរបស់អង្គការមិនមែនរដ្ឋាភិបាល ក្នុងការលើកកម្ពស់ការអនុវត្តអនុសញ្ញានេះ។ |
| ***គណៈកម្មាធិការសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌*** E/C.12/KHM/CO/1 (២០០៩) |
| **២៤.** គណៈកម្មាធិការបញ្ជាក់យ៉ាងច្បាស់ថា សិទ្ធិរបស់កម្មករ ដូចមានចែងក្នុងមាត្រា៨ នៃកតិកាសញ្ញានេះ អាចត្រូវបានប្រើតែក្នុងបរិយាកាសមួយដែលគ្មានអំពើហឹង្សា ការគាបសង្កត់ ឬការគំរាមកំហែង តាមបែបណាក៏ដោយ។ គណៈកម្មាធិការស្នើយ៉ាងទទូចដល់រដ្ឋភាគីឲ្យចាត់វាល់វិធានការចាំបាច់ ដូចដែលបានស្នើដោយគណៈកម្មាធិការទទួលបន្ទុកសេរីភាពខាងសមាគមនៃអង្គការ ILO ដើម្បីធានាថា សិទ្ធិខាងសហជីពរបស់កម្មករនៅកម្ពុជា ត្រូវបានគោរពយ៉ាងពេញលេញ ហើយថា សមាជិកសហជីពកម្មករទាំងអស់ អាចធ្វើសកម្មភាពរបស់ខ្លួនក្នុងបរិយាកាសមួយដែលគ្មានការបំភិតបំភ័យ និងហានិភ័យចំពោះសន្តិសុខផ្ទាល់ខ្លួន និងជីវិតរបស់ពួកគាត់។ គណៈកម្មាធិការស្នើ |

| |
|---|
| ឲ្យរដ្ឋភាគីស្វែងរកកិច្ចសហការផ្នែកបច្ចេកទេសពីអង្គការ ILO ជាពិសេស ក្នុងវិស័យនៃការពង្រឹងសមត្ថភាពស្ថាប័ន ក៏ដូចជាក្នុងការបង្កើតតុលាការការងារ និងការពិនិត្យឡើងវិញនៃច្បាប់ស្តីពីសហជីព។ គណៈកម្មាធិការស្នើផងដែរ ឲ្យរដ្ឋភាគីបញ្ចូលក្នុងរបាយការណ៍តាមកាលកំណត់លើកក្រោយរបស់ខ្លួន នូវព័ត៌មានថ្មីៗលំអិតអំពីបញ្ហានេះ។ |
| *អ្នករាយការណ៍ពិសេស* |
| A/HRC/21/63/Add.1/Rev.1.Para.241. រដ្ឋាភិបាលទាំងនៅកំរិតជាតិ និងខេត្ត ត្រូវធានាថាអង្គការសង្គម ស៊ីវិល សហគមន៍ និងបណ្តាញដែលមានមូលដ្ឋាននៅសហគមន៍ មានសេរីភាពចូលរួមក្នុងសកម្មភាពនានាពាក់ព័ន្ធនឹងការអប់រំដីធ្លី ពាក់ព័ន្ធជាអាទិ៍នីតិវិធីផ្តល់ប័ណ្ណកម្មសិទ្ធិ និងសកម្មភាពគណៈបក្សនយោបាយជាដើម ដោយមិនគិតថាការប្រជុំនោះធ្វើភ្លាមៗ ឧទា. ការរៀបចំបោះឆ្នោត និងក្រោយការបោះឆ្នោតក៏ដោយ។<br><br>A/HRC/33/62 Para 61(l). ធានាពីការផ្សព្វផ្សាយឱ្យបានពេញលេញនូវច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធី និងគោលការណ៍ណែនាំអនុវត្តច្បាប់នេះ គាំទ្រដោយកម្មវិធីបណ្តុះបណ្តាលសមស្របដល់អាជ្ញាធរខេត្ត និងមន្ត្រីអនុវត្តន៍ច្បាប់ ដើម្បីធានាថា ច្បាប់នេះត្រូវបានអនុវត្តន៍យ៉ាងត្រឹមត្រូវ និងពិចារណារៀបចំគោលការណ៍ណែនាំស្រដៀងគ្នាអំពីការអនុវត្តច្បាប់ស្តីពីសមាគមនិងអង្គការមិនមែនរដ្ឋាភិបាល និងច្បាប់សហជីព ដោយសហការជាមួយអ្នកពាក់ព័ន្ធ ដើម្បីធានាថា ច្បាប់នេះត្រូវបានអនុវត្តតាមលក្ខណៈមួយស្របនឹងកាតព្វកិច្ចសិទ្ធិមនុស្សរបស់រដ្ឋ។ |

## *ឃ. ប្រព័ន្ធផ្សព្វផ្សាយតាមអ៊ិនធើណិត និងការទទួលបានព័ត៌មាន*

| |
|---|
| *អនុសាសន៍នៃការពិនិត្យជាសកលតាមកាលកំណត់ (២០១៤)* |
| **១១៨.១៤.** បង្កើតច្បាប់ស្តីពីសេរីភាពទទួលបានព័ត៌មាន ស្របតាមបទដ្ឋានអន្តរជាតិ។ (ប៊ែលហ្ស៊ិក)<br><br>**១១៨.១០១.** ស្របតាមការប្តេជ្ញាចិត្តរបស់ខ្លួនក្រោមUPRកាលពីជុំមុន ធ្វើការឆ្ពោះទៅរកការធានាឲ្យមានការប្រើប្រាស់ដោយសេរីនូវប្រព័ន្ធផ្សព្វផ្សាយអេឡិចត្រូនិក និងធ្វើសេរីភាវូបនីយកម្មនៃវិធានកម្មសិទ្ធិប្រព័ន្ធផ្សព្វផ្សាយអេឡិចត្រូនិក តាមរយៈការធ្វើសេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងប្រព័ន្ធអ៊ីនធើណិត ស្របតាមស្តង់ដារអន្តរជាតិ។ (ហុងគ្រី)<br><br>**១១៨.១០៣.** ដោះស្រាយបញ្ហានៃការធ្វើនិយ័តកម្មសេរីភាពនៃការបញ្ចេញមតិតាមអ៊ីនធើណិតតាមរយៈការពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធទាំងអស់។ (ស៊ុយអែត) |
| *អនុសាសន៍នៃការពិនិត្យជាសកលតាមកាលកំណត់ (២០០៩)* |
| **៤៧.** សូមរៀបចំផែនការសកម្មភាពឲ្យបានល្អិតល្អន់ដើម្បីធានាដល់សិទ្ធិប្រើប្រាស់ប្រព័ន្ធព័ត៌មានតាមអេឡិចត្រូនិចដោយសេរី និងរំដោះប្រព័ន្ធព័ត៌មានឲ្យរួចផុតពីការគ្រប់គ្រងជាកម្មសិទ្ធិផ្តាច់មុខ។ (ហុងគ្រី) |

| |
|---|
| ***អ្នករាយការណ៍ពិសេស*** |
| A/HRC/15/46. Para. 101. គួរតែមានច្បាប់ស្តីពីសេរីភាពទទួលបានព័ត៌មាននៅកម្ពុជាដើម្បីផ្តល់លទ្ធភាពឲ្យអ្នកសារព័ត៌មាន និងសាធារណៈជន ទទួលបានព័ត៌មានស្តីពីបញ្ហានៃប្រយោជន៍សាធារណៈ។ ច្បាប់បែបនេះ ក៏នឹងលើកកំពស់ដល់វិជ្ជាជីវៈសារព័ត៌មាន ឲ្យប្រកបដោយការទទួលខុសត្រូវ តម្លាភាព និងគណនេយ្យភាពផងដែរ។ |

# IV. និទណ្ឌភាព និងអ្នកការពារសិទ្ធិមនុស្ស

| *អនុសាសន៍នៃការពិនិត្យជាសកលតាមកាលកំណត់ (២០១៨)* |
|---|
| **១១៨. ១៣.** អនុម័តវិធានការមានប្រសិទ្ធភាពនានា ដើម្បីប្រយុទ្ធនឹងវប្បធម៌ហិង្សា និងនិទណ្ឌភាព [...] (អាល្លឺម៉ង់)<br>**១១៨.៩២.** បន្តចាត់វិធានការនានា ដើម្បីពង្រឹងការស៊ើបអង្កេតដោយឯករាជ្យ និងមិនលំអៀងលើករណីរំលោភសិទ្ធិមនុស្ស។ (អាហ្សង់ទីន)<br>**១១៨.១០៥.** គោរព និងការពារសិទ្ធិរបស់អ្នកការពារសិទ្ធិមនុស្ស និងអ្នកសារព័ត៌មាន ដើម្បីអនុវត្តការងាររបស់ពួកគេដោយគ្មានការរារាំង ការបំភិតបំភ័យ ឬការយាយី។ (អូទ្រីស)<br>**១១៨.១១២.** ធានាថា សិទ្ធិរបស់អ្នកការពារសិទ្ធិមនុស្សត្រូវបានគោរព ស្របតាមអនុសាសន៍ ដែលបានទទួលយកដោយកម្ពុជា ក្នុងអំឡុងពេល UPR ជុំទីមួយ។ (បែលហ្ស៊ិក)<br>**១១៨.១១៣.** អនុម័តវិធានការចាំបាច់នានាដើម្បីគោរព និងការពារអ្នកការពារសិទ្ធិមនុស្ស។ (ឈីលី)<br>**១១៨.១១៤.** ចាត់វិធានការចាំបាច់ទាំងអស់ ដើម្បីការពារអ្នកការពារសិទ្ធិមនុស្ស ជាពិសេស តាមរយៈការផ្តន្ទាទោសជនល្មើសនៃអំពើហិង្សា ឬការបំភិតបំភ័យប្រឆាំងពួកគេ។ (បារាំង)<br>**១១៨.១១៥.** ការពារសិទ្ធិរបស់អ្នកការពារសិទ្ធិមនុស្ស។ (អាល្លឺម៉ង់)<br>**១១៨.១១៦.** ធានាថា សិទ្ធិរបស់អ្នកការពារសិទ្ធិមនុស្ស ដើម្បីបំពេញការងារដោយគ្មានការរារាំង ការបំភិតបំភ័យ ឬការយាយី ត្រូវបានគោរព និងការពារ ដូចដែលបានផ្តល់អនុសាសន៍ និងទទួលយកដោយកម្ពុជា ក្នុងUPR កាលពីជុំមុន។ (អៀរឡង់ដ៍) |
| *អនុសាសន៍នៃការពិនិត្យជាសកលតាមកាលកំណត់ (២០០៩)* |
| **៥២.** សូមជួយសម្រួលដល់ការងាររបស់អង្គការមិនមែនរដ្ឋាភិបាល និងក្រុមសង្គមស៊ីវិលពាក់ព័ន្ធផ្សេងៗទៀតនៅក្នុងប្រទេស។ (អ៊ីតាលី)<br>**៥៣.** សូមបង្កើតឲ្យមានគោលនយោបាយមួយ ដើម្បីការពារដល់អ្នកការពារសិទ្ធិមនុស្ស។ (ប្រេស៊ីល)<br>**៥៤-ក).** ស្របតាមអនុសាសន៍មួយធ្វើឡើងកាលពីពេលមុន ដោយគណៈកម្មាធិការស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌ សូមដាក់ចេញនូវវិធានការប្រកបដោយប្រសិទ្ធភាពដើម្បីប្រយុទ្ធប្រឆាំងនឹងវប្បធម៌នៃអំពើហិង្សា និងនិទណ្ឌភាព និងដើម្បីការពារឲ្យបានប្រសើរឡើងដល់អ្នកការពារសិទ្ធិមនុស្ស រាប់បញ្ចូលទាំងអ្នកដឹកនាំជនជាតិដើមភាគតិច និងសកម្មជនតាមមូលដ្ឋាន។ (អាល្លឺម៉ង់)<br>ខ).សូមផ្សព្វផ្សាយឲ្យបានដឹងជាសាធារណៈអំពីករណីនៃការបំភិតបំភ័យនិងអំពើហឹង្សាដែលបានរាយការណ៍ រាប់បញ្ចូលទាំងអំពើឃាតកម្មលើសកម្មជនសហជីព បុគ្គលិកអង្គការមិនមែនរដ្ឋាភិបាល និងអ្នកសារព័ត៌មាន ព្រមទាំងធានាឲ្យមានការស៊ើបអង្កេតយ៉ាងហ្មត់ចត់ និងឲ្យមានការទទួលខុសត្រូវរបស់ជនល្មើស។ (អូទ្រីស) |

| |
|---|
| គ). សូមស៊ើបអង្កេតប្រកបដោយប្រសិទ្ធភាពនិងផ្តន្ទាទោសឧក្រិដ្ឋកម្មនិងការរំលោភនានាលើអ្នកការពារសិទ្ធិមនុស្ស ព្រមទាំងផ្តន្ទាទោសអ្នកដែលទទួលខុសត្រូវ។ (ណ័រវេស)<br>ឃ). សូមធ្វើការស៊ើបអង្កេត និងផ្តន្ទាទោសអំពើវាយប្រហារ ឬការអះអាងមិនពិតណាមួយទៅលើអ្នកការពារសិទ្ធិមនុស្ស ជាពិសេស អ្នកទាំងនោះដែលធ្វើការជាមួយសហគមន៍ ដើម្បីការពារដីធ្លី ផ្ទះសម្បែងនិងសិទ្ធិប្រើប្រាស់ធនធានធម្មជាតិ ព្រមទាំងទប់ស្កាត់ការជម្លៀសចេញដោយបង្ខំ ជាបញ្ហាមួយដែលអ្នករាយការណ៍ពិសេស និងគណៈកម្មាធិការស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ បានរាយការណ៍។ (អៀកឡង់ដ៍)<br>៥៥. អនុម័តវិធានការសមស្រប ដើម្បីផ្សព្វផ្សាយឲ្យទូលំទូលាយ និងធានាឲ្យមានការអនុវត្តទាំងស្រុងតាមសេចក្តីប្រកាសស្តីពីអ្នកការពារសិទ្ធិមនុស្ស។ (ណ័រវេស) |
| *គណៈកម្មាធិការសិទ្ធិមនុស្ស* (CCPR/C/SR.3157) (២០១៥) |
| ១១. គណៈកម្មាធិការរំលឹកអំពីអនុសាសន៍កន្លងមករបស់ខ្លួន(CCPR/C/79/Add.108, para.11) ថា រដ្ឋភាគី មានកាតព្វកិច្ចស៊ើបអង្កេតករណីទាំងអស់នៃការរំលោភសិទ្ធិមនុស្សកន្លងមក ជាពិសេស ការរំលោភបំពានលើមាត្រា៦នៃកតិកាសញ្ញានេះ ធ្វើការចោទប្រកាន់ និងផ្តន្ទាទោសជនដៃដល់ តាមការសមស្រប ហើយត្រូវផ្តល់សំណងដល់គ្រួសារជនរងគ្រោះ។<br>២១. [...] ដោយធ្វើដូច្នេះ រដ្ឋភាគីគួរតែះ<br>(ក). ចាត់វិធានការជាបន្ទាន់ដើម្បីស៊ើបអង្កេតពាក្យបណ្តឹងនៃការសម្លាប់ និងការផ្តល់កិច្ចការពារដ៏មានប្រសិទ្ធភាពដល់អ្នកកាសែត អ្នកការពារសិទ្ធិមនុស្ស និងតួអង្គសង្គមស៊ីវិលផ្សេងៗទៀតដែលត្រូវបានទទួលរងនូវការបំភិតបំភ័យ និងការវាយប្រហារនានាដោយសារតែសកម្មភាពវិជ្ជាជីវៈរបស់ពួកគេ។ [...]<br>(ខ). ចៀសវាងពីការផ្តន្ទាទោសអ្នកកាសែត អ្នកការពារសិទ្ធិមនុស្ស និងតួអង្គសង្គមស៊ីវិលផ្សេងៗទៀត ដែលយកការផ្តន្ទាទោសនេះជាមធ្យោបាយនៃការធ្វើឲ្យញញើត ឬបង្អាក់ទឹកចិត្តដល់ពួកគេពីការសម្តែងមតិរបស់ពួកគេដោយសេរី។ [...] |
| *គណៈកម្មាធិការសិទ្ធិកុមារះ ពេស្យាចារកុមារ* CRC/C/OPSC/KHM/CO/1 (២០១៥) |
| ២៣. គណៈកម្មាធិការសូមជំរុញរដ្ឋភាគីឱ្យពង្រឹងកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួន ដើម្បីប្រយុទ្ធប្រឆាំងនឹងនិទណ្ឌភាពដែលទទួលបានដោយជនល្មើស ហើយធានាថាឧក្រិដ្ឋកម្មក្រោមពិធីសារបន្ថែមនេះ ត្រូវបានស៊ើបអង្កេត ហើយជនល្មើសដែលជាប់ចោទត្រូវបានកាត់ទោស និងផ្តន្ទាទោសដ៏ត្រឹមត្រូវ។ ដើម្បីសម្រេចបានគោលដៅនេះ រដ្ឋភាគីគួរះ<br>(ក). ចេញសេចក្តីណែនាំច្បាស់លាស់ដល់ព្រះរាជអាជ្ញាទាំងអស់ ឱ្យធ្វើការចោទប្រកាន់ឱ្យបានសកម្ម និងធានាថាដំណើរការនីតិវិធីរឿងក្តីព្រហ្មទណ្ឌតាមផ្លូវច្បាប់ ត្រូវបានធ្វើជាប្រព័ន្ធប្រឆាំងនឹងជនល្មើសនៃបទល្មើសដែលស្ថិតក្រោមពិធីសារបន្ថែម។ |

(ខ). ដោះស្រាយពីបញ្ហាពុករលួយ ថាជាបញ្ហាអត្ថិភាព តាមរយៈការស៊ើបអង្កេតដ៏ម៉ត់ចត់ពីបណ្ដឹងដែលមានការសមគំនិតពីមន្ត្រីរដ្ឋាភិបាល និងធានាថាការដាក់ទោសទណ្ឌមន្ត្រីប្រតិបត្តិច្បាប់ និងមន្ត្រីនគរបាល ដែលបង្ហាញពីភាពអសកម្ម និង/ឬចូលរួមពាក់ព័ន្ធនឹងអំពើពុករលួយ ក្នុងការដោះស្រាយពីបទល្មើសនានា ដែលស្ថិតក្រោមពិធីសារបន្ថែម។

*គណៈកម្មាធិការស្ដីពីសិទ្ធិកុមារ* CRC/C/KHM/CO/2-3 (២០១១)

**២៥.** គណៈកម្មាធិការសូមជំរុញរដ្ឋភាគីឱ្យចាត់វិធានការដ៏រឹងមាំ ដើម្បីផ្ដល់នូវការទទួលស្គាល់ដោយស្របច្បាប់នូវសកម្មជនការពារសិទ្ធិមនុស្ស ព្រមទាំងការងាររបស់ពួកគេ ដើម្បីស្ដារឡើងវិញនូវបរិយាកាសជឿទុកចិត្ត និងសហប្រតិបត្តិការជាមួយសង្គមស៊ីវិល ព្រមទាំងឱ្យមានការចូលរួមជាប្រព័ន្ធពីសហគមន៍ ក៏ដូចជាសង្គមស៊ីវិល និងអង្គការកុមារក្នុងការរៀបចំផែនការ ការអនុវត្ត ការពិនិត្យតាមដាន និងការវាយតម្លៃគោលនយោបាយ ផែនការ និងកម្មវិធីដែលមានការពាក់ព័ន្ធជាមួយសិទ្ធិកុមារ។ គណៈកម្មាធិការក៏សូមជំរុញផងដែរឱ្យរដ្ឋភាគី ធ្វើការធានាឱ្យមានការស៊ើបអង្កេតជាបន្ទាន់នូវឧបទ្ទវហេតុនានាដែលត្រូវបានរាយការណ៍ពាក់ព័ន្ធជាមួយការបំភិតបំភ័យ និងការរុកគួន។ គណៈកម្មាធិការក៏សូមជំរុញបន្ថែមទៀតឱ្យរដ្ឋភាគីអនុវត្តតាមអនុសាសន៍ទាំងឡាយដែលបានដាក់ចេញដោយអ្នករាយការណ៍ពិសេសអង្គការសហប្រជាជាតិស្ដីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជាពាក់ព័ន្ធនឹងបញ្ហានេះ(A/HRC/១៥/៤៦ កថាខណ្ឌ៩៥)។

*គណៈកម្មាធិការលុបបំបាត់ការរើសអើងពូជសាសន៍* CERD/C/KHM/CO/8-13 (២០១០)

**១៧.** គណៈកម្មាធិការស្នើយ៉ាងទទូចដល់រដ្ឋភាគីឲ្យផ្ដល់ការការពារពេញលេញដល់ក្រុមជនងាយរងគ្រោះ ប្រឆាំងនឹងការវាយប្រហារលើរូបកាយ និងការបំភិតបំភ័យ នៅពេលដែលពួកគាត់ព្យាយាមប្រើប្រាស់សិទ្ធិរបស់ខ្លួនទាក់ទងនឹងដីសហគមន៍។ គណៈកម្មាធិការស្នើយ៉ាងទទូចដល់រដ្ឋភាគីឲ្យនាំខ្លួនអ្នកប្រព្រឹត្តល្មើសទៅតុលាការដើម្បីផ្ដន្ទាទោសទៅតាមច្បាប់។ [...]

*គណៈកម្មាធិការសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌* E/C.12/KHM/CO/1 (២០០៩)

**៣១.** គណៈកម្មាធិការស្នើយ៉ាងទទូចឲ្យរដ្ឋភាគីចាត់រាល់វិធានការចាំបាច់ ដើម្បីប្រយុទ្ធប្រឆាំងនឹងវប្បធម៌ហឹង្សា និងនិទណ្ឌភាពដែលកើតមានជាទូទៅក្នុងរដ្ឋភាគី និងការពារសកម្មជនសិទ្ធិមនុស្ស រួមទាំងតំណាងជនជាតិដើមភាគតិច សកម្មជនកសិករដែលបានចូលរួមក្នុងការការពារសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌របស់សហគមន៍ខ្លួន ប្រឆាំងនឹងការបំភិតបំភ័យ ការគំរាមកំហែង និងអំពើហឹង្សា ទោះជាអំពើទាំងនោះត្រូវបានប្រព្រឹត្តដោយកងកំលាំង និងភ្នាក់ងារសន្តិសុខរដ្ឋ ឬដោយតួអង្គមិនមែនរដ្ឋក្តី។ គណៈកម្មាធិការអំពាវនាវផងដែរដល់រដ្ឋភាគី ឲ្យធានាថា រាល់ករណីដែលបានចោទប្រកាន់អំពីការគាបសង្កត់និងការរំលោភទាំងប៉ុន្មាន ត្រូវបានធ្វើការស៊ើបអង្កេតទាំងស្រុង និងយ៉ាងឆាប់រហ័ស ហើយថាជនដែលគេអះអាងថាជាជនដៃដល់ ត្រូវតែចោទប្រកាន់ និងផ្តន្ទាទោសទៅតាមច្បាប់

ប្រសិនជារកឃើញថាពិតជាមានពិរុទ្ធភាពមែននោះ។ គណៈកម្មាធិការស្នើឲ្យរដ្ឋភាគីផ្តល់នៅក្នុងរបាយការណ៍តាមកាលកំណត់លើកក្រោយរបស់ខ្លួននូវព័ត៌មានលំអិតអំពីសមិទ្ធផលដែលសំរេចបានក្នុងការបង្ការ និងការផ្តន្ទាទោសចំពោះការគាបសង្កត់ និងអំពើរំលោភផ្សេងៗ។

### *អ្នករាយការណ៍ពិសេស*

A/HRC/24/36.Para.69. អ្នកការពារសិទ្ធិមនុស្ស និងជាពិសេស អ្នកទាំងឡាយណាដែលការពារសិទ្ធិដីធ្លី គួរត្រូវបានអនុញ្ញាតឲ្យអនុវត្តការងាររបស់គេ ដោយគ្មានការបំភិតបំភ័យ និងការយាយី។

A/HRC/24/63.Para.74. រដ្ឋាភិបាលគួរតែពន្លឿនការស៊ើបអង្កេតរឿងក្តីដែលមានពីមុនយូរមកហើយ ដែលពុំទាន់បានស៊ើបអង្កេតឲ្យបានសមស្រប ដោយពុំទាន់មានការកាត់ទោសបុគ្គលណាមួយនៅឡើយនោះ។

A/HRC/7/42,para.101 រដ្ឋាភិបាលត្រូវដោះស្រាយរឿងក្តីជាក់លាក់នានាឲ្យបានត្រឹមត្រូវដែលអ្នកតំណាងពិសេស និងអង្គការសិទ្ធិមនុស្សនានា បានទាញការចាប់អារម្មណ៍របស់រដ្ឋាភិបាលដល់រឿងក្តីទាំងនោះ រួមទាំងកាលៈទេសៈនៃការបាត់ខ្លួនព្រះតេជគុណទឹម សាខន។ វិធានការទាំងនេះ គួររាប់បញ្ចូលផងដែរនូវការផ្តល់យុត្តិធម៌ដល់ឃាតករដែលត្រូវបានចោទប្រកាន់ថាបានសំលាប់មេដឹកនាំសហជីពលោកជា វិជ្ជា ហើយត្រូវនាំខ្លួនឃាតករពិតមកផ្តន្ទាទោស តាមច្បាប់។

A/HRC/21/63/Add.1/Rev.1.Para.221. រដ្ឋាភិបាលត្រូវធានាថា ក្រុមហ៊ុនសម្បទាន មិនត្រូវប្រើប្រាស់ ឬលើកទឹកចិត្តសន្តិសុខឯកជនឲ្យចូលរួម ឬប្រើប្រាស់កំលាំងប្រឆាំងនឹងអ្នកតវ៉ា ឬសហគមន៍ណាដែលរងផលប៉ះពាល់ពីសម្បទាននោះទេ។

A/HRC/27/70 Para 81(e). នាំខ្លួនជនល្មើសទាំងអស់ដែលបានប្រព្រឹត្តិអំពើហិង្សាក្នុងកំឡុងពេលបាតុកម្មមកកាត់ទោសភ្លាមៗ រួមទាំងសមាជិកកម្លាំងសន្តិសុខដែលបានធ្វើឱ្យមានមនុស្សស្លាប់និងរងរបួស និងធានាឱ្យមានការជួសជុលសំណងសមរម្យដល់ជនរងគ្រោះ ឬអ្នកដែលនៅរស់រានមានជីវិត។

A/HRC/27/70 Para. 81(l). ការពារអ្នកការពារសិទ្ធិមនុស្ស និងជាពិសេស អ្នកទាំងឡាយណាដែលការពារសិទ្ធិដីធ្លី និងសិទ្ធិកម្មករ ធ្វើដូច្នេះ ដើម្បីឱ្យពួកគេអាចបំពេញការងាររបស់ពួកគេបានដោយគ្មានការបំភិតបំភ័យ ឬការយាយី។

A/HRC/27/70 Para. 81(m). ទប់មិនឱ្យមានការប្រើប្រាស់តុលាការដើម្បីបំភិតបំភ័យ យាយី ឬដាក់ពន្ធនាគារអ្នកការពារសិទ្ធិមនុស្ស និងអ្នកតំណាងសហជីព។

## V. កំណែទម្រង់ការបោះឆ្នោត និងការចូលរួមនយោបាយ

| *អនុសាសន៍នៃការពិនិត្យជាសកលតាមកាលកំណត់* (២០១៤) |
| --- |
| **១១៨.២៣.** ចាត់វិធានការចាំបាច់នានា ដើម្បីពង្រឹងក្របខ័ណ្ឌច្បាប់ជុំវិញការបោះឆ្នោត ក្នុងគោលបំណងធានាថា ការបោះឆ្នោតនាពេលអនាគត មានលក្ខណៈសេរី និងយុត្តិធម៌ ដែលអនុញ្ញាតឲ្យពលរដ្ឋកម្ពុជា មានសម្លេងនៅក្នុងការធ្វើសេចក្តីសម្រេចនានា ដែលប៉ះពាល់ដល់ជីវិតរបស់ពួកគេ និងដើម្បីជ្រើសរើសមន្ត្រីដែលឆ្លុះបញ្ចាំង និងឆ្លើយតបដោយប្រសិទ្ធភាពទៅនឹងតម្រូវការរបស់ពួកគេ។ (កាណាដា)<br>**១១៨.១១៧.** ដោះស្រាយពីកង្វះខាតនៅក្នុងការបោះឆ្នោត ដែលបានលើកឡើងដោយតួអង្គជាច្រើន រួមទាំងអ្នករាយការណ៍ពិសេសស្តីពីកម្ពុជា និងបេសកកម្មជំនួយបច្ចេកទេសរបស់សហព័ន្ធអឺរ៉ុប (ស៊ុយអែត)<br>**១១៨.១១៨.** ត្រឹមដំណាច់ឆ្នាំ២០១៤ អនុម័ត និងអនុវត្តអនុសាសន៍នានាស្តីពីការកែទម្រង់ការបោះឆ្នោត របស់អ្នករាយការណ៍ពិសេសស្តីពីកម្ពុជា។ (ចក្រភពអង់គ្លេស)<br>**១១៨.១១៩.** អនុវត្តកំណែទម្រង់ការបោះឆ្នោតសំខាន់ៗ ដើម្បីៈ (១).កែលំអពីសុចរិតភាពនៃប្រព័ន្ធចុះឈ្មោះអ្នកបោះឆ្នោត និងបញ្ជីឈ្មោះអ្នកបោះឆ្នោត (២).ធានាថាបេក្ខជនទាំងអស់មានសិទ្ធិស្មើគ្នាក្នុងការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយ និង(៣).ធានាថាគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត មានឯករាជ្យពេញលេញ។ (សហរដ្ឋអាមេរិច)<br>**១១៨.១២០.** ធានាថា បេក្ខជនទាំងអស់មានសិទ្ធិស្មើគ្នា ក្នុងការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយ ជៀសវាងការបញ្ឆោតអ្នកបោះឆ្នោត និងជំរុញវប្បធម៌នៃការសន្ទនាគ្នាក្នុងចំណោមគណបក្សនយោបាយទាំងអស់។ (សាធារណរដ្ឋឆែក)<br>**១១៨.១២១.** គណបក្សដែលពាក់ព័ន្ធ គួរលើកស្ទួយការសន្ទនា និងសហប្រតិបត្តិការអំពីលទ្ធផលនៃការបោះឆ្នោតសកលកាលពីឆ្នាំកន្លងទៅ ដើម្បីធ្វើឲ្យស្ថានការណ៍បានវិលមករកភាពប្រក្រតីវិញដោយឆាប់រហ័ស និងដើម្បីធ្វើឲ្យសម្រេចបាននូវការកែទម្រង់ការបោះឆ្នោត។ (ជប៉ុន)<br>**១១៨.១២២.** អនុវត្តកំណែទម្រង់ការបោះឆ្នោត តាមអនុសាសន៍របស់អ្នករាយការណ៍ពិសេសស្តីពីកម្ពុជា ដើម្បីបង្ការពីការកើតឡើងផ្ទួនៗនៃបញ្ហាទាំងនេះ នៅពេលខាងមុខ។ (ណូវ៉ែលហ្សេឡង់ដ៍)<br>**១១៨.១២៣.** អនុវត្តកំណែទម្រង់ការបោះឆ្នោត ដើម្បីធានាពីដំណើរការការបោះឆ្នោតដែលអាចជឿទុកចិត្តបាន (អូស្ត្រាលី) |
| *អនុសាសន៍នៃការពិនិត្យជាសកលតាមកាលកំណត់* (២០០៩) |
| ៤៨-(ក). ត្រូវប្តេជ្ញាដោយខ្លួនឯង ក្នុងការគោរពសេរីភាពខាងការបញ្ចេញមតិ និងយោបល់សំរាប់ទាំងអស់គ្នា ជាពិសេស សំរាប់សមាជិកក្រុមប្រឆាំង។ (កាណាដា)<br>(ខ). ត្រូវពិនិត្យឡើងវិញពីរបៀបលើកអភ័យឯកសិទ្ធិសភា ដើម្បីធានាថា ការអនុវត្តន៍បែបនេះមិនបំពារបំពានគោលការណ៍ពហុនិយម និងគោរពសេរីភាពនៃការបញ្ចេញមតិ។ (បារាំង)<br>៤៩. ចាត់វិធានការត្រឹមត្រូវ ឆ្ពោះទៅរកការអនុវត្តន៍ដ៏ពេញលេញនៃច្បាប់បោះឆ្នោត នាពេលអនាគត។ (ហុងគ្រី) |

| *គណៈកម្មាធិការសិទ្ធិមនុស្ស* (CCPR/C/SR.3157) (២០១៥) |
|---|
| **២៥.** រដ្ឋភាគីគួរធានាឱ្យបាននូវតម្លាភាព ក្នុងដំណើរការអង្គនីតិបញ្ញត្តិ និងគួរពិចារណាលើការធ្វើសេចក្តីព្រាងច្បាប់ទាំងឡាយ ឲ្យសាធារណៈជនបានដឹង ដើម្បីងាយស្រួលឲ្យប្រជាពលរដ្ឋ ជជែកដេញដោល និងធ្វើកិច្ចសន្ទនាជាសាធារណៈជាមួយតំណាងរបស់ពួកគេ ដោយត្រូវគិតគូរអំពីសេចក្តីពន្យល់ទូទៅលេខ២៥ (១៩៩៦) របស់គណៈកម្មាធិការនេះ ស្តីពីសិទ្ធិចូលរួមក្នុងកិច្ចការសាធារណៈ សិទ្ធិបោះឆ្នោត និងសិទ្ធិទទួលបានស្មើភាពគ្នានូវសេវាសាធារណៈ។<br><br>**២៦.** រដ្ឋភាគីគួរពិនិត្យឡើងវិញនូវច្បាប់របស់ខ្លួន ដែលបដិសេធសិទ្ធិបោះឆ្នោតរបស់ទណ្ឌិតទាំងអស់ ក្រោយពេលពិចារណាលើកថាខ័ណ្ឌ១៤ នៃសេចក្តីពន្យល់ទូទៅរបស់គណៈកម្មាធិការនេះលេខ២៥(១៩៩៦) លើមាត្រា២៥ (ការចូលរួមក្នុងកិច្ចការសាធារណៈ និងសិទ្ធិបោះឆ្នោត)។ រដ្ឋភាគីក៏គួរតែធានាផងដែរថា ច្បាប់របស់ខ្លួនមិនបានរើសអើងប្រឆាំងនឹងជនមានសតិវិបល្លាសដោយបដិសេធនូវសិទ្ធិបោះឆ្នោតរបស់ពួកគេ ដោយឈរលើមូលដ្ឋានដែលមានការទាក់ទងតិចតួច ឬដែលមិនមានទំនាក់ទំនងសមហេតុផល និងជាសត្យានុម័តទៅនឹងសមត្ថភាពក្នុងការបោះឆ្នោតរបស់ពួកគេ ដោយត្រូវគិតគូរពិចារណាលើមាត្រា២៥ នៃកតិកាសញ្ញានេះ។ |
| *អ្នករាយការណ៍ពិសេស* |
| អនុសាសន៍ខាងក្រោមនេះ ដកស្រង់ចេញពី A/HRC/18/46 រហូតដល់មានការបង្ហាញផ្សេងពីនេះ៖<br>**៦៤.** កម្ពុជាត្រូវការពន្លឿនថែមទៀតដល់ដំណើរការប្រជាធិបតេយ្យភាវូបនីយកម្មក្នុងប្រទេស។ គួរតែមានឆន្ទៈមួយពិតប្រាកដ និងការខិតខំព្យាយាមធ្វើការផ្សះផ្សារបញ្ហាវិបត្តិនយោបាយដើម្បីឲ្យតួអង្គគណបក្សទាំងអស់មានឱកាសស្មើគ្នា ក្នុងការចូលរួមជាវិភាគទាន ឬរួមចំណែកក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ច និងនយោបាយរបស់ប្រទេសជាតិ និងដំណើរការសភានិយម។ សិទ្ធិរបស់សមាជិកសភាទាំងអស់ ចាប់ពីតំណាងរាស្ត្រមកពីគណបក្សដែលមានអាសនៈភាគច្រើនដល់គណបក្សដែលមានអាសនៈភាគតិចក្នុងសភា អាចអនុវត្តតួនាទីភារកិច្ចរបស់ខ្លួនគួរតែត្រូវបានគោរពអនុវត្តតាម។<br><br>**៦៨.** នីតិវិធីផ្ទៃក្នុងរបស់សភាជាទូទៅ ជាពិសេស នីតិវិធីផ្ទៃក្នុងរបស់រដ្ឋសភា គួរត្រូវបានពិនិត្យឡើងវិញដើម្បីលើកទឹកចិត្តឲ្យមានការបែងចែកអំណាច និងការទទួលខុសត្រូវប្រកបដោយភាពស្មើគ្នា ឬមានសមាមាត្រនៅក្នុងសកម្មភាពការងាររបស់សភា និងជាពិសេស ក្នុងតួនាទីភាពជាអ្នកដឹកនាំនៅក្នុងគណៈកម្មការសភាផ្សេងៗ។<br><br>**៦៩.** នីតិវិធីសំរាប់ការដកហូតអភ័យឯកសិទ្ធិសភា និងការដាក់ទណ្ឌកម្មខាងវិន័យ ប្រឆាំងនឹងសមាជិកក្នុងសម័យប្រជុំ គួរតែអនុវត្ត ស្របតាមគោលការណ៍យុត្តិធម៌ធម្មជាតិ បទដ្ឋានរដ្ឋធម្មនុញ្ញ និងសេរីភាពនៃការបញ្ចេញមតិ។<br><br>**៧៧.** សេចក្តីតម្រូវជាសមាជិកនៃក្រុមមួយដែលមានសមាជិកសភាចំនួនដប់រូប ចូលរួមជជែកវែកញែកក្នុងសភា គួរតែរក្សាឲ្យមានតទៅទៀត ដើម្បីឲ្យសមាជិកសភាគ្រប់រូប មានឱកាសស្មើគ្នាក្នុងការចូលរួមជជែកវែកញែកលើបញ្ហាផ្សេងៗ។ |

៧៨. គណបក្សប្រឆាំងសំខាន់មួយ គួរតែមានតួនាទីមួយត្រូវបំពេញ ប្រកបដោយន័យស្ថាបនា ក្នុងការតែងតាំងសមាជិកស្ថាប័នទាំងឡាយដែលបង្កើតឡើងដោយរដ្ឋធម្មនុញ្ញ ដូចជាគណៈកម្មការរៀបចំការបោះឆ្នោត ដើម្បីធ្វើឲ្យប្រាកដថា គណៈកម្មការទាំងនោះអាចប្រតិបត្តិការប្រកបដោយភាពឯករាជ្យ និងមិនលំអៀង។

អនុសាសន៍ខាងក្រោមនេះ ដកស្រង់ចេញពី A/HRC/21/63 រហូតដល់មានការបង្ហាញផ្សេងពីនេះ៖
៦៥. គ ជ ប គួរតែមានឋានៈស្វ័យភាព និងឯករាជ្យ នៅក្នុងរចនាសម្ព័ន្ធច្បាប់ និងរដ្ឋធម្មនុញ្ញនៃកម្ពុជា ជាមួយនឹងថវិកាឯករាជ្យផ្ទាល់ខ្លួនដែលមានការអនុម័តបែងចែកពីសភា។ ប្រធាន និងសមាជិក គ ជ ប គួរតែជ្រើសរើសចេញពីថៅក្រមជាន់ខ្ពស់ចូលនិវត្តន៍ សមាជិកជាន់ខ្ពស់ និងកិត្តិយសនៃគណៈមេធាវីកម្ពុជា និងសាស្ត្រាចារ្យជាន់ខ្ពស់ផ្នែកច្បាប់ វិទ្យាសាស្ត្រនយោបាយ និងរដ្ឋបាលសាធារណៈ។

៦៦. គួរតែមានការព្រមព្រៀងគ្នាជាទូទៅខាងផ្នែកនយោបាយ ពីក្នុងចំណោមគណៈបក្សនយោបាយធំៗ ដែលមានតំណាងនៅរដ្ឋសភា ពីការតែងតាំងប្រធាន និងសមាជិក គ ជ ប និងគណៈកម្មាធិការរៀបចំការបោះឆ្នោតខេត្ត។

៦៧. រាជរដ្ឋាភិបាលគួរផ្តួចផ្តើមដំណើរការធ្វើវិសោធនកម្មមាត្រា១៣ថ្មី ចំនុចទី២ នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគ ជ ប និងមាត្រាពាក់ព័ន្ធដទៃទៀត ដើម្បីធានាថា នៅក្នុងសមាសភាពគ្រប់ជាន់ថ្នាក់នៃស្ថាប័នរៀបចំការបោះឆ្នោត មានតុល្យភាពនៃតំណាងមកពីគ្រប់គណៈបក្សនយោបាយដែលមានតំណាងនៅក្នុងរដ្ឋសភា។

៦៨. ប្រធាន និងសមាជិក គ.ជ.ប. និងគណៈកម្មាធិការរៀបចំការបោះឆ្នោតខេត្ត គួរតែត្រូវបានតែងតាំងសំរាប់អណត្តិកំណត់មួយ និងគួរមានការធានាការពារនូវតំណែងរបស់ពួកគេផង។ ពួកគេ គួរតែត្រូវបានរារាំងមិនឲ្យមានតួនាទីនៅក្នុងគណៈបក្សនយោបាយក្នុងអណត្តិរបស់ពួកគេ និងរហូតដល់ទៅ២ឆ្នាំទៀត បន្ទាប់ពីផុតអណត្តិរបស់ពួកគេ។

៦៩. អ្នករាយការណ៍ពិសេសបានសំលឹងមើលយន្តការដោះស្រាយវិវាទបោះឆ្នោត ហើយយល់ឃើញថា គួរតែត្រូវបានកែលម្អ។ បច្ចុប្បន្ននេះគឺមន្ត្រីរៀបចំការបោះឆ្នោតខ្លួនឯងដែលត្រូវធ្វើឲ្យគេជឿជាក់លើភារកិច្ចនៃការដោះស្រាយវិវាទបោះឆ្នោតបឋម។ ដើម្បីបង្កើនជំនឿចិត្តលើគ្រប់គណៈបក្សនយោបាយនៅក្នុងដំណើរការបោះឆ្នោត ត្រូវតែធ្វើវិសោធនកម្មច្បាប់ និងបង្កើតស្ថាប័នមួយទៀត ដូចជា តុលាការពិសេសសំរាប់ការបោះឆ្នោត ឬតុលាការសំរាប់ការបោះឆ្នោត នៅក្នុងរចនាសម្ព័ន្ធតុលាការរបស់កម្ពុជា ឬជាតុលាការពិសេសសំរាប់ការបោះឆ្នោតនៅក្នុងក្រុមប្រឹក្សាធម្មនុញ្ញ គឺមិនមែន គ ជ ប ខ្លួនឯង ដែលត្រូវយកបញ្ហាពាក់ព័ន្ធនឹងវិវាទនៃការបោះឆ្នោតមកដោះស្រាយនោះទេ។

៧០. គ្រប់គណៈបក្សនយោបាយធំៗគួរតែទទួលបានដោយយុត្តិធម៌ និងស្មើភាពគ្នានូវប្រព័ន្ធផ្សព្វផ្សាយសាធារណៈ ដើម្បីបញ្ជូនសាររបស់ខ្លួនទៅកាន់អ្នកបោះឆ្នោត និងគួរតែមានឱកាសផ្សព្វផ្សាយសារនោះនៅក្នុងម៉ោងសំខាន់ៗ។ ជំហានបន្ទាប់ គួរត្រូវបង្កើតគណៈកម្មាធិការឯករាជ្យមួយសំរាប់ការគ្រប់គ្រង និងការប្រើប្រាស់ស្ថានីយ៍វិទ្យុ និងទូរទស្សន៍ដែលគ្រប់គ្រងដោយរដ្ឋ ដោយអនុញ្ញាតឲ្យគណៈបក្សនយោបាយធំៗទាំងអស់ដែលមានតំណាងនៅក្នុងរដ្ឋសភា ប្រើប្រាស់ដោយពេញលេញនូវប្រព័ន្ធផ្សព្វផ្សាយទាំងនេះ រហូតដល់ថ្ងៃយុទ្ធនាការបោះឆ្នោត ដោយឈរលើជំហរស្មើភាពគ្នា។

**៧១.** បញ្ហាមួយផ្សេងទៀត គឺការប្រើប្រាស់ធនធានរបស់រដ្ឋដោយគណៈបក្សនយោបាយនានា នៅក្នុងពេលយុទ្ធនាការឃោសនារបស់ពួកគេ រួមទាំងពេលម៉ោងធ្វើការរបស់រដ្ឋ យានជំនិះ និងសម្ភារៈផ្សេងៗ។ រដ្ឋាភិបាលត្រូវធានាថា មន្ត្រីរាជការទាំងអស់ នគរបាល និងយោធា មិនត្រូវចូលរួមក្នុងសកម្មភាពនយោបាយណាមួយ នៅពេលបំពេញការងារក្នុងសមត្ថភាពផ្លូវការរបស់ពួកគេ ដែលរាប់ទាំងការប្រើប្រាស់ធនធានរបស់រដ្ឋាភិបាល ហើយធានាថា ភាពអព្យាក្រឹត្យ គឺជាចំណុចកំពូល។

**៧២.** ដើម្បីឲ្យការបោះឆ្នោតទទួលបានទំនុកចិត្ត គ្រប់គណៈបក្សប្រឆាំងត្រូវតែមានសេរីភាពរៀបចំ និងឃោសនាដោយគ្មានការរារាំងនិងការភ័យខ្លាច។ ការបោះឆ្នោតមិនមែនគិតត្រឹមតែថ្ងៃបោះឆ្នោតនោះទេ ក៏ប៉ុន្តែត្រូវគិតពីបរិបទសិទ្ធិមនុស្សជារួមនៅក្នុងប្រទេស។ អ្នករាយការណ៍ពិសេសបានទទួលព័ត៌មានជាច្រើនអំពីករណីនៃការយាយី និងការបំភិតបំភ័យដល់ពលរដ្ឋដែលចូលរួមក្នុងការប្រជុំនយោបាយរបស់គណៈបក្សប្រឆាំង ដោយមន្ត្រីរដ្ឋាភិបាល និងប៉ូលីសសំងាត់។ ដូចនេះ រដ្ឋាភិបាលត្រូវតែធានាថា គណៈបក្សប្រឆាំងមានសេរីភាពធ្វើសកម្មភាពនយោបាយរបស់ខ្លួន ដោយគ្មានការយាយី និងការបំភិតបំភ័យណាមួយឡើយ មិនត្រឹមតែជុំវិញថ្ងៃបោះឆ្នោតប៉ុណ្ណោះទេ ប៉ុន្តែត្រូវគិតពីពេលដែលខិតមកជិតដល់ថ្ងៃបោះឆ្នោត និងពេញមួយអណត្តិសភាផង។

**៧៣.** គួរតែមាននីតិវិធីមួយ ដែលមានប្រសិទ្ធភាពជាង មិនលំអៀងជាង និងគ្មានការរើសអើងជាង សំរាប់ការចុះឈ្មោះអ្នកបោះឆ្នោតនៅកម្ពុជា។ អាស្រ័យហេតុនេះ អាជ្ញាធររបស់រដ្ឋាភិបាល គួរតែផ្តល់ឯកសារចាំបាច់ អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ លិខិតឆ្លងដែន និងឯកសារអាត្រានុកូលដ្ឋានចាំបាច់ដទៃទៀតដល់ពលរដ្ឋទាំងអស់ក្នុងតំលៃថោក និងឲ្យបានលឿន ហើយគួរចុះឈ្មោះអ្នកបោះឆ្នោតសារជាថ្មី ដោយប្រើប្រាស់ទិន្នន័យពីអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរធ្វើជាមូលដ្ឋាន ដើម្បីការចុះបញ្ជីថ្មីនៃអ្នកបោះឆ្នោត។

**៧៤.** ពលរដ្ឋខ្មែរគ្រប់រូបដែលមានសិទ្ធិបោះឆ្នោតគួរតែត្រូវបានផ្តល់សិទ្ធិឲ្យធ្វើសំណើពីការចុះឈ្មោះជាមួយអាជ្ញាធរបោះឆ្នោត ឬអាជ្ញាធរដែនដី នៅពេលណាក៏បាននៃឆ្នាំ ហើយនៅពេលដែលពួកគេទទួលបានអត្តសញ្ញាណប័ណ្ណដែលគួរតែមានសុពលភាពអស់មួយជីវិតនោះ លើកលែងតែមានការផ្លាស់ប្តូរភិនភាគរបស់ពួកគេ តម្រូវឲ្យធ្វើការផ្លាស់ប្តូរ។

**៧៥.** ការបោះឆ្នោតក្រុមប្រឹក្សាឃុំសង្កាត់/ ឆ្នាំ២០១២ បានបង្ហាញថា បញ្ហាដ៏ជាក់លាក់ នៅតែកើតមានជាមួយឯកសារបញ្ជាក់អត្តសញ្ញាណអ្នកបោះឆ្នោត ដែលត្រូវបានស្គាល់ជាទូទៅថាទំរង់១០១៨ ជាពិសេសទាក់ទងនឹងការចេញឯកសារក្លែងក្លាយ និងការប្រើប្រាស់ឯកសារទាំងនេះ នៅក្នុងករណីមួយចំនួន។ គ ជ ប គួរតែពិនិត្យពីដំណើរការនៃការចេញឯកសារបែបនេះ ដើម្បីធានាថា ប្រព័ន្ធនេះមិនត្រូវបំពានដោយគណៈបក្សនយោបាយណាមួយ ក្នុងគោលបំណងបំរើផលប្រយោជន៍របស់ពួកគេនោះទេ និងធានាថា គ្មានការបោះឆ្នោតមិនត្រឹមត្រូវកើតមានឡើងលើផ្នែកនៃតួអង្គណាមួយនៅក្នុងសង្គមនោះទេ។

**៧៦.** គ ជ ប គួរបង្កើតវិធានការពិសេសនានាដើម្បីធានាថា អ្នកគ្មានទីជំរក ឬអ្នកដែលត្រូវបានបណ្តេញចេញពីដីធ្លីរបស់ពួកគេថ្មីៗនេះមិនត្រូវបានដកហូតសិទ្ធិបោះឆ្នោតនៅក្នុងការបោះឆ្នោតដែលនឹងចូលមកដល់នាពេលខាងមុខ។

**៧៧**. ដើម្បីឱ្យការបោះឆ្នោតប្រព្រឹត្តទៅដោយសេរី និងត្រឹមត្រូវ បរិយាកាសនយោបាយទាំងមូល គួរតែប្រព្រឹត្តទៅដោយសេរី និងនាំមកនូវការអនុវត្តសិទ្ធិ និងសេរីភាពទាំងឡាយដែលធានាការពារដោយរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និងសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិដែលកម្ពុជាបានផ្តល់សច្ចាប័ន។ ដូចនេះ រាជរដ្ឋាភិបាលគួរតែធានាថា បុគ្គលគ្រប់រូបអាចប្រើប្រាស់សិទ្ធិ និងសេរីភាពនៃការបញ្ចេញមតិ សេរីភាពនៃការជួបប្រជុំ និងសមាគម។

**៧៨**. ដំណើរការបោះឆ្នោត រួមមានដំណើរការចុះឈ្មោះអ្នកបោះឆ្នោត និងរបៀបក្នុងការដោះស្រាយវិវាទបោះឆ្នោតគួរតែមានតម្លាភាព និងស្របតាមស្តង់ដារអន្តរជាតិ។ ឧទាហរណ៍ គ ជ ប គួរបិទផ្សាយជាសាធារណៈនូវឈ្មោះមន្ត្រីនៃការិយាល័យបោះឆ្នោត និងបញ្ជីឈ្មោះអ្នកបោះឆ្នោត ត្រូវផ្តល់ជូនបេក្ខជនទាំងឡាយដែលមកពីគ្រប់គណៈបក្សនយោបាយទៅតាមការស្នើសុំ ដោយផ្តល់ឲ្យពួកគាត់នូវឱកាស ដើម្បីតតាំងការក្លែងបន្លំឈ្មោះក្នុងបញ្ជីឈ្មោះអ្នកបោះឆ្នោត។

**៧៩**. គ ជ ប គួរតែងតាំងអភិបាលបោះឆ្នោតដែលមានវិជ្ជាជីវៈ ដែលអាចជំនួសមេភូមិ ទាំងក្នុងពេលការចុះឈ្មោះអ្នកបោះឆ្នោត និងនៅថ្ងៃបោះឆ្នោត ហើយដាក់មន្ត្រីបោះឆ្នោតឃុំ/សង្កាត់ទាំងអស់ និងដំណើរការនានាឱ្យស្ថិតនៅក្រោមយន្តការត្រួតពិនិត្យដ៏តឹងរឹងរបស់ខ្លួន។

**៨០**. ច្បាប់បច្ចុប្បន្នដែលតម្រូវអោយបុគ្គលណាមួយដែលមានបំណងឈរឈ្មោះបោះឆ្នោត ត្រូវមានឈ្មោះក្នុងបញ្ជីបោះឆ្នោតរបស់គណបក្សនយោបាយមួយ បញ្ញត្តិនេះគួរតែបានធ្វើវិសោធនកម្ម ដើម្បីផ្តល់លទ្ធភាពអោយបេក្ខជនឯករាជ្យ អាចឈរឈ្មោះបោះឆ្នោតជាតិបាន។

**៨១**. អាស្រ័យដោយប្រទេសកម្ពុជាអនុញ្ញាតឲ្យប្រជាពលរដ្ឋអាចមានសញ្ជាតិពីរ ដូច្នេះ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត គួរតែផ្តល់លទ្ធភាពឲ្យប្រជាពលរដ្ឋខ្មែរ ដែលកំពុងរស់នៅក្រៅប្រទេសអាចប្រើប្រាស់សិទ្ធិបោះឆ្នោតរបស់ខ្លួនបាន យ៉ាងហោចណាស់ក៏នៅប្រទេសទាំងឡាយដែលមានតំណាងស្ថានទូត និង/ឬស្ថានកុងស៊ុលប្រចាំនៅទីនោះ ដូចការអនុវត្តនៅក្នុងបណ្តាប្រទេសដទៃទៀតដែរ។

**៨២**. នៅទីបញ្ចប់ អ្នករាយការណ៍ពិសេសដឹងអំពីស្ថានភាពរបស់លោកសម រង្ស៊ី ប្រធានគណបក្សសម រង្ស៊ី គាត់ត្រូវបានតុលាការផ្តន្ទាទោសពីបទចោទប្រកាន់ទាក់ទងនឹងរឿងនយោបាយ។ គួរតែស្វែងរកដំណោះស្រាយនយោបាយមួយដើម្បីផ្តល់លទ្ធភាពអោយគាត់ដែលជាប្រធានគណបក្សប្រឆាំង បានដើរតួនាទីមួយពេញលេញក្នុងជីវភាពនយោបាយនៅកម្ពុជា។ អ្នករាយការណ៍ពិសេសជឿជាក់ថា កិច្ចខិតខំប្រឹងប្រែងរួមគ្នាមួយ ដោយគណបក្សកាន់អំណាច និងគណបក្សប្រឆាំងឈានទៅការផ្សះផ្សាគ្នា ជាប្រយោជន៍ដល់ដំណើរការប្រជាធិបតេយ្យមួយដែលខ្លាំង និងស៊ីជម្រៅជាងនេះថែមទៀតនៅកម្ពុជា។ ការនេះសំខាន់ជាពិសេសសំរាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនៅថ្ងៃខាងមុខ។ សំរាប់សុខសន្តិភាព និងវិបុលភាពរយៈពេលដ៏យូរអង្វែង គួរតែរក្សាអោយមានទីលានប្រកួតមួយដែលរាបស្មើសំរាប់គណបក្សនយោបាយទាំងអស់ចូលរួមប្រកួតប្រជែងដោយស្មើភាពគ្នា។ ប្រជាពលរដ្ឋមានការជឿជាក់លើប្រព័ន្ធអភិបាលកិច្ចក្នុងប្រទេសនិងក្នុងការបោះឆ្នោតតាមកាលកំណត់ដែលជាស្នូលនៃលិទ្ធិប្រជាធិបតេយ្យ។

A/HRC/24/36. Para. 67. ដោយមិនគិតពីលទ្ធផលបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៣ គួរចាត់វិធានការសមស្រប ដើម្បីពង្រឹងឯករាជ្យភាព និងសមត្ថភាពរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដើម្បីទទួលបានការទុកចិត្ត និងជំនឿពេញលេញពីអ្នកបោះឆ្នោតទាំងអស់នៅក្នុងប្រទេសសំរាប់ការបោះឆ្នោតលើកក្រោយៗទៀត។ ជាពិសេស ចាំបាច់ត្រូវខិតខំព្យាយាមខ្លាំងក្លាជាងនេះថែមទៀត ធ្វើយ៉ាងណាឲ្យអ្នកមានសិទ្ធិបោះឆ្នោតទាំងអស់អាចអនុវត្តសិទ្ធិនយោបាយរបស់គេប្រកបដោយអត្ថន័យ។

A/HRC/24/36. Para.75. អ្នករាយការណ៍ពិសេស សូមសំដែងសេចក្តីសង្ឃឹមថា គ្រប់គណបក្សនយោបាយ និងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត នឹងធានាឲ្យការបោះឆ្នោតនៅថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៣ ប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ និងសន្តិវិធី ដែលគ្រប់ភាគីអាចចូលរួមប្រកួតប្រជែងដោយស្មើភាពគ្នា។

A/HRC/27/70 Para. 81(c). សម្រេចបានកិច្ចព្រមព្រៀងពិស្តារមួយជាមួយគណៈបក្សប្រឆាំង អំពីកំណែទម្រង់ដែលបានសន្យានូវស្ថាប័នបោះឆ្នោត ស្ថាប័នសភា និងស្ថាប័នដទៃទៀតដែលទទួលខុសត្រូវដល់ការលើកកំពស់សិទ្ធិរបស់ប្រជាពលរដ្ឋ និងឆ្ពោះទៅអនុវត្តកំណែទម្រង់នេះដោយគ្មានការពន្យាពេល។

A/HRC/33/62 Para. 61(u). ពិចារណាយន្តការសម្របសម្រួលការចុះឈ្មោះអ្នកដែលគ្រប់អាយុបោះឆ្នោត និងការបោះឆ្នោតបានទាន់ពេល រួមទាំងអ្នកទាំងឡាយណាដែលគ្មានផ្ទះសំបែង ជនពិការ អ្នកតាំងទីលំនៅថ្មី ឬស្ថិតនៅក្រោមការឃុំខ្លួនបណ្តោះអាសន្ន ឬពលករចំណាកស្រុកក្នុងប្រទេស ទន្ទឹមនឹងយកមកពិចារណាពីពលករកម្ពុជាទាំងស្របច្បាប់ និងមិនស្របច្បាប់ដែលទៅធ្វើការនៅក្រៅប្រទេស រួមទាំងក្នុងបណ្តាប្រទេសអាស៊ានដទៃទៀត។

A/HRC/33/62 Para. 61(f). ពិនិត្យច្បាប់ គោលនយោបាយ និងយុទ្ធសាស្ត្រឡើងវិញតាមការចាំបាច់ ដើម្បីធានាថា សមភាពរវាងបុរស និងស្ត្រី ក្លាយជាការពិត ដោយធ្វើការអប់រំជាសាធារណៈដើម្បីពង្រឹងសារជាវិជ្ជមានអំពីសមភាពនេះ និងពិចារណាចាត់វិធានការដើម្បីលប់បំបាត់ឧបសគ្គមិនឱ្យស្ត្រីឈរឈ្មោះឱ្យគេបោះឆ្នោតដោយឆ្លុះបញ្ចាំងពីលទ្ធភាពនៃការចាត់វិធានការពិសេសបណ្តោះអាសន្ន រួមទាំងបញ្ជីបេក្ខជនសម្រាំងសំរាប់តែស្ត្រី ឬបញ្ជីជំនួសបុរស ដោយស្ត្រី។

## VI. ស្ថាប័នជាតិសិទ្ធិមនុស្ស

### *អនុសាសន៍នៃការពិនិត្យជាសកលតាមកាលកំណត់ (២០១៤)*

**១១៨.២៨.** បន្តពង្រឹងសមត្ថភាពស្ថាប័នជាតិរបស់ខ្លួននៅក្នុងការលើកស្ទួយនិងការពារសិទ្ធិមនុស្សរួមទាំងតាមរយៈការបញ្ចប់ដំណើរការនៃការបង្កើតស្ថាប័នសិទ្ធិមនុស្សជាតិមួយ ស្របតាមគោលការណ៍ទីក្រុងប៉ារីស។ (ឥណ្ឌូនេស៊ី)

**១១៨.២៩.** បង្កើតឲ្យបានឆាប់នូវស្ថាប័នសិទ្ធិមនុស្សជាតិមួយ ស្របតាមគោលការណ៍ទីក្រុងប៉ារីស។ (ទុយនេស៊ី)

**១១៨.៣០.** បង្កើតស្ថាប័នឯករាជ្យមួយទទួលបន្ទុកសិទ្ធិមនុស្ស ស្របតាមគោលការណ៍ទីក្រុងប៉ារីស។(អាល់ហ្សេរី)

**១១៨.៣១.** ត្រូវបង្ហើយការបង្កើតស្ថាប័នសិទ្ធិមនុស្សជាតិមួយ ស្របតាមគោលការណ៍ទីក្រុងប៉ារីស។ (អេហ្ស៊ីប)

**១១៨.៣២.** ពិចារណាពីការបង្កើតស្ថាប័នសិទ្ធិមនុស្សជាតិមួយស្របតាមគោលការណ៍ទីក្រុងប៉ារីស។ (ឥណ្ឌា)

**១១៨.៣៣.** បង្កើតស្ថាប័នសិទ្ធិមនុស្សជាតិឯករាជ្យមួយ។ (ថៃ)

**១១៨.៣៤.** បង្កើនកិច្ចខិតខំប្រឹងប្រែងបង្កើតស្ថាប័នសិទ្ធិមនុស្សជាតិមួយស្របតាមគោលការណ៍ទីក្រុងប៉ារីស។ (ឈីលី)

**១១៨.៣៥.** បន្តវិធានការវិជ្ជមានដែលខ្លួនបានដាក់ចេញកន្លងមក ដើម្បីបង្កើតស្ថាប័នសិទ្ធិមនុស្សជាតិមួយ ដោយផ្អែកលើគោលការណ៍ទីក្រុងប៉ារីស។ (ម៉ាឡេស៊ី)

**១១៨.៣៦.** បង្កើតស្ថាប័នជាតិមួយសម្រាប់លើកស្ទួយនិងការពារសិទ្ធិមនុស្សស្របតាមគោលការណ៍ទីក្រុងប៉ារីស។ (ម៉ូរ៉ុកកូ)

**១១៨.៣៧.** បន្តកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួនក្នុងការបង្កើតស្ថាប័នសិទ្ធិមនុស្សជាតិឯករាជ្យមួយ ស្របតាមគោលការណ៍ទីក្រុងប៉ារីស។ (ប៉ាគីស្ថាន)

**១១៨.៣៨.** បង្កើតស្ថាប័នសិទ្ធិមនុស្សជាតិឯករាជ្យមួយ ស្របតាមគោលការណ៍ទីក្រុងប៉ារីស។ (អូស្ត្រាលី)

**១១៨.៨៦.** ពង្រឹងស្ថាប័នតុលាការ និងស្ថាប័នសិទ្ធិមនុស្សជាតិរបស់ខ្លួនបន្ថែមទៀត ដើម្បីធានាឯករាជ្យភាពនៃស្ថាប័នទាំងនេះ ឲ្យមានប្រសិទ្ធភាព។ (កេនយ៉ា)

### *អនុសាសន៍នៃការពិនិត្យជាសកលតាមកាលកំណត់ (២០០៩)*

**៧.** ពន្លឿនប្រតិបត្តិការនីយកម្មនៃស្ថាប័នសិទ្ធិមនុស្សឯករាជ្យ ស្របតាមគោលការណ៍ទីក្រុងប៉ារីស។ (ប៉ាគីស្ថាន)

ពន្លឿនជំហានដែលកំពុងតែធ្វើសព្វថ្ងៃ ដើម្បីបង្កើតស្ថាប័នសិទ្ធិមនុស្សឯករាជ្យ ស្របតាមគោលការណ៍ទីក្រុងប៉ារីស។ (អេហ្ស៊ីប)

បន្តកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួន ដើម្បីបង្កើតស្ថាប័នជាតិសិទ្ធិមនុស្ស ស្របតាមគោលការណ៍ទីក្រុងប៉ារីសដែលនឹងពង្រឹងហេដ្ឋារចនាសម្ព័ន្ធសិទ្ធិមនុស្សនៅក្នុងប្រទេស។ (ថៃ)

ធ្វើឲ្យជឿនលឿនដល់ដំណើរការនៃការបង្កើតស្ថាប័នសិទ្ធិមនុស្សឯករាជ្យ ក្នុងលក្ខណៈប្រាកដនិយម និងក្នុងការពិគ្រោះយោបល់ជាមួយផ្នែកពាក់ព័ន្ធទាំងអស់។ (ហ្វីលីពីន)

| |
|---|
| ***គណៈកម្មាធិការសិទ្ធិមនុស្ស*** (CCPR/C/SR.3157) (២០១៥) |
| **៦.** គណៈកម្មាធិការជម្រុញលើកទឹកចិត្តឲ្យរដ្ឋភាគី បង្កើតស្ថាប័នជាតិសិទ្ធិមនុស្ស ឯករាជ្យមួយ ស្របតាមគោលការណ៍ទីក្រុងប៉ារីស (សេចក្តីសម្រេចលេខ៤៨/១៣៤ ឧបសម្ព័ន្ធរបស់មហាសន្និបាត)។ |
| ***គណៈកម្មាធិការសិទ្ធិកុមារ៖ កុមារក្នុងជម្លោះប្រដាប់អាវុធ*** (២០១៥)<br>CRC/C/OPAC/KHM/CO/1 |
| **៩.** យោងតាមស្មារតីនៃអនុសាសន៍មុនៗ (CRC/C/KHM/CO/2-3 វាក្យខណ្ឌ១៥) គណៈកម្មាធិការជំរុញរដ្ឋភាគីបង្កើតយន្តការឯករាជ្យ ដើម្បីតាមឃ្លាំមើលការអនុវត្តសិទ្ធិនានាក្រោមពិធីសារបន្ថែមនេះ និងដោះស្រាយបណ្តឹងកុមារតាមលក្ខណៈមួយឆាប់រហ័ស និងកុមារមេត្រី។ |
| ***គណៈកម្មាធិការស្តីពីសិទ្ធិកុមារ*** CRC/C/KHM/CO/2-3 (២០១១) |
| **១៥.** គណៈកម្មាធិការសូមរំលឹកឡើងវិញនូវការអំពាវនាវរបស់ខ្លួនដល់រដ្ឋភាគី(CRC/C/15/Add.128 កថាខ័ណ្ឌ១៤) ក្នុងការបង្កើតយន្តការឯករាជ្យ អនុលោមតាមគោលការណ៍ទីក្រុងប៉ារីស ដែលជាផ្នែកមួយនៃស្ថាប័នជាតិសិទ្ធិមនុស្ស រួមមានផ្នែកកុមារ ឬក្នុងការបង្កើតយន្តការដាច់ដោយឡែកមួយ។ យន្តការបែបនេះ ត្រូវតែកុមារអាចប្រើប្រាស់បាន និងធ្វើការពិនិត្យតាមដាននូវការធ្វើឱ្យសម្រេចនូវសិទ្ធិរបស់ពួកគេ និងធ្វើការដោះស្រាយពាក្យបណ្តឹងទាំងឡាយនៃការរំលោភលើសិទ្ធិរបស់ពួកគេក្នុងទម្រង់កុមារមេត្រី និងយ៉ាងឆាប់រហ័ស ព្រមទាំងផ្តល់នូវដំណោះស្រាយសម្រាប់ការរំលោភបំពានបែបនោះទៀតផង។ គណៈកម្មាធិការ សូមទាញចំណាប់អារម្មណ៍ពីរដ្ឋភាគីចំពោះសេចក្តីពន្យល់ទូទៅលេខ២ (២០០២) ស្តីពីតួនាទីនៃស្ថាប័នសិទ្ធិមនុស្សឯករាជ្យ(CRC/GC/២០០២/២)។ |
| ***គណៈកម្មាធិការប្រឆាំងទារុណកម្ម*** CAT/C/KHM/CO/2 (២០១០) |
| **២៩.** រដ្ឋភាគីគួរពន្លឿនកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួន ក្នុងការបង្កើតស្ថាប័នសិទ្ធិមនុស្សឯករាជ្យថ្នាក់ជាតិមួយ ដែលគោរពទៅតាមគោលការណ៍ទីក្រុងប៉ារីស។ គណៈកម្មាធិការស្នើឲ្យរដ្ឋភាគីធ្វើការធានាថា ស្ថាប័នសិទ្ធិមនុស្សថ្នាក់ជាតិដែលនឹងបង្កើតនេះ គឺត្រូវមានអាណត្តិការងារ ដើម្បីការពារ និងលើកកម្ពស់បទប្បញ្ញត្តិនៃអនុសញ្ញាស្តីពីសិទ្ធិមនុស្សនិងទទួលបានធនធានហិរញ្ញវត្ថុគ្រប់គ្រាន់សម្រាប់ប្រតិបត្តិការឯករាជ្យដោយខ្លួនឯង។ ទាក់ទងនឹងបញ្ហានេះ រដ្ឋភាគី គួរស្វែងរកជំនួយបច្ចេកទេសពីការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំប្រទេសកម្ពុជា។ |

| *គណៈកម្មាធិការលុបបំបាត់ការរើសអើងពូជសាសន៍*(២០១០) CERD/C/KHM/CO/8-13 |
| --- |
| ១៥. គណៈកម្មាធិការជំរុញលើកទឹកចិត្តឲ្យរដ្ឋភាគីបង្កើតស្ថាប័នសិទ្ធិមនុស្សឯករាជ្យមួយ ស្របតាមគោលការណ៍ស្តីពីឋានៈនៃស្ថាប័នជាតិសំរាប់ការលើកស្ទួយនិងការការពារសិទ្ធិមនុស្ស(គោលការណ៍ទីក្រុងប៉ារីស)(សេចក្តីសំរេចរបស់មហាសន្និបាតលេខ៤៨/១៣៤)។ អាស្រ័យហេតុនេះ គណៈកម្មាធិការផ្តល់អនុសាសន៍ថា រដ្ឋាភិបាលពិគ្រោះយោបល់ជាមួយការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា និងពិចារណាទទួលយកជំនួយផ្នែកបច្ចេកទេស ដើម្បីពង្រឹងជាថ្មីនូវកិច្ចខិតខំប្រឹងជាបន្ត ដើម្បីតាក់តែងច្បាប់មួយស្តីពីការបង្កើតស្ថាប័នជាតិសិទ្ធិមនុស្ស ស្របទាំងស្រុងទៅនឹងគោលការណ៍ទីក្រុងប៉ារីស។ |
| *គណៈកម្មាធិការសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌* E/C.12/KHM/CO/1 (២០០៩) |
| ១៣. គណៈកម្មាធិការផ្តល់ជាអនុសាសន៍យ៉ាងមុតមាំថា អនុលោមតាមសំណើរបស់នាយករដ្ឋមន្ត្រី ចុះខែកញ្ញា ឆ្នាំ ២០០៦ រដ្ឋភាគីគួរពន្លឿនកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួនក្នុងការបង្កើតស្ថាប័នសិទ្ធិមនុស្សជាតិមួយឯករាជ្យស្របតាមគោលការណ៍ទីក្រុងប៉ារីស។ គណៈកម្មាធិការស្នើឲ្យរដ្ឋភាគីធានាថា ស្ថាប័នសិទ្ធិមនុស្សជាតិមួយដែលនឹងបង្កើតឲ្យមាននេះ គួរតែមានអាណត្តិការពារ និងលើកស្ទួយបទបញ្ញត្តិនៃកតិកាសញ្ញានេះ ហើយគួរតែផ្តល់ឲ្យស្ថាប័ននេះ នូវធនធានហិរញ្ញវត្ថុគ្រប់គ្រាន់ សំរាប់ប្រតិបត្តិការរបស់ខ្លួនដោយឯករាជ្យ។ ដូច្នេះ គណៈកម្មាធិការស្នើយ៉ាងទទូចដល់រដ្ឋភាគី ឲ្យស្វែងរកការជួយឧបត្ថម្ភផ្នែកបច្ចេកទេសពីការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំនៅកម្ពុជា។ |
| *អ្នករាយការណ៍ពិសេស* |
| A/HRC/7/42, para. 101 រដ្ឋាភិបាលត្រូវបង្កើតអាជ្ញាធរឯករាជ្យមួយ ដើម្បីទទួលបណ្តឹងអំពីរដ្ឋបាលមិនល្អដោយស្ថាប័នរដ្ឋ (រួមទាំងស្ថាប័នយុត្តិធម៌)។ គណៈកម្មការសិទ្ធិមនុស្ស ដែលត្រូវបានបង្កើតឡើងយ៉ាងពេញលេញដោយឈរលើគោលការណ៍ទីក្រុងប៉ារីស គួរតែទទួលបានភារកិច្ចនេះ។<br><br>A/HRC/27/70, Para. 81(b). ពន្លឿនដំណើរការបង្កើតស្ថាប័នសិទ្ធិមនុស្សជាតិមួយឯករាជ្យ ស្របតាមទាំងស្រុងនឹងគោលការណ៍ស្តីពីឋានៈនៃស្ថាប័នជាតិសំរាប់ការលើកស្ទួយ និងការការពារសិទ្ធិមនុស្ស (គោលការណ៍ទីក្រុងប៉ារីស)។ |

## VII. អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

| |
|---|
| *អនុសាសន៍នៃការពិនិត្យជាសកលតាមកាលកំណត់* (២០១៤) |
| **១១៨.៩៧.** ធ្វើការខិតខំប្រឹងប្រែងបន្ថែមទៀត រួមទាំងផ្នែកហិរញ្ញវត្ថុ ដើម្បីធានាពីការអនុវត្តដោយរលូន និងការបញ្ចប់ដោយជោគជ័យនូវសាលាក្តីខ្មែរក្រហម ដោយសហការជាមួយសហគមន៍អន្តរជាតិ។ (ជប៉ុន)<br>**១១៨.៩៨.** ជាបញ្ហាបន្ទាន់ ត្រូវធានាថា ថវិកាពីភាគីជាតិសម្រាប់អង្គជំនុំជម្រះវិសាមញ្ញ ត្រូវបានបំពេញ។ (ណូវ៉ែលហ្សេឡង់)<br>**១១៨.៩៩.** បន្តវិធានការនានាដែលខ្លួនបានចាត់ឡើងលើកំណែទម្រង់ប្រព័ន្ធយុត្តិធម៌ ដើម្បីគាំទ្រដល់សកម្មភាពរបស់អង្គជំនុះជម្រះវិសាមញ្ញ និងបន្តសហការជាមួយអ្នករាយការណ៍ពិសេស។ (រ៉ូម៉ានី) |
| *អនុសាសន៍នៃការពិនិត្យជាសកលតាមកាលកំណត់* (២០០៩) |
| **៤៥.** សហការពេញលេញជាមួយសហប្រជាជាតិ ដើម្បីធានាថា ការអះអាងថាមានអំពើពុករលួយ និងឥទ្ធិពលនយោបាយ ត្រូវបានស៊ើបអង្កេតជាបន្ទាន់ដោយយន្តការឯករាជ្យ និងមិនលំអៀង ហើយធានាថា ករណីទាំងឡាយរកឃើញ ត្រូវបានដាក់ជូនអាជ្ញាធរដើម្បីដំណើរការក្តីផ្នែកតុលាការ។ (ប៊ែលហ្ស៊ីក) |
| *គណៈកម្មាធិការសិទ្ធិមនុស្ស* (CCPR/C/SR.3157) (២០១៥) |
| **១៩.** រដ្ឋភាគីគួរចាត់វិធានការដើម្បីការពារឯករាជ្យភាពពេញលេញនៃអ.វ.ត.ក. និងសហការជាមួយECCC ក្នុងការបំពេញមុខងាររបស់សាលាក្តី។ |
| *គណៈកម្មាធិការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ* (២០១៣)<br>CEDAW/C/KHM/CO/4-5 |
| **១៥.** គណៈកម្មាធិការទទូចឲ្យរដ្ឋភាគី៖<br>(ក). ផ្តល់សំណងប្រកបដោយប្រសិទ្ធភាព ដល់ជនរងគ្រោះដោយអំពើហិង្សាផ្តោតលើយេនឌ័រ ជាពិសេស អំពើហិង្សាផ្លូវភេទលើស្ត្រីដែលបានប្រព្រឹត្តក្នុងរបបខ្មែរក្រហម និងរៀបចំកម្មវិធីយុត្តិធម៌អន្តរកាលមិនមែនតុលាការ រាប់បញ្ចូលទាំងការផ្តល់សំណងជួសជុលគ្រប់គ្រាន់ ការគាំទ្រផ្លូវចិត្ត និងការគាំទ្រសមស្របផ្សេងទៀត និង |

| |
|---|
| (ខ). ឆ្លៀតឱកាសទាញយកផលប្រយោជន៍ ពីដំណើរការធ្វើសេចក្តីព្រាងផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី (NAPVAW) ដំណាក់កាលទី២ ដើម្បីបញ្ចូលបញ្ញត្តិនៃអនុសញ្ញា និងសេចក្តីសម្រេចលេខ ១៣២៥ របស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិឲ្យបានពេញលេញ។ |
| *អ្នករាយការណ៍ពិសេស* |
| A/HRC/7/ 42, para. 101 រដ្ឋាភិបាលត្រូវគោរពឯករាជភាពរបស់ចៅក្រម និងព្រះរាជអាជ្ញា រួមទាំងអ្នកទាំងឡាយ (ស្នាក្តី និងមន្ត្រីរដ្ឋបាល) ធ្វើការក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។<br>A/HRC/7/ 42, para. 103. ស្ថាប័នអប់រំ និងអង្គការមិនមែនរដ្ឋាភិបាល គួរធ្វើឲ្យសាធារណៈជនចូលរួមក្នុងនីតិវិធី និងការអនុវត្តន៍ ព្រមទាំងការសម្រេចក្តី និងសាលក្រមរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា តាមរយៈសិក្ខាសាលា ប្រព័ន្ធផ្សព្វផ្សាយ និងការបោះពុម្ពផ្សព្វផ្សាយ ដើម្បីបង្កើតការយល់ដឹងពីអត្ថន័យ និងសារៈសំខាន់នៃនីតិរដ្ឋ។ |

## VIII. **ការប្រតិបត្តិច្បាប់**

### *ក. ទារុណកម្ម ការប្រព្រឹត្តិមិនគប្បី និងការប្រតិបត្តិច្បាប់*

*អនុសាសន៍នៃការពិនិត្យជាសកលតាមកាលកំណត់* (២០១៨)

**១១៨.៦៦.** ចាត់វិធានការចាំបាច់នានា ដើម្បីធានាថា កុមារ និងអនីតិជននៅក្នុងមជ្ឈមណ្ឌលស្តារនីតិសម្បទា និងមជ្ឈមណ្ឌលយុវជន ទោះយ៉ាងណាក៏ដោយ មិនត្រូវដាក់ឲ្យទៅជាកន្លែងធ្វើទារុណកម្ម ឬការប្រព្រឹត្តមិនគប្បីឡើយ ស្របតាមបទប្បញ្ញត្តិនៃអនុសញ្ញាស្តីពីសិទ្ធិកុមារ។ (បែលហ្សិក)

**១១៨.៩៦.** ពង្រឹងអាជ្ញាធរអនុវត្តន៍ច្បាប់។ (អ៊ីរ៉ាក់)

*អនុសាសន៍នៃការពិនិត្យជាសកលតាមកាលកំណត់* (២០០៩)

**២៧.** ធ្វើការស៊ើបអង្កេតដោយឯករាជ្យ និងមិនលំអៀង ទៅលើគ្រប់ការអះអាងអំពីការធ្វើទារុណកម្ម និងការធ្វើទុក្ខបុកម្នេញផ្សេងៗ ហើយនាំយកជនល្មើសមកផ្តន្ទាទោសតាមច្បាប់។ (ដាណឺម៉ាក)

**២៨.** ចាត់វិធានការជាក់ស្តែងថែមទៀត ដើម្បីដោះស្រាយករណីធ្វើទារុណកម្មនៅក្នុងពន្ធនាគារ ជាពិសេស ដើម្បីធានាថា ការស៊ើបអង្កេត ត្រូវបានធ្វើឡើងដោយឯករាជ្យ និងមិនលំអៀង ទៅលើករណីទាំងឡាយណាដែលបានអះអាងថាមានការធ្វើបាប ឬទារុណកម្ម។ សូមផ្តន្ទាទោសមន្ត្រីទាំងឡាយណាដែលទទួលខុសត្រូវក្នុងកាធ្វើទារុណកម្ម ឬធ្វើបាប និងសូមផ្តល់សិទ្ធិទទួលបានដំណោះស្រាយប្រកបដោយប្រសិទ្ធភាព ជូនជនរងគ្រោះដោយអំពើទារុណកម្ម។ (សាធារណរដ្ឋឆែក)

*គណៈកម្មាធិការសិទ្ធិមនុស្ស* (CCPR/C/SR.3157) (២០១៥)

**១២.** រដ្ឋភាគីគួរស៊ើបអង្កេតរាល់ការចោទប្រកាន់ទាក់ទងនឹងការប្រើកម្លាំងហួសហេតុ ជាពិសេស ការប្រើកម្លាំងប្រល័យដោយនគរបាល និងយោធា ហើយធានាថា ជនដៃដល់ត្រូវបានកាត់ទោស និងផ្តល់សំណងគ្រប់គ្រាន់ដល់ជនរងគ្រោះ។ ម្យ៉ាងវិញទៀត រដ្ឋភាគីគួរបង្កើនកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួន ដើម្បីផ្តល់ការបណ្តុះបណ្តាលជាប្រព័ន្ធដល់កម្លាំងសន្តិសុខទាំងអស់ រួមទាំង កំលាំងសន្តិសុខ សណ្តាប់ធ្នាប់ខណ្ឌផងដែរ អំពីការប្រើកម្លាំង ជាពិសេស ក្នុងបរិបទនៃការធ្វើបាតុកម្ម ដោយគិតគូរឲ្យបានត្រឹមត្រូវអំពីគោលការណ៍របស់អង្គការសហប្រជាជាតិស្តីពីការប្រើប្រាស់កម្លាំង និងអាវុធ ដោយមន្ត្រីប្រតិបត្តិច្បាប់។

**១៣.** [...] រដ្ឋភាគីគួរធានាផងដែរថា ជនដៃដល់នៃបទល្មើសទាំងនេះត្រូវបានកាត់ទោស ហើយថាជនរងគ្រោះ ត្រូវបានផ្តល់សំណងគ្រប់គ្រាន់។ រដ្ឋភាគីគួរចាត់វិធានការចាំបាច់ ដើម្បីធានាថា ចម្លើយសារភាពដែលបានមកពីការធ្វើទារុណកម្ម ឬការប្រព្រឹត្តមិនគប្បី មិនអាចយកជាការបានឡើយនៅក្នុងតុលាការ ក្នុងគ្រប់ករណី ស្របតាមច្បាប់ជាតិរបស់ខ្លួន និងមាត្រា១៤ នៃកតិកាសញ្ញានេះ។ [...]

**១៥.** ដោយចាត់ទុកជាបញ្ហាបន្ទាន់ រដ្ឋភាគីគួរចាត់វិធានការជាបន្ទាន់ និងមានប្រសិទ្ធភាពដើម្បីទប់ស្កាត់អំពើទារុណកម្ម និងប្រព្រឹត្តកម្មមិនគប្បីមកលើខ្លួន រាប់ទាំងអំពើហិង្សាផ្លូវភេទ នៅពេលកំពុងឃុំខ្លួន/ឃាត់ខ្លួននៅទូទាំងប្រទេស តាមរយៈការប្រកាសពីគោលនយោបាយដែលនឹងបង្កើតឱ្យមានលទ្ធផលដែលអាចវាស់វែងបាន ក្នុងការលប់បំបាត់អំពើទារុណកម្មនិងការប្រព្រឹត្តិមិនគប្បីមកលើខ្លួន ប្រព្រឹត្តិឡើងដោយមន្ត្រីរាជការ និងតាមរយៈការឃ្លាំមើល និង/ឬការកត់ត្រានូវដំណើរការសាកសួរចម្លើយរបស់នគរបាល។

រដ្ឋភាគីគួរធានាផងដែរថា ការចោទប្រកាន់ពីបទធ្វើទារុណកម្ម និងប្រព្រឹត្តកម្មមិនគប្បីមកលើខ្លួនទាំងអស់ រួមទាំងអំពើហិង្សាផ្លូវភេទនៅពេលកំពុងឃុំខ្លួន/ឃាត់ខ្លួន ត្រូវធ្វើការស៊ើបអង្កេតជាបន្ទាន់ ប្រកបដោយប្រសិទ្ធភាព និងមិនលម្អៀង ហើយថាជនល្មើសត្រូវតែបានចោទប្រកាន់ និងផ្តន្ទាទោសឲ្យស្របទៅតាមទម្ងន់នៃអំពើល្មើស តាមលក្ខខណ្ឌតម្រូវនៅក្នុងមាត្រា៤ នៃអនុសញ្ញា។ រដ្ឋភាគីគួរអនុម័តផែនការកំណត់ទោសសម្រាប់ផ្តន្ទាទោសពីបទធ្វើទារុណកម្ម និងប្រព្រឹត្តកម្មមិនគប្បីមកលើខ្លួន ប្រព្រឹត្តឡើងដោយមន្ត្រីរដ្ឋាភិបាល ដើម្បីធានាថាមានការផ្តន្ទាទោសធួនល្មមចំពោះជនដែលត្រូវបានរកឃើញថា បានប្រព្រឹត្តអំពើបែបនេះ។

រដ្ឋភាគីគួរធានាថា ច្បាប់ជាតិរបស់ខ្លួន មានបញ្ចូលបទប្បញ្ញត្តិដែលហាមឃាត់ដាច់ខាតមិនឲ្យប្រើកាលៈទេសៈពិសេសណាមួយ មកធ្វើជាលេសក្នុងការធ្វើទារុណកម្មឡើយ។

**១៦.** រដ្ឋភាគីគួរពង្រឹងវិធានការរបស់ខ្លួន ដើម្បីធានាឲ្យមានការស៊ើបអង្កេតជាបន្ទាន់ ប្រកបដោយប្រសិទ្ធភាព និងមិនលម្អៀងលើការចោទប្រកាន់ពីបទធ្វើទារុណកម្ម និងប្រព្រឹត្តកម្មមិនគប្បីមកលើខ្លួនទាំងអស់លើទណ្ឌិត និងពិរុទ្ធជន រួមទាំងនៅក្នុងស្ថានីយ៍នគរបាល និងដើម្បីយកមន្ត្រីប្រតិបត្តិច្បាប់ និងមន្ត្រីពន្ធនាគារដែលបានប្រព្រឹត្ត និងបញ្ជា ឬបណ្តែតបណ្តោយឲ្យប្រព្រឹត្តអំពើបែបនេះមកផ្តន្ទាទោសតាមផ្លូវច្បាប់។ រដ្ឋភាគីគួរបង្កើតយន្តការបណ្តឹងតវ៉ាលើការប្រតិបត្តិច្បាប់ដោយឯករាជ្យ និងធានាថា ស្ថាប័នស៊ីវិលសម្រាប់ឃ្លាំមើលដោយឯករាជ្យ ធ្វើការស៊ើបអង្កេតលើការប្តឹងតវ៉ាពីបទធ្វើទារុណកម្ម និងប្រព្រឹត្តកម្មមិនគប្បីមកលើខ្លួនពីសំណាក់មន្ត្រីប្រតិបត្តិច្បាប់។

ទាក់ទងនឹងករណីនៃការធ្វើទារុណកម្ម និងប្រព្រឹត្តកម្មមិនគប្បីមកលើខ្លួនតាមការមើលឃើញបឋម ជនសង្ស័យត្រូវតែព្យួរការងារ ឬតែងតាំងការងារជាថ្មីក្នុងអំឡុងពេលធ្វើការស៊ើបអង្កេត ដើម្បីចៀសវាងប្រការគ្រោះថ្នាក់ណាមួយដែលជនសង្ស័យនោះអាចបង្កឲ្យមានការរាំងស្ទះដល់ការស៊ើបអង្កេត ឬបន្តធ្វើសកម្មភាពដែលមិនអនុញ្ញាតដូចដែលបានរាយការណ៍ ដែលរំលោភបំពានទៅលើអនុសញ្ញា។

លើសពីនេះទៅទៀត រដ្ឋភាគីគួរបង្កើតកម្មវិធីការពារជនរងគ្រោះ និងសាក្សី ដើម្បីជួយធានាឲ្យមានការរក្សាការសម្ងាត់ និងដើម្បីការពារអ្នកដែលចេញមុខមករាយការណ៍ ឬប្តឹងតវ៉ាទាក់ទងនឹងអំពើទារុណកម្ម ក៏ដូចជាធានាឲ្យមានការបែងចែកមូលនិធិគ្រប់គ្រាន់ សម្រាប់ការប្រព្រឹត្តទៅរបស់ខ្លួនឲ្យមានប្រសិទ្ធភាព។

**២៥.** ដោយមានសហប្រតិបត្តិការជាមួយអង្គការមិនមែនរដ្ឋាភិបាល រដ្ឋភាគីគួរបង្កើត និងពង្រឹងកម្មវិធីអប់រំបន្ថែម ដើម្បីធានាថា មន្ត្រីទាំងអស់ មានមន្ត្រីប្រតិបត្តិច្បាប់ និងមន្ត្រីពន្ធនាគារផង ត្រូវយល់ដឹងជ្រៅជ្រះពីបទប្បញ្ញត្តិនៃ

អនុសញ្ញា ហើយនឹងធ្វើការស៊ើបអង្កេតដោយគ្មានអនុគ្រោះ នៅពេលមានរបាយការណ៍ស្តីពីការរំលោភបំពាន រួមមានករណីអំពើហិង្សាផ្លូវភេទជាដើម ដើម្បីឲ្យជនល្មើសទាំងនោះទទួលការកាត់ទោសតាមផ្លូវច្បាប់។ បន្ថែមពីនេះទៀត នគរបាល និងមន្ត្រីពាក់ព័ន្ធផ្សេងៗទៀតគួរទទួលបានការបណ្តុះបណ្តាលក្នុងការសម្ភាសជាមួយសាក្សី ការការពារសាក្សី វិធីសាស្ត្រនីតិវេជ្ជវិទ្យា និងការប្រមូលភស្តុតាង ហើយបុគ្គលិកជាប់ពាក់ព័ន្ធទាំងអស់គួរទទួលបានការបណ្តុះបណ្តាលជាក់លាក់ស្តីពីរបៀបកំណត់សញ្ញានៃការធ្វើទារុណកម្ម និងប្រព្រឹត្តកម្មមិនគប្បីមកលើខ្លួន រួមមាន មន្ត្រីដែលនឹងធ្វើការស៊ើបអង្កេត និងចងក្រងឯកសារទាក់ទងនឹងករណីទាំងនេះ។ ការបណ្តុះបណ្តាលនេះ គួរមានបញ្ចូលការប្រើប្រាស់សៀវភៅក្បួនស្តីពីការស៊ើបអង្កេត និងការចងក្រងឯកសារប្រកបដោយប្រសិទ្ធភាព ទាក់ទងនឹងទារុណកម្ម និងប្រព្រឹត្តកម្មមិនគប្បីមកលើខ្លួន ឬទណ្ឌកម្មឯទៀតដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប(ពិធីសារIstanbul)។ បន្ថែមពីនេះទៀត រដ្ឋភាគីគួរធានាថា ក្រមសីលធម៌វិជ្ជាជីវៈដែលពាក់ព័ន្ធ និងសារៈសំខាន់ក្នុងការគោរពក្រមសីលធម៌ទាំងនេះ ត្រូវតែធ្វើឲ្យទៅជាផ្នែកចាំបាច់មួយសំរាប់សកម្មភាពបណ្តុះបណ្តាល។ បន្ថែមពីនេះ រដ្ឋភាគីគួរវាយតម្លៃពីប្រសិទ្ធភាព និងផលប៉ះពាល់នៃកម្មវិធីបណ្តុះបណ្តាល/កម្មវិធីអប់រំ។

**២៦**. គណៈកម្មាធិការលើកឡើងថា រដ្ឋភាគីគឺជាអ្នកទទួលខុសត្រូវលើការផ្តល់សំណងដល់ប្រជាពលរដ្ឋរងគ្រោះពីការធ្វើទារុណកម្ម និងក្រុមគ្រួសាររបស់ពួកគេ។ ដើម្បីសម្រេចគោលបំណងនេះ រដ្ឋភាគីគួរបង្កើនកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួន ដើម្បីឲ្យប្រជាពលរដ្ឋរងគ្រោះពីការធ្វើទារុណកម្ម ទទួលបានសំណង រួមមានប្រាក់សំណងដែលត្រឹមត្រូវ និងគ្រប់គ្រាន់ និងការស្តារនីតិសម្បទាឲ្យបានពេញលេញ តាមដែលអាចធ្វើបាន។

រដ្ឋភាគីគួរបង្កើនកិច្ចខិតខំប្រឹងប្រែងបន្ថែមទៀតដើម្បីកែលំអលទ្ធភាពទទួលបានសេវាខាងវេជ្ជសាស្ត្រ និងសេវាខាងផ្លូវចិត្តសម្រាប់ប្រជាពលរដ្ឋរងគ្រោះពីការធ្វើទារុណកម្ម ជាពិសេស ក្នុងអំឡុងពេល និងបន្ទាប់ពីការជាប់ឃុំក្នុងពន្ធនាគារ ហើយធានាថា ជនរងគ្រោះទាំងនោះទទួលបានសេវាស្តារនីតិសម្បទាដែលមានប្រសិទ្ធភាព និងបន្ទាន់ ដើម្បីលើកកម្ពស់ការយល់ដឹងពីផលវិបាកនៃទារុណកម្ម និងតម្រូវការការស្តារនីតិសម្បទាសម្រាប់ជនរងគ្រោះពីការធ្វើទារុណកម្ម ក្នុងចំណោមអ្នកជំនាញខាងសុខភាព និងអ្នកជំនាញខាងសុខុមាលភាពសង្គម និងដើម្បីបង្កើនការបញ្ជូនជនរងគ្រោះទាំងនេះពីប្រព័ន្ធថែទាំសុខភាពកម្រិតបឋម ទៅកាន់សេវាឯកទេសជំនួសវិញ និងដើម្បីបង្កើនសមត្ថភាពទីភ្នាក់ងារសុខភាពជាតិឲ្យផ្តល់សេវាស្តារនីតិសម្បទាឯកទេសផ្អែកលើបទដ្ឋានអន្តរជាតិបែបអនុសាសន៍ ដល់ប្រជាពលរដ្ឋរងគ្រោះពីការធ្វើទារុណកម្ម រួមទាំងសមាជិកក្រុមគ្រួសាររបស់ពួកគេ ជាពិសេស ក្នុងវិស័យសុខភាពផ្លូវចិត្ត។

## *ខ. លក្ខខណ្ឌនៅពន្ធនាគារ និងការឃុំខ្លួន*

### *អនុសាសន៍នៃការពិនិត្យជាសកលតាមកាលកំណត់* (២០១៤)

**១១៨.៦០**. ពិចារណាចាត់វិធានការចាំបាច់ ដើម្បីកែលម្អស្ថានភាពពន្ធនាគារបន្ថែមទៀត។ (ឥណ្ឌា)

**១១៨.៦១**. ចាត់វិធានការនានា ដើម្បីជៀសវាងការប្រើកម្លាំងហួសហេតុ និងធានាថា លក្ខខណ្ឌនៃការចាប់ខ្លួន និងការឃុំខ្លួនបណ្តោះអាសន្ន ស្របតាមស្តង់ដារអន្តរជាតិ។ (បែលហ្ស៊ិក)

| |
|---|
| *អនុសាសន៍នៃការពិនិត្យជាសកលតាមកាលកំណត់* (២០០៩) |
| **២៩.** កែតម្រូវទីកន្លែងឃុំឃាំង និងពន្ធនាគារ ក៏ដូចជាបទដ្ឋាននៃការគ្រប់គ្រង ដើម្បីឲ្យមានការយល់ដឹងពីយ៉េនឌ័រ និងធានាឲ្យមានការការពារដ៏មានប្រសិទ្ធភាព ដល់សុវត្ថិភាពបុគ្គលរបស់អ្នកជាប់ឃុំឃាំង និងអ្នកទោសទាំងអស់។ (សាធារណៈរដ្ឋឆែក) |
| *គណៈកម្មាធិការសិទ្ធិមនុស្ស* (CCPR/C/SR.3157) (២០១៥) |
| **១៤.** រដ្ឋភាគីគួរអនុម័តវិធានការមានប្រសិទ្ធភាព ដើម្បីកាត់បន្ថយចំនួនអ្នកទោសដាក់ច្រើនលើសចំណុះ នៅក្នុងមណ្ឌលឃុំឃាំង និងធានាលក្ខខណ្ឌនៃការឃុំខ្លួន ដែលគោរពសេចក្តីថ្លៃថ្នូររបស់អ្នកទោស ស្របតាមមាត្រា១០ នៃកតិកាសញ្ញានេះ។ រដ្ឋភាគីគួរធានាផងដែរឲ្យមានការស៊ើបអង្កេតឆាប់រហ័ស និងឯករាជ្យ និងផ្តន្ទាទោសជាយថាហេតុចំពោះមន្ត្រីរដ្ឋដែលទទួលខុសត្រូវចំពោះអំពើពុករលួយដាក់ពន្ធនាគារ។ ម្យ៉ាងវិញទៀត រដ្ឋភាគីគួរធានាថា ចុងចោទត្រូវបានឃុំខ្លួនរង់ចាំសវនាការ តែក្នុងករណីចាំបាច់បំផុតប៉ុណ្ណោះ ហើយអនុវត្តជម្រើសផ្សេងៗជំនួសឲ្យការដាក់ពន្ធនាគារ។ គួរតែមានការចាត់វិធានការបន្ទាន់ ដើម្បីធានាទំនាក់ទំនង ឬការបញ្ជូនសាលក្រមស្ថាពររបស់តុលាការទៅអាជ្ញាធរពន្ធនាគារ និងសាមីជនជាប់ឃុំ។<br><br>**១៦.** រដ្ឋភាគីគួរតែចាត់វិធានការចាំបាច់ទាំងអស់ដើម្បីបញ្ឈប់នូវការចាប់ខ្លួន និងការឃុំខ្លួនដោយបំពានលើជនគ្មានផ្ទះសម្បែង អ្នកសុំទាន អ្នកប្រើប្រាស់គ្រឿងញៀន កុមារតាមចិញ្ចើមផ្លូវ និងអ្នករកស៊ីផ្លូវភេទ។ រាល់ករណីនៃការធ្វើទារុណកម្ម និងការធ្វើបាបទាំងអស់ គួរតែស៊ើបអង្កេត ហើយប្រសិនបើមានភ័ស្តុតាងពិតប្រាកដ បង្ហាញពីករណីទាំងនេះ គួរតែផ្តន្ទាទោស និងដាក់ទោសទណ្ឌ។<br><br>**១៧.** រដ្ឋភាគីគួរតែធានាថា គ្រប់ទិដ្ឋភាពច្បាប់ និងទន្លាប់អនុវត្តរបស់ខ្លួនលើការឃុំខ្លួនបណ្តោះអាសន្ន ត្រូវមានសុខដុមនីយកម្មជាមួយនឹងលក្ខខណ្ឌតម្រូវនៃមាត្រា៩ និង១៤នៃកតិកាសញ្ញា ដូចមានចែងក្នុងសេចក្តីពន្យល់ទូទៅលេខ៣២(២០០៧)ស្តីពីសិទ្ធិស្មើភាពគ្នានៅចំពោះមុខតុលាការនិងសាលាជម្រះក្តី និងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ និងសេចក្តីពន្យល់ទូទៅលេខ៣៥ (២០១៤) ស្តីពីសេរីភាព និងសន្តិសុខរបស់មនុស្ស រាប់ទាំងតាមរយៈការអនុញ្ញាតឲ្យជនជាប់ឃុំ ដែលជាប់ចោទពីបទល្មើសព្រហ្មទណ្ឌ អាចទទួលបានភ្លាមៗនូវសិទ្ធិទទួលបានជំនួយពីមេធាវី ចាប់ពីដំណើរការដំបូងនៃការដកហូតសេរីភាពរបស់ខ្លួន។ ការទទួលបានកិច្ចពិគ្រោះយោបល់គួរតែត្រូវផ្តល់ឲ្យនៅគ្រប់ដំណាក់កាលនៃនីតិវិធីព្រហ្មទណ្ឌ។ |
| *គណៈកម្មាធិការស្តីពីសិទ្ធិកុមារ* CRC/C/KHM/CO/2-3 (២០១១) |
| **៣៩.** គណៈកម្មាធិការសូមទទូចឱ្យរដ្ឋភាគី៖<br>ក). ធ្វើការធានាថា កុមារនៅក្នុងទម្រង់ណាក៏ដោយ នៃការឃុំខ្លួនតាមទំនើងចិត្ត ទោះបីជានៅក្នុងមណ្ឌលព្យាបាលនិងស្តារគ្រឿងញៀនក្តីឬមណ្ឌលស្តារនីតិសម្បទាសង្គមកិច្ចក្តី ឬប្រភេទផ្សេងទៀតនៃមណ្ឌលណាមួយដែលគ្រប់គ្រងដោយរដ្ឋក្តី ត្រូវធ្វើការដោះលែងកុមារដោយមិនមានការបង្អែរបង្អង់ឡើយ។ |

ខ). ធានាឱ្យមានការស៊ើបអង្កេតភ្លាមៗចំពោះការចោទប្រកាន់អំពីការប្រព្រឹត្តមិនគប្បី និងការធ្វើទារុណកម្មកុមារនៅក្នុងមណ្ឌលទាំងនោះ និងធានាថា ជនល្មើសត្រូវបាននាំខ្លួនមកតុលាការ និង

គ). បង្កើតយន្តការឯករាជ្យ ដែលគិតគូរអំពីកុមារ សម្រាប់ទទួលពាក្យបណ្ដឹងប្រឆាំងនឹងមន្ត្រីអនុវត្តច្បាប់ និងដើម្បីផ្ដល់ដល់ជនរងគ្រោះនូវដំណោះស្រាយ ដូចដែលបានលើកជាអនុសាសន៍ដោយគណៈកម្មាធិការប្រឆាំងការធ្វើទារុណកម្ម (CAT/C/KHM/CO/២ កថាខណ្ឌ២០)។

៥៦. គណៈកម្មាធិការសូមក្រើនរំលឹកនូវអនុសាសន៍របស់ខ្លួនឡើងវិញចំពោះរដ្ឋភាគី [...]

ខ). ធានាថា យុវវ័យ ការបន្សាបគ្រឿងញៀន ការព្យាបាល ការស្តារនីតិសម្បទា និងការធ្វើអន្តរាគមន៍ សមាហរណកម្មកុមារដែលប្រើប្រាស់គ្រឿងញៀន ត្រូវអនុលោមតាមបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ ហើយក្នុងគោលបំណងនេះ ត្រូវធ្វើការអភិវឌ្ឍកម្មវិធីព្យាបាល និងស្តារគ្រឿងញៀននៅថ្នាក់សហគមន៍។

៦៤. គណៈកម្មាធិការសូមទទូចឱ្យរដ្ឋភាគីធ្វើការធានានូវសិទ្ធិរបស់កុមារ និងម្ដាយរបស់កុមារដែលរស់នៅក្នុងពន្ធនាគារ ត្រូវបានគោរព។ គណៈកម្មាធិការសូមទទូចឱ្យរដ្ឋភាគី ចាត់វិធានការជាបន្ទាន់ ដើម្បីធានាថា ម្ដាយ និងកូនរបស់ពួកគេ ត្រូវបានផ្ដល់នូវម្ហូបអាហារ ព្រមទាំងសេវាសុខភាព ហើយគណៈកម្មាធិការសូមទទូចថា កុមារត្រូវមានសិទ្ធិទទួលបានការអប់រំ និងសកម្មភាពកំសាន្តសប្បាយទាំងឡាយ។ គណៈកម្មាធិការ ក៏សូមទទូចឱ្យរដ្ឋភាគីចាត់រាល់វិធានការដ៏ចាំបាច់ ដើម្បីការពារកុមារពីរាល់ទម្រង់នៃការរំលោភបំពាន និងធ្វើការស៊ើបអង្កេតនូវរាល់របាយការណ៍អំពីការរំលោភបំពានកុមារដោយមន្ត្រីពន្ធនាគារ និងដោយអ្នកជាប់ពន្ធនាគារផ្សេងទៀត ព្រមទាំងចាត់វិធានការដាក់វិន័យដ៏សមស្រប ប្រឆាំងនឹងជនល្មើសដែលបានរំលោភបំពានលើកុមារ។

## *គណៈកម្មាធិការប្រឆាំងទារុណកម្ម* CAT/C/KHM/CO/2 (២០១០)

១៩. រដ្ឋភាគីគួរពង្រីកកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួនដើម្បីកាត់បន្ថយភាពចង្អៀតណែនហួសហេតុឲ្យមានប្រសិទ្ធភាពនៅទីកន្លែងទាំងឡាយដែលមនុស្សត្រូវបានដកហូតសេរីភាព រួមមានស្ថានីយ៍នគរបាល និងពន្ធនាគារ ហើយដើម្បីកែលំអលក្ខខណ្ឌឃុំខ្លួននៅតាមទីកន្លែងទាំងនេះ មានដូចជា អនាម័យ និងការផ្គត់ផ្គង់ម្ហូបអាហារជាដើម។ ដើម្បីសម្រេចបានគោលបំណងនេះ គណៈកម្មាធិការសូមលើកជាអនុសាសន៍ថារដ្ឋភាគីត្រូវអនុវត្តវិធានការផ្សេងៗជំនួសឲ្យការដាក់ពន្ធនាគារ និងធានាឲ្យមានការបែងចែកថវិកាគ្រប់គ្រាន់ ដើម្បីអភិវឌ្ឍ និងជួសជុលហេដ្ឋារចនាសម្ព័ន្ធពន្ធនាគារ និងទីកន្លែងឃុំខ្លួនផ្សេងៗទៀត។ លើសពីនេះ រដ្ឋភាគីគួរបង្កើត និងកំណត់មុខងារ និងតួនាទីរបស់ "គណៈកម្មាធិការស្វ័យគ្រប់គ្រងពន្ធនាគារ" ឲ្យបានច្បាស់លាស់ និងធានាថា មានការស៊ើបអង្កេតលើករណីរំលោភបំពាន និងប្រព្រឹត្តកម្មមិនគប្បីមកលើខ្លួនពីសំណាក់អង្គភាពនេះ ហើយជនល្មើសត្រូវតែបានដាក់ទណ្ឌកម្ម។ បន្ថែមពីនេះ មន្ត្រីអគ្គនាយកដ្ឋានពន្ធនាគារដែលមិនអើពើ ឬបណ្តែតបណ្តោយឲ្យមានការប្រព្រឹត្តអំពើទាំងនេះ ត្រូវទទួលខុសត្រូវចំពោះទង្វើរបស់ខ្លួន ដោយជនសង្ស័យត្រូវផ្អាកពីការងារ ឬចាត់តាំងការងារសាជាថ្មីក្នុងអំឡុងពេលដំណើរការស៊ើបអង្កេត។ គណៈកម្មាធិការក៏ស្នើសុំផងដែរឲ្យផ្តល់ព័ត៌មានថ្មីៗ ស្តីពីកាលៈទេសៈទាំងឡាយជុំវិញមរណភាពរបស់ជនជាប់ឃុំឈ្មោះគង់ ឡា, ហេង ទូច និងម៉ៅ សុខ ព្រមទាំងព័ត៌មានស្តីពីការស៊ើបអង្កេត ការចោទប្រកាន់ និងការផ្តន្ទាទោសដែលកើតចេញពីករណីទាំងនេះ។

រដ្ឋភាគីគួរពិនិត្យឡើងវិញផងដែរនូវគោលនយោបាយ និងនីតិវិធីទាំងឡាយស្តីពីការឃុំខ្លួន/ឃាត់ខ្លួន និងការប្រព្រឹត្តមកលើជនជាប់ឃុំ រួមមាននៅស្ថានីយ៍នគរបាល គួរធានាថា ជនជាប់ឃុំជាស្រ្តី និងបុរស ត្រូវដាក់ឲ្យនៅដាច់ដោយឡែកពីគ្នា ហើយជនជាប់ឃុំជាស្រ្តីត្រូវតែបានយាមការពារដោយមន្រ្តីដែលមានភេទដូចគ្នា ត្រូវឃ្លាំពិនិត្យមើល និងចងក្រងឯកសារស្តីពីឧប្បត្តិហេតុនៃអំពើហិង្សាផ្លូវភេទក្នុងពេលឃុំខ្លួន/ឃាត់ខ្លួន និងផ្តល់ទិន្នន័យស្តីពីបញ្ហាទាំងនេះ ដោយបែងចែកទៅតាមសូចនាករដែលពាក់ព័ន្ធជូនគណៈកម្មាធិការ។ គណៈកម្មាធិការសូមលើកអនុសាសន៍ផងដែរថា រដ្ឋភាគីត្រូវធ្វើការពិចារណាលើការចងក្រងព័ត៌មានពិស្តារស្តីពីស្ថិតិពន្ធនាគារដែលអាចជឿជាក់បាន និងមានភាពត្រឹមត្រូវ រួមទាំងព័ត៌មានលំអិតស្តីពីរយៈពេលដាក់ទោស ប្រភេទនៃបទល្មើស និងអាយុរបស់ជនល្មើស ដើម្បីជួយផ្តល់ព័ត៌មានពីសេចក្តីសម្រេចលើគោលនយោបាយយុត្តិធម៌ព្រហ្មទណ្ឌ។

## *គណៈកម្មាធិការសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌* E/C.12/KHM/CO/1 (២០០៩)

**៣៣.** គណៈកម្មាធិការផ្តល់ជាអនុសាសន៍យ៉ាងខ្លាំងថា រដ្ឋភាគីពិចារណាអនុម័តច្បាប់ស្តីពីសុខភាពផ្លូវចិត្ត និងអនុម័តផែនការយុទ្ធសាស្រ្តស្តីពីសុខភាពផ្លូវចិត្ត ដែលបញ្ចូលភាពជាដៃគូជាមួយអង្គការមិនមែនរដ្ឋាភិបាល និងស្ថាប័នដៃគូក្នុងវិស័យឯកជននានា។ គណៈកម្មាធិការផ្តល់ជាអនុសាសន៍ផងដែរថា រដ្ឋភាគីធានាថាបុគ្គលទាំងឡាយដែលមានបញ្ហាសុខភាពផ្លូវចិត្ត មិនត្រូវបានបញ្ជូនទៅដាក់ពន្ធនាគារឡើយ។

## *អ្នករាយការណ៍ពិសេស*

A/HRC/33/62, Para. 61(q). ដោយឈរលើមូលដ្ឋាននៃអនុសាសន៍ដែលដាក់ស្នើដោយអ្នកកាន់អាណត្តិមុនៗ (សូមមើលA/HRC/18/46) ចាប់ផ្តើមកម្មវិធីពង្រឹងឯករាជ្យភាពតុលាការនៅគ្រប់កំរិត និងញែកឱ្យដាច់ពីគ្នានូវតួនាទីនីតិប្រតិបត្តិនៅក្នុងដំណើរការរបស់តុលាការ និងនៅក្នុងកម្មវិធីបណ្តុះបណ្តាល និងដាក់វិន័យសមាជិកណាមួយនៃតុលាការ។

A/HRC/33/62, Para. 61(t). បង្កើនកិច្ចខិតខំប្រឹងប្រែងធ្វើឱ្យនៅតិចបំផុតនៃការឃុំខ្លួនបណ្តោះអាសន្ន ជាអាទិ៍ដើម្បីកាត់បន្ថយភាពចង្អៀតណែននៅក្នុងពន្ធនាគារ។

## IX. **ការអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គម**

### *ក. ការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម/គោលដៅអភិវឌ្ឍន៍សហស្សវត្ស*

| *អនុសាសន៍នៃការពិនិត្យជាសកលតាមកាលកំណត់ (២០១៤)* |
|---|
| **១១៨.១៣៩.** បន្តកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួន ដើម្បីរក្សាស្ថិរភាពសង្គម និងលើកកម្ពស់ការអភិវឌ្ឍសេដ្ឋកិច្ច និងធ្វើការខិតខំប្រឹងប្រែងល្អៗដើម្បីអភិវឌ្ឍន៍ និងកែលំអជីវភាពរបស់ប្រជាជន។ (ចិន)<br><br>**១១៨.១៤៤.** បន្តធ្វើការទៅលើការឆ្លើយតបនឹងគោលដៅរបស់ខ្លួន នៅក្នុងវិស័យអភិវឌ្ឍន៍ ដូចបានដាក់ចេញនៅក្នុងសេចក្តីប្រកាសសហស្សវត្ស។ (សហព័ន្ធរុស្ស៊ី)<br><br>**១១៨.១៤៥.** បន្តបង្កើនកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួន ដើម្បីធានាពីការទទួលបានសិទ្ធិសង្គម សេដ្ឋកិច្ចដោយប្រជាពលរដ្ឋ។ (សហព័ន្ធរុស្ស៊ី)<br><br>**១១៨.១៥៨.** ជំរុញសកម្មភាព និងយុទ្ធសាស្ត្រនានា សំដៅសម្រេចបានគោលដៅអភិវឌ្ឍន៍សហស្សវត្សទាំងអស់ ជាពិសេស គោលដៅទាំងឡាយណាដែលទាក់ទងនឹងសិទ្ធិទទួលបានការអប់រំ និងការថែទាំសុខភាព និងសិទ្ធិរបស់ក្រុមងាយរងគ្រោះ។ (វៀតណាម) |
| *អនុសាសន៍នៃការពិនិត្យជាសកលតាមកាលកំណត់ (២០០៩)* |
| **១១.** បង្កើនកិច្ចខិតខំប្រឹងប្រែង និងធនធានឲ្យបានទ្វេដងដើម្បីឈានទៅដល់គោលដៅកំណត់ដោយគោលដៅអភិវឌ្ឍន៍សហវត្សអង្គការសហប្រជាជាតិ សំរាប់ធ្វើឲ្យប្រសើរដល់សិទ្ធិនយោបាយ សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌របស់ប្រជាជនកម្ពុជា។ (ម៉ាឡេស៊ី)<br><br>**១២.** បន្តកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួនដើម្បីប្រយុទ្ធប្រឆាំងនឹងភាពក្រីក្រ ធានាឲ្យមានការអភិវឌ្ឍន៍ប្រកបដោយនិរន្តភាព ធ្វើឲ្យប្រសើរដល់សិទ្ធិទទួលបានការគាំពារផ្នែកសុខភាព និងការអប់រំ ព្រមទាំងសម្រេចឲ្យបាននូវគោលដៅអភិវឌ្ឍន៍សហសវត្ស។ (សហព័ន្ធរុស្ស៊ី)<br><br>**៦៩.** ពង្រីកកម្មវិធីផ្សេងៗ ក្នុងគោលបំណងលុបបំបាត់ភាពក្រីក្រ និងធ្វើឲ្យប្រសើរឡើងដល់សូចនាករសេដ្ឋកិច្ចសង្គម។ (អាល់ហ្សេរី)<br><br>**៨៩.** បន្តពង្រឹងការអភិវឌ្ឍន៍សេដ្ឋកិច្ច នយោបាយ និងសង្គមកិច្ច ដោយមានការចូលរួមពេញលេញពីប្រជាជនរបស់ខ្លួន។ (ឡាវ) |

| |
|---|
| ***គណៈកម្មាធិការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ*** (២០១៣)<br>CEDAW/C/KHM/CO/4-5 |
| ៤៩. គណៈកម្មាធិការអំពាវនាវឲ្យរដ្ឋភាគីបញ្ចូលទស្សនៈយេនឌ័រ ស្របតាមបញ្ញត្តិនៃអនុសញ្ញា ក្នុងរាល់កិច្ចប្រឹងប្រែងដែលមានគោលបំណងក្នុងការសម្រេចគោលដៅអភិវឌ្ឍន៍សហសវត្ស និងក្របខណ្ឌអភិវឌ្ឍន៍ថ្មីត្រឹមឆ្នាំ២០១៥។ |
| ***គណៈកម្មាធិការស្តីពីសិទ្ធិកុមារ*** CRC/C/KHM/CO/2-3 (២០១១) |
| ១៧. គណៈកម្មាធិការសូមទទូចដល់រដ្ឋភាគី៖<br>ក). ធ្វើការផ្គត់ផ្គង់ធនធានថវិកាឱ្យបានគ្រប់គ្រាន់ ស្របនឹងមាត្រា៤ នៃអនុសញ្ញាសម្រាប់ការអនុវត្តសិទ្ធិកុមារ និងជាពិសេស បង្កើនការផ្គត់ផ្គង់ថវិកាទៅឱ្យវិស័យសង្គមកិច្ច ប៉ុន្តែមិនផ្តាច់មុខសម្រាប់តែវិស័យអប់រំទេ។<br>ខ).ប្រាស់នូវវិធីសាស្ត្ររបស់សិទ្ធិកុមារនៅក្នុងការបរិយាយអំពីថវិការដ្ឋតាមរយៈការអនុវត្តប្រព័ន្ធតាមដានសម្រាប់ការផ្គត់ផ្គង់ និងប្រើប្រាស់ធនធានទាំងឡាយសម្រាប់កុមារតាមរយៈថវិកា។ ការធ្វើបែបនេះ ធ្វើឱ្យមានការស្តែងចេញនូវការវិនិយោគលើកុមារ។ គណៈកម្មាធិការក៏សូមទទូចថា ប្រព័ន្ធតាមដាននេះ ត្រូវតែប្រើប្រាស់សម្រាប់ការវាយតម្លៃផលប៉ះពាល់ ថាតើ ការវិនិយោគនៅក្នុងវិស័យណាមួយអាចបម្រើ "ឧត្តមប្រយោជន៍របស់កុមារ" បានយ៉ាងដូចម្តេចខ្លះ? ដោយធានាថា ផលប៉ះពាល់ផ្សេងគ្នានៃការវិនិយោគបែបនេះទៅលើកុមារី និងកុមារា ត្រូវបានធ្វើការវាស់វែង។<br>គ). នៅពេលដែលអាចធ្វើទៅបាន ត្រូវអនុវត្តតាមអនុសាសន៍អង្គការសហប្រជាជាតិ ក្នុងការចាប់ផ្តើមលទ្ធផលទៅតាមថវិកាផ្តល់ឱ្យ ដើម្បីធ្វើការពិនិត្យតាមដាន និងវាយតម្លៃពីប្រសិទ្ធភាពនៃធនធានដែលបានផ្តល់ឱ្យ ថែមទាំងប្រសិនបើចាំបាច់ ត្រូវស្វែងរកកិច្ចសហប្រតិបត្តិការអន្តរជាតិ ដើម្បីសម្រេចនូវកិច្ចការនេះ។<br>ឃ). ធ្វើការសិក្សាឱ្យបានគ្រប់ជ្រុងជ្រោយអំពីសេចក្តីត្រូវការខាងថវិកានិងវិភាជន៍ ឱ្យបានច្បាស់លាស់សម្រាប់វិស័យទាំងនោះ ដែលដោះស្រាយដោយភាពជឿនលឿននូវអសមភាពដែលមាននៅក្នុងសូចនាករទាក់ទងនឹងសិទ្ធិកុមារ។<br>ង). ធានានូវការរៀបចំថវិកាដោយតម្លាភាព និងមានការចូលរួមតាមរយៈការសន្ទនាជាសាធារណៈ ជាពិសេសជាមួយកុមារ និងមានការទទួលខុសត្រូវដ៏សមស្របដោយអាជ្ញាធរមូលដ្ឋាន។<br>ច). កំណត់ខ្ទង់ថវិកាទៅតាមយុទ្ធសាស្ត្រសម្រាប់កុមារនៅក្នុងស្ថានភាពមិនអំណោយផល និងងាយរងគ្រោះដែលអាចតម្រូវឱ្យមានវិធានការសង្គមជាវិជ្ជមាន និងត្រូវធ្វើឱ្យប្រាកដថា ខ្ទង់ថវិកាទាំងនោះត្រូវបានការពារ សូម្បីនៅក្នុងស្ថានភាពនៃវិបត្តិសេដ្ឋកិច្ច គ្រោះមហន្តរាយធម្មជាតិ ឬភាពអាសន្នដទៃផ្សេងទៀតក៏ដោយ។<br>ឆ). ចាត់វិធានការបន្ទាន់ ដើម្បីប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ និងពង្រឹងសមត្ថភាពស្ថាប័នដើម្បីរកឱ្យឃើញស៊ើបអង្កេត និងដាក់ទោសអំពើពុករលួយ និង<br>ជ). ពិចារណានូវអនុសាសន៍របស់គណៈកម្មាធិការ ក្នុងអំឡុងទិវានៃការពិភាក្សាទូទៅក្នុងឆ្នាំ២០០៧ ស្តីពី "ធនធានសម្រាប់សិទ្ធិកុមារ និងការទទួលខុសត្រូវរបស់រដ្ឋទាំងឡាយ"។ |

| *គណៈកម្មាធិការសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌* E/C.12/KHM/CO/1 (២០០៩) |
| --- |
| **២៧.** គណៈកម្មាធិការស្នើឲ្យរដ្ឋភាគី យកចិត្តទុកដាក់ចំពោះសេចក្តីថ្លែងការណ៍របស់ខ្លួនស្តីពី "ការវាយតំលៃអំពីកាតព្វកិច្ចចាត់វិធានការជា 'អតិបរមានៃធនធានដែលមានរបស់ខ្លួន' ក្រោមពិធីសារបន្ថែមនៃកតិកាសញ្ញា" (E/C.12/2007/1) ហើយផ្តល់ជាអនុសាសន៍ថា រដ្ឋភាគីគួរបង្កើនការចំណាយថវិកាជាតិរបស់ខ្លួនទៅលើសេវា និងការជួយឧបត្ថម្ភផ្នែកសង្គមកិច្ច ដូចជា ផ្ទះសម្បែង ស្បៀងអាហារ សុខភាព និងការអប់រំ ធ្វើដូច្នេះបាន ដើម្បីសម្រេចបាន ស្របតាមមាត្រា២ កថាខ័ណ្ឌទី១ នូវការរីកចំរើនជាលំដាប់នៃសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដែលមានចែងក្នុងកតិកាសញ្ញានេះ។ គណៈកម្មាធិការផ្តល់ជាអនុសាសន៍ថែមទៀតថា រដ្ឋភាគីគួរលៃបំរុងធនធានគ្រប់គ្រាន់សំរាប់ការអនុវត្តន៍យុទ្ធសាស្ត្ររបស់ខ្លួនស្តីពីការកាត់បន្ថយភាពក្រីក្រ និងធានាការធ្វើសមាហរណកម្មយ៉ាងពេញទំហឹងនូវសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ទៅក្នុងយុទ្ធសាស្ត្រនោះ ដូចដែលគណៈកម្មាធិការបានផ្តល់ជាអនុសាសន៍ក្នុងសេចក្តីថ្លែងការណ៍របស់ខ្លួនស្តីពី "ភាពក្រីក្រ និងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌" (E/C.12/2001/10)។<br><br>**៣៨.** គណៈកម្មាធិការស្នើឲ្យរដ្ឋភាគីធានាថា ធនធានដែលមានជាអតិបរមាត្រូវបានលៃបំរុងសំរាប់ការការពារ និងការអនុវត្តន៍ឲ្យបាននូវសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ជាពិសេស ចំពោះបុគ្គល ឬក្រុមមនុស្សដែលងាយរងគ្រោះបំផុត និងដែលគេមិនសូវគិតគូរ។ គណៈកម្មាធិការជំរុញលើកទឹកចិត្តដល់រដ្ឋភាគីឲ្យបង្កើនតម្លាភាព និងគណនេយ្យភាព ដើម្បីពង្រឹងប្រសិទ្ធភាពក្នុងការអនុវត្តន៍កម្មវិធីអភិវឌ្ឍន៍ ដែលបានផ្តល់មូលនីធិដោយម្ចាស់ជំនួយអន្តរជាតិនានា ជាពិសេសសំរាប់កំណែទម្រង់ប្រព័ន្ធយុត្តិធម៌ និងស្ថាប័ន និងសំរាប់ការលើកកំពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋដែលរស់នៅក្នុងភាពក្រីក្រ។ ក្នុងករណីនេះ គណៈកម្មាធិការសូមទាញចំណាប់អារម្មណ៍របស់រដ្ឋភាគីចំពោះសេចក្តីពន្យល់ទូទៅលេខ៣ របស់ខ្លួន ស្តីពីចរិតលក្ខណៈនៃកាតព្វកិច្ចរបស់រដ្ឋភាគី(E/1991/23) និងសេចក្តីថ្លែងការណ៍របស់ខ្លួន "ការវាយតំលៃអំពីកាតព្វកិច្ចចាត់វិធានការជាអតិបរមានៃធនធានដែលមានរបស់ខ្លួន" ក្រោមពិធីសារបន្ថែមនៃកតិកាសញ្ញានេះ (E/C.12/2007/1) (មាត្រា ២.១)។ |
| *អ្នករាយការណ៍ពិសេស* |
| A/HRC/33/62, Para. 61(b). ពិគ្រោះឱ្យបានទូលាយ បង្កើយ និងផ្សព្វផ្សាយគោលនយោបាយ និងផែនការយុទ្ធសាស្ត្រ ដើម្បីទទួលបានជោគជ័យដែលអាចវាស់វែងបាន ក្នុងការសម្រេចបានគោលដៅអភិវឌ្ឍន៍ដោយចេរភាព។ |

## ខ. ការកាត់បន្ថយភាពក្រីក្រ ទ្រព្យសម្បត្តិ/គម្លាតជនបទ-ទីក្រុង

| *អនុសាសន៍នៃការពិនិត្យជាសកលតាមកាលកំណត់ (២០១៤)* |
|---|
| **១១៨.១២៨.** ពង្រឹងកិច្ចខិតខំប្រឹងប្រែងដើម្បីកាត់បន្ថយភាពក្រីក្រនៅក្នុងតំបន់ជនបទ និងភ្ជាប់គម្លាតទ្រព្យធនរវាងតំបន់ជនបទ និងទីក្រុង។ (ស្រីលង្កា) |
| **១១៨.១៣៤.** បន្តកំណែទម្រង់ប្រព័ន្ធកាន់កាប់ដីធ្លី ដើម្បីឆ្លើយតបនឹងគោលដៅជាតិនៃការកាត់បន្ថយភាពក្រីក្រ សន្តិសុខស្បៀង និងការការពារបរិស្ថាន។ (ម៉ូរ៉ុកកូ) |
| **១១៨.១៣៦.** បង្កើនកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួន ដើម្បីសម្រេចបានគោលដៅជាតិសម្រាប់ការកាត់បន្ថយភាពក្រីក្រ សន្តិសុខស្បៀង និងការអភិវឌ្ឍសង្គមសេដ្ឋកិច្ច រួមទាំងតាមរយៈកំណែទម្រង់ ការគ្រប់គ្រងដីធ្លី។ (ម៉ាឡេស៊ី) |
| **១១៨.១៣៨.** បង្កើនកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួនដើម្បីកាត់បន្ថយវិសមភាពប្រាក់ចំណូលរវាងតំបន់ជនបទ និងទីក្រុង ដោយមានការគាំទ្រពីសហគមន៍អន្តរជាតិ និងទីភ្នាក់ងារអង្គការសហប្រជាជាតិដែលពាក់ព័ន្ធដទៃទៀត។ (ប៊ូតង់) |
| **១១៨.១៤១.** បន្តកាត់បន្ថយអត្រាភាពក្រីក្រនៅតំបន់ជនបទ និងគម្លាតទ្រព្យធនរវាងអ្នកមាន និងអ្នកក្រ និងរវាងប្រជាជននៅជនបទ និងទីក្រុង។ (មីយ៉ាន់ម៉ា) |
| **១១៨.១៤២.** កាត់បន្ថយគម្លាតរវាងតំបន់ទីក្រុង និងតំបន់ជនបទ តាមរយៈការកាត់បន្ថយភាពក្រីក្រ នៅតំបន់ជនបទ។ (អ៊ីរ៉ាក់) |
| **១១៨.១៤៣.** ដោយសហការជាមួយសហគមន៍អន្តរជាតិ អនុវត្តកម្មវិធីនានាប្រកបដោយប្រសិទ្ធភាព សំដៅកាត់បន្ថយភាពក្រីក្រ ជាពិសេស នៅតំបន់ជនបទនៃប្រទេស។ (អាហ៊្សែបៃហ្សង់) |
| *អនុសាសន៍នៃការពិនិត្យជាសកលតាមកាលកំណត់ (២០០៩)* |
| **១៤.** បន្តយកចិត្តទុកដាក់ជាពិសេសក្នុងការបន្តដំណើរការទាំងស្រុងដោយយកមកពិចារណានូវគ្រប់លក្ខណៈចាំបាច់របស់សង្គម ព្រមទាំងបង្កើតឲ្យមានលក្ខខណ្ឌអនុគ្រោះ ជាពិសេស សំរាប់អ្នកទាំងនោះដែលរស់នៅតំបន់ជនបទក្នុងក្របខ័ណ្ឌនៃផែនការអភិវឌ្ឍន៍យុទ្ធសាស្ត្រដូចបានលើកឡើងក្នុងកថាខណ្ឌ៣៣ នៃរបាយការណ៍ជាតិ។(ម៉ូរ៉ុកកូ) |
| **៦៣.** សូមពិចារណាពង្រឹងគោលនយោបាយប្រើប្រាស់ដីធ្លី និងចំពោះភាពមិនស្មើភាពនៅតាមតំបន់ទីក្រុង និងជនបទ ព្រមទាំងបន្តកិច្ចខិតខំប្រឹងប្រែង ដើម្បីប្រយុទ្ធប្រឆាំងនឹងភាពក្រីក្រ។ (ប្រេស៊ីល) |
| **៧០.** បន្តអនុវត្តយុទ្ធសាស្ត្រជាតិរបស់ខ្លួនដើម្បីកាត់បន្ថយភាពក្រីក្រ ជាពិសេសនៅតាមតំបន់ជនបទ និងដើម្បីលើកកម្ពស់ជីវភាពរស់នៅជាទូទៅរបស់ប្រជាពលរដ្ឋខ្លួន។ (បេឡារូស) |
| **៧៣.** លើកកម្ពស់និងការពារសិទ្ធិប្រជាជនងាយរងគ្រោះ សិទ្ធិអប់រំនិងសិទ្ធិទទួលបានការអភិវឌ្ឍន៍ដើម្បីកាត់បន្ថយភាពក្រីក្រនៅតាមតំបន់ទីក្រុង និងតំបន់ជនបទ ក្នុងពេលជាមួយគ្នា នៅពេលដែលរក្សាសន្តិភាព ស្ថេរភាព និងការការពារដល់បរិស្ថាន។ (ឡាវ) |

៧៦. ពង្រីកការចំណាយសាធារណៈរបស់ខ្លួនទៅលើការអនុវត្តសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌។ បន្តកិច្ចខិតខំប្រឹងប្រែងក្នុងការបែងចែកធនធានបន្ថែមទៀត ដើម្បីធានាដល់ការធ្វើឲ្យប្រសើរឡើងចំពោះសិទ្ធិសេដ្ឋកិច្ចនិងសង្គមរបស់ប្រជាពលរដ្ឋ ជាពិសេស ក្នុងវិស័យកាត់បន្ថយភាពក្រីក្រ សមភាពនៅតាមទីក្រុង-ជនបទ ការអប់រំ និងសេវាសាធារណៈ។ល។ អនុវត្តកិច្ចខិតខំប្រឹងប្រែងចាំបាច់ក្នុងការបង្កើនការចំណាយសំរាប់កម្មវិធីសង្គមកិច្ច ជាពិសេសទាក់ទងនឹងការអប់រំ និងសិទ្ធិទទួលបានលំនៅដ្ឋានសមរម្យ បង្កើនការចំណាយរបស់ជាតិបន្ថែមទៀតទៅលើវិស័យសុខភាព និងអប់រំ ដើម្បីឆ្លើយតបនឹងទិសដៅនៃគោលបំណងអភិវឌ្ឍន៍សហសវត្ស។ (អាហ្សែបៃហ្សង់)

៧៨. ពង្រឹងការលើកកម្ពស់គោលនយោបាយសង្គមឲ្យបានគ្រប់គ្រាន់ ដែលមានបំណងសម្រេចឲ្យបាននូវការបែងចែងទ្រព្យសម្បត្តិ និងសុខមាលភាពសង្គមរបស់ពលរដ្ឋឲ្យបានត្រឹមត្រូវ។ (វេណេហ្ស៊ុយអេឡា)

៩១-ឃ). ដោយមានជំនួយឧបត្ថម្ភពីអន្តរជាតិ សូមបន្តបង្កើតកម្មវិធីប្រកបដោយប្រសិទ្ធភាព ក្នុងគោលបំណងកាត់បន្ថយភាពក្រីក្រ ជាពិសេស នៅតាមតំបន់ជនបទដែលមានប្រជាពលរដ្ឋ៨០%។ (អាហ្សែបៃហ្សង់)

## *គណៈកម្មាធិការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ* (២០១៣)

CEDAW/C/KHM/CO/4-5

៤១. គណៈកម្មាធិការផ្តល់អនុសាសន៍ឲ្យរដ្ឋភាគី៖

(ក). បង្កើនកិច្ចប្រឹងប្រែងរបស់ខ្លួន ក្នុងការជួយសម្រួលឲ្យស្ត្រីជនបទទទួលសេវាមូលដ្ឋាន បង្គន់ ទឹកពិសារ សុវត្ថិភាព ការអប់រំ ការងារ សេវាសុខាភិបាល ឥណទាន និងប្រាក់កម្ចី។ ក្នុងន័យនេះ រដ្ឋភាគីគប្បីពិចារណាលើការបញ្ចូលបច្ចេកវិជ្ជាទំនាក់ទំនងព័ត៌មាន ក្នុងការផ្សព្វផ្សាយព័ត៌មានអំពីកម្មវិធីបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រីសម្រាប់ស្ត្រីដែលរស់នៅតំបន់ជនបទ។

(ខ). បង្កើតសូចនាករដែលឆ្លុះបញ្ចាំងបានល្អប្រសើរពីការផ្លាស់ប្តូរតំបន់ និងការផ្លាស់ប្តូរសេដ្ឋកិច្ចសង្គម ជាផ្នែកមួយនៃការប្រឹងប្រែងរបស់ខ្លួន ក្នុងការលើកកម្ពស់កម្មវិធីសុខភាព អប់រំ និងការងារសម្រាប់ស្ត្រី ជនបទ និង

(គ). បន្តធានាថា ស្ត្រីចូលរួមយ៉ាងសកម្មក្នុងការធ្វើសេចក្តីសម្រេច ទាំងក្នុងនយោបាយ និងកម្មវិធីទប់ស្កាត់ និងគ្រប់គ្រងគ្រោះមហន្តរាយ ជាពិសេស គោលនយោបាយ និងកម្មវិធីទាក់ទងនឹងការបន្សាំ និងការកាត់បន្ថយផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ។

## *គណៈកម្មាធិការស្តីពីសិទ្ធិកុមារ* CRC/C/KHM/CO/2-3 (២០១១)

៦០. គណៈកម្មាធិការសូមទទូចឱ្យរដ្ឋភាគីធ្វើការពង្រឹងកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួន ក្នុងការផ្តល់នូវការគាំទ្រ និងជំនួយជាសម្ភារៈដល់គ្រួសារដែលខ្សត់ខ្សោយខាងសេដ្ឋកិច្ច ជាពិសេស គ្រួសារទាំងឡាយដែលរស់នៅក្នុងតំបន់ជនបទ និងធ្វើការធានានូវសិទ្ធិរបស់កុមារគ្រប់រូប ក្នុងការទទួលបានបទដ្ឋានរស់នៅគ្រប់គ្រាន់។

| *គណៈកម្មាធិការលុបបំបាត់ការរើសអើងពូជសាសន៍* CERD/C/KHM/CO/8-13 (២០១០) |
| --- |
| **១៦.** គណៈកម្មាធិការផ្តល់អនុសាសន៍ថា រដ្ឋភាគីធានាឲ្យមានតុល្យភាពមួយសមស្រប រវាងការអភិវឌ្ឍន៍ និងសិទ្ធិពលរដ្ឋរបស់ខ្លួនត្រូវបានទទួល និងធានាថាការអភិវឌ្ឍន៍សេដ្ឋកិច្ចរបស់ខ្លួនមិនត្រូវធ្វើឲ្យខាតបង់សិទ្ធិក្រុម ឬបុគ្គលដែលងាយរងគ្រោះដូចមានចែងក្នុងអនុសញ្ញានេះឡើយ។ [...] |
| *អ្នករាយការណ៍ពិសេស* |
| A/HRC/21/63/Add.1/Rev.1.Para.212. រដ្ឋាភិបាលគួរលើកកំពស់កិច្ចខិតខំប្រឹងប្រែងទាំងអស់ ដើម្បីអនុវត្តចំរុះគ្នានូវច្បាប់ គោលនយោបាយ និងបទបញ្ញានានា ដែលតម្រូវឲ្យមានការវាយតំលៃពីផលប៉ះពាល់សង្គម និងបរិដ្ឋានដែលត្រូវធ្វើ*មុនពេល* ការផ្តល់ដីសម្បទាន រួមទាំងច្បាប់ស្តីពីការការពារបរិដ្ឋាន និងការគ្រប់គ្រងធនធានធម្មជាតិ ហើយលទ្ធផលនៃការវាយតំលៃនេះ ត្រូវផ្សព្វផ្សាយជាសាធារណៈ។<br><br>A/HRC/21/63/Add.1/Rev.1.Para.226. ជីវភាពរស់នៅ និងឱកាសរកចំណូលរបស់គ្រួសារដែលត្រូវរងផលប៉ះពាល់ដោយការផ្តល់សម្បទាននេះគួរត្រូវយកមកពិនិត្យ និងធ្វើជាផ្នែកមួយនៃការសិក្សាពីបរិមាណ និងគុណភាពជាមួយនឹងដំណោះស្រាយដែលត្រូវបានស្នើឡើង ដើម្បីឆ្លើយតបនឹងផលប៉ះពាល់ហិរញ្ញវត្ថុជាអវិជ្ជមានដល់ផ្ទះសម្បែង និងកំរិតសហគមន៍របស់ពួកគេ។ |

## *គ. ការទទួលខុសត្រូវធុរកិច្ច/មុខរបរ*

| *អនុសាសន៍នៃការពិនិត្យជាសកលតាមកាលកំណត់* (២០១៤) |
| --- |
| **១១៨.១២៥.** ពង្រឹងគោលនយោបាយរបស់ខ្លួន ដើម្បីកែលម្អស្តង់ដារការងារសម្រាប់កម្មករទាំងអស់ និងបន្តកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួន ក្នុងការកាត់បន្ថយពលកម្មកុមារ។ (អេស្ប៉ាញ)<br><br>**១១៨.១២៦.** បន្តពង្រឹងកម្មវិធីបង្កើតការងារប្រកបដោយប្រសិទ្ធភាព ដើម្បីប្រយុទ្ធប្រឆាំងនឹងភាពក្រីក្រ និងវិសមភាពសង្គម។ (វេណេហ្ស៊ុយអេឡា (សាធារណរដ្ឋបូលីវី))<br><br>**១១៨.១២៧.** ជំរុញឲ្យមានច្បាប់ស្តីពីការទទួលខុសត្រូវសង្គមរបស់សាជីវកម្ម និងការផ្សព្វផ្សាយអំពីគោលការណ៍ណែនាំស្តីពីធុរកិច្ច និងសិទ្ធិមនុស្ស ដើម្បីធ្វើឲ្យប្រសើរដល់សុវត្ថិភាពនៅកន្លែងធ្វើការ និងលក្ខខណ្ឌការងារសម្រាប់និយោជិក។ (ម៉ិកស៊ិកូ) |

### *អនុសាសន៍នៃការពិនិត្យជាសកលតាមកាលកំណត់* (២០០៩)

**៥៧.** ធ្វើការកាត់បន្ថយកំរិតនៃការអត់ការងារធ្វើបន្ថែមទៀត រាប់បញ្ចូលទាំងតាមរយៈការបង្កើតនិងការអនុវត្តកម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈនិងការបណ្តុះបណ្តាលឡើងវិញដល់ប្រជាពលរដ្ឋរបស់ខ្លួននិងការបង្កើតឲ្យមានការងារធ្វើ។ (បេឡារូស)

**៧៥.** ធានាឲ្យមានការគ្រប់គ្រងប្រេងឧស្ម័ន និងចំណូលពីរ៉ែប្រកបដោយតម្លាភាព ដើម្បីឆ្លើយតបនឹងសិទ្ធិសង្គមកិច្ច និងសេដ្ឋកិច្ចរបស់ប្រជាជនរស់នៅកម្ពុជា ដោយប្រកាន់យកការអនុវត្តល្អបំផុតជាលក្ខណៈអន្តរជាតិ ក្នុងការអនុវត្តឧស្សាហកម្មចំរាញ់ផលពីធម្មជាតិ។ (អៀកឡង់ដ៍)

### *គណៈកម្មាធិការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ* (២០១៣)

CEDAW/C/KHM/CO/4-5

**៣៥.** គណៈកម្មាធិការផ្តល់អនុសាសន៍ឲ្យរដ្ឋភាគី៖

(ក). បន្តអនុម័តវិធានការប្រតិសកម្មនិងជាក់ស្តែង ដើម្បីលុបបំបាត់ការបែងចែកមុខងារនិងធ្វើឲ្យរួមតូចនូវគម្លាតប្រាក់ឈ្នួលដោយសារតែភេទ។

(ខ). ចាត់វិធានការដើម្បីធានាថាច្បាប់ការងារត្រូវបានអនុវត្តប្រកបដោយប្រសិទ្ធភាព និងបង្កើនចំនួនអធិការការងារដែលមានសមត្ថភាពឲ្យបានគ្រប់គ្រាន់ ដើម្បីជួយពួកគេអាចពិនិត្យតាមដានលក្ខខណ្ឌការងាររបស់ស្ត្រីប្រកបដោយប្រសិទ្ធភាព ជាពិសេស ក្នុងឧស្សាហកម្មកាត់ដេរ និងវិស័យដែលមានប្រាក់ឈ្នួលទាបដទៃទៀត។

### *គណៈកម្មាធិការស្តីពីសិទ្ធិកុមារ* CRC/C/KHM/CO/2-3 (២០១១)

**២៧.** គណៈកម្មាធិការសូមស្នើឱ្យរដ្ឋភាគីបន្តឃ្លាំមើលអំពីការអនុវត្តតាមច្បាប់ជាតិដោយក្រុមហ៊ុនក្នុងស្រុក និងក្រុមហ៊ុនបរទេសដែលមាននៅពាសពេញទឹកដីរបស់ខ្លួន ព្រមទាំងបង្កើត និងអនុវត្តបទបញ្ជានានា ដើម្បីធានាថា វិស័យពាណិជ្ជកម្មទាំងនោះអនុវត្តតាមបទដ្ឋានអន្តរជាតិ និងបទដ្ឋានក្នុងស្រុកស្តីពីការទទួលខុសត្រូវរបស់សាជីវកម្មទៅលើសង្គម និងបរិស្ថាន ជាពិសេស ទាក់ទងនឹងសិទ្ធិកុមារដើម្បីឱ្យស្របទៅនឹងក្របខណ្ឌសហប្រជាជាតិស្តីពីធុរកិច្ច និងសិទ្ធិមនុស្ស ដែលត្រូវបានអនុម័តជាឯកច្ឆ័នក្នុងឆ្នាំ២០០៨ ដោយក្រុមប្រឹក្សាសិទ្ធិមនុស្ស ព្រមទាំងបានគូសបញ្ជាក់នូវភារកិច្ចរបស់រដ្ឋទាំងឡាយក្នុងការផ្តល់កិច្ចការពារប្រឆាំងនឹងការរំលោភបំពានលើសិទ្ធិមនុស្ស ដោយក្រុមហ៊ុនពាណិជ្ជកម្មនានា។ ការទទួលខុសត្រូវរបស់សាជីវកម្ម ក្នុងការគោរពសិទ្ធិមនុស្ស និងសេចក្តីត្រូវការ ក្នុងការទទួលបានដោយប្រសិទ្ធភាពនូវដំណោះស្រាយ នៅពេលដែលមានការរំលោភកើតឡើង។

| *គណៈកម្មាធិការលុបបំបាត់ការរើសអើងពូជសាសន៍* CERD/C/KHM/CO/8-13 (២០១០) |
| --- |
| **១៦.** [...]គណៈកម្មាធិការបន្តជំរុញលើកទឹកចិត្តដល់ក្រុមហ៊ុនសាជីវកម្មទាំងអស់ថា នៅពេលចូលពាក់ព័ន្ធក្នុងបញ្ហាសម្បទានដីសេដ្ឋកិច្ច ត្រូវគិតគូរអំពីការទទួលខុសត្រូវផ្នែកសង្គមរបស់ក្រុមហ៊ុន ព្រោះការងារនេះ វាទាក់ទងដល់សិទ្ធិ និងសុខមាលភាពរបស់ប្រជាពលរដ្ឋមូលដ្ឋាន។ |
| *គណៈកម្មាធិការសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌* E/C.12/KHM/CO/1 (២០០៩) |
| **២១.** គណៈកម្មាធិការផ្តល់អនុសាសន៍ថារដ្ឋភាគីគួរពិនិត្យឡើងវិញនូវគោលនយោបាយការងាររបស់ខ្លួន និងបង្កើតផែនការយុទ្ធសាស្ត្រស្តីពីការងារ ដើម្បីលើកកំពស់ការងាររបស់យុវជន។ គណៈកម្មាធិការផ្តល់អនុសាសន៍ដែរឲ្យរដ្ឋភាគីពិនិត្យឡើងវិញអំពីយុទ្ធសាស្ត្របណ្តុះបណ្តាលក្នុងគោលដៅធានាការអប់រំវិជ្ជាជីវៈ និងបច្ចេកទេស ដើម្បីឆ្លើយតបនឹងតម្រូវការការងារ ដោយមានការពិគ្រោះយោបល់ជាមួយកម្មករ និងអង្គការនិយោជកនានា ព្រមទាំងស្ថាប័នជាដៃគូក្នុងស្រុក។<br>**២២.** គណៈកម្មាធិការផ្តល់ជាអនុសាសន៍យ៉ាងខ្លាំងដល់រដ្ឋភាគីថា គោលការណ៍នៃប្រាក់ឈ្នួលស្មើគ្នាសំរាប់ការងារដែលមានតំលៃស្មើគ្នារវាងបុរសនិងស្ត្រី គួរតែបានឆ្លុះបញ្ចាំងយ៉ាងពេញលេញ និងយ៉ាងច្បាស់លាស់នៅក្នុងច្បាប់មួយ ហើយច្បាប់នោះទៀតសោត ក៏គួរតែបានអនុវត្តយ៉ាងម៉ឺងម៉ាត់បំផុត ហើយត្រូវចាត់វិធានការច្បាស់លាស់ និងមានប្រសិទ្ធភាពក្នុងបញ្ហានេះ។<br>**២៣.** គណៈកម្មាធិការផ្តល់ជាអនុសាសន៍ថា រដ្ឋភាគីគួរកំណត់ប្រាក់ឈ្នួលអប្បបរិមាជាលក្ខណៈទូទៅមួយ ដែលអាចឲ្យកម្មករទាំងអស់ និងក្រុមគ្រួសាររបស់ពួកគាត់ មានកំរិតជីវភាពរស់នៅសមរម្យ។ |
| *អ្នករាយការណ៍ពិសេស* |
| A/HRC/18/46 Para 93. នៅពេលចូលរួមដោះស្រាយបញ្ហាដីធ្លី ទាំងជាមួយរដ្ឋាភិបាលកម្ពុជា ទាំងជាមួយម្ចាស់ដីផ្សេងៗ រដ្ឋាភិបាលបរទេស និងអង្គការពាណិជ្ជកម្មអន្តរជាតិនានា គួរតែចងចាំក្នុងចិត្តថាខ្លួនមានការទទួលខុសត្រូវមួយតាមច្បាប់អន្តរជាតិក្នុងការគោរពសិទ្ធិរបស់ប្រជាជនកម្ពុជា។ ការគាំទ្រ ការប្រើប្រាស់មន្ត្រីប្រតិបត្តិច្បាប់ប្រដាប់អាវុធឲ្យធ្វើការបណ្តេញដោយខុសច្បាប់ គឺជាការអនុវត្តន៍ផ្ទុយទៅនឹងច្បាប់អន្តរជាតិ ហើយគួរតែចាត់ទុកថាជាទង្វើមួយខុសច្បាប់ផងដែរនៅកម្ពុជា។<br>អនុសាសន៍ខាងក្រោមនេះ ដកស្រង់ចេញពីA/HRC/21/63/Add.1/Rev.1 រហូតដល់មានការបង្ហាញផ្សេងពីនេះ៖<br>**២១៦.** គួរធ្វើការពិចារណាឲ្យបានត្រឹមត្រូវដល់សំណើសុំរបស់សម្បទានិកជាមួយនឹងលក្ខខណ្ឌតម្រូវតាមច្បាប់ និងតាមបទបញ្ជានានាបន្ថែម ដោយភ្ជាប់ទៅនឹងគំរោងវិនិយោគរបស់ពួកគេ (ដូចជាគំរោងបញ្ជាក់ភាគីទី៣ និងក្រមសីលធម៌ដ៏តឹងរឹងជាដើម) ដែលត្រូវស៊ីគ្នានឹងបទដ្ឋានអន្តរជាតិនៃចិរភាពសង្គម និងបរិដ្ឋាន។ |

**២១៧**. ក្រុមហ៊ុនគ្រប់ទម្រង់ រចនាសម្ព័ន្ធ និងរបៀបប្រតិបត្តិការ ទាំងក្រុមហ៊ុនក្នុងស្រុកនិងក្រុមហ៊ុនបរទេស ហើយទោះជាក្រុមហ៊ុនរដ្ឋទាំងស្រុងឬក្រុមហ៊ុនពាក់កណ្តាលរដ្ឋ គួរដោះស្រាយពីផលប៉ះពាល់សិទ្ធិមនុស្សរបស់ខ្លួន ដោយអនុវត្តតាមវិរិយភាពដ៏ត្រឹមត្រូវ រួមទាំងការអនុវត្តវិធានការនានា ដើម្បីកំណត់អត្តសញ្ញាណ បង្ការ និងជួយសម្រាលដល់ផលវិបាកសិទ្ធិមនុស្សធ្ងន់ធ្ងរ ព្រមទាំងយកចិត្តទុកដាក់ដល់សកម្មភាពអាជីវកម្មរបស់ខ្លួន។

**២២២**. ក្រុមហ៊ុនសម្បទាន គួរចាត់វាល់វិធានការដើម្បីចៀសវាងការបំផ្លាញបរិដ្ឋាននៅក្នុងប្រតិបត្តិការរបស់ខ្លួន រួមទាំងបង្ការមិនឲ្យទឹកកកក្ខក់មានរោគ បំផ្លិចបំផ្លាញដល់ដី និងការកាប់រានយកដីដោយមិនចាំបាច់ ឬការកាប់បំផ្លាញព្រៃឈើដោយខុសច្បាប់។ ក្រុមហ៊ុនទាំងនេះគួរធានាថា ការទទួលបានហេដ្ឋារចនាសម្ព័ន្ធ ដូចជាការកសាងផ្លូវថ្មីនៅលើដីសម្បទានរបស់ខ្លួន អាចត្រូវបានប្រើប្រាស់ដោយសហគមន៍នានានៅជុំវិញនោះ ហើយមិនគួររាំងខ្ទប់មិនឲ្យមានការធ្វើដំណើរនៅក្នុងព្រំដែននៃដីសម្បទានរបស់ខ្លួនឡើយ។

**២២៤**. ក្រុមហ៊ុនសម្បទាន—ដោយប្រើប្រាស់ផលលាភដែលបានពីសកម្មភាពសម្បទានរបស់ខ្លួន—គួរបង្កើនវិភាគទានរបស់ខ្លួនដល់សហគមន៍មូលដ្ឋាន រួមទាំងផ្តល់ផលប្រយោជន៍ដល់សង្គម ដូចជាសេវាកម្មសុខាភិបាល ឱកាសអប់រំ និងវិធានការការពារបរិដ្ឋានជាដើម។

អនុសាសន៍ខាងក្រោមនេះ ដកស្រង់ចេញពី A/HRC/27/70 រហូតដល់មានការបង្ហាញផ្សេងពីនេះ៖

៨១-(ឈ). ធានាថា យន្តការថ្មីដើម្បីកំណត់ប្រាក់ឈ្នួលអប្បបរមា ត្រូវយកមកពិចារណានូវការស្រាវជ្រាវចាំបាច់សំរាប់ការធ្វើសេចក្តីសម្រេចដោយឈរលើមូលដ្ឋានភស្តុតាង និងការកែសម្រួលជាទៀងទាត់ ជាពិសេសការកំណត់កំរិតប្រាក់ឈ្នួលគ្រប់គ្រាន់ផ្តល់ឱ្យកម្មករទាំងអស់ និងគ្រួសាររបស់ពួកគេ នូវកំរិតជីវភាពរស់នៅមួយសមរម្យ ដូចបានតម្រូវដោយកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ហើយត្រូវពិនិត្យឡើងវិញជាទៀងទាត់ នូវប្រាក់ឈ្នួលអប្បបរមាជាតិ ដែលត្រូវកំណត់ដូច្នេះ។

(ញ). បន្តការកែទម្រង់រដ្ឋបាលសាធារណៈ ហើយក្នុងការធ្វើដូច្នេះ បង្កើតរចនាសម្ព័ន្ធប្រាក់ឈ្នួលដើម្បីធានាថាប្រាក់បៀវត្សរ៍គ្រប់គ្រាន់ផ្តល់ឱ្យមន្ត្រីរាជការត្រូវបានធានាការពារដើម្បីឱ្យមានកំរិតជីវភាពរស់នៅសមរម្យ បង្កើតសូចនាករបំពេញការងារច្បាស់លាស់ និងយន្តការគណនេយ្យភាពសំរាប់មន្ត្រីរាជការទាំងអស់ និងបង្កើតកម្មវិធីប្រយុទ្ធប្រឆាំងអំពើពុករលួយឱ្យបានកាន់តែខ្លាំងក្លាថែមទៀតនៅគ្រប់កំរិត។

(ដ). គោរពយ៉ាងពេញលេញនូវសិទ្ធិសហជីពរបស់កម្មករទាំងអស់នៅកម្ពុជា និងការពារមន្ត្រីសហជីព ធ្វើដូច្នេះពួកគេអាចអនុវត្តសកម្មភាពរបស់ខ្លួនបាននៅក្នុងបរិយាកាសមួយដែលមិនមានការបំភិតបំភ័យ និងហានិភ័យដល់សន្តិសុខផ្ទាល់ខ្លួន ឬអាយុជីវិតរបស់ពួកគេ។

## X. ដីធ្លី និងសិទ្ធិលំនៅដ្ឋាន

### *ក. ការកាន់កាប់ដីធ្លី ការបណ្តេញចេញ និងការតាំងទីលំនៅថ្មី និងក្របខ័ណ្ឌច្បាប់*

| *អនុសាសន៍នៃការពិនិត្យជាសកលតាមកាលកំណត់ (២០១៤)* |
|---|
| **១១៨.១២៩.** បញ្ឈប់ការដកហូតដោយបង្ខំ និងធានាដំណើរការប្រកបដោយយុត្តិធម៌ និងតម្លាភាពទាក់ទងទៅនឹងសិទ្ធិប្រើប្រាស់ដីធ្លី។ (ម៉ិកស៊ិក) <br> **១១៨.១៣០.** អនុវត្តក្របខ័ណ្ឌច្បាប់ដ៏តឹងរឹងមួយដែលធានាថា ការបណ្តេញចេញ និងការតាំងទីលំនៅថ្មី ត្រូវធ្វើត្រឹមត្រូវតាមផ្លូវច្បាប់ ចរចា និងត្រូវផ្តល់សំណងដោយយុត្តិធម៌។ (អូទ្រីស) <br> **១១៨.១៣៣.** បន្តជំរុញវឌ្ឍនភាពទៅលើបញ្ហាសំខាន់ៗសម្រាប់ការលើកស្ទួយសិទ្ធិមនុស្សនិងប្រជាធិបតេយ្យភាវូបនីយកម្មរបស់ខ្លួន ជាពិសេស នៅក្នុងកំណែទម្រង់តុលាការ និងវិធានការនានា ដើម្បីដោះស្រាយបញ្ហាដីធ្លី។(ជប៉ុន) <br> **១១៨.១៣៤.** បន្តកំណែទម្រង់ប្រព័ន្ធកាន់កាប់ដីធ្លី ដើម្បីឆ្លើយតបនឹងគោលដៅជាតិនៃការកាត់បន្ថយភាពក្រីក្រ សន្តិសុខស្បៀង និងការការពារបរិស្ថាន។ (ម៉ូរ៉ុកកូ) <br> **១១៨.១៣៥.** បង្កើនវិធានការនានាដើម្បីដោះស្រាយការបណ្តេញចេញពីដីធ្លីដោយខុសច្បាប់រួមទាំងវិធានការនានាប្រឆាំងនឹងជនជាតិដើមភាគតិច និងពិចារណាពង្រឹងក្របខ័ណ្ឌច្បាប់ ស្របតាមស្តង់ដារអន្តរជាតិ។ (អ៊ីតាលី) |
| *អនុសាសន៍នៃការពិនិត្យជាសកលតាមកាលកំណត់ (២០០៩)* |
| **៦០.**បង្កើនការចូលរួមរបស់ខ្លួនជាមួយសហគមន៍អន្តរជាតិដើម្បីចែករំលែកបទពិសោធន៍ក្នុងការពង្រឹងអភិបាលកិច្ចល្អ និងកម្មវិធីកំណែទម្រង់ដីធ្លី ក្នុងគោលបំណងបំពេញប្រកបដោយប្រសិទ្ធភាព នូវកាតព្វកិច្ចទទួលខុសត្រូវរបស់រាជរដ្ឋាភិបាល និងបន្តអនុវត្តការគ្រប់គ្រងលើការបែងចែង និងការប្រើប្រាស់ដីធ្លីប្រកបដោយសមធម៌ និងប្រសិទ្ធភាព។ (ភូមា) <br> **៦១.** បង្កើនកិច្ចខិតខំប្រឹងប្រែងដើម្បីលើកស្ទួយសិទ្ធិកម្មសិទ្ធិត្រឹមត្រូវលើដីធ្លី និងអភិបាលកិច្ចល្អ ព្រមទាំងបន្តកំណែទម្រង់ដែលបានធ្វើឡើង ដោយមានជំនួយឧបត្ថម្ភពីសហគមន៍អន្តរជាតិ ជាពិសេសពីការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្ស ដើម្បីពង្រឹងឡើងវិញដល់សមត្ថភាពស្ថាប័ន និងសម្រេចនូវការទទួលបានសិទ្ធិមនុស្សពេញលេញដោយប្រជាជន។ (អាល់ហ្សេរី) <br> **៦៤-(ក).** អនុវត្តឲ្យបានពេញលេញនូវច្បាប់ភូមិបាល ឆ្នាំ២០០១ និងផ្អាកការបណ្តេញចេញរហូតដល់មានការការពារទាំងឡាយ ដូចជា ការផ្តល់សំណងពេញលេញ និងសិទ្ធិប្រើប្រាស់សេវាជាមូលដ្ឋាននានា នៅតំបន់តាំងទីលំនៅថ្មី ត្រូវបានធានា។ (ស៊ុយអែត) |

(ខ). អនុម័តការផ្អាកការបណ្តេញចេញរហូតដល់វិធានការនានាត្រូវបានចាត់ឡើង ដើម្បីធានាដល់ការអនុវត្ត ច្បាប់ភូមិបាល ឆ្នាំ២០០១ ប្រកបដោយប្រសិទ្ធភាពស្តីពីទ្រព្យសម្បត្តិដីធ្លី និងដើម្បីដោះស្រាយបញ្ហាប្រកបដោយ មនុស្សធម៌ និងសេចក្តីថ្លៃថ្នូរ។ (ស្វីស)

(គ). សូមបញ្ចប់ការបណ្តេញចេញដោយបង្ខំ ដោយធ្វើឲ្យប្រសើរឡើងដល់ការអនុវត្តច្បាប់ភូមិបាល ឆ្នាំ២០០១ ដោយធានាឲ្យមានការពិនិត្យផ្ទៀងផ្ទាត់ប័ណ្ណកម្មសិទ្ធិ និងធានាដល់ការពង្រឹងការការពារប្រជាជន ដែលទទួលរង ផលប៉ះពាល់ដោយអស្សាមិករណ៍ ដែលត្រូវឲ្យមានការពិគ្រោះយោបល់ជាមុនសិន ដែលជាការស្រាវជ្រាវមួយ សំរាប់ដំណោះស្រាយតាមជម្រើសផ្សេងៗចំពោះអស្សាមិករណ៍ សូមផ្តល់ទីជម្រកថ្មី និងសំណងសមរម្យជូនជន ដែលត្រូវបានបណ្តេញចេញ។ (បារាំង)

**៦៥**. សូមបន្តកំណត់ជាអាទិភាពនូវបញ្ហានៃការបណ្តេញចេញពីដីធ្លី និងសូមធ្វើការជាមួយអ្នករាយការណ៍ពិសេស ដើម្បីធានាឲ្យមានការបញ្ចប់ចំពោះការបណ្តេញចេញដោយបង្ខំ ព្រមទាំងបំពេញតាមកាតព្វកិច្ចរបស់ខ្លួនក្នុងការ គោរពនិងការពារដល់សិទ្ធិមនុស្សរបស់ពលរដ្ឋកម្ពុជាគ្រប់រូបរាប់បញ្ចូលទាំងបុគ្គលរបស់ក្រុមជនជាតិដើមភាគតិច។ (អៀកឡង់ដ៍)

**៦៦**-(ក). រៀបចំដំណើរការប្រកបដោយតម្លាភាព និងត្រឹមត្រូវ ដើម្បីកំណត់លក្ខខណ្ឌ និងនីតិវិធីផ្សេងៗនៃការតាំង ទីលំនៅដោយមិនស្ម័គ្រចិត្ត។ (កាណាដា)

(ខ). បញ្ឈប់ការផ្លាស់ប្តូរទីលំនៅរបស់គ្រួសារទាំងឡាយទៅកាន់តំបន់ដែលមិនអាចរស់នៅបាន និងគួរប្រើការ បណ្តេញចេញជាជំរើសចុងក្រោយបង្អស់ ដូចបានស្នើសុំដោយអគ្គលេខាធិការអង្គការសហប្រជាជាតិ។ (អាឡឺម៉ង់)

(គ). បង្កើតគោលនយោបាយតាំងទីលំនៅថ្មី និងដំណើរការមួយដែលមានប្រសិទ្ធភាព តម្លាភាព និងត្រឹមត្រូវ ដែលផ្អែកលើការពិគ្រោះយោបល់ថ្នាក់ជាតិ និងការអនុវត្តដែលល្អបំផុតរបស់អន្តរជាតិ ព្រមទាំងត្រូវព្យួរការតាំងទី លំនៅថ្មីដែលបានគ្រោងទុកទាំងអស់ រហូតដល់ក្របខណ្ឌនេះត្រូវបានបង្កើតឡើងរួចរាល់។ (ចក្រភពអង់គ្លេស)

(ឃ). បង្កើនកិច្ចខិតខំប្រឹងប្រែង ដើម្បីធានាថា ការបណ្តេញចេញកើតឡើង ត្រូវស្របតាមច្បាប់ភូមិបាល និង ត្រូវធានាឲ្យមានការយកចិត្តទុកដាក់បានខ្លាំងខ្លា ដើម្បីធានាថា សហគមន៍ដែលត្រូវបានបណ្តេញចេញទៅកន្លែង តាំងលំនៅថ្មី ទទួលបានសេវាសមរម្យ ជាពិសេស នៅតាមតំបន់ទីក្រុង។ (អូស្ត្រាលី)

(ង). សូមធ្វើឲ្យប្រសើរដល់ក្របខ័ណ្ឌច្បាប់ និងក្របខ័ណ្ឌគោលនយោបាយស្តីពីការបណ្តេញចេញ អស្សា មិករណ៍ និងការតាំងលំនៅថ្មី ព្រមទាំងធានាថា អ្នកដែលតាំងលំនៅថ្មី ទទួលបានសេវា និងការគាំពារចាំបាច់។ (ណូវែលហ្សេឡង់)

**៦៧**. អនុម័ត និងអនុវត្តក្របខណ្ឌច្បាប់ឲ្យបានតឹងរឹងលើការបណ្តេញចេញ និងការតាំងទីលំនៅថ្មីដើម្បីធានាឱ្យ បានថា រាល់ការបណ្តេញចេញ និងការតាំងទីលំនៅថ្មី គឺមានលក្ខណៈស្របច្បាប់ មានការចរចា និងមានសំណង សមរម្យ។ (អូទ្រីស)

| |
|---|
| *គណៈកម្មាធិការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ* (២០១៣)<br>CEDAW/C/KHM/CO/4-5 |
| ៤៣. គណៈកម្មាធិការទទូចឲ្យរដ្ឋភាគី៖<br>(ក). ធ្វើឲ្យប្រសើរឡើងនូវការទទួលបានដីធ្លី និងសុវត្ថិភាពក្នុងការកាន់កាប់ដីធ្លីសម្រាប់ស្ត្រី ធានាថា លទ្ធកម្មដីធ្លីសម្រាប់សម្បទានសេដ្ឋកិច្ច និងសម្បទានផ្សេងទៀត គោរពតាមដំណើរការសមស្រប និងធានាថា សំណងគ្រប់គ្រាន់ត្រូវបានផ្តល់ បន្ទាប់ពីដំណើរការពិគ្រោះយោបល់គ្រប់គ្រាន់។<br>(ខ). ទទួលស្គាល់ថា ការបណ្តេញចេញដោយបង្ខំ មិនមែនហេតុការណ៍ដែលមានអព្យាក្រិតភាពយេនឌ័រនោះទេ (បាតុភូតយេនឌ័រ ឬលម្អៀង) ប៉ុន្តែវាមានផលប៉ះពាល់ដល់ស្ត្រីខ្លាំងជាង និងចាត់វិធានការបន្ទាន់ដើម្បីការពារស្ត្រី និងកុមារពីការបណ្តេញចេញបន្ថែមទៀត។<br>(គ). ស៊ើបអង្កេតភ្លាមៗ និងក្នុងករណីសមស្រប ធ្វើការចោទប្រកាន់លើករណីនៃការបំភិតបំភ័យ និងការយាយីដែលត្រូវបានប្រព្រឹត្តដោយមន្ត្រីអនុវត្តច្បាប់លើស្ត្រីជាអ្នកការពារសិទ្ធិមនុស្ស ដែលតស៊ូមតិដើម្បីសិទ្ធិដីធ្លី និង<br>(ឃ). ធានាថា សហគមន៍ដែលត្រូវបានបណ្តេញចេញ ត្រូវបានផ្លាស់ទីលំនៅទៅកាន់តំបន់ដែលអាចជួយឲ្យស្ត្រីងាយស្រួលក្នុងការទៅមកកន្លែងធ្វើការ សាលារៀន មណ្ឌលសុខភាព (រាប់ទាំងការថែទាំសុខភាពផ្លូវភេទ និងសុខភាពបន្តពូជ) មជ្ឈមណ្ឌលសហគមន៍ សេវា និងទីកន្លែងផ្សេងៗទៀតដែលចាំបាច់ ក្នុងការធានានូវការសម្រេចបាននូវសិទ្ធិមនុស្សរបស់ពួកគេ ស្របតាមអនុសញ្ញានេះ។ |
| *គណៈកម្មាធិការស្តីពីសិទ្ធិកុមារ* CRC/C/KHM/CO/2-3 (២០១១) |
| ៦២. គណៈកម្មាធិការសូមទទូចឱ្យរដ្ឋភាគីបង្អង់ការបណ្តេញចេញជាថ្នាក់ជាតិ ទម្រាំមានការកំណត់នីត្យានុកូលភាពនៃដីធ្លីដែលបានទាមទារ។ គណៈកម្មាធិការក៏សូមទទូចផងដែរឱ្យរដ្ឋភាគីធ្វើការធានាថា គ្រួសារនិងកូនៗរបស់ពួកគេ មិនក្លាយជាអ្នកគ្មានផ្ទះសម្បែងជ្រកនោះទេ ដែលកើតចេញពីការបណ្តេញចេញសម្រាប់សកម្មភាពឯកជន និងអភិវឌ្ឍន៍។ គណៈកម្មាធិការសូមស្នើបន្ថែមទៀតឱ្យរដ្ឋភាគី អនុវត្តឱ្យបានពេញលេញនូវអនុសាសន៍របស់អ្នករៀបចំរបាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិស្តីពីស្ថានភាពនៃសិទ្ធិមនុស្សក្នុងប្រទេសកម្ពុជា ទាក់ទងនឹងការទទួលបានដីធ្លី និងការមានជីវភាពរស់នៅសមរម្យ (A/HRC/4/36 និង A/HRC/7/42)។ |
| *គណៈកម្មាធិការសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌* E/C.12/KHM/CO/1 (២០០៩) |
| ១៦. គណៈកម្មាធិការស្នើយ៉ាងទទូចដល់រដ្ឋភាគីឲ្យអនុវត្តច្បាប់ភូមិបាលឆ្នាំ២០០១ ដោយមិនត្រូវអូសបន្លាយពេលវេលាតទៅទៀត និងធានាថា គោលនយោបាយរបស់ខ្លួនស្តីពីការចុះបញ្ជីដីធ្លី មិនត្រូវឲ្យផ្ទុយនឹងស្មារតីនៃច្បាប់នេះឡើយ។ គណៈកម្មាធិការបញ្ជាក់អំពីសេចក្តីត្រូវការឲ្យមានការវាយតំលៃអំពីផលប៉ះពាល់ខាងសង្គម និងបរិស្ថាន និងការពិគ្រោះយោបល់ជាមួយសហគមន៍នានា ដែលរងផលប៉ះពាល់ពាក់ព័ន្ធនឹងសកម្មភាពសេដ្ឋកិច្ច រួមទាំងការ |

ធ្វើអាជីវកម្មរ៉ែ និងអាជីវកម្មប្រេង ក្នុងគោលដៅធានាថា សកម្មភាពទាំងនេះ មិនត្រូវដកហូតពីជនជាតិដើមភាគតិច នូវការទទួលបានយ៉ាងពេញលេញនូវសិទ្ធិរបស់ពួកគាត់លើដីធ្លី និងធនធានធម្មជាតិនៃបុព្វបុរសរបស់ខ្លួនឡើយ។ គណៈកម្មាធិការជំរុញលើកទឹកចិត្តឲ្យរដ្ឋភាគី ពិចារណាផ្តល់សច្ចាប័នលើអនុសញ្ញាលេខ១៦៩របស់អង្គការពលកម្មអន្តរជាតិស្តីពីជនជាតិដើមភាគតិច និងក្រុមកុលសម្ព័ន្ធ។

២៩. គណៈកម្មាធិការស្នើឲ្យរដ្ឋភាគី អនុម័តជាបញ្ហាអាទិភាព នូវគោលនយោបាយជាតិស្តីពីផ្ទះសម្បែងដែលលើកកំពស់ប្រជាជនក្រីក្ររស់នៅទីក្រុង និងធានាសុវត្ថិភាពកាន់កាប់ដីធ្លី ផ្ទះសម្បែងដែលត្រូវមានស្ថាប័នច្បាស់លាស់ទទួលខុសត្រូវអនុវត្តការងារនេះ នៅថ្នាក់ជាតិ ថ្នាក់ខេត្ត និងថ្នាក់មូលដ្ឋាន និងផ្តល់ធនធានហិរញ្ញវត្ថុគ្រប់គ្រាន់ដើម្បីឲ្យការអនុវត្តន៍នេះមានប្រសិទ្ធភាព។

៣០. គណៈកម្មាធិការស្នើយ៉ាងទទូចឲ្យរដ្ឋភាគីធ្វើការផ្អាកជាបណ្តោះអាសន្ននូវរាល់ការបណ្តេញចេញ រហូតដល់មានក្របខ័ណ្ឌច្បាប់ត្រឹមត្រូវ និងដំណើរការផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លីត្រូវបានបញ្ចប់ ដើម្បីធានាការការពារសិទ្ធិមនុស្សនៃប្រជាជនកម្ពុជាគ្រប់រូប ដោយរួមទាំងជនជាតិដើមភាគតិចផងដែរ។ គណៈកម្មាធិការផ្តល់អនុសាសន៍ឲ្យរដ្ឋភាគីធ្វើការពិគ្រោះយោបល់ជាបន្ទាន់ជាមួយស្ថាប័នជាដៃគូនានាដើម្បីឈានទៅបំពេញន័យនៃពាក្យ "ផលប្រយោជន៍សាធារណៈ" ដូចមានចែងក្នុងច្បាប់ភូមិបាលឆ្នាំ២០០១ និងបង្កើតគោលការណ៍ណែនាំមួយច្បាស់លាស់សំរាប់ការបណ្តេញចេញ ប្រសិនជាអាចមាន។ គណៈកម្មាធិការស្នើយ៉ាងទទូចផងដែរឲ្យរដ្ឋភាគី កំណត់ព្រំប្រទល់ឲ្យបានច្បាស់លាស់រវាងដីសាធារណៈរបស់រដ្ឋ និងដីឯកជនរបស់រដ្ឋ។ ដោយចាត់ទុកជាបញ្ហាអាទិភាព គណៈកម្មាធិការផ្តល់អនុសាសន៍យ៉ាងខ្លាំងថា រដ្ឋភាគីធ្វើការពិគ្រោះយោបល់ជាចំហ ដោយមានការចូលរួម និងប្រកបដោយអត្ថន័យជាមួយអ្នកភូមិ និងសហគមន៍នានាដែលរងផលប៉ះពាល់ជាមុន មុននឹងអនុវត្តគំរោងអភិវឌ្ឍន៍ និងគំរោងរៀបចំទីក្រុងជាថ្មី ហើយត្រូវធានាថា បុគ្គលទាំងឡាយដែលត្រូវបានបណ្តេញចេញដោយបង្ខំពីដីរបស់ខ្លួន ត្រូវបានផ្តល់សំណងសមរម្យ និង/ឬផ្តល់ជូនគាត់នូវទីតាំងថ្មី ស្របតាមគោលការណ៍ណែនាំដែលបានអនុម័តដោយគណៈកម្មាធិការ ក្នុងសេចក្តីពន្យល់ទូទៅរបស់ខ្លួនលេខ៧(១៩៩៧) ស្តីពីការបណ្តេញចេញដោយបង្ខំ និងធានាថាទីតាំងថ្មីត្រូវផ្តល់ឲ្យមានសេវាមូលដ្ឋានផ្សេងៗ រួមទាំងទឹកស្អាត ភ្លើងអគ្គីសនី សំភារៈសំរាប់ជុសសំអាត និងអនាម័យគ្រប់គ្រាន់ព្រមទាំងសេវាឯទៀត រួមមានសាលារៀន មណ្ឌលគាំពារសុខភាព និងមធ្យោបាយដឹកជញ្ជូននៅពេលធ្វើការតាំងទីលំនៅថ្មី។ គណៈកម្មាធិការទាញចំណាប់អារម្មណ៍ផងដែរដល់រដ្ឋភាគីចំពោះគោលការណ៍ណែនាំស្តីពីការបណ្តេញចេញ និងការធ្វើចំណាកស្រុក ផ្អែកលើការអភិវឌ្ឍន៍ (UN Doc. No. A/HRC /4/18) ដែលបានរៀបចំដោយអ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិស្តីពីសិទ្ធិមានលំនៅដ្ឋានសមរម្យ។

## *អ្នករាយការណ៍ពិសេស*

អនុសាសន៍ខាងក្រោមនេះ ដកស្រង់ចេញពី E/CN.4/2006/41/Add.3 រហូតដល់មានការបង្ហាញផ្សេងពីនេះ៖

៨២. ហេតុដូច្នេះ អ្នករាយការណ៍ពិសេសអះអាងយ៉ាងរឹងមាំឱ្យមានការអនុម័តយកវិធីសាស្រ្តអវិភាគភាពចំពោះសិទ្ធិ មានលំនៅដ្ឋានសមរម្យ និងសិទ្ធិដទៃទៀតទាក់ទងនឹងអាណត្តិរបស់លោក ហើយមានបំណងស្នើដាក់អនុសាសន៍ជាក់លាក់ដូចខាងក្រោម៖

(ក). មានតម្រូវការបន្ទាន់ឱ្យមានផែនទីច្បាស់លាស់ពីតម្រូវការផ្ទះសំបែងនៅក្នុងប្រទេស និងការបកស្រាយពីទិន្នន័យនេះពីទស្សនទានសិទ្ធិមនុស្ស សំដៅអភិវឌ្ឍន៍គោលនយោបាយផ្ទះសំបែងជាតិដ៏គ្រប់ជ្រុងជ្រោយមួយ។

(ខ). ទាក់ទងនឹងអនុសាសន៍មុនៗ ក៏មានតម្រូវការឱ្យបង្កើនតម្លាភាពក្នុងការអភិវឌ្ឍន៍គោលនយោបាយ និងការបើកចំហក្នុងការវាយតំលៃពីអាទិភាព និងលទ្ធផល ដោយបើកច្រកឱ្យមានការឃ្លាំមើលជាសាធារណៈ និងការចូលរួមពេញលេញពីប្រជាជនដែលរងផលប៉ះពាល់។

(គ). ត្រូវផ្តល់ការយកចិត្តទុកដាក់បន្ទាន់ដល់អ្នកទាំងឡាយណាដែលរស់នៅក្នុងលំនៅដ្ឋានយ៉ាប់យ៉ឺន និងលក្ខខណ្ឌរស់នៅមានការលំបាក រួមទាំងអ្នករស់នៅកន្លែងដែលមិនទាន់រៀបរយ និងអ្នករស់នៅកន្លែងតាំងទីលំនៅថ្មីដោយផ្តល់ឱ្យភ្លាមៗនូវគ្រឿងជួយសម្រួលជាមូលដ្ឋាន។

(ឃ). បទប្បញ្ញត្តិទាក់ទងនឹងលំនៅដ្ឋាននៃច្បាប់ភូមិបាលឆ្នាំ២០០១គួរត្រូវអនុវត្តភ្លាមៗ រួមទាំងបទប្បញ្ញត្តិទាំងឡាយនៃអនុក្រិត្យដែលទើបតែអនុម័តថ្មីៗ។ ច្បាប់នានាគួរតែត្រូវបានអនុម័តដែលមានបញ្ចូលបទប្បញ្ញត្តិស្តីពីស្ថានភាពលំនៅដ្ឋានរបស់គ្រួសាររស់នៅលើដីរដ្ឋ និងបំភ្លឺពីស្ថានភាពផ្លូវច្បាប់នៃការដោះដូរដីទាំងអស់ ដែលកើតឡើងរវាងច្បាប់ភូមិបាលឆ្នាំ២០០១ និងការអនុម័តច្បាប់នេះ។ បន្ថែមពីនេះ ព័ត៌មានពាក់ព័ន្ធនឹងការដោះដូរដីទាំងអស់ដែលស្ថិតក្រោមការចរចាគួរតែត្រូវបានលាតត្រដាងភ្លាមៗ។ ទន្ទឹមនឹងនេះ ក្រៅពីផ្អាកការដោះដូរទាំងអស់ គួរយកចិត្តទុកដាក់ឱ្យបានពេញលេញដល់គ្រួសារដែលបានរងផលប៉ះពាល់ ដើម្បីធានាការពារដល់លក្ខខណ្ឌមានលំនៅដ្ឋានសមរម្យ និងសន្តិសុខនៃការកាន់កាប់នៅកន្លែងតាំងទីលំនៅថ្មីរបស់ពួកគេ។ នៅពេលដែលការបណ្តេញចេញមិនទាន់អនុវត្តនៅឡើង គួរខិតខំប្រឹងប្រែងពិចារណាឱ្យបានជាក់ច្បាស់ពីការតាំងទីលំនៅថ្មីទុកជាដំណោះស្រាយចុងក្រោយ ហើយត្រូវធានាឱ្យមានការពិគ្រោះយោបល់ជាមួយសហគមន៍ដែលរងផលប៉ះពាល់។

(ង). ច្បាប់ស្តីពីការបណ្តេញចេញថ្នាក់ជាតិមួយគួរត្រូវបានអនុម័ត ស្របតាមបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ ជាពិសេស សេចក្តីពន្យល់ទូទៅលេខ៤ និងលេខ៧ របស់គណៈកម្មាធិការសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌។

(ច). តុលាការ និងគណៈកម្មការសុរិយោដី មានតួនាទីសំខាន់នៅក្នុងវិវាទផ្ទះសំបែង ហើយកិច្ចការរបស់ពួកគេគួរត្រូវបានពង្រឹងតាមរយៈការគោរពយ៉ាងតឹងរឹងនូវនីតិរដ្ឋ និងដំណើរការត្រឹមត្រូវ រួមទាំងការបង្កើតនីតិវិធីស៊ើបសួរដែលមិនលំអៀង ដើម្បីផ្ទៀងផ្ទាត់ពីយថាភូតនៃការទាមទារកម្មសិទ្ធិ និងការពិនិត្យឡើងវិញដោយមិនលំអៀង នូវសេចក្តីសម្រេចរដ្ឋបាល និងតុលាការ។

(ឆ). គួរបង្កើតគោលនយោបាយជាក់លាក់ ដើម្បីដោះស្រាយការរើសអើងប្រឆាំងស្ត្រីភេទ ទាក់ទងនឹងកម្មសិទ្ធិ និងសិទ្ធិទទួលបានស្មើគ្នានៃលំនៅដ្ឋាន និងដីធ្លី។ គោលនយោបាយបែបនេះ គួរដោះស្រាយពីផលប៉ះពាល់ដោយអសមាមាត្រយ៉ាងធ្ងន់ធ្ងរដែលការបណ្តេញចេញដោយបង្ខំ ការផ្លាស់ទី និងលក្ខខណ្ឌរស់នៅក្រីក្រមានចំពោះស្ត្រី។

(ជ). វិធានការនានាសំដៅដល់ការសម្រេចបានសិទ្ធិមានលំនៅដ្ឋានសមរម្យរបស់ជនជាតិដើមភាគតិច គួររួមបញ្ចូលការគោរពដីប្រពៃណីរបស់ពួកគេ និងការអធិប្បាយពីគោលនយោបាយផ្ទះសំបែង និងដីធ្លីដែលគិតគូរដល់វប្បធម៌របស់ពួកគេ។ រហូតដល់ការអនុម័តអនុក្រិត្យស្តីពីកម្មសិទ្ធិរួមនៃដីធ្លីជនជាតិដើមភាគតិច អាជ្ញាធរពាក់ព័ន្ធគួរពិចារណាផ្អាកជាបណ្តោះអាសន្ននូវការលក់ដីដែលប៉ះពាល់ដល់ជនជាតិដើមភាគតិច។

(ឈ). គួរអនុម័តវិធានការនានាដើម្បីសម្រួលដល់ការងារសិទ្ធិមនុស្ស និងការអភិវឌ្ឍអង្គការមិនមែនរដ្ឋាភិបាលនៅក្នុងប្រទេស ដោយគោរពយ៉ាងពេញលេញដល់សិទ្ធិសេរីភាពសមាគម ការសម្តែងមតិ និងការដើរហើរ។

៨៣. ឧបសគ្គនានាដែលរាំងស្ទះដល់ការអនុវត្តសិទ្ធិមានលំនៅដ្ឋានសមរម្យ គឺជាផ្នែកដ៏ធំមហិមានិងកំពុងជួបប្រទះនូវបញ្ហាប្រឈមនានា នឹងតម្រូវឱ្យមានកិច្ចខិតខំប្រឹងប្រែងរួមគ្នាមិនមែនតែរដ្ឋាភិបាលតែមួយនោះទេ តែរួមទាំងតួអង្គក្រៅរដ្ឋាភិបាលជាតិ និងសហគមន៍អន្តរជាតិផងដែរ។

A/HRC/7/42,Para.101. រដ្ឋាភិបាលត្រូវខិតខំឲ្យអស់លទ្ធភាពរបស់ខ្លួនដើម្បីបញ្ចប់ការបណ្តេញចេញដោយបង្ខំ។ រដ្ឋាភិបាលមិនត្រូវចូលរួមសហការក្នុងការបណ្តេញចេញដោយខុសច្បាប់នោះទេ។ គោលការណ៍ណែនាំដែលត្រូវបានទទួលស្គាល់ជាអន្តរជាតិ ត្រូវយកមកប្រតិបត្តិតាម រួមទាំងគោលការណ៍នានាដែលថាគ្មាននរណាម្នាក់ត្រូវបានធ្វើឲ្យគ្មានលំនៅដ្ឋាន ដោយសារតែការបណ្តេញចេញដើម្បីអភិវឌ្ឍន៍នោះឡើយ ត្រូវមានការឯកភាពទាំងស្រុង និងទទួលបានព័ត៌មានគ្រប់គ្រាន់ដោយអ្នកដែលត្រូវទទួលរងពីការបណ្តេញចេញ។ ការបណ្តេញចេញគួរតែអនុវត្តតែក្នុងកាលៈទេសៈពិសេស និងសំរាប់តែគោលបំណងនៃការលើកស្ទួយសុខុមាលភាពទូទៅ នៅក្នុងសង្គមប្រជាធិបតេយ្យ។ ការប្រើប្រាស់កំលាំងត្រូវបានហាមឃាត់។ គ្មាននរណាម្នាក់ត្រូវបានជាប់ពន្ធនាគារដោយសារតែការការពារសិទ្ធិដីធ្លី និងលំនៅដ្ឋានរបស់ខ្លួនឡើយ ហើយនរណាក៏ដោយដែលត្រូវបានឃុំខ្លួននៅក្នុងបរិបទនេះ គួរត្រូវបានដោះលែង។ ការផ្អាកជាបណ្តោះអាសន្ននូវការបណ្តេញចេញដោយបង្ខំ គួរត្រូវបានប្រកាសឲ្យដឹងជាសាធារណៈដើម្បីទុកលទ្ធភាពដល់ការសម្រេចពីនីត្យានុកូលនៃការទាមទារដីធ្លី តាមលក្ខណៈមួយត្រឹមត្រូវ និងសត្យានុម័ត។

A/HRC/21/63/Add.1/Rev.1.Para.215. ដីធ្លីដែលត្រូវបានកាន់កាប់ជាប្រពៃណីដោយជនជាតិដើមភាគតិចគួរតែត្រូវបានគូសវាសផែនទីនិងវាស់វែងព្រំឲ្យបានឆាប់រហ័ស។ គ្មានដីសម្បទានណាគួរត្រូវបានផ្តល់ឲ្យនៅលើដី ឬក្បែរដីសហគមន៍របស់ជនជាតិដើមភាគតិចទេ រហូតដល់ពេល*ក្រោយបញ្ចប់*ដំណើរការទទួលស្គាល់ការចុះបញ្ជី និងការអនុវត្តប័ណ្ណកម្មសិទ្ធិដីសហគមន៍រួចរាល់។ សារាចរអន្តរក្រសួងឆ្នាំ២០១១ ស្តីពីវិធានការការពារបណ្តោះអាសន្ន គួរយកមកអនុវត្តឲ្យបានតឹងរឹង សំរាប់សហគមន៍ទាំងឡាយណា ដែលត្រូវបានទទួលស្គាល់ដោយក្រសួងអភិវឌ្ឍន៍ជនបទ និងក្រសួងមហាផ្ទៃ ហើយដំណើរការចុះបញ្ជីដីសហគមន៍ ត្រូវបានធ្វើឲ្យបានឆាប់ ដើម្បីជៀសវាងវិវាទបន្ថែមទៀត។

A/HRC/21/63/Add.1/Rev.1.Para.219. ការបណ្តេញចេញ និងការតាំងទីលំនៅថ្មី គួរយកមកប្រើប្រាស់តែក្នុងករណីចុងក្រោយប៉ុណ្ណោះ ហើយការផ្អាកជាបណ្តោះអាសន្ននូវការបណ្តេញចេញដោយបង្ខំ គួរតែយកមកអនុវត្តចំពោះសកម្មភាពដីសម្បទានទាំងអស់។ ចំពោះការរំលោភបំពានពីអតីតកាល គួរធ្វើការខិតខំប្រឹងប្រែងទាំងអស់ដើម្បីធានាពីការកែសម្រួលលើបញ្ហានេះវិញ។ ពេលណាអនុវត្តបានតាមដំណើរការត្រឹមត្រូវតាមនីតិវិធី ហើយការបណ្តេញចេញត្រូវបានមើលឃើញថាស្របច្បាប់ និងក្នុងផលប្រយោជន៍សាធារណៈ គ្រួសារដែលរងផលប៉ះពាល់គួរត្រូវបានពិគ្រោះយោបល់ថាត្រូវធ្វើដូចម្តេច និងនៅពេលណាដែលការតាំងទីលំនៅថ្មីនឹងកើតឡើង ហើយត្រូវខិតខំប្រឹងប្រែងទាំងអស់ដើម្បីធានាថា ការបណ្តេញចេញត្រូវបានអនុវត្តតាមលក្ខខណ្ឌនានាដែលប្រកាន់ខ្ជាប់តាមបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ ទាក់ទងនឹងការមានលំនៅដ្ឋានសមរម្យ ព្រមទាំងសំណងត្រឹមត្រូវ និងយុត្តិធម៌។ គួរខិតខំប្រឹងប្រែងថែមទៀត ដើម្បីកសាងឡើងវិញនូវឱកាសជីវភាពរស់នៅ។

A/HRC/18/46. Para. 92. រដ្ឋាភិបាលត្រូវបានស្នើយ៉ាងទទូច ឲ្យពង្រឹងការអនុវត្តន៍បញ្ញត្តិដែលមានស្រាប់នៃច្បាប់ភូមិបាលឆ្នាំ២០០១ ដែលហាមប្រាមការជ្រៀតជ្រែករំខានលើដីជនជាតិដើមភាគតិច និងពន្លឿនសន្ទុះនៃការចុះបញ្ជីដី ដើម្បីឲ្យជនជាតិដើមភាគតិចទទួលបានប័ណ្ណកម្មសិទ្ធិសមូហភាព។ រដ្ឋាភិបាលគួរតែអនុវត្តវិធានការការពារជាបណ្តោះអាសន្នលើដីទាំងអស់ ដែលសហគមន៍ជនជាតិដើមភាគតិចទាំងឡាយកំពុងរស់នៅ រហូតដល់ដំណើរការចុះបញ្ជីដីចប់សព្វគ្រប់ ហើយពួកគាត់ទទួលបានប័ណ្ណកម្មសិទ្ធិរួចសិន។

A/HRC/27/70, Para. 81(n). ដោះស្រាយភ្លាមៗនូវជម្លោះដែលកំពុងមានវិវាទទាក់ទងនឹងសិទ្ធិមានដីធ្លី ទុកជាបញ្ហាអទិភាពមួយ ហើយធានាទាំងក្នុងច្បាប់ ទាំងក្នុងការអនុវត្តថា ការផ្តល់ដីសម្បទានថ្មីអាចធ្វើបាន តែក្នុងករណីដែលសិទ្ធិរបស់ប្រជាពលរដ្ឋដែលរងផលប៉ះពាល់ត្រូវបានផ្តល់ឱ្យ សំរាប់ការពិនិត្យឡើងវិញពីកន្លែងតាំងទីលំនៅថ្មីទាំងអស់ ដើម្បីបំពេញបានភ្លាមៗតាមស្តង់ដារសិទ្ធិមនុស្ស ហើយត្រូវហាមឃាត់រាល់ការតាំងទីលំនៅថ្មីដោយបង្ខំនាពេលអនាគតទៅលើទីតាំងណាដែលមិនបានបំពេញតាមស្តង់ដារទាំងនេះ។

A/HRC/33/62 Para 61 (c). អនុវត្តយុទ្ធវិធីគ្រប់ជ្រុងជ្រោយចំពោះបញ្ហាទាំងអស់ដែលមានផលប៉ះពាល់ដល់ជនជាតិដើមភាគតិច ដោយធានាឱ្យមានការពិគ្រោះយោបល់ដ៏ពិតប្រាកដ អំពីសេចក្តីសម្រេចទាំងអស់ដែលប៉ះពាល់ដល់ពួកគេ។ ប្រសិនបើតម្រូវឱ្យមានការតាំងទីលំនៅថ្មី ត្រូវអនុវត្តការពិគ្រោះយោបល់ដ៏ពិតប្រាកដ ដើម្បីធានាថាជនជាតិដើមភាគតិចបានដឹងជាមុន និងផ្តល់ការយល់ព្រមដោយសេរីដល់ការតម្រូវពីការតាំងទីលំនៅថ្មីណាមួយ ហើយត្រូវពិចារណាដោយម៉ត់ចត់ ពីលទ្ធភាពតាមជម្រើសផ្សេងដែលស្នើដោយសហគមន៍នានា។

A/HRC/33/62 Para 61 (d). ពន្លឿនការផ្តល់ប័ណ្ណកម្មសិទ្ធិសហគមន៍ដល់ជនជាតិដើមភាគតិច ចេញនិងអនុវត្តវិធានការបណ្តោះអាសន្ន និងពិចារណាពីការធ្វើឱ្យកាន់តែងាយស្រួលដល់ដំណើរការនៃការសុំប័ណ្ណ។

## ខ. ដំណើរការដីធ្លីដោយមានតម្លាភាព និងមានការចូលរួម

| *អនុសាសន៍នៃការពិនិត្យជាសកលតាមកាលកំណត់* (២០១៤) |
|---|
| **១១៨.១៣១.** បន្តកិច្ចខិតខំប្រឹងប្រែងនៅក្នុងបញ្ហាដីធ្លី រួមទាំងតាមរយៈការអនុវត្តប្រកបដោយប្រសិទ្ធភាព និងតម្លាភាពនូវការបែងចែកដីធ្លី។ (បារាំង) |
| *អនុសាសន៍នៃការពិនិត្យជាសកលតាមកាលកំណត់* (២០០៩) |
| **៦២.** លើកស្ទួយក្របខ័ណ្ឌច្បាប់ ដែលផ្តល់ភាពប្រាកដប្រជាតាមផ្លូវច្បាប់ក្នុងបញ្ហាទ្រព្យសម្បត្តិ ជាពិសេស កម្មសិទ្ធិដីធ្លី និងការការពារប្រឆាំងនឹងការបណ្តេញចេញដោយបង្ខំ។ (ម៉ិចស៊ីកូ)<br>**៦៨.** ចូលរួមពិភាក្សាជាមួយសង្គមស៊ីវិលពាក់ព័ន្ធ ក្នុងគោលបំណងដំណោះស្រាយករណីរំលោភយកដីធ្លី និងការបណ្តេញចេញពីដីធ្លីខុសច្បាប់។ (ហូឡង់ដ៍) |

| |
|---|
| ***គណៈកម្មាធិការសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌*** E/C.12/KHM/CO/1(២០០៩) |
| ២៩. គណៈកម្មាធិការស្នើឲ្យរដ្ឋភាគីអនុម័តជាបញ្ហាអាទិភាពនូវគោលនយោបាយជាតិស្តីពីផ្ទះសម្បែង ដែលលើកកំពស់ប្រជាជនក្រីក្ររស់នៅទីក្រុង និងធានាសុវត្ថិភាពកាន់កាប់ដីធ្លី ផ្ទះសម្បែងដែលត្រូវមានស្ថាប័នច្បាស់លាស់ទទួលខុសត្រូវអនុវត្តការងារនេះ នៅថ្នាក់ជាតិ ថ្នាក់ខេត្ត និងថ្នាក់មូលដ្ឋាន និងផ្តល់ធនធានហិរញ្ញវត្ថុគ្រប់គ្រាន់ដើម្បីឲ្យការអនុវត្តន៍នេះមានប្រសិទ្ធភាព។ |
| ***អ្នករាយការណ៍ពិសេស*** |
| A/HRC/ 15/46. Para.94. រដ្ឋាភិបាល និងស្ថាប័នរដ្ឋផ្សេងៗ គួរទទួលស្គាល់ពីសារៈសំខាន់នៃការអនុវត្តន៍តាមការបែងចែកការងាររវាងគណៈកម្មាធិការសុរិយោដី និងតុលាការនានា អនុលោមតាមបទប្បញ្ញត្តិក្នុងមាត្រា៤៧ នៃច្បាប់ភូមិបាលឆ្នាំ២០០១។<br><br>A/HRC/18/46.Para. 89. រដ្ឋាភិបាលត្រូវបានជំរុញលើកទឹកចិត្តឲ្យពិនិត្យមើលនិន្នាការបច្ចុប្បន្ននៃទំនាស់ដីធ្លីមួយចំនួន ដែលមិនទាន់ដោះស្រាយក្នុងប្រទេស និងដោះស្រាយលំនាំធ្ងន់ធ្ងរនៃអំពើហិង្សា តាមរយៈការជួយសម្រួលឲ្យមានកិច្ចសន្ទនាគ្នារវាងសហគមន៍ដែលរងផលប៉ះពាល់ អាជ្ញាធរជាតិ អាជ្ញាធរខេត្ត អាជ្ញាធរមូលដ្ឋាន និងសហគ្រាសឯកជននានា។<br><br>A/HRC/18/46.Para.90. រដ្ឋាភិបាលគួរតែចូលរួមពិគ្រោះយោបល់ប្រកបដោយអត្ថន័យជាមួយប្រជាពលរដ្ឋដែលរងផលប៉ះពាល់ដោយជំលោះដីធ្លី អំពីសំណងសមរម្យ ឬជំរើសផ្សេងៗ មានដូចជា ការផ្តល់លំនៅដ្ឋានសមរម្យប្រសិនជាអាចធ្វើបាន។ អាជ្ញាធរនានាគួរតែគោរព និងការពារសិទ្ធិប្រជាពលរដ្ឋទាំងនេះ រាប់ទាំងតាមរយៈការធានាថា ពួកគេមិនស្ថិតក្នុងកម្មវត្ថុនៃការប្រើប្រាស់កំលាំងហួសហេតុ ការឃាំឃ្លាំង និងការបំភិតបំភ័យដែលពួកគេអាចប្រើប្រាស់សិទ្ធិរបស់ខ្លួនស្តីពីបាតុកម្មដោយសន្តិវិធី ហើយថាការចោទប្រកាន់ពីបទបរិហារកេរ្តិ៍ ការផ្សាយព័ត៌មានពិត និងការញុះញង់ មិនត្រូវបានធ្វើតាមទំនើងចិត្តឡើយ។<br><br>A/HRC/24/36. Para. 72. គួរចាត់វិធានការបន្ថែមទៀតដើម្បីអនុវត្តសិទ្ធិទទួលបានដំណោះស្រាយសមស្របទាក់ទងនឹងទំនាស់ដីធ្លី ទោះជាធ្វើឡើងតាមរយៈការពង្រឹងយន្តការដោះស្រាយវិវាទផ្លូវការ និងថ្នាក់ជាតិដែលធានាការពង្រឹងការពិនិត្យលើសហគ្រាសពាណិជ្ជកម្មដែលជាភាគីវិវាទ ឬតាមរយៈការពង្រឹងការទប់ស្កាត់កុំឲ្យមានវិវាទកើតឡើង និងសមត្ថភាពពិគ្រោះយោបល់របស់មន្ត្រី និងកងកម្លាំងប្រដាប់អាវុធក្នុងការដោះស្រាយជាមួយសហគមន៍ដែលរងផលប៉ះពាល់ក្តី។<br><br>A/HRC/21/63/Add.1/Rev.1. Para.206. ប្រព័ន្ធសម្របសម្រួល និងមានការចូលរួមបន្ថែមទៀតចំពោះការផ្តល់ដីសម្បទានគួរត្រូវយកមកពិចារណាដោយរដ្ឋាភិបាល និងត្រូវយកមកអនុវត្តដោយអាជ្ញាធរមូលដ្ឋាន រួមទាំងយកចិត្តទុកដាក់ដល់ដំណើរការផែនការនៅថ្នាក់ខេត្តនិងថ្នាក់ជាតិ។ វិធីសាស្រ្តគួរមានការចូលរួម ហើយដំណើរការអភិវឌ្ឍន៍គួរមានការដាក់បញ្ចូល ស្របតាមផែនការអភិវឌ្ឍន៍យុទ្ធសាស្រ្តជាតិដែលបានធ្វើបច្ចុប្បន្នភាព (២០០៩-២០១៣)។ |

| |
|---|
| A/HRC/33/62 Para 61 (n). ចាត់វិធានការនានាដើម្បីធានាថា ជម្លោះដីធ្លីត្រូវបានដោះស្រាយភ្លាមៗ ដោយត្រឹមត្រូវ និងជាស្ថាពរ ហើយត្រូវធ្វើឱ្យទៅជាស្តង់ដារ និងបោះពុម្ពផ្សាយនូវឱកាសនៃដំណោះស្រាយជម្លោះ ដើម្បីកាត់បន្ថយភាពច្រំដែល និងសេចក្តីសម្រេចដែលមានវិវាទគ្នាធ្វើដោយស្ថាប័នផ្សេងៗគ្នា។<br><br>A/HRC/33/62 Para 61 (o). នៅក្នុងករណីដែលសហគមន៍ត្រូវតែធ្វើការតាំងទីលំនៅថ្មី ត្រូវធានាថា ផែនការតាំងទីលំនៅថ្មីមានលក្ខណៈគ្រប់ជ្រុងជ្រោយ រួមមានការពិចារណាពីស្បៀងអាហារ ទឹក ការងារ ការអប់រំ និងការថែទាំសុខភាព ហើយត្រូវចាត់វិធានការផ្តល់ការបណ្តុះបណ្តាលបន្ថែមទៀត តាមការចាំបាច់ ព្រមទាំងផ្តល់សិទ្ធិឱ្យទទួលបានស្បៀងអាហារ ទឹក និងឋាមពល ខណៈដែលសហគមន៍ធ្វើចំការ នេសាទ និងជំនាញប្រាតិភោគរបស់ខ្លួន ឱ្យដល់កំរិតចេរភាពមួយ។<br><br>A/HRC/33/62 Para 61 (p). ទាមទារ និងអនុវត្តលក្ខខណ្ឌតម្រូវឱ្យមានកិច្ចពិគ្រោះយោបល់ដ៏មានអត្ថន័យថែមទៀតជាមុនជាមួយសហគមន៍ ក្នុងករណីដែលមានតម្រូវឱ្យមានការតាំងទីលំនៅថ្មី។ |

## គ. ដីសម្បទាន

| *អនុសាសន៍នៃការពិនិត្យជាសកលតាមកាលកំណត់* (២០១៤) |
|---|
| ១១៨.១៣២. ធានាថា ការផ្តល់ដីសម្បទាន ឬការដកហូតកម្មសិទ្ធិដី ឬសិទ្ធិស្របច្បាប់ក្នុងការប្រើប្រាស់ដីធ្លី មិននាំឲ្យមានការរំលោភបំពានសិទ្ធិមនុស្សនោះទេ។ (អាល្លឺម៉ង់) |
| *គណៈកម្មាធិការលុបបំបាត់ការរើសអើងពូជសាសន៍* CERD/C/KHM/CO/8-13 (២០១០) |
| ១៦. គណៈកម្មាធិការផ្តល់អនុសាសន៍ទៀតថា រដ្ឋភាគីតាក់តែងវិធានការសមស្របស្តីពីវិធានការបង្ការដូចជា៖<br><br>(១). ការពន្យាពេលផ្តល់សម្បទានលើដីធ្លីដែលសហគមន៍ជនជាតិដើមភាគតិចរស់នៅ ដែលគាត់បានដាក់ពាក្យសុំចុះបញ្ជីតាមផ្លូវច្បាប់ ដើម្បីទទួលបានប័ណ្ណកម្មសិទ្ធិដីធ្លី<br><br>(២). ការផ្តល់ដីសម្បទានត្រូវរង់ចាំដល់ការចេញប័ណ្ណកម្មសិទ្ធិសមូហភាព និងសិទ្ធិរបស់ជនជាតិដើមភាគតិចក្នុងការកាន់កាប់ ការអភិវឌ្ឍន៍ ការគ្រប់គ្រង និងការប្រើប្រាស់ដីសហគមន៍របស់ខ្លួនត្រូវបានផ្តល់<br><br>(៣). ការផ្តល់សម្បទានអាចធ្វើបាននៅតំបន់ដែលមានការវាយតំលៃ និងការពិគ្រោះយោបល់ដោយការយល់ព្រមពីជនជាតិដើមភាគតិច និងដោយគ្មានការបោកបន្លំ ឬដែលគាត់បានដឹងច្បាស់ពីផលវិបាកនៅថ្ងៃអនាគត។<br><br>គណៈកម្មាធិការបន្តជំរុញលើកទឹកចិត្តដល់ក្រុមហ៊ុនសាជីវកម្មទាំងអស់ថា នៅពេលចូលពាក់ព័ន្ធក្នុងបញ្ហាសម្បទានដីសេដ្ឋកិច្ច ត្រូវគិតគូរអំពីការទទួលខុសត្រូវផ្នែកសង្គមរបស់ក្រុមហ៊ុន ព្រោះការងារនេះវាទាក់ទងដល់សិទ្ធិ និងសុខមាលភាពរបស់ប្រជាពលរដ្ឋមូលដ្ឋាន ។ |

| *គណៈកម្មាធិការសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌* (២០០៩) E/C.12/KHM/CO/1 |
| --- |
| ១៥. គណៈកម្មាធិការស្នើយ៉ាងទទូចដល់រដ្ឋភាគីឲ្យពិនិត្យឡើងវិញនូវគោលនយោបាយរបស់ខ្លួន ពាក់ព័ន្ធនឹងការបង្វែរតំបន់ការពារ ឲ្យទៅជាសម្បទានសេដ្ឋកិច្ច ដោយមិនបានធ្វើការវាយតំលៃពីផលប៉ះពាល់ខាងសង្គម និងបរិស្ថានជាមុន ជាមួយស្ថាប័នជាដៃគូពាក់ព័ន្ធ និងសហគមន៍នានា ដោយគោរពយ៉ាងត្រឹមត្រូវចំពោះសិទ្ធិរបស់ពួកគាត់ ដើម្បីចូលរួមក្នុងការសំរេចផ្សេងៗដែលពួកគាត់ត្រូវតែបានដឹងជាមុនអំពីបញ្ហាទាំងឡាយដែលប៉ះពាល់ដល់ការរស់នៅរបស់ខ្លួន។ គណៈកម្មាធិការផ្តល់ជាអនុសាសន៍យ៉ាងខ្លាំងថា ការផ្តល់សម្បទានសេដ្ឋកិច្ចគួរតែគិតគូរអំពីសេចក្តីត្រូវការសំរាប់ការអភិវឌ្ឍន៍ប្រកបដោយចិរភាព និងដើម្បីឲ្យប្រជាជនកម្ពុជាគ្រប់រូបទទួលបានអត្ថប្រយោជន៍ពីការរីកចំរើននេះ ជាជាងសំរាប់តែផលប្រយោជន៍របស់បុគ្គលឯកជន។ គណៈកម្មាធិការស្នើឲ្យរដ្ឋភាគីបញ្ចូលក្នុងរបាយការណ៍ តាមកាលកំណត់លើកក្រោយរបស់ខ្លួន នូវព័ត៌មានលំអិតស្តីពីសមិទ្ធិផលដែលសំរេចបានក្នុងការអនុវត្តន៍គោលនយោបាយទាំងនេះ។<br>១៦. គណៈកម្មាធិការស្នើយ៉ាងទទូចដល់រដ្ឋភាគីឲ្យអនុវត្តច្បាប់ភូមិបាលឆ្នាំ២០០១ ដោយមិនត្រូវអូសបន្លាយពេលវេលាតទៅទៀត និងធានាថាគោលនយោបាយរបស់ខ្លួនស្តីពីការចុះបញ្ជីដី មិនត្រូវឲ្យផ្ទុយនឹងស្មារតីនៃច្បាប់នេះឡើយ។ គណៈកម្មាធិការបញ្ជាក់អំពីសេចក្តីត្រូវការឲ្យមានការវាយតំលៃអំពីផលប៉ះពាល់ខាងសង្គម និងបរិស្ថាន និងការពិគ្រោះយោបល់ជាមួយសហគមន៍នានា ដែលរងផលប៉ះពាល់ពាក់ព័ន្ធនឹងសកម្មភាពសេដ្ឋកិច្ច រួមទាំង ការធ្វើអាជីវកម្មរ៉ែ និងអាជីវកម្មប្រេង ក្នុងគោលដៅធានាថា សកម្មភាពទាំងនេះ មិនត្រូវដកហូតពីជនជាតិដើមភាគតិចនូវការទទួលបានយ៉ាងពេញលេញនូវសិទ្ធិរបស់ពួកគាត់លើដីធ្លី និងធនធានធម្មជាតិនៃបុព្វបុរសរបស់ខ្លួនឡើយ។ គណៈកម្មាធិការ ជំរុញលើកទឹកចិត្តឲ្យរដ្ឋភាគី ពិចារណាផ្តល់សច្ចាប័នលើអនុសញ្ញាលេខ១៦៩ របស់អង្គការពលកម្មអន្តរជាតិស្តីពីជនជាតិដើមភាគតិច និងក្រុមកុលសម្ព័ន្ធ។ |
| *អ្នករាយការណ៍ពិសេស* |
| A/HRC/18/46. Para. 91. រដ្ឋាភិបាលត្រូវបានផ្តល់ប្រឹក្សាយោបល់ឲ្យបង្កើតតម្លាភាពច្រើនថែមទៀត ក្នុងការផ្តល់សម្បទានដីសេដ្ឋកិច្ច និងការចុះកិច្ចព្រមព្រៀងដីធ្លីជាមួយមន្ត្រីរដ្ឋាភិបាល ឬសហគ្រាសឯកជននានា និងសូមជំរុញលើកទឹកចិត្តឲ្យពង្រឹងសមត្ថភាព និងឯករាជ្យភាពនៃប្រព័ន្ធតុលាការ គណៈកម្មការសុរិយោដី និងអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី ដើម្បីឲ្យស្ថាប័នទាំងនេះអនុវត្តដោយគណៈនេយ្យភាព ភាពមិនលំអៀង និងប្រសិទ្ធភាពថែមទៀត ក្នុងការដោះស្រាយទំនាស់ផ្សេងៗ។<br>A/HRC/24/36. Para. 70. ការសន្យាថាត្រួតពិនិត្យឡើងវិញលើសម្បទានដីសេដ្ឋកិច្ច និងសម្បទានដីផ្សេងទៀតដែលមានស្រាប់ គួរតែធ្វើឡើងជាអាទិភាព និងជាប្រយោជន៍របស់ប្រជាពលរដ្ឋ ដែលទទួលរងផលប៉ះពាល់ដោយសារសម្បទានទាំងនេះ គួរតែជាបញ្ហាចម្បងសំរាប់ការត្រួតពិនិត្យឡើងវិញនេះ។ |

A/HRC/24/36. Para. 71. គួរផ្តល់ការយកចិត្តទុកដាក់ថែមទៀតទៅលើការពង្រឹងសិទ្ធិទទួលបានព័ត៌មាន និងតម្លាភាពចំពោះបញ្ហាមួយចំនួន រួមទាំងការពិគ្រោះយោបល់ និងការត្រួតពិនិត្យ ស្របតាមអនុសាសន៍ដែលបានលើកឡើងក្នុងរបាយការណ៍របស់អ្នករាយការណ៍ពិសេសស្តីពីការផ្តល់ និងការគ្រប់គ្រងសម្បទានដីសេដ្ឋកិច្ច និងសម្បទានដីផ្សេងទៀត។

A/HRC/21/63/Add.1/Rev.1. Para. 223. អាជ្ញាធរដែលមានអំណាចផ្តល់សម្បទាន គួរប្រឹងប្រែងឲ្យអស់ពីសមត្ថភាព ដើម្បីការពារសកម្មភាពនានានៅតាមតំបន់វប្បធម៌ និងទីកន្លែងសក្ការៈ ព្រមទាំងដោះស្រាយ (តាមរយៈការផ្សះផ្សារឡើងវិញ) ពីផលប៉ះពាល់ធ្ងន់ធ្ងរដែលកើតឡើងរួចមកហើយ។ ក្រសួងពាក់ព័ន្ធ ដូចជាក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ អាចចូលអន្តរាគមន៍ដោះស្រាយពីផលប៉ះពាល់ទាំងនេះ។

A/HRC/21/63/Add.1/Rev.1. Para.229. ក្នុងករណីផ្តល់ដីសម្បទានចំដីដែលកាន់កាប់ និងប្រើប្រាស់ជាប្រពៃណីដោយជនជាតិដើមភាគតិច ត្រូវធ្វើបដិទានកម្ម និងប្រគល់សងវិញតាមតែអាចធ្វើបាន ដោយផ្តល់ឱកាសឲ្យសហគមន៍ទាំងនោះចុះបញ្ជីជានីតិបុគ្គល និងអាចសុំកាន់កាប់ជាដីសហគមន៍បាន។

A/HRC/27/70 Para 81 (n). [...] ធានាទាំងក្នុងច្បាប់ ទាំងក្នុងការអនុវត្តថា ការផ្តល់ដីសម្បទានថ្មី អាចធ្វើបានតែនៅពេលណាដែលសិទ្ធិរបស់ប្រជាជនដែលរងផលប៉ះពាល់ត្រូវបានផ្តល់ឱ្យ [...].

## XI. សុខភាព និងការអប់រំ សំណាញ់សុវត្ថិភាព និងក្រុមងាយរងគ្រោះ ក្រុមជនភាគតិច

### *ក. សុខភាព រួមទាំង HIV*

| *អនុសាសន៍នៃការពិនិត្យជាសកលតាមកាលកំណត់ (២០១៤)* |
|---|
| **១១៨.១៤៧.** គាំទ្របន្ថែមទៀតដល់ការអភិវឌ្ឍវិស័យសុខាភិបាល ដោយយកចិត្តទុកដាក់ជាពិសេសដល់តំបន់ជនបទ ដែលភាពអាចរកបាន ការទទួលបានគុណភាព និងការប្រើប្រាស់សេវាកម្មសុខភាព នៅតែមានកំរិត ក្នុងកិច្ចខិតខំប្រឹងប្រែងមួយដើម្បីលើកស្ទួយនិងការពារសិទ្ធិមនុស្សរបស់ប្រជាពលរដ្ឋរបស់ខ្លួនបន្ថែមទៀត។ (ប៉ាឡេស្ទីន) |
| **១១៨.១៤៨.** បង្កើនកិច្ចខិតខំប្រឹងប្រែងជាបន្ត សំដៅលើកកម្ពស់សិទ្ធិទទួលបានសុខភាពប្រកបដោយសមធម៌សម្រាប់ប្រជាជនកម្ពុជាគ្រប់រូប។ (ទីម័រខាងកើត) |
| **១១៨.១៥០.** ផ្តល់ការព្យាបាលដោយឥតគិតថ្លៃដល់ស្រ្តី និងបុរសដែលរស់នៅជាមួយមេរោគអេដស៍/ជំងឺអេដស៍ ដើម្បីបង្ការការចម្លងពីម្តាយទៅកូន។ (អ៊ុយរុយហ្គាយ) |
| **១១៨.១៥១.** បង្កើនការផ្សព្វផ្សាយព័ត៌មានអំពីសុខភាពផ្លូវភេទ និងសុខភាពបន្តពូជ រួមទាំងមធ្យោបាយការពារកំណើតទំនើប ជាពិសេស សម្រាប់ស្ត្រីដែលរស់នៅតំបន់ជនបទ។ (អ៊ុយរុយហ្គាយ) |
| **១១៨.១៥២.** បន្តកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួន ក្នុងការសម្រេចឲ្យបានគោលដៅអភិវឌ្ឍន៍សហស្សវត្ស ជាពិសេសនៅក្នុងវិស័យសុខាភិបាលនៃប្រជាជនរបស់ខ្លួន។ (វេណេហ្ស៊ុយអេឡា (សាធារណរដ្ឋបូលីវ៉ា)) |
| **១១៨.១៥៣.** បន្តអនុម័តគោលនយោបាយសង្គមប្រកបដោយប្រសិទ្ធភាពស្តីពីការទទួលបានសេវាអប់រំ និងសុខភាព ជាពិសេសសម្រាប់ស្ត្រី និងកុមារ។ (វេណេហ្ស៊ុយអេឡា (សាធារណរដ្ឋបូលីវ៉ា)) |
| **១១៨.១៥៤.** បន្តកែលម្អគុណភាពសេវាសុខភាពរបស់ខ្លួន តាមរយៈការអនុវត្តផែនការយុទ្ធសាស្ត្រសុខាភិបាលជាតិរបស់ខ្លួន។ (ប្រ៊ុយណេដារូសាឡាម) |
| **១១៨.១៥៥.** បន្តយកចិត្តទុកដាក់ដល់សិទ្ធិទទួលបានសុខភាពរបស់កុមារ មនុស្សចាស់ ក្រុមជនក្រីក្រ និងក្រុមជនងាយរងគ្រោះដទៃទៀត។ (ចិន) |
| **១១៨.១៥៦.** បន្តលើកកម្ពស់ការអភិវឌ្ឍវិស័យសុខាភិបាលប្រកបដោយចីរភាព ដោយផ្តល់អាទិភាពដល់ភាពជាដៃគូជាមួយសហគមន៍ជាតិ ក្នុងការផ្តល់សេវាសុខភាពដល់ប្រជាពលរដ្ឋគ្រប់រូប។ (សាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យកូរ៉េ) |
| **១១៨.១៥៧.** មិនត្រឹមតែបន្ត ថែមទាំងពង្រឹងគោលនយោបាយ និងកម្មវិធីនានា ដែលជួយសម្រួលដល់ការទទួលបានសេវាថែទាំសុខភាពសម្រាប់ជនងាយរងគ្រោះ។ (សេនេហ្គាល់) |

| |
|---|
| **១១៨.១៦០.** លើកកម្ពស់ការទទួលបានការអប់រំ និងសេវាថែទាំសុខភាពដោយឥតគិតថ្លៃ ជាពិសេស នៅតាមតំបន់ជនបទ រួមទាំងតាមរយៈកិច្ចសហការដែលត្រូវបង្កើនឡើងជាមួយប្រទេសជិតខាង និងដៃគូអភិវឌ្ឍន៍។ (ថៃ) |
| *អនុសាសន៍នៃការពិនិត្យជាសកលតាមកាលកំណត់* (២០០៩) |
| **៩១. ង).** សូមពង្រឹងភាពជាដៃគូរបស់ខ្លួនជាមួយសហគមន៍អន្តរជាតិ ក្នុងគោលបំណងធ្វើឲ្យប្រសើរឡើង ដល់សុខភាពសាធារណៈរបស់ប្រទេស។ (អង់ហ្គោឡា) |
| *គណៈកម្មាធិការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ* (២០១៣)<br>CEDAW/C/KHM/CO/4-5 |
| **៣៧.** គណៈកម្មាធិការអំពាវនាវឲ្យរដ្ឋភាគី៖<br>(ក). ធានាថា មធ្យោបាយរំលូតកូនទំនើបដែលមានសុវត្ថិភាពផ្នែកវេជ្ជសាស្ត្រ អាចរកបាន និងអាចប្រើប្រាស់ស្របតាមអនុសាសន៍ទូទៅលេខ២៤(ឆ្នាំ២០០៤) ស្តីពីស្ត្រី និងកុមារ<br>(ខ). ផ្តល់ការព្យាបាល ដោយផ្តល់ថ្នាំប្រឆាំងនឹងមេរោគអេដស៍ដល់ស្ត្រី និងបុរសដែលផ្ទុកមេរោគអេដស៍/ជំងឺអេដស៍ រាប់បញ្ចូលទាំងស្ត្រីរកស៊ីផ្លូវភេទ និងស្ត្រីមានផ្ទៃពោះ ដើម្បីបង្ការការចម្លងរោគអេដស៍ពីម្តាយទៅកូន<br>(គ). ប្រយុទ្ធប្រឆាំងរាល់ទម្រង់នៃការរើសអើងលើស្ត្រីមានផ្ទៃពោះដែលផ្ទុកមេរោគអេដស៍ និង<br>(ឃ). បង្កើនការផ្តល់ព័ត៌មាននិងសេវាសុខភាពផ្លូវភេទ និងសុខភាពបន្តពូជដល់ស្ត្រី រាប់បញ្ចូលទាំងមធ្យោបាយពន្យារកំណើតទំនើប ជាពិសេស ដល់ស្ត្រីដែលរស់នៅតំបន់ជនបទ។<br>**៣៩.** គណៈកម្មាធិការផ្តល់អនុសាសន៍ឲ្យរដ្ឋភាគី៖<br>(ក). ពង្រឹងការអនុវត្តកម្មវិធី និងគោលនយោបាយដែលមានគោលបំណងផ្តល់សេវាថែទាំសុខភាពដែលមានតម្លៃសមស្របដល់ស្ត្រី ជាពិសេស ស្ត្រីក្រីក្រ ស្ត្រីពិការ និងស្ត្រីចាស់ជរា និង<br>(ខ). យកចិត្តទុកដាក់ជាពិសេសចំពោះតម្រូវការផ្នែកសុខភាពរបស់ស្ត្រីពិការ ដោយធានាថាស្ត្រីទាំងនេះទទួលបានការថែទាំមុនសម្រាល និងសេវាសុខភាពបន្តពូជ។ |
| *គណៈកម្មាធិការស្តីពីសិទ្ធិកុមារ* (២០១១) CRC/C/KHM/CO/2-3 |
| **៥៤.** គណៈកម្មាធិការសូមស្នើឱ្យរដ្ឋភាគី៖<br>ក). ពង្រីកការទទួលយកបាននូវសេវាកម្មថែទាំសុខភាព ដោយមិនគិតកម្រៃ នៅគ្រប់ខេត្ត និងផ្តល់នូវធនធានមនុស្ស បច្ចេកទេស និងហិរញ្ញវត្ថុគ្រប់គ្រាន់ សម្រាប់ផ្គត់ផ្គង់សេវាកម្មទាំងនេះ ក្នុងទម្រង់មួយដែលផ្តល់អត្ថប្រយោជន៍ដល់ប្រជាជន ទាំងនៅទីប្រជុំជន និងទាំងនៅទីជនបទ។ |

ខ). ពង្រឹងនូវកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួន ដើម្បីកាត់បន្ថយអត្រាមរណភាពកុមារអាយុក្រោម១ឆ្នាំ និងកុមារអាយុក្រោម៥ឆ្នាំ និងម្ដាយដែលមានផ្ទៃពោះ រួមទាំងការថែទាំមុន និងពេលសម្រាលកូន។

គ). ចាត់វិធានការជាបន្ទាន់ ដើម្បីដោះស្រាយឱ្យបានទូលំទូលាយនូវបញ្ហានៃការខ្វះអាហារូបត្ថម្ភចំពោះកុមារអាយុក្រោម៥ឆ្នាំ។

ឃ). ចាត់វិធានការបន្ទាន់ដើម្បីដោះស្រាយបញ្ហាសុខភាព ដែលអាចបង្ការទប់ស្កាត់បាន ក្នុងចំណោមកុមាររួមទាំងកង្វះជាតិអ៊ីយ៉ូដ ជំងឺគ្រុនចាញ់ ជំងឺរាគ ជំងឺផ្លូវដង្ហើមស្រួចស្រាវ ជំងឺកញ្ជ្រិល និងជំងឺរលាកស្រោមខួរ។

ង). អភិវឌ្ឍន៍គោលនយោបាយកុមារជាតិ និងសុខភាពផ្លូវចិត្តដ៏ស៊ីជម្រៅមួយ រួមទាំងរាល់សមាសភាពដែលមានកាតព្វកិច្ចទាំងអស់នៃអនុសាសន៍ស្នូលរបស់អង្គការសុខភាពពិភពលោក រួមទាំងការលើកកម្ពស់សុខភាពផ្លូវចិត្ត ការប្រឹក្សាយោបល់ ការបង្ការភាពមិនប្រក្រតីនៃសុខភាពផ្លូវចិត្ត នៅក្នុងការថែទាំសុខភាពបឋម នៅក្នុងសាលារៀន និងសហគមន៍ ក៏ដូចជា សេវាសុខភាពផ្លូវចិត្តសម្រាប់អ្នកជំងឺពីខាងក្រៅ និងអ្នកជំងឺនៅក្នុងមន្ទីរពេទ្យសម្រាប់កុមារ និងយុវវ័យដែលមានបញ្ហាផ្លូវចិត្តធ្ងន់ធ្ងរ និង

ច). ស្វែងរកជំនួយបច្ចេកទេស មានជាអាទិ៍ ពីអង្គការយូនីសេហ្វ និងអង្គការសុខភាពពិភពលោកពាក់ព័ន្ធនឹងបញ្ហានេះ។

**៥៦**. គណៈកម្មាធិការសូមក្រើនរំលឹកនូវអនុសាសន៍របស់ខ្លួនឡើងវិញចំពោះរដ្ឋភាគី (CRC/C/15/Add.128 para.53) ដើម្បីធ្វើការសិក្សាឱ្យបានស៊ីជម្រៅ និងមានលក្ខណៈពហុវិស័យ ដើម្បីកំណត់វិសាលភាពនៃបញ្ហាយុវវ័យ រួមទាំងសុខភាពផ្លូវចិត្ត ដែលជាមូលដ្ឋានសម្រាប់លើកកម្ពស់គោលនយោបាយ សុខភាពយុវវ័យ និងពង្រឹងការអប់រំសុខភាពបន្តពូជ។ គណៈកម្មាធិការក៏សូមស្នើឱ្យរដ្ឋភាគី៖

ក). ធ្វើការពង្រឹងកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួនសម្រាប់ការអភិវឌ្ឍសេវាកម្មដែលមានលក្ខណៈយុវវ័យមេត្រី និងការប្រឹក្សាយោបល់ពីបញ្ហារសើបទាក់ទងនឹងយេនឌ័រ ក៏ដូចជាកន្លែងផ្ដល់ការថែទាំ និងការស្ដារនីតិសម្បទាសម្រាប់យុវវ័យ។

ខ). ធានាថាយុវវ័យ ការបន្សាបគ្រឿងញៀន ការព្យាបាល ការស្ដារនីតិសម្បទា និងការធ្វើអន្តរាគមន៍សមាហរណកម្មកុមារដែលប្រើប្រាស់គ្រឿងញៀន ត្រូវអនុលោមតាមបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ ហើយក្នុងគោលបំណងនេះ ត្រូវធ្វើការអភិវឌ្ឍនូវកម្មវិធីព្យាបាល និងស្ដារគ្រឿងញៀននៅថ្នាក់សហគមន៍។

គ). ធ្វើការសិក្សាស៊ីជម្រៅអំពីការធ្វើអត្តឃាតរបស់យុវជន និងបុព្វហេតុរបស់វា និងប្រើប្រាស់នូវព័ត៌មានទាំងនេះ ដើម្បីអភិវឌ្ឍ និងអនុវត្តផែនការសកម្មភាពជាតិស្ដីពីការធ្វើអត្តឃាតរបស់យុវជន ដោយសហការជាមួយភ្នាក់ងារសង្គមកិច្ច គ្រូបង្រៀន បុគ្គលិកសុខាភិបាល និងអ្នកមានវិជ្ជាជីវៈពាក់ព័ន្ធផ្សេងទៀត និង

ឃ). ទទួលយកការណែនាំដែលមាននៅក្នុងសេចក្ដីពន្យល់ទូទៅលេខ៤ (២០០៣) របស់គណៈកម្មាធិការស្ដីពីសុខភាពយុវវ័យ និងការអភិវឌ្ឍ។

| |
|---|
| ៥៨. គណៈកម្មាធិការសូមទទូចឱ្យរដ្ឋភាគីផ្តល់នូវធនធានមនុស្ស បច្ចេកទេស និងហិរញ្ញវត្ថុដ៏ចាំបាច់សម្រាប់ឱ្យមានការអនុវត្តដ៏ពេញលេញនៃផែនការយុទ្ធសាស្ត្រជាតិសម្រាប់ការបង្ការ និងត្រួតពិនិត្យមេរោគអេដស៍ និងដើម្បីចាត់វិធានការដ៏ចាំបាច់ ដើម្បីទប់ស្កាត់ការធ្វើឱ្យមានស្លាកស្នាមទុរយ៉ស និងការរើសអើងប្រឆាំងនឹងកុមារដែលរស់នៅជាមួយមេរោគអេដស៍/ជំងឺអេដស៍ ជាពិសេសតាមរយៈយុទ្ធនាការអប់រំជាសាធារណៈ។ គណៈកម្មាធិការសូមទាញការយកចិត្តទុកដាក់របស់រដ្ឋភាគីចំពោះសេចក្តីពន្យល់ទូទៅលេខ៣ (២០០៣) របស់ខ្លួន ស្តីពីអេដស៍/ជំងឺអេដស៍ និងសិទ្ធិកុមារ ព្រមទាំងគោលការណ៍ណែនាំអន្តរជាតិស្តីពីមេរោគអេដស៍/ជំងឺអេដស៍ និងសិទ្ធិមនុស្ស។ |
| ***គណៈកម្មាធិការប្រឆាំងទារុណកម្ម*** (២០១០) CAT/C/KHM/CO/2 |
| ២៦. គណៈកម្មាធិការលើកឡើងថា រដ្ឋភាគីគឺជាអ្នកទទួលខុសត្រូវលើការផ្តល់សំណងដល់ប្រជាពលរដ្ឋរងគ្រោះពីការធ្វើទារុណកម្ម និងក្រុមគ្រួសាររបស់ពួកគេ។ ដើម្បីសម្រេចគោលបំណងនេះ រដ្ឋភាគីគួរបង្កើនកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួន ដើម្បីឲ្យប្រជាពលរដ្ឋរងគ្រោះពីការធ្វើទារុណកម្ម ទទួលបានសំណង រួមមានប្រាក់សំណងដែលត្រឹមត្រូវនិងគ្រប់គ្រាន់ និងការស្តារនីតិសម្បទាឲ្យបានពេញលេញ តាមដែលអាចធ្វើបាន។ រដ្ឋភាគីគួរបង្កើនកិច្ចខិតខំប្រឹងប្រែងបន្ថែមទៀត ដើម្បីកែលំអលទ្ធភាពទទួលបានសេវាខាងវេជ្ជសាស្ត្រ និងសេវាខាងផ្លូវចិត្តសម្រាប់ប្រជាពលរដ្ឋរងគ្រោះពីការធ្វើទារុណកម្ម ជាពិសេសក្នុងអំឡុងពេល និងបន្ទាប់ពីការជាប់ឃុំក្នុងពន្ធនាគារ ហើយធានាថា ជនរងគ្រោះទាំងនោះ ទទួលបានសេវាស្តារនីតិសម្បទាដែលមានប្រសិទ្ធភាព និងបន្ទាន់ ដើម្បីលើកកម្ពស់ការយល់ដឹងពីផលវិបាកនៃទារុណកម្ម និងតម្រូវការស្តារនីតិសម្បទាសម្រាប់ជនរងគ្រោះពីការធ្វើទារុណកម្ម ក្នុងចំណោមអ្នកជំនាញខាងសុខភាព និងអ្នកជំនាញខាងសុខុមាលភាពសង្គម និងដើម្បីបង្កើនការបញ្ជូនជនរងគ្រោះទាំងនេះពីប្រព័ន្ធថែទាំសុខភាពកម្រិតបឋម ទៅកាន់សេវាឯកទេសជំនួសវិញ និងដើម្បីបង្កើនសមត្ថភាពទីភ្នាក់ងារសុខភាពជាតិឲ្យផ្តល់សេវាស្តារនីតិសម្បទាឯកទេស ផ្អែកលើបទដ្ឋានអន្តរជាតិបែបអនុសាសន៍ ដល់ប្រជាពលរដ្ឋរងគ្រោះពីការធ្វើទារុណកម្ម រួមទាំងសមាជិកក្រុមគ្រួសាររបស់ពួកគេ ជាពិសេស ក្នុងវិស័យសុខភាពផ្លូវចិត្ត ។ |
| ***គណៈកម្មាធិការសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌*** (២០០៩) E/C.12/KHM/CO/1 |
| ១៩. គណៈកម្មាធិការផ្តល់ជាអនុសាសន៍ដល់រដ្ឋភាគី គួរដោះស្រាយបញ្ហានៃការបែងចែកអវិជ្ជមានដែលធ្វើឲ្យស្ត្រីរិតតែងាយរងគ្រោះថែមទៀត ដោយសារជម្ងឺហ៊ីវ/អេដស៍ និងជំរុញឲ្យមានការចូលរួមពីបុរសក្នុងកម្មវិធីទាំងឡាយដែលផ្តល់ព័ត៌មានអំពីសិទ្ធិខាងផ្លូវភេទ និងសិទ្ធិខាងការបន្តពូជ។ គណៈកម្មាធិការគូសបញ្ជាក់អំពីសារៈសំខាន់នៃការធ្វើឲ្យមន្ត្រីប្រតិបត្តិច្បាប់ និងអ្នកឯទៀតដែលមានតួនាទីនៃអំណាច យល់ដឹងអំពីច្បាប់ តាមរយៈការរៀបចំឲ្យមានកម្មវិធីផ្តល់ព័ត៌មានមានប្រសិទ្ធភាពថែមទៀតដល់ពួកគាត់។<br><br>៣២. គណៈកម្មាធិការផ្តល់ជាអនុសាសន៍ថា រដ្ឋភាគីពង្រឹងការអនុវត្តន៍ និងតាមឃ្លាំមើលការអនុវត្តន៍គោលនយោបាយដូរវេន និងការពង្រាយបុគ្គលិកក្រសួងសុខាភិបាល ដើម្បីធានាឲ្យមានពេទ្យឆ្មបនៅតាមមណ្ឌលសុខភាពទាំងអស់នៅទូទាំងប្រទេស និងផ្តល់កន្លែងស្នាក់នៅ និងរបបហូបចុកដល់ពេទ្យឆ្មបទាំងនោះ។ គណៈកម្មាធិការផ្តល់ជា |

| |
|---|
| អនុសាសន៍ផងដែរថា រដ្ឋភាគីគួរបង្កើតមណ្ឌលសំរាប់ឲ្យស្ត្រីមានផ្ទៃពោះស្នាក់នៅបណ្តោះអាសន្នមុនពេលសំរាលកូននៅតាមតំបន់ជនបទ មណ្ឌលគាំពារមាតា និងទារកនៅតាមសហគមន៍ និងរៀបចំឲ្យមានវគ្គបណ្តុះបណ្តាលជំនាញពេទ្យឆ្មបដល់បុគ្គលិកពេទ្យនានា។ គណៈកម្មាធិការផ្តល់ជាអនុសាសន៍យ៉ាងខ្លាំងថា រដ្ឋភាគីគួរលើកកំពស់ការបណ្តុះបណ្តាល និងសេវាកម្មបង្កើតកូន ដោយអនុវត្តយ៉ាងម៉ឺងម៉ាត់នូវច្បាប់ស្តីពីការរំលូតកូន។<br>៣៣. គណៈកម្មាធិការផ្តល់ជាអនុសាសន៍យ៉ាងខ្លាំងថា រដ្ឋភាគីពិចារណាអនុម័តច្បាប់ស្តីពីសុខភាពផ្លូវចិត្ត និងអនុម័តផែនការយុទ្ធសាស្ត្រស្តីពីសុខភាពផ្លូវចិត្ត ដែលបញ្ចូលភាពជាដៃគូជាមួយអង្គការមិនមែនរដ្ឋាភិបាល និងស្ថាប័នដៃគូក្នុងវិស័យឯកជននានា។ គណៈកម្មាធិការផ្តល់ជាអនុសាសន៍ផងដែរថា រដ្ឋភាគីធានាថា បុគ្គលទាំងឡាយដែលមានបញ្ហាសុខភាពផ្លូវចិត្ត មិនត្រូវបានបញ្ជូនទៅដាក់ពន្ធនាគារឡើយ។ |

## *ខ. ការអប់រំ*

| *អនុសាសន៍នៃការពិនិត្យជាសកលតាមកាលកំណត់* (២០១៤) |
|---|
| **១១៨.១៤០.** បន្តចាត់វិធានការនានា ដើម្បីធានាពីការលុបបំបាត់ភាពក្រីក្រ និងការទទួលបានសេវាសុខភាព និងអប់រំ។ (គុយបា)<br>**១១៨.១៥៩.** បង្កើនការចំណាយថវិកាជាតិរបស់ខ្លួនបន្ថែមទៀតលើវិស័យសុខភាព និងអប់រំ ដើម្បីបំពេញបានតាមទិសដៅនៃគោលដៅអភិវឌ្ឍន៍សហស្សវត្ស។ (អាហ្វ្រិចខាងត្បូង)<br>**១១៨.១៦២.** បន្តកិច្ចខិតខំប្រឹងប្រែង ដើម្បីសម្រេចបានការអប់រំបឋមជាសកល ស្របតាមចក្ខុវិស័យនៃផែនការជាតិស្តីពី "ការអប់រំសម្រាប់ទាំងអស់គ្នា"។ (ស្រីលង្កា)<br>**១១៨.១៦៣.** បន្តអនុវត្តវិធានការនានាសំដៅកែលំអដល់វិជ្ជមាត្រ និងគុណភាពនៃសេវាអប់រំ ជាពិសេស នៅតាមតំបន់ជនបទដាច់ស្រយាល។ (រដ្ឋប៉ាឡេស្ទីន)<br>**១១៨.១៦៤.** ដោយសហការជាមួយUNDP និងUNESCO បន្តកែលម្អប្រព័ន្ធអប់រំ និងការបណ្តុះបណ្តាល វិជ្ជាជីវៈដល់ប្រជាពលរដ្ឋរបស់ខ្លួន។ (សិង្ហបុរី)<br>**១១៨.១៦៥.**បន្តជំរុញការចុះឈ្មោះចូលរៀនដោយឥតគិតថ្លៃ។ (សាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យកូរ៉េ)<br>**១១៨.១៦៦.** បន្តកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួន ដើម្បីប្រែក្លាយវឌ្ឍនភាពរបស់ខ្លួននៅកំរិតត្រឹមសូចនាករម៉ាក្រូសេដ្ឋកិច្ច ទៅជាវិធានការកាន់តែរឹងមាំនៃយុត្តិធម៌សង្គម និងឈានដល់កំរិតខ្ពស់នៃការអភិវឌ្ឍន៍ធនធានមនុស្ស ជាពិសេស ដោយធានាពីការអប់រំជាមូលដ្ឋាន ជាសកល កាតព្វកិច្ច និងដោយឥតគិតថ្លៃ។ (អេហ្ស៊ីប)<br>**១១៨.១៦៧.** បន្តធ្វើការលើផែនការជាតិរបស់ខ្លួនស្តីពី "ការអប់រំសម្រាប់ទាំងអស់គ្នា" ដើម្បីឲ្យកុមារ និងយុវជនកម្ពុជាទាំងអស់ទទួលបានបន្ថែមទៀតនូវសេវាអប់រំប្រកបដោយសមធម៌ (មីយ៉ាន់ម៉ា) |

| |
|---|
| **១១៨.១៦៨.** បន្តលើកកម្ពស់កម្មវិធីដើម្បីទទួលបានការអប់រំសម្រាប់ទាំងអស់គ្នា ជាពិសេស នៅក្នុងការអប់រំបឋមសិក្សា។ (នីការ៉ាហ្គ័រ) |
| *អនុសាសន៍នៃការពិនិត្យជាសកលតាមកាលកំណត់* (២០០៩) |
| **៧១.** បន្តអនុវត្តយុទ្ធសាស្ត្រនានាដើម្បីកាត់បន្ថយភាពក្រីក្រ និងដើម្បីធ្វើឲ្យប្រសើរឡើង និងលើកកម្ពស់ការអប់រំ។ (អង់ហ្គោឡា)<br>**៨៥.** សូមធ្វើការអប់រំកំរិតបឋមឲ្យក្លាយជាកាតព្វកិច្ច និងដាក់បញ្ចូលការប្រយុទ្ធប្រឆាំងនឹងភាពមិនចេះអក្សរ ចូលទៅក្នុងផែនការយុទ្ធសាស្ត្រអប់រំរបស់រដ្ឋាភិបាល។ (ទួកគី)<br>**៨៦.** សូមសង្កត់ធ្ងន់លើវិស័យអប់រំបន្ថែមទៀត ដើម្បីផ្លាស់ប្តូរឲ្យមានភាពស្មើគ្នា និងប្រព័ន្ធអប់រំជាន់ខ្ពស់បន្តិចម្តងៗ ពីព្រោះការអប់រំ គឺជាឧបករណ៍ស្នូលមួយសំរាប់ការអភិវឌ្ឍន៍ជាតិ។ (មីយ៉ាន់ម៉ា)<br>**៨៧.** តាមរយៈជំនួយសមរម្យពីអន្តរជាតិ សូមព្យាយាមពង្រឹងប្រព័ន្ធអប់រំរបស់ខ្លួននិងការអប់រំសំរាប់គ្រប់កម្មវិធី រាប់បញ្ចូលទាំង សំរាប់ស្ត្រី និងជនពិការ។ (ហ្វីលីពីន) |
| *គណៈកម្មាធិការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ* (២០១៣)<br>CEDAW/C/KHM/CO/4-5 |
| ៣៣. គណៈកម្មាធិការផ្តល់អនុសាសន៍ឲ្យរដ្ឋភាគី៖<br>(ក). ចាត់វិធានការដែលមានប្រសិទ្ធភាព ដើម្បីបង្កើនការទទួលបានការអប់រំដល់កុមារី រាប់បញ្ចូលទាំង តាមរយៈការពង្រឹងហេដ្ឋារចនាសម្ព័ន្ធសាលា និងបង្កើនចំនួនកន្លែងសិក្សានៅក្នុងសាលាកំរិតមធ្យមសិក្សា ជាពិសេសនៅតាមឃុំនានា។<br>(ខ). រៀបចំបង្កើតវិធានការនានា សំដៅធានាឲ្យបាននូវការរក្សាស្ត្រី និងកុមារីនៅក្នុងសាលា ជាពិសេស នៅពេលឆ្លងពីបឋមសិក្សាទៅមធ្យមសិក្សា និងកម្រិតឧត្តមសិក្សា។<br>(គ). បង្កើនការអប់រំដែលសមស្រប តាមអាយុអំពីសិទ្ធិផ្លូវភេទ និងសិទ្ធិបន្តពូជ នៅតាមសាលារៀនអំពីទំនាក់ទំនងយេនឌ័រ និងការប្រព្រឹត្តផ្លូវភេទដែលមានការទទួលខុសត្រូវ ដើម្បីទប់ស្កាត់ការមានគភ៌វ័យក្មេង និង<br>(ឃ). លើកកម្ពស់គុណភាពនៃការអប់រំ តាមរយៈការបណ្តុះបណ្តាលគ្រូបង្រៀន និងធានាថា គ្រូបង្រៀនទទួលបានប្រាក់បំណាច់គ្រប់គ្រាន់។ |
| *គណៈកម្មាធិការស្តីពីសិទ្ធិកុមារ* (២០១១) CRC/C/KHM/CO/2-3 |
| **៦៦.** គណៈកម្មាធិការសូមស្នើឱ្យរដ្ឋភាគី៖ |

ក). កំណត់ការអប់រំជាមូលដ្ឋានថាជាកាតព្វកិច្ច។

ខ). ផ្តល់ និងបង្កើនធនធានដល់វិស័យអប់រំ ដើម្បីពង្រីក និងសាងសង់អគារសិក្សាឱ្យបានគ្រប់គ្រាន់ ទូទាំងប្រទេស និងបង្កើតនូវប្រព័ន្ធអប់រំដែលមានលក្ខណៈរួមបញ្ចូលដ៏ពិតប្រាកដ ដែលស្វាគមន៍កុមារពិការ ក៏ដូចជាកុមារមកពីជនជាតិភាគតិចទាំងអស់។

គ). ចាត់វិធានការចាំបាច់ដើម្បីបញ្ឈប់រាល់ទម្រង់នៃអំពើពុករលួយនៅក្នុងប្រព័ន្ធអប់រំ។

ឃ). ខិតខំប្រឹងប្រែងឱ្យកាន់តែខ្លាំងក្លាថែមទៀត ក្នុងការដោះស្រាយអត្រាបោះបង់សាលារៀន និងអត្រាត្រួតថ្នាក់ ដោយយកចិត្តទុកដាក់ជាពិសេសនៅតំបន់ទាំងឡាយដែលមានប្រជាពលរដ្ឋជនជាតិភាគតិចរស់នៅច្រើន ដូចជាខេត្តរតនគីរី និងខេត្តមណ្ឌលគីរីជាដើម។

ង). ចាត់វិធានការដ៏សកម្មដើម្បីលើកកម្ពស់សិទ្ធិក្មេងស្រី ឱ្យទទួលបាននូវការអប់រំតាមរយៈយុទ្ធនាការកៀងគរផ្នែកសង្គម និងបង្កើនចំនួនគ្រូបង្រៀនជាស្ត្រីភេទដែលមានការបណ្តុះបណ្តាលគ្រប់គ្រាន់ និងធានានូវសន្តិសុខរបស់ពួកគេ។

ច). ពង្រីកបន្ថែមនូវការអប់រំ ២ ភាសា សម្រាប់អ្នកមិននិយាយភាសាខ្មែរ។

ឆ). លើកកម្ពស់គុណភាពអប់រំ ដោយធ្វើការកែសម្រួលមេរៀន ដោយប្រើប្រាស់វិធីសាស្ត្រអន្តរកម្ម និងជ្រើសរើសគ្រូបង្រៀនដែលមានការបណ្តុះបណ្តាល។

ជ). ធ្វើការអភិវឌ្ឍបន្ថែមទៀតនូវកម្មវិធីអភិវឌ្ឍន៍កុមារតូច និងកម្មវិធីអប់រំ រួមទាំងកម្មវិធីថ្នាក់សហគមន៍ និងធ្វើការធានាថា កុមារដែលរស់នៅក្នុងគ្រួសារដែលមានប្រាក់ចំណូលទាប និងគ្រួសារដែលរស់នៅតំបន់ជនបទ ក៏អាចទទួលបានកម្មវិធីទាំងនេះផងដែរ។

ឈ). ផ្តល់ការអប់រំវិជ្ជាជីវៈសម្រាប់យុវវ័យ និងអ្នកឆាប់ចាកចេញពីសាលារៀន និង

ញ). ធ្វើការពិចារណាសេចក្តីពន្យល់ទូទៅលេខ១ ស្តីពីគោលបំណងនៃការអប់រំ (CRC/GC/២០០១/១)។

## *គណៈកម្មាធិការលុបបំបាត់ការរើសអើងពូជសាសន៍* (២០១០) CERD/C/KHM/CO/8-13

២០. គណៈកម្មាធិការផ្តល់អនុសាសន៍ឲ្យរដ្ឋភាគីបន្តកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួន ដើម្បីសំរេចគោលដៅរបស់ខ្លួនស្តីពី "ការអប់រំសំរាប់មនុស្សគ្រប់រូប" និងគិតគូរអំពីកម្មវិធីអប់រំពីរភាសា តាមការគួរ នៅតំបន់ដាច់ស្រយាល ជាមធ្យោបាយនៃការពង្រឹងបរិស្ថានសិក្សា សំរាប់ជនភាគតិច ជាតិពន្ធុ និងជនជាតិដើមភាគតិច។

## *គណៈកម្មាធិការសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌* (២០០៩) E/C.12/KHM/CO/1

៣៥. គណៈកម្មាធិការផ្តល់ជាអនុសាសន៍ដល់រដ្ឋភាគីថា កំណែទម្រង់សេវាសាធារណៈ គួរតែសង្កត់ធ្ងន់ជាពិសេសលើការដំឡើងប្រាក់បៀវត្សរ៍ និងការផ្តល់ប្រាក់រង្វាន់លើកទឹកចិត្តដល់គ្រូបង្រៀន ដោយភ្ជាប់ទៅនឹងការធ្វើចំណាត់ថ្នាក់មុខងារ សិទ្ធិ និងការទទួលខុសត្រូវរបស់គ្រូបង្រៀនផងដែរ។

| |
|---|
| ៤៣. គណៈកម្មាធិការផ្តល់ជាអនុសាសន៍ថារដ្ឋភាគីធានាឲ្យមានការលៃបំរុងថវិកាគ្រប់គ្រាន់សំរាប់ការអប់រំនៅគ្រប់កំរិត ជាពិសេស ការអប់រំកំរិតមូលដ្ឋាន និងតម្លាភាពនៃប្រព័ន្ធបែងចែក និងចំណាយថវិកាសំរាប់ការអនុវត្តន៍សិទ្ធិអប់រំ។ គណៈកម្មាធិការផ្តល់ជាអនុសាសន៍ដែរថា រដ្ឋភាគីគួរពង្រីកកម្មវិធីអប់រំក្រៅប្រព័ន្ធសំរាប់កុមារីដែលនៅក្រៅសាលារៀន (មាត្រា១៣)។ |
| *អ្នករាយការណ៍ពិសេស* |
| A/HRC/33/62 Para 61 (e). បន្តកម្មវិធីអប់រំពីរភាសា ដល់កុមារជនជាតិដើម និងធានាថា វប្បធម៌ និងជំនឿរបស់ជនជាតិដើមភាគតិច ត្រូវបានដាក់បញ្ចូលទៅក្នុងកម្មវិធីអប់រំចាតិ និងត្រូវបានការពារយ៉ាងសកម្ម ទាំងនៅក្នុងច្បាប់ទាំងនៅក្នុងការអនុវត្តជាក់ស្តែង។ |

## *គ. សំណាញ់សុវត្ថិភាព និងក្រុមងាយរងគ្រោះ*

| |
|---|
| *អនុសាសន៍នៃការពិនិត្យជាសកលតាមកាលកំណត់ (២០១៤)* |
| **១១៨.៧៣.** តាក់តែងយន្តការគ្រប់គ្រាន់មួយសម្រាប់ជួយកុមារអនាថាដើម្បីឲ្យពួកគេអាចទទួលបានអត្ថប្រយោជន៍ពីជំនួយ និងសេវាសមោហរណកម្មឡើងវិញ។ (ឌ្យីប៊ូទី)<br>**១១៨.៧៤.** បង្កើនកិច្ចខិតខំប្រឹងប្រែងលើប្រព័ន្ធការពារកុមារ ជាពិសេស កុមារដែលស្ថិតក្នុងក្រុមឯកោ និងក្រុមងាយរងគ្រោះ។ (អ៊ីរ៉ង់ (សាធារណរដ្ឋអ៊ីស្លាម))<br>**១១៨.១៤៦.** ពង្រឹង និងកែលម្អបណ្តាញសុវត្ថិភាពសង្គម។ (អ៊ីរ៉ាក់)<br>**១១៨.១៤៩.** អភិវឌ្ឍកម្មវិធីជាតិបន្ថែមទៀត ដោយផ្តោតលើការផ្តល់សេវាសុខភាពដល់ប្រជាជន ដែលរស់នៅក្រោមបន្ទាត់ភាពក្រីក្រ។ (ទីម័រខាងកើត)<br>**១១៨.១៧១.** បន្តកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួនលើសុខភាព ប្រព័ន្ធសេវាសង្គម និងការអប់រំ ដើម្បីជួយជនដែលងាយរងគ្រោះ និងជនពិការ ជាពិសេស ស្ត្រី និងកុមារ។ (អ៊ីរ៉ង់ (សាធារណរដ្ឋអ៊ីស្លាម)) |
| *អនុសាសន៍នៃការពិនិត្យជាសកលតាមកាលកំណត់ (២០០៩)* |
| **៧២.** កំណត់អាទិភាពនៅក្នុងផែនការអនាគតរបស់ខ្លួន ដើម្បីធ្វើឲ្យប្រសើរឡើងដល់ស្ថានភាពក្រុមងាយរងគ្រោះពិតប្រាកដ ដូចជា ស្ត្រី ជាពិសេស អ្នកទាំងនោះដែលរស់នៅតាមតំបន់ជនបទ កុមារ និងជនពិការ។ (អាល់ហ្សេរី)<br>ចាត់វិធានការបន្ថែមទៀតដើម្បីផ្តល់ការការពារ និងជំនួយឧបត្ថម្ភដល់ក្រុមសង្គមងាយរងគ្រោះ រាប់បញ្ចូលទាំងចាស់ជរា ជនពិការ ក្រុមគ្រួសារក្រីក្រ ក្មេងកំព្រា និងជនផ្សេងៗទៀត។ (បេលឡារូស) |

| |
|---|
| ៧៤. បិទមជ្ឈមណ្ឌលស្តារនីតិសម្បទា ដែលជាកន្លែងជនអនាថាត្រូវបាននគរបាលចាប់ខ្លួនយកទៅឃុំឃាំង និងអនុវត្តគោលនយោបាយសង្គមកិច្ចឲ្យបានគ្រប់គ្រាន់ ដើម្បីដោះស្រាយបញ្ហាក្រុមមនុស្សដែលមិនទទួលបានផលប្រយោជន៍ពីសង្គម។ (អូទ្រីស) |
| *គណៈកម្មាធិការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ* (២០១៣)<br>CEDAW/C/KHM/CO/4-5 |
| ៤៥. គណៈកម្មាធិការផ្តល់អនុសាសន៍ឲ្យរដ្ឋភាគីប្រមូល និងវិភាគទិន្នន័យដោយបែងចែកតាមអាយុ និងភេទ សម្រាប់ធ្វើគោលនយោបាយ និងអនុវត្តវិធីសាស្រ្តរយៈពេលយូរ សម្រាប់ដោះស្រាយការរើសអើងស្ត្រីចាស់ជរា។ |
| *គណៈកម្មាធិការស្តីពីសិទ្ធិកុមារ* (២០១១) CRC/C/KHM/CO/2-3 |
| ២៩. គណៈកម្មាធិការសូមទទូចឱ្យរដ្ឋភាគីធ្វើការវាយតម្លៃយ៉ាងប្រុងប្រយ័ត្ន និងជាទៀងទាត់នូវវិសមភាពដែលកើតមាននៅក្នុងការទទួលបានសិទ្ធិរបស់កុមារ និងដោយផ្អែកលើការវាយតម្លៃនោះ សូមចាត់វិធានការដ៏ចាំបាច់ ដើម្បីប្រយុទ្ធប្រឆាំងនឹងការរើសអើងប្រឆាំងនឹងកុមារ ដែលស្ថិតនៅក្នុងក្រុមដែលគេមិនសូវគិតគូរដល់ និងក្រុមដែលអាចរងគ្រោះ។ [...]<br><br>៧០. គណៈកម្មាធិការសូមទទូចឱ្យរដ្ឋភាគី៖<br><br>ក). ចាត់រាល់វិធានការចាំបាច់ដើម្បីការពារកុមាររស់នៅតាមចិញ្ចើមថ្នល់ ធានាថាពួកគេត្រូវបានផ្តល់នូវដំណោះស្រាយ និងសេវាសមាហរណកម្ម និងការចាត់អាទិភាពនូវការធ្វើអន្តរាគមន៍បែបគ្រួសារ និងសហគមន៍ សំដៅបង្រួបបង្រួមកុមារទាំងនេះ ទៅក្នុងគ្រួសាររបស់ពួកគេវិញ។<br><br>ខ). បញ្ឈប់ការអនុវត្ត "ប្រតិបត្តិការបោសសម្អាតផ្លូវ" និងការប្រព្រឹត្តចំពោះកុមាររស់នៅតាមចិញ្ចើមថ្នល់ដូចជាជនល្មើស ហើយធ្វើការដោះស្រាយស្ថានភាពរបស់ពួកគេក្នុងទម្រង់មួយដែលមានការគោរពចំពោះសិទ្ធិ និងសេចក្តីថ្លៃថ្នូររបស់ពួកគេ និង<br><br>គ). ធ្វើការស៊ើបអង្កេតឯករាជ្យនៅក្នុងការឃុំខ្លួន និងការរំលោភបំពានលើកុមារនៅក្នុងមណ្ឌលកោះរំដួល និងព្រៃស្ពឺ ព្រមទាំងផ្តល់ព័ត៌មានស៊ីជម្រៅអំពីលទ្ធផលនៃការស៊ើបអង្កេតទាំងនោះនៅក្នុងរបាយការណ៍តាមកាលកំណត់បន្ទាប់របស់ខ្លួន។ |
| *គណៈកម្មាធិការប្រឆាំងទារុណកម្ម* (២០១០) CAT/C/KHM/CO/2 |
| ២០. [...] រដ្ឋភាគីគួរធានាថាស្ថាប័នរដ្ឋាភិបាលពាក់ព័ន្ធទាំងអស់គោរពសិទ្ធិមិនត្រូវបានឃុំឃាំងតាមអំពើចិត្ត ដោយផ្អែកលើឋានៈសង្គមតាមទស្សនៈរបស់រដ្ឋាភិបាល និងដោយគ្មានមូលដ្ឋានច្បាប់ និងដីកាពីតុលាការឡើយ។ [...] |

| |
|---|
| លើសពីនេះ គណៈកម្មាធិការលើកទឹកចិត្តដល់រដ្ឋភាគីឲ្យធ្វើកិច្ចសហប្រតិបត្តិការជាមួយដៃគូពាក់ព័ន្ធដទៃទៀត ដើម្បីរិះរកជម្រើសផ្សេងៗដែលមាននិរន្តរភាព និងមានមនុស្សធម៌សម្រាប់ក្រុមមនុស្សរងគ្រោះ និងក្រុមងាយរងគ្រោះ រួមទាំងអ្នករស់នៅ និងធ្វើការតាមដងផ្លូវសាធារណៈ និងដើម្បីផ្តល់ជំនួយតាមតម្រូវការរបស់ពួកគេ។ |
| *គណៈកម្មាធិការសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌* (២០០៩) E/C.12/KHM/CO/1 |
| **១៧.** គណៈកម្មាធិការផ្តល់ជាអនុសាសន៍ថា រដ្ឋភាគីគួរអនុម័តច្បាប់ជាតិមួយស្តីពីសិទ្ធិជនពិការ។ គណៈកម្មាធិការស្នើឲ្យរដ្ឋភាគីបញ្ចូលក្នុងរបាយការណ៍តាមកាលកំណត់លើកក្រោយរបស់ខ្លួននូវព័ត៌មានលំអិតអំពីជនពិការ ដោយបញ្ចូលទាំងកុមារ និងស្ត្រីក្នុងនោះផងដែរ ពាក់ព័ន្ធនឹងការទទួលបានសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌។<br>**២៨.** គណៈកម្មាធិការផ្តល់ជាអនុសាសន៍ដល់រដ្ឋភាគី ឲ្យពង្រឹងយុទ្ធសាស្ត្រអន្តរាគមន៍របស់ខ្លួនក្នុងការឆ្លើយតបទៅនឹងស្ថានភាពអាសន្ននៃការកើនឡើងនូវបញ្ហាអសន្តិសុខស្បៀង។ គណៈកម្មាធិការស្នើឲ្យរដ្ឋភាគី បញ្ចូលក្នុងរបាយការណ៍តាមកាលកំណត់លើកក្រោយរបស់ខ្លួននូវព័ត៌មានលំអិតអំពីលទ្ធផលនៃយុទ្ធសាស្ត្រអន្តរាគមន៍ទាំងនេះ។<br>**៤០.** គណៈកម្មាធិការស្នើឲ្យរដ្ឋភាគី ពង្រីកវិសាលភាពគ្របដណ្តប់នៃប្រព័ន្ធសុវត្ថិភាពសង្គម តាមរយៈការបង្កើតវិធានការនានា ដែលមានគោលដៅដោះស្រាយស្ថានការណ៍របស់បុគ្គល និងក្រុមមនុស្សដែលក្រលំបាក និងដែលគេមិនសូវគិតគូរជាពិសេស ជនអានាថានៅក្នុងមណ្ឌលនានានៅទីក្រុង ជនរងគ្រោះដោយការជួញដូរ កុមារអានាថារស់នៅតាមចិញ្ចើមថ្នល់ ឬដែលទំនាស់នឹងច្បាប់ និងប្រជាជននិងគ្រួសារក្រីក្រ។ គណៈកម្មាធិការស្នើយ៉ាងទទូចឲ្យរដ្ឋភាគី ពិចារណាអំពីការបង្កើតកម្មវិធីជំនួយសង្គមកិច្ចទូទៅមួយ ដើម្បីធានាការទទួលបានសិទ្ធិខាងសន្តិសុខសង្គមសំរាប់ជនគ្រប់រូប នៅក្នុងរដ្ឋភាគី (មាត្រា៩ មាត្រា១០ និងមាត្រា១១)។ |

## *ឃ. ជនភាគតិច*

| |
|---|
| *អនុសាសន៍នៃការពិនិត្យជាសកលតាមកាលកំណត់* (២០១៤) |
| **១១៨.៥៨.** បង្កើតលក្ខខណ្ឌដែលមានលក្ខណៈអំណោយផលដល់ការអនុគ្រោះអន្តរជនជាតិនៅកម្ពុជា សម្រាប់អនាគតប្រជាធិបតេយ្យរបស់ប្រទេស។ (ស្វីស)<br>**១១៨.៥៩.** បន្តជាមួយវិធានការនានាដើម្បីធានាការចុះបញ្ជីកំណើតកុមារដោយគ្មានការរើសអើងនឹងកុមារទេសន្តរប្រវេសន៍ និងបន្តពង្រឹងក្របខ័ណ្ឌច្បាប់សម្រាប់នីតិវិធីនៃការទទួលបានសញ្ជាតិ។ (អាហ្សង់ទីន) |
| *អនុសាសន៍នៃការពិនិត្យជាសកលតាមកាលកំណត់* (២០០៩) |
| **៨៤.** ធានាឲ្យមានការចុះបញ្ជីកំណើតរបស់កុមារទាំងអស់ រាប់បញ្ចូលទាំងពលរដ្ឋមិនមែនជាពលរដ្ឋខ្មែរដែលកើតនៅប្រទេសកម្ពុជាផង។ (សាធារណៈរដ្ឋឆែក) |

៨៨. សូមចាត់វិធានការបន្ថែមទៀតដើម្បីជួយគាំទ្រដល់សិទ្ធិទទួលបានការអប់រំរបស់កុមារជនជាតិភាគតិច ក្នុងការជួយពួកគេ រក្សា និងអភិវឌ្ឍន៍ប្រពៃណី និងភាសារបស់ពួកគេ។ (ម៉ូរ៉ុកកូ)

*គណៈកម្មាធិការសិទ្ធិមនុស្ស* (*២០១៥*) (CCPR/C/SR.3157)

៨. រដ្ឋភាគីគួរពង្រឹងកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួនដើម្បីប្រយុទ្ធប្រឆាំងនឹងការវាយប្រហារលក្ខណៈពូជសាសន៍និយមប្រឆាំងនឹងជនជាតិភាគតិចវៀតណាម។ រដ្ឋភាគីគួរពិចារណាផងដែរអំពីការបង្កើតផែនការសកម្មភាពប្រឆាំងនឹងការរើសអើងពូជសាសន៍។

២៧. រដ្ឋភាគី គួរតែចាត់វាល់វិធានការចាំបាច់ ដើម្បីធានាឱ្យបាននូវការទទួលបានសិទ្ធិពេញលេញពីកតិកាសញ្ញានេះ ដោយអ្នកតាំងទីលំនៅទាំងអស់ រាប់ទាំងបុគ្គលគ្មានរដ្ឋផង។ រដ្ឋភាគីក៏គួរតែជួយសម្រួលផងដែរដល់ការទទួលបានសំណុំឯកសារអត្តសញ្ញាណកម្ម។ លើសពីនេះទៀត រដ្ឋភាគីគួរតែធានាសិទ្ធិកុមារគ្មានរដ្ឋ ដែលបានកើតនៅលើទឹកដីនៃប្រទេសកម្ពុជា ចំពោះឪពុកម្ដាយកុមារគ្មានរដ្ឋទាំងនេះ ដើម្បីទទួលបានសញ្ជាតិមួយ។

២៨. រដ្ឋភាគីគួរបង្កើតយន្តការពិគ្រោះយោបល់មួយដែលមានប្រសិទ្ធភាព និងធានាបាននូវការពិគ្រោះយោបល់ប្រកបដោយអត្ថន័យជាមួយនឹងជនជាតិដើមភាគតិច ក្នុងការធ្វើសេចក្ដីសម្រេចលើគ្រប់វិស័យដែលមានផលប៉ះពាល់លើសិទ្ធិរបស់ពួកគេ។

*គណៈកម្មាធិការសិទ្ធិកុមារ* (*២០១៥*) CRC/C/OPAC/KHM/CO/1

១៥. គណៈកម្មាធិការអំពាវនាវដល់រដ្ឋភាគីឱ្យ៖

ក). បន្ត និងពង្រឹងនូវកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួន ដើម្បីធានាពីការចុះបញ្ជីសំបុត្រកំណើតដល់ក្មេងទាំងអស់ រួមទាំងតាមរយៈភ្នាក់ងារចល័ត ថាជាវិធានការមួយដើម្បីបង្ការការជ្រើសរើសកុមារឱ្យធ្វើទាហាន រួមទាំងកុមាររស់នៅតាមភូមិនិងតំបន់ដាច់ស្រយាល និងកុមារស្ថិតក្នុងស្ថានភាពរស់នៅតាមផ្លូវដូចដែលបានផ្ដល់អនុសាសន៍ដោយគណៈកម្មាធិការ នៅក្នុងសេចក្ដីសង្កេតសន្និដ្ឋានកាលពីលើកមុនរបស់ខ្លួន(CRC/C/KHM/CO/2-3, para. 37)

ខ). លើកចោលនូវរបាំងទាំងអស់ ដើម្បីជួយសម្រួលដល់ការទទួលបានជាសកលនូវនីតិវិធីនៃការចុះបញ្ជីសំបុត្រកំណើត

គ). ធានាថា នីតិវិធីជ្រើសរើសដែលនៅជាធរមាន ត្រូវបានប្រកាន់យ៉ាងខ្ជាប់ខ្ជួនដោយស្ថាប័នយោធា និងនគរបាលទាំងអស់ ដែលត្រូវជ្រើសរើសបុគ្គលិកជាប់កិច្ចសន្យា ឬមន្ត្រីអាជីព និងដោយសាលាយោធាទាំងអស់ ហើយត្រូវបង្កើតវិធានការដើម្បីកំណត់ពីការប្រើប្រាស់ឯកសារក្លែងដោយបុគ្គលអាយុក្រោម១៨ឆ្នាំ។

២៣. គណៈកម្មាធិការសូមផ្តល់អនុសាសន៍ថា រដ្ឋភាគីត្រូវដាក់ឱ្យដំណើរការនូវយន្តការ និងនីតិវិធី ដើម្បីធានាពីការការពារពេញលេញដល់ការស្វែងរកការជ្រកកោនរបស់ជនភៀសខ្លួន ជនអន្តោប្រវេសន្តនិងក្មេងដែលមិនបានតាមពួកគេមក ដែលស្ថិតនៅក្រោមយុត្តាធិការរបស់រដ្ឋភាគី ដោយកំណត់អត្តសញ្ញាណពីដំណាក់កាលដំបូងនូវកុមារដែលបានចូលរួមក្នុងជម្លោះប្រដាប់អាវុធ និងធានាថាមន្ត្រីដែលទទួលខុសត្រូវចំពោះអត្តសញ្ញាណកម្មបែបនេះ ត្រូវទទួលបានការបណ្តុះបណ្តាលពីសិទ្ធិកុមារ ការការពារកុមារ និងជំនាញសម្ភាសន៍កុមារមេត្រី។ គណៈកម្មាធិការសូមផ្តល់អនុសាសន៍បន្ថែមទៀតថា រដ្ឋភាគីធានាថា កុមារបែបនេះត្រូវបានផ្តល់ជំនួយគ្រប់គ្រាន់ដល់ការជាសះស្បើយទាំងផ្លូវកាយ និងផ្លូវចិត្ត និងការធ្វើសមាហរណកម្មពួកគេទៅក្នុងសង្គមវិញ។

## *គណៈកម្មាធិការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ* (២០១៣)

CEDAW/C/KHM/CO/4-5

៣១. គណៈកម្មាធិការអំពាវនាវឲ្យរដ្ឋភាគី៖

(ក). បង្កើនកិច្ចប្រឹងប្រែងក្នុងការជួយសម្រួលដល់ការចុះបញ្ជីកំណើតកូនរបស់ស្ត្រីវៀតណាម និងការទទួលបានសញ្ជាតិ និង

(ខ). ពិចារណាលើការចុះហត្ថលេខាលើសន្ធិសញ្ញាឆ្នាំ១៩៥៤ស្តីពីស្ថានភាពរបស់ជនដែលគ្មានរដ្ឋ និងអនុសញ្ញាឆ្នាំ១៩៦១ ស្តីពីការកាត់បន្ថយភាពគ្មានរដ្ឋ។

## *គណៈកម្មាធិការស្តីពីសិទ្ធិកុមារ* (២០១១) CRC/C/KHM/CO/2-3

៣៧. អនុលោមតាមមាត្រា៧ នៃអនុសញ្ញា គណៈកម្មាធិការសូមទទូចឱ្យរដ្ឋភាគីធ្វើការធានាការចុះបញ្ជីកំណើតដោយមិនគិតកម្រៃចំពោះកុមារគ្រប់រូប ដោយមិនគិតពីស្ថានភាពផ្លូវច្បាប់ និងដើមកំណើតរបស់ឪពុកម្តាយរបស់កុមារឡើយ។

៤០. គណៈកម្មាធិការសូមទទូចឱ្យរដ្ឋភាគីទទួលស្គាល់ថា កុមារដើមកំណើតវៀតណាម បានទទួលរងនូវការរើសអើង និងត្រូវចាត់វាល់វិធានការចាំបាច់ ដើម្បីដោះស្រាយស្ថានភាពរបស់ពួកគេ ព្រមទាំងធ្វើការធានាថា កុមារទាំងនោះមានសិទ្ធិពេញលេញទទួលបាននូវការចុះបញ្ជីកំណើត លិខិតស្នាមបញ្ជាក់អត្តសញ្ញាណ ការអប់រំជាសាធារណៈ និងសេវាថែទាំសុខភាព។ គណៈកម្មាធិការ ក៏សូមទទូចឱ្យរដ្ឋភាគី ផ្តល់ព័ត៌មាននៅក្នុងរបាយការណ៍តាមកាលកំណត់បន្ទាប់របស់ខ្លួនស្តីពីវិធានការដែលបានប្រកាន់យក ដើម្បីបញ្ចប់នូវភាពរើសអើងប្រឆាំងនឹងកុមារដើមកំណើតវៀតណាម និងវិធានការដើម្បីបង្ការការធ្វើអាជីវកម្មផ្លូវភេទ និងការរំលោភបំពានលើស្ត្រី និងក្មេងស្រី ដែលរស់នៅក្នុងសហគមន៍ជនជាតិវៀតណាមនេះ។

## *គណៈកម្មាធិការលុបបំបាត់ការរើសអើងពូជសាសន៍* (២០១០) CERD/C/KHM/CO/8-13

១១. គណៈកម្មាធិការផ្តល់អនុសាសន៍ថា ច្បាប់នេះគួរតែបានបំពេញបង្គ្រប់ ដើម្បីធានាឲ្យមាននិយមន័យច្បាស់លាស់ចំពោះការរើសអើងពូជសាសន៍ ស្របតាមមាត្រា១ នៃអនុសញ្ញានេះ និងសិទ្ធិបុគ្គលគ្រប់រូបមិនត្រូវបានគេរើសអើងប្រឆាំង ក្នុងការអាស្រ័យផលនូវសិទ្ធិទាំងអស់ដែលមានចែងក្នុងមាត្រា៥ នៃអនុសញ្ញានេះ។ គណៈកម្មាធិការផ្តល់អនុសាសន៍ថែមទៀតថា រដ្ឋភាគីត្រូវធានាថាបញ្ញត្តិទាំងអស់នេះ ត្រូវបានផ្សព្វផ្សាយឲ្យសាធារណៈជនបានយល់ដឹងទាំងស្រុង និងត្រូវបានដាក់ឲ្យអនុវត្ត។

១២. ស្របតាមសេចក្តីពន្យល់ទូទៅលេខ៨(១៩៩០)របស់ខ្លួន និងតាមកថាខ័ណ្ឌទី១០ដល់ទី១២ នៃគោលការណ៍ណែនាំអំពីការធ្វើរបាយការណ៍សំរាប់ឯកសារជាក់លាក់ CERD ដែលបានអនុម័តនាសម័យប្រជុំលើកទី៧១របស់ខ្លួន(CERD/C/2007/1) គណៈកម្មាធិការស្នើឲ្យរដ្ឋភាគី ដាក់បញ្ចូលទៅក្នុងរបាយការណ៍តាមកាលកំណត់លើកក្រោយរបស់ខ្លួននូវទិន្នន័យបំបែកស្តីពីជនភាគតិចជាតិពន្ធុរបស់រដ្ឋភាគី រាប់ទាំងជនជាតិដើមភាគតិច និងទិន្នន័យស្តីពីស្ថានភាពសេដ្ឋកិច្ចសង្គមរបស់ពួកគេផង។

១៨. គណៈកម្មាធិការផ្តល់អនុសាសន៍ឲ្យរដ្ឋភាគីធានាថា ខ្មែរក្រោមគ្រប់រូបដែលសុំបញ្ជាក់ឯកសារសញ្ជាតិរបស់ខ្លួន អាចទទួលបានអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរទាន់ពេលវេលា និងស្ថិតក្រោមនីតិវិធីស្មើគ្នា និងដូចគ្នា ដែលមានសារសំខាន់ចំពោះបុគ្គលគ្រប់រូប ដែលគេចាត់ទុកថាជាពលរដ្ឋខ្មែរ។

១៩. ដោយយល់ឃើញថា ឈ្មោះបុគ្គលម្នាក់ៗគឺជាផ្នែកមួយដ៏សំខាន់នៃអត្តសញ្ញាណវប្បធម៌និងជាតិពន្ធុ ហើយថាជីវប្រវត្តិផ្ទាល់ខ្លួន រាប់ទាំងថ្ងៃខែឆ្នាំកំណើតនិងទីកន្លែងកំណើត ក៏ជាផ្នែកមួយនៃអត្តសញ្ញាណដែរ គណៈកម្មាធិការផ្តល់អនុសាសន៍យ៉ាងខ្លាំងថា រដ្ឋភាគីចាត់វិធានការចាំបាច់ដើម្បីធានាថា ខ្មែរក្រោមដែលសុំបញ្ជាក់សញ្ជាតិរបស់ខ្លួនមានសិទ្ធិពេញលេញក្នុងការចុះឈ្មោះ និងទីកន្លែងកំណើតពិតប្រាកដរបស់ខ្លួន តាមការជ្រើសរើសរបស់គាត់។

២០. គណៈកម្មាធិការផ្តល់អនុសាសន៍ឲ្យរដ្ឋភាគី បន្តកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួន ដើម្បីសំរេចគោលដៅរបស់ខ្លួនស្តីពី "ការអប់រំសំរាប់ទាំងអស់គ្នា" និងគិតគូរអំពីកម្មវិធីអប់រំពីរភាសាតាមការសមស្របនៅតំបន់ដាច់ស្រយាល ជាមធ្យោបាយនៃការពង្រឹងបរិស្ថានសិក្សាសំរាប់ជនភាគតិចជាតិពន្ធុ និងជនជាតិដើមភាគតិច។

## *គណៈកម្មាធិការសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌*(២០០៩) E/C.12/KHM/CO/1

១៦. គណៈកម្មាធិការស្នើយ៉ាងទទូចដល់រដ្ឋភាគីឲ្យអនុវត្តច្បាប់ភូមិបាលឆ្នាំ២០០១ ដោយមិនត្រូវអូសបន្លាយពេលវេលាតទៅទៀត និងធានាថា គោលនយោបាយរបស់ខ្លួនស្តីពីការចុះបញ្ជីដីមិនត្រូវឲ្យផ្ទុយនឹងស្មារតីនៃច្បាប់នេះឡើយ។ គណៈកម្មាធិការបញ្ជាក់អំពីសេចក្តីត្រូវការឲ្យមានការវាយតំលៃអំពីផលប៉ះពាល់ខាងសង្គម និងបរិស្ថាន និងការពិគ្រោះយោបល់ជាមួយសហគមន៍នានា ដែលរងផលប៉ះពាល់ ពាក់ព័ន្ធនឹងសកម្មភាពសេដ្ឋកិច្ច រួមទាំងការធ្វើអាជីវកម្មរ៉ែ និងអាជីវកម្មប្រេង ក្នុងគោលដៅធានាថា សកម្មភាពទាំងនេះ មិនត្រូវដកហូតពីជនជាតិដើមភាគតិចនូវការទទួលបានយ៉ាងពេញលេញនូវសិទ្ធិរបស់ពួកគាត់លើដីធ្លី និងធនធានធម្មជាតិនៃបុព្វបុរសរបស់ខ្លួនឡើយ។

គណៈកម្មាធិការជំរុញលើកទឹកចិត្តឲ្យរដ្ឋភាគីពិចារណាផ្តល់សច្ចាប័នលើអនុសញ្ញាលេខ១៦៩របស់អង្គការពលកម្មអន្តរជាតិស្តីពីជនជាតិដើមភាគតិច និងក្រុមកុលសម្ព័ន្ធ។

៣៤. គណៈកម្មាធិការផ្តល់ជាអនុសាសន៍ដល់រដ្ឋភាគី ឲ្យពង្រីកវិសាលភាពនៃច្បាប់ស្តីពីការអប់រំ ដើម្បីធានាសិទ្ធិអប់រំជាថ្មី ដល់កុមារកម្ពុជាទាំងអស់ដែលភាសាដំបូង (ភាសាដើមកំណើត) របស់ខ្លួន មិនមែនជាភាសាខ្មែរ។

*អ្នករាយការណ៍ពិសេស*

A/HRC/7/42, para.101. រដ្ឋាភិបាលត្រូវការពារសិទ្ធិជនជាតិដើមភាគតិច និងជនភាគតិចដទៃទៀត ដោយសារតែអនក្ខរភាព ការរំពឹងទុក និងការអនុវត្តន៍តាមបែបប្រពៃណី អង្គការចាត់តាំងតាមបែបទម្រង់សហគមន៍ជាដើម។ល។ ដែលមិនធ្លាប់ស្គាល់ច្បាប់ និងនីតិវិធី វិធាននានាសំរាប់ការធ្វើកិច្ចការជំនួញ ឬសេដ្ឋកិច្ចទីផ្សារ។ ត្រូវចាត់វិធានការនានា ដើម្បីធានាថា អាជ្ញាធររដ្ឋ រួមទាំងឃុំ-សង្កាត់ មិនត្រូវពាក់ព័ន្ធនឹងកិច្ចការជំនួញ ដែលមិនមានច្បាប់ច្បាស់លាស់ ឬសីលធម៌នៃកិច្ចការនេះគួរឲ្យសង្ស័យ ដែលធ្វើឲ្យអន្តរាយដល់សិទ្ធិរបស់សហគមន៍នេះ ឬសិទ្ធិរបស់បុគ្គលនានា។

សូមមើលអនុសាសន៍នានា ពាក់ព័ន្ធនឹងសិទ្ធិដីធ្លីរបស់សហគមន៍ជនជាតិដើមភាគតិច ក្នុងផ្នែកទី IX ស្តីពីដីធ្លី។

A/HRC/27/70 Para82. អ្នករាយការណ៍ពិសេសសូមអំពាវនាវដល់តួអង្គនយោបាយទាំងអស់នៅកម្ពុជា ឱ្យគោរពពីភាពចំរុះ និងលើកស្ទួយសុខដុមរមនា និងភាពអនុគ្រោះខាងពូជសាសន៍។

## XII. សិទ្ធិស្ត្រី សិទ្ធិកុមារ និងសិទ្ធិជនពិការ

### *ក. កិច្ចការពារទូទៅដល់ស្ត្រី និងកុមារ*

| *អនុសាសន៍នៃការពិនិត្យជាសកលតាមកាលកំណត់* (២០១៤) |
|---|
| **១១៨.៥១**. បន្តវឌ្ឍនភាពរបស់ខ្លួននៅក្នុងការលើកស្ទួយ និងការពារសិទ្ធិស្ត្រី ដោយពង្រឹងយន្តការស្ថាប័ន និងការអនុវត្តច្បាប់ដែលកំពុងត្រូវបានលើកកំពស់ជាវិជ្ជមាន។ (វេណេហ្ស៊ុយអេឡា (សាធារណរដ្ឋបូលីវ៉ា))<br>**១១៨.៥៥**. បន្តផ្តល់ភាពអង់អាចដល់ស្ត្រី កុមារ និងក្រុមដែលងាយរងគ្រោះដទៃទៀតក្នុងសង្គម។ (នេប៉ាល់)<br>**១១៨.៦៥**. កែទម្រង់ច្បាប់ជាតិ ក្នុងគោលបំណងកែលម្អកិច្ចការពារកុមារ និងស្ត្រី ពីអំពើហិង្សា និងសំខាន់បំផុត គឺរាល់អំពើហិង្សាក្នុងគ្រួសារ។ (សហព័ន្ធរុស្ស៊ី) |
| *អនុសាសន៍នៃការពិនិត្យជាសកលតាមកាលកំណត់* (២០០៩) |
| **៧៩**. ដូចគណៈកម្មាធិការស្តីពីសិទ្ធិកុមារ និងគណៈកម្មាធិការស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ បានផ្តល់អនុសាសន៍ សូមបង្កើនកិច្ចខិតខំប្រឹងប្រែង ដើម្បីសម្រេចឲ្យកាន់តែប្រសើរឡើងដល់ការលើកកម្ពស់ និងការការពារសិទ្ធិកុមារ។ (អាល់ហ្សេរី)<br>**៨០**. បន្តបង្កើតច្បាប់ជាក់លាក់ ដើម្បីលើកកម្ពស់ និងការពារសិទ្ធិកុមារ រាប់បញ្ចូលទាំងការចូលរួមពីសង្គមស៊ីវិល វិធានការទប់ស្កាត់ខាងផ្នែកអប់រំ និងការដាក់បញ្ចូលសង្គមអនីតិជនក្នុងស្ថានភាពលំបាក។ (អេស្ប៉ាញ) |
| *គណៈកម្មាធិការសិទ្ធិកុមារ* (២០១៥) CRC/C/OPSC/KHM/CO/1 |
| **១៧**. ដោយយោងដល់សេចក្តីសង្កេតសន្និដ្ឋានកាលពីលើកមុនរបស់ខ្លួនស្តីពីពលកម្មកុមារ (CRC/C/KHM/ CO/2-3, កថាខ័ណ្ឌទី៦៨) និងការបៀតបៀនផ្លូវភេទ និងអាជីវកម្មផ្លូវភេទ (កថាខ័ណ្ឌទី៧២) គណៈកម្មាធិការសូមផ្តល់អនុសាសន៍ថា រដ្ឋភាគីត្រូវ៖<br>ក). អនុម័តវិធីសាស្ត្រគ្រប់ជ្រុងជ្រោយ និងចំទិសដៅមួយដែលដោះស្រាយឬសគល់បញ្ហា និងកត្តាហានិភ័យដែលពាក់ព័ន្ធនៃបទល្មើសនានាក្រោមពិធីសារបន្ថែមនេះ រួមមានភាពក្រីក្រ ភាពគ្មានការងារធ្វើ និងការងារតាមរដូវ ហើយដែលមានគោលដៅចំពោះកុមារក្នុងស្ថានភាពងាយរងគ្រោះបំផុតដែលមានហានិភ័យក្លាយជាកុមាររងគ្រោះពីបទល្មើសក្រោមពិធីសារបន្ថែមនេះ។<br>ខ). បន្តកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួន ធានាពីការចុះបញ្ជីកំណើតដល់កុមារទាំងអស់ដូចបានផ្តល់អនុសាសន៍នៅក្នុងសេចក្តីសង្កេតសន្និដ្ឋានដទៃទៀតរបស់គណៈកម្មាធិការ(CRC/C/KHM/CO/2-3, កថាខ័ណ្ឌទី៣៧ និង CRC/C/OPAC/KHM/CO/1, កថាខ័ណ្ឌទី១៤)។ |

គ). ពង្រឹងការអនុវត្តច្បាប់ដែលនៅជាធរមាន ព្រមទាំងវិធានការដ្ឋបាល កម្មវិធី និងគោលនយោបាយសង្គម សំដៅបង្ការ និងបង្កើនចំនួនអធិការកិច្ចការងារ រួមទាំងដើម្បីការពារកុមារដែលកំពុងធ្វើការនៅក្នុងវិស័យក្រៅប្រព័ន្ធ នៅក្នុងកន្លែងធ្វើការដែលមានគ្រោះថ្នាក់ និងនៅតាមកន្លែងកំសាន្តនានា។

ឃ). ធានាថាគ្រប់ករណីសុំកូន ត្រូវតែស្របតាមទាំងស្រុងនឹងពិធីសារបន្ថែមនេះ ព្រមទាំងគោលការណ៍និងបទប្បញ្ញត្តិនៃអនុសញ្ញាទីក្រុងឡាអេស្តីពីការការពារកុមារ និងកិច្ចសហប្រតិបត្តិការពាក់ព័ន្ធនឹងការសុំកូនអន្តរប្រទេស ដោយអនុម័តច្បាប់ស្តីពីការសុំកូនអន្តរប្រទេសដែលមិនទាន់អនុម័តនៅឡើយ តាមរយៈការបង្កើត និងការអនុវត្តកម្មវិធីដើម្បីបង្ការការសុំកូនដោយខុសច្បាប់ និងបញ្ញត្តិពីការផ្តល់អាជ្ញាប័ណ្ណ និងការឃ្លាំមើលទីភ្នាក់ងារសុំកូននានា ព្រមទាំងកម្រៃដែលទីភ្នាក់ងារទាំងនេះតម្រូវឱ្យបង់សំរាប់សេវានានារបស់ពួកគេ។

អនុវត្តន៍យុទ្ធនាការឱ្យចំទិសដៅ និងកម្មវិធីអប់រំឯកទេស ដើម្បីប្រយុទ្ធប្រឆាំងនឹងអំពើអាសអាភាសកុមារ និងពេស្យាកម្មកុមារ ដើម្បីដោះស្រាយពីហានិភ័យនានាពីការភ្ជាប់ទៅប្រើបណ្តាញអ៊ិនធឺណិត ដោយផ្តល់ការអប់រំអំពីសុវត្ថភាពអ៊ិនធឺណិតដល់កុមារ និងដោះស្រាយបញ្ហានៃការចង់បានកុមារសំរាប់គោលបំណងអាជីវកម្មផ្លូវភេទ។

### *គណៈកម្មាធិការសិទ្ធិកុមារ* (២០១៥) CRC/C/OPAC/KHM/CO/1

២១. គណៈកម្មាធិការទទូចឱ្យរដ្ឋភាគីធានាថា គ្មានកុមារណាម្នាក់ស្លៀកពាក់ឯកសណ្ឋាន [យោធា] មានវត្តមាននៅតាមបណ្តោយព្រំដែនកម្ពុជា-ថៃឡើយ ហើយត្រូវផ្តល់ឱ្យកុមារទាំងនោះដែលបានចូលរួមក្នុងជម្លោះប្រដាប់អាវុធ នូវកិច្ចគាំពារសមស្របដល់ពួកគេ ឱ្យបានជាសះស្បើយទាំងផ្លូវកាយ និងផ្លូវចិត្ត និងការធ្វើសមោហរណកម្មពួកគេទៅក្នុងសង្គមវិញ។

### *គណៈកម្មាធិការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ* (២០១៣) CEDAW/C/KHM/CO/4-5

១៧. គណៈកម្មាធិការអំពាវនាវឲ្យរដ្ឋភាគី បន្តធ្វើសុខដុមនីយកម្ម និងពង្រឹងយន្តការជាតិ សម្រាប់ការលើកកម្ពស់ស្ត្រី។ គណៈកម្មាធិការក៏សូមផ្តល់អនុសាសន៍ឲ្យរដ្ឋភាគីបង្កើនការបែងចែកថវិកាសម្រាប់យន្តការជាតិ ហើយយន្តការនេះនឹងធានាថា ធនធានមានស្របទៅតាមភារកិច្ច និងសកម្មភាពរបស់ខ្លួន។ រដ្ឋភាគីក៏គប្បីធានាថា ការបែងចែកថវិកាត្រូវបានពិនិត្យវាយតម្លៃជារៀងរាល់ឆ្នាំ និងកែតម្រូវតាមការចាំបាច់។

### *គណៈកម្មាធិការស្តីពីសិទ្ធិកុមារ* (២០១១) CRC/C/KHM/CO/2-3

១៣. គណៈកម្មាធិការសូមស្នើឱ្យរដ្ឋភាគីធ្វើការអភិវឌ្ឍ និងអនុវត្តន៍គោលនយោបាយ និងយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយពាក់ព័ន្ធនឹងកុមារ ព្រមទាំងអនុម័តផែនការសកម្មភាពជាតិសម្រាប់កុមារ ឬក៏ក្របខណ្ឌបែបនេះដទៃទៀតសម្រាប់ការអនុវត្ត ដែលបង្កើតបានជាផែនការសកម្មភាពទាក់ទងនឹងវិស័យផ្សេងៗ ព្រមទាំងគ្របដណ្តប់លើវិស័យ

| |
|---|
| ទាំងអស់នៃអនុសញ្ញា។ គណៈកម្មាធិការក៏សូមស្នើឱ្យមានការផ្សារភ្ជាប់យ៉ាងជិតស្និទ្ធនូវយុទ្ធសាស្ត្រនេះ ទៅនឹងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម (២០០៩-២០១៣) និងយុទ្ធសាស្ត្រជាតិគាំពារសង្គម ហើយត្រូវមានធនធានគ្រប់គ្រាន់។ គណៈកម្មាធិការសូមស្នើថា ក្នុងការបង្កើតនូវគោលនយោបាយ និងផែនការបែបនោះ ត្រូវមានការយកចិត្តទុកដាក់ឱ្យបានសមស្រប ចំពោះឯកសារជាលទ្ធផលនៃសម័យប្រជុំពិសេសរបស់មហាសន្និបាតអង្គការសហប្រជាជាតិឆ្នាំ២០០២ ស្តីពី "ពិភពលោកមួយសមស្របសម្រាប់កុមារ" ព្រមទាំងសេចក្តីពិនិត្យឡើងវិញពាក់កណ្តាលអាណត្តិរបស់មហាសន្និបាតក្នុងឆ្នាំ២០០៧ ព្រមទាំងយកចិត្តទុកដាក់ចំពោះសេចក្តីពន្យល់ទូទៅលេខ៥ ឆ្នាំ២០០៣ ស្តីពីវិធានការទូទៅនៃការអនុវត្តអនុសញ្ញាស្តីពីសិទ្ធិកុមារ។ |

## ១. សមភាពយេនឌ័រ និងការរើសអើងប្រឆាំងនារីភេទ

| *អនុសាសន៍នៃការពិនិត្យជាសកលតាមកាលកំណត់ (២០១៤)* |
|---|
| **១១៨.៤៩.** បន្តកិច្ចខិតខំប្រឹងប្រែងថែមទៀត ដើម្បីបង្កើនការយល់ដឹងអំពីសមភាពយេនឌ័រ និងប្រយុទ្ធនឹងការរើសអើងប្រឆាំងស្ត្រី។ (ស្លូវេនី)<br><br>**១១៨.៥០.** អនុវត្តរាល់វិធានការ រួមទាំងយុទ្ធនាការបង្កើនការយល់ដឹងថ្នាក់ជាតិ និងកិច្ចខិតខំប្រឹងប្រែងសំដៅកែប្រែ ឬលុបបំបាត់ឥរិយាបទបុរសជាធំ និងផ្នត់គំនិតនានាដែលរើសអើងប្រឆាំងស្ត្រី រួមទាំងឥរិយាបទ និងផ្នត់គំនិតទាំង ឡាយដែលផ្អែកលើច្បាប់ស្រី។ (អ៊ុយរុយហ្គាយ)<br><br>**១១៨.៥២.** បន្តកិច្ចខិតខំប្រឹងប្រែងលើការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងស្ត្រី។ (អាល់ហ្សេរី)<br><br>**១១៨.៥៣.** ជំរុញច្បាប់ស្តីពីសមភាពយេនឌ័រទាក់ទងនឹងសិទ្ធិលើទ្រព្យសម្បត្តិ មរតកនិងអាពាហ៍ពិពាហ៍។(ម៉ិកស៊ិកូ)<br><br>**១១៨.៥៤.** បន្តវិធានការរបស់ខ្លួនអំពីយុទ្ធនាការបង្កើនការយល់ដឹង និងវិធានការចាំបាច់ដទៃទៀត ទាក់ទងទៅនឹងការលើកកម្ពស់សមធម៌ក្នុងសង្គម និងការលុបបំបាត់នូវការរើសអើងប្រឆាំងស្ត្រី។ (អារ៉ាប់រួមបែហ្សង់)<br><br>**១១៨.៥៦.** បន្តកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួនដើម្បីលុបបំបាត់ការរើសអើងប្រឆាំងស្ត្រី។ (ប៉ាគីស្ថាន)<br><br>**១១៨.៦៤.** បង្កើនយុទ្ធនាការលើកកំពស់ការយល់ដឹងអំពីសិទ្ធិស្ត្រី និងកុមារ ដោយមានការចូលរួមពីអ្នកសារព័ត៌មាន និងវិជ្ជាជីវៈផ្សព្វផ្សាយព័ត៌មាន ថាជាក្រុមគោលដៅមួយក្នុងចំណោមក្រុមគោលដៅនានារបស់ខ្លួន។ (អ៊ីតាលី) |
| *អនុសាសន៍នៃការពិនិត្យជាសកលតាមកាលកំណត់ (២០០៩)* |
| **២២.** អនុម័តច្បាប់ដែលកំណត់យ៉ាងច្បាស់លាស់ អំពីការរើសអើងប្រឆាំងនឹងស្ត្រីភេទ និងផ្តល់ដំណោះស្រាយប្រកបដោយប្រសិទ្ធភាព។ (អូទ្រីស)<br><br>**២៣.** បន្តអនុវត្តវិធានការវិជ្ជមានចាំបាច់ ដើម្បីសម្រេចឲ្យបាននូវភាពស្មើគ្នារបស់យេនឌ័រ។ (គុយបា) |

| |
|---|
| **២៤**. ដោះស្រាយបញ្ហាឫសគុលនៃភាពមិនស្មើគ្នារបស់យ៉េនឌ័រ តាមរយៈការចាត់វិធានការជាក់ស្តែង ក្នុងគោលបំណងរក្សា ការពារសិទ្ធិស្ត្រីនៅក្នុងគ្រួសារ ព្រមទាំងចាត់វិធានការ ធ្វើការលើកកម្ពស់ការយល់ដឹង និងការអប់រំអំពីសិទ្ធិមនុស្ស។ (អ៊ីតាលី)<br>**២៥**. បង្កើនកិច្ចខិតខំប្រឹងប្រែងក្នុងការលើកកម្ពស់ ការផ្តល់អំណាច និងក្នុងការពង្រឹងសមត្ថភាពស្ត្រី តាមរយៈការផ្សព្វផ្សាយ ការអប់រំ និងការបណ្តុះបណ្តាលជំនាញ។ (ម៉ាឡេស៊ី)<br>**២៦**. រៀបចំយុទ្ធនាការផ្សព្វផ្សាយឲ្យបានទូលំទូលាយ ដើម្បីធ្វើឲ្យសង្គម បានជ្រួតជ្រាបអំពីបញ្ហាសមភាពនៃយ៉េនឌ័រ។ (អាហ្សែបៃហ្សាន) |
| *គណៈកម្មាធិការសិទ្ធិមនុស្ស* (២០១៥) (CCPR/C/SR.3157) |
| **៧**. រដ្ឋភាគីគួរពង្រឹងវិធានការរបស់ខ្លួន ដើម្បីធានាសមភាពរវាងស្ត្រីនិងបុរសនៅគ្រប់វិស័យ រួមទាំងតាមរយៈការអនុវត្តឲ្យកាន់តែមានប្រសិទ្ធភាពបន្ថែមទៀត នូវច្បាប់ និងគោលនយោបាយពាក់ព័ន្ធនានា។ ក្នុងន័យនេះ រដ្ឋភាគីគួរបន្តអនុវត្តវិធានការបណ្តោះអាសន្នពិសេស ដើម្បីបង្កើនការចូលរួមរបស់ស្ត្រីនៅក្នុងជីវភាពនយោបាយ និងសាធារណៈ។ រដ្ឋភាគីគួរបង្កើនកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួន ដើម្បីបំបាត់គំនិតចាស់គំរិលខាងយេនឌ័រ សំដៅធ្វើការផ្លាស់ប្តូរទស្សនៈអំពីតួនាទីរបស់ស្ត្រីនៅក្នុងសង្គម។ ម្យ៉ាងវិញទៀត រដ្ឋភាគីគួរចាត់វិធានការ ដើម្បីកាត់បន្ថយគម្លាតប្រាក់ឈ្នួលទាក់ទងនឹងយេនឌ័រ និងការដោះស្រាយមូលហេតុទាំងអស់សម្រាប់គម្លាតនោះ។<br>**៩**. រដ្ឋភាគីគួរពិនិត្យឡើងវិញនូវច្បាប់របស់ខ្លួនដើម្បីធានាថា ការរើសអើងឈរលើហេតុផលនៃទំនោរផ្លូវភេទ និងអត្តសញ្ញាណយេនឌ័រ ត្រូវបានហាមឃាត់។ រដ្ឋភាគីគួរអនុវត្តផងដែរ នូវសកម្មភាពផ្សព្វផ្សាយការយល់ដឹង ដល់សាធារណៈជន ដើម្បីចូលរួមប្រយុទ្ធប្រឆាំងនឹងការរើសអើងសង្គម ប្រឆាំងនឹងមនុស្សស្រីស្រលាញ់ភេទដូចគ្នា មនុស្សប្រុសស្រលាញ់ភេទដូចគ្នា មនុស្សស្រលាញ់ភេទទាំងពីរ និងមនុស្សប្តូរភេទ (LGBT)។<br>**២៣**. រដ្ឋភាគីគួរលុបចោលបទប្បញ្ញត្តិដែលរើសអើង ដោយឈរលើហេតុផលភេទ អាយុ និងប្រាក់ចំណូល ទាក់ទងទៅនឹងអាពាហ៍ពិពាហ៍។ |
| *គណៈកម្មាធិការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ* (២០១៣)<br>CEDAW/C/KHM/CO/4-5 |
| **១៩**. គណៈកម្មាធិការបញ្ជាក់ឡើងវិញលើអនុសាសន៍មុនរបស់ខ្លួន (CEDAW/C/KHM/CO/3 កថាខណ្ឌទី១៨) និងផ្តល់អនុសាសន៍ឲ្យរដ្ឋភាគី៖<br>(ក). បញ្ចូលយុទ្ធសាស្ត្រដែលមានប្រសិទ្ធភាព និងគ្រប់ជ្រុងជ្រោយ ក្នុងផែនការយុទ្ធសាស្ត្រនារីរតនៈទី៤ ដែលមានគោលបំណងកែសម្រួល ឬលុបបំបាត់ផ្នត់គំនិតបិតាធិបតេយ្យ និងទស្សនៈតាមទម្លាប់ដែលរើសអើងលើស្ត្រី រាប់បញ្ចូលទាំងផ្នត់គំនិត និងទស្សនៈតាមទម្លាប់ផ្អែកលើច្បាប់ស្រី។ |

(ខ). ធ្វើយុទ្ធនាការផ្សព្វផ្សាយបង្កើនការយល់ដឹងជាសាធារណៈទូទាំងប្រទេសនិងជំរុញកិច្ចពិភាក្សាសាធារណៈឲ្យបានទូលំទូលាយ ដើម្បីដោះស្រាយផ្នត់គំនិត និងទស្សនៈតាមទម្លាប់ដែលរើសអើងលើស្ត្រី ដោយសហការជាមួយសង្គមស៊ីវិល អ្នកដឹកនាំសហគមន៍ និងប្រព័ន្ធផ្សព្វផ្សាយ។

(គ). សិក្សាពិនិត្យលើការប្រើប្រាស់បច្ចេកវិជ្ជា សារគមនាគមន៍ ព័ត៌មាន រាប់បញ្ចូលទាំងបណ្ដាញព័ត៌មានសង្គម ក្នុងការផ្សព្វផ្សាយព័ត៌មានអំពីសិទ្ធិស្ត្រី និងសមភាពយេនឌ័រ និង

(ឃ). បង្កើតយន្តការពិនិត្យតាមដាន និងវាយតម្លៃដែលមានប្រសិទ្ធភាព ក្នុងគោលបំណងវាយតម្លៃវឌ្ឍនភាពក្នុងការលុបបំបាត់ផ្នត់គំនិតយេនឌ័រដែលមានស្រាប់។

**២៧.** គណៈកម្មាធិការផ្ដល់អនុសាសន៍ឲ្យរដ្ឋភាគី ចាត់វិធានការដែលមានប្រសិទ្ធភាព ក្នុងការដោះស្រាយមូលហេតុជាឫសគល់នៃពេស្យាកម្ម រាប់បញ្ចូលទាំងតាមរយៈការផ្ដល់កម្មវិធីសម្រាប់ស្ត្រីដែលមានបំណងចាកចេញពីការរកស៊ីផ្លូវភេទ។ [...]

**២៩.** គណៈកម្មាធិការបញ្ជាក់ឡើងវិញលើការសង្កេតសន្និដ្ឋានមុនៗរបស់ខ្លួន (CEDAW/C/KHM/CO/3 កថាខណ្ឌទី១៤) និងជំរុញឲ្យរដ្ឋភាគីធានាថា ផែនការនារីរតនៈទី៤ ផ្ដល់នូវយុទ្ធសាស្ត្រប្រកបដោយប្រសិទ្ធភាព រាប់បញ្ចូលទាំងវិធានការពិសេសបណ្ដោះអាសន្ន ដែលមានគោលបំណងបង្កើនតំណាងរបស់ស្ត្រីក្នុងតួនាទីធ្វើសេចក្ដីសម្រេចជាពិសេស ក្នុងកិច្ចការនយោបាយ តុលាការ ការទូត និងការបរទេស។

៤៨. គណៈកម្មាធិការអំពាវនាវឲ្យរដ្ឋភាគីប្រើប្រាស់សេចក្ដីប្រកាស និងផែនការសកម្មភាពក្រុងប៉េកាំង ក្នុងកិច្ចប្រឹងប្រែងរបស់ខ្លួន ក្នុងការអនុវត្តបញ្ញត្តិទាំងឡាយនៃអនុសញ្ញានេះ។

### *គណៈកម្មាធិការស្ដីពីសិទ្ធិកុមារ* (២០១១) CRC/C/KHM/CO/2-3

**២៩.**[...] គណៈកម្មាធិការក៏សូមទទូចដល់រដ្ឋភាគីឱ្យធ្វើការពង្រឹងកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួនដើម្បីបញ្ចប់ជាពិសេសនូវការរើសអើងប្រឆាំងនឹងក្មេងស្រី និងធ្វើការលុបបំបាត់នូវការរីករាលដាលនៃឥរិយាបថផ្អែកលើយេនឌ័រ ការអនុវត្ត និងក្រមដែលកំណត់តួនាទីតូចទាប ដែលគ្មានទីបញ្ចប់សម្រាប់ស្ត្រី និងក្មេងស្រីនៅក្នុងសង្គម។

### *គណៈកម្មាធិការសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌* (២០០៩) E/C.12/KHM/CO/1

**១៨.** គណៈកម្មាធិការផ្ដល់ជាអនុសាសន៍យ៉ាងខ្លាំង សូមឲ្យរដ្ឋភាគីដក *ច្បាប់ស្រី* ចេញពីកម្មវិធីអប់រំនៅកំរិតបឋមសិក្សា ហើយដាក់ជំនួសវិញដោយឧបករណ៍អប់រំដែលលើកស្ទួយតំលៃស្ត្រី ទាំងនៅក្នុងផ្ទះ ទាំងនៅក្នុងសង្គម។ គណៈកម្មាធិការផ្ដល់ជាអនុសាសន៍ផងដែរថា រដ្ឋភាគីគួរចាត់វិធានការដើម្បីអនុវត្តច្បាប់របស់ខ្លួនស្ដីពីការរើសអើងប្រឆាំងនឹងស្ត្រីភេទ និងធ្វើយុទ្ធនាការផ្សព្វផ្សាយព័ត៌មាន និងកម្មវិធីផ្សព្វផ្សាយការយល់ដឹងដើម្បីលុបបំបាត់ចរិតអួតអាង និងការអនុវត្តន៍ទាំងឡាយណាដែលដាក់តួនាទីរបស់ស្ត្រីឲ្យស្ថិតនៅទាបជាងបុរស។

| |
|---|
| ២០. [...] គណៈកម្មាធិការស្នើឲ្យរដ្ឋភាគី យកចិត្តទុកដាក់ចំពោះសេចក្តីពន្យល់ទូទៅលេខ១៦ របស់ខ្លួន ស្តីពីសិទ្ធិស្មើគ្នារវាងបុរសនិងស្ត្រីក្នុងការទទួលបានសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ចនិងវប្បធម៌ ហើយស្នើឲ្យរដ្ឋភាគីបញ្ចូលក្នុងរបាយការណ៍តាមកាលកំណត់លើកក្រោយរបស់ខ្លួន នូវព័ត៌មានលំអិតអំពីសមិទ្ធិផលដែលសំរេចបានក្នុងបញ្ហានេះ។ |
| *អ្នករាយការណ៍ពិសេស* |
| A/HRC/15/46. Para.74. តំណែងមួយចំនួននៅឧត្តមក្រុមប្រឹក្សានេះគួរតែបំរុងទុកសម្រាប់ស្ត្រី។ សំណើនេះ អនុលោមតាមការទទួលខុសត្រូវរបស់កម្ពុជា ក្រោមអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនារីភេទ។ បន្ថែមពីលើនេះទៀត ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម គួរតែចែងអំពីភារកិច្ចជាក់លាក់មួយសំរាប់ក្រុមប្រឹក្សានេះដើម្បីលើកស្ទួយការតែងតាំងនិងការតំឡើងឋានន្តរសក្តិ៍ដល់ចៅក្រម និងព្រះរាជអាជ្ញាជាស្ត្រី ដែលមានសមត្ថភាព និងស្នាដៃ។<br>A/HRC/33/62 Para 61 (f). ពិនិត្យឡើងវិញនូវច្បាប់ គោលនយោបាយ និងយុទ្ធសាស្ត្រ តាមការចាំបាច់ ដើម្បីធានាថា សមភាពរវាងបុរសនិងស្ត្រីក្លាយជាការពិត ធ្វើការអប់រំជាសាធារណៈដើម្បីពង្រឹងសារវិជ្ជមាននៃសមភាព និងពិចារណាចាត់វិធានការលុបបំបាត់ឧបសគ្គនានាដែលរារាំងស្ត្រីមិនឱ្យឈរឈ្មោះបោះឆ្នោត ដោយឆ្លុះបញ្ចាំងពីលទ្ធភាពនៃវិធានការពិសេសបណ្តោះអាសន្ន រួមទាំងបញ្ជីសំរាំងសំរាប់តែស្ត្រី និងបញ្ជីដាក់ជំនួសបុរសដោយស្ត្រី។<br>A/HRC/33/62 Para 61 (j). បន្តអភិវឌ្ឍន៍យុទ្ធសាស្ត្រអប់រំក្នុងប្រព័ន្ធ និងក្រៅប្រព័ន្ធ ដើម្បីលើកកំពស់ការយល់ដឹងរបស់សិទ្ធិស្ត្រី និងប្រយុទ្ធប្រឆាំងនឹងផ្នត់គំនិតចាស់គំរិលតាមយេនឌ័រប្រពៃណី។ |

## *គ. អំពើហឹង្សាប្រឆាំងនារីភេទ និងកុមារ*

| |
|---|
| *អនុសាសន៍នៃការពិនិត្យជាសកលតាមកាលកំណត់* (២០១៤) |
| **១១៨.២៦.** អនុម័ត និងអនុវត្តច្បាប់ដែលហាមឃាត់រាល់ទម្រង់នៃការប្រព្រឹត្តិមិនគប្បីលើកុមារ និងដែលការពារពួកគេពីពលកម្មដោយបង្ខំ ការកេងប្រវ័ញ្ចផ្លូវភេទ និងការបំពាន។ (ព័រទុយហ្គាល់)<br>**១១៨.៦២.** ចាត់គ្រប់វិធានការចាំបាច់ដើម្បីទប់ស្កាត់និងប្រយុទ្ធនឹងអំពើហិង្សានិងការបំពានផ្លូវភេទលើស្ត្រីនិងកុមារ រួមទាំងការរំលោភសេពសន្ថវៈ ដោយលើកស្ទួយយន្តការប្រកបដោយប្រសិទ្ធភាពមួយ ដើម្បីទទួល និងស៊ើបអង្កេតពាក្យបណ្តឹងអំពីអំពើហិង្សាផ្លូវភេទ ហើយផ្តល់ដល់ជនរងគ្រោះនូវជំនួយផ្លូវចិត្តនិងផ្នែកសុខភាព។ (អ៊ុយរុយហ្គាយ)<br>**១១៨.៦៣.** ធ្វើការខិតខំប្រឹងប្រែងបន្ថែមទៀតដើម្បីទប់ស្កាត់ និងដាក់ទោសទណ្ឌអំពើហិង្សា រួមទាំង ការរំលោភសេពសន្ថវៈលើស្ត្រី និងកុមារ និងយកចិត្តទុកដាក់ជាពិសេសដល់គ្រួសារដែលងាយរងគ្រោះបំផុតដែលរស់នៅក្នុងបរិដ្ឋានក្រីក្រ។ (អ៊ីតាលី) |

**១១៨.៧២.** ប្រយុទ្ធប្រឆាំងនឹងបញ្ហានៃការរំលោភសេពសន្ថវៈ និងពេស្យាចារលើអនីតិជន ដោយធានាពីការអនុវត្តដោយពេញលេញនូវច្បាប់នានា ដែលដាក់ទោសដល់អំពើរំលោភបំពាន និងអាជីវកម្មផ្លូវភេទ។ (បែលហ្ស៊ិក)

**១១៨.១២៤.** បង្កើនការប្រយុទ្ធប្រឆាំងនឹងការផ្តល់ការងារក្លែងក្លាយ និងចុះហត្ថលេខាលើកិច្ចព្រមព្រៀងជាមួយប្រទេសនានាដែលជួលស្ត្រីកម្ពុជាឲ្យធ្វើការនៅទីនោះ។ (អេស្ប៉ាញ)

*អនុសាសន៍នៃការពិនិត្យជាសកលតាមកាលកំណត់* (២០០៩)

**៣០.** ទាក់ទងនឹងអំពើហឹង្សាផ្លូវភេទលើស្ត្រី សូមធ្វើការស៊ើបអង្កេតឲ្យបានត្រឹមត្រូវ និងទាន់ពេលវេលា ទៅលើគ្រប់ករណីដែលត្រូវបានរាយការណ៍ ផ្តន្ទាទោសជនល្មើស និងអនុវត្តកម្មវិធីស្តារនីតិសម្បទាចាំបាច់សំរាប់ជនរងគ្រោះ។ សូមបង្កើនកិច្ចខិតខំប្រឹងប្រែងរបស់រដ្ឋាភិបាលដើម្បីលើកកម្ពស់ការយល់ដឹងជាសាធារណៈប្រឆាំងនឹងបាតុភូតអវិជ្ជមាន និងដើម្បីប្រយុទ្ធប្រឆាំងនឹងការរើសអើងតាមបែបប្រពៃណី។ (ស្លូវ៉ាគី)

**៣១.** សូមធ្វើឲ្យមន្ត្រីនគរបាល និងមន្ត្រីអនុវត្តច្បាប់មានការយល់ដឹង និងសូមចាត់វិធានការដើម្បីផ្តន្ទាទោស អំពើហឹង្សាផ្លូវភេទ និងអំពើហឹង្សាក្នុងគ្រួសារឲ្យមានប្រសិទ្ធភាព។ (អូទ្រីស)

*គណៈកម្មាធិការសិទ្ធិមនុស្ស* (២០១៥) (CCPR/C/SR.3157)

**១០.** រដ្ឋភាគីគួរធានាថា ករណីអំពើហិង្សាក្នុងគ្រួសារ និងអំពើហិង្សាផ្លូវភេទ ត្រូវបានធ្វើការស៊ើបអង្កេតឲ្យបានហ្មត់ចត់ដែលជនដៃដល់ត្រូវបាននាំខ្លួនទៅផ្តន្ទាទោសតាមច្បាប់ហើយផ្តល់សំណងគ្រប់គ្រាន់ដល់ជនរងគ្រោះ។ រដ្ឋភាគីគួរផ្តល់ផងដែរនូវការបណ្តុះបណ្តាលចាំបាច់ដល់មន្ត្រីអនុវត្តច្បាប់ និងមន្ត្រីតុលាការផ្សេងៗស្តីពីការផ្តន្ទាទោសអំពើហិង្សាទាក់ទងនឹងយេនឌ័រ និងជួយសម្រួលដល់ជនរងគ្រោះ ក្នុងការស្វែងរកយុត្តិធម៌។

**២៤.** រដ្ឋភាគីគួរចាត់វិធានការជាក់ស្តែង ដោយរាប់ទាំងតាមវិធានការច្បាប់តាមការចាំចាច់ដើម្បីបញ្ចប់ការដាក់ទណ្ឌកម្មលើរាងកាយនៅគ្រប់ទីកន្លែង។ គួរលើកទឹកចិត្តរាល់ទម្រង់វិន័យអហិង្សា ធ្វើជាជម្រើសក្នុងការដាក់ទណ្ឌកម្មលើរាងកាយ និងគួរធ្វើយុទ្ធនាការផ្សព្វផ្សាយព័ត៌មានជាសាធារណៈ ដើម្បីលើកកម្ពស់ការយល់ដឹងអំពីផលប៉ះពាល់ដែលបង្កគ្រោះថ្នាក់នៃការដាក់ទណ្ឌកម្មលើរាងកាយនេះ។

*គណៈកម្មាធិការសិទ្ធិកុមារ* (២០១៥) CRC/C/OPSC/KHM/CO/1

**១៩.** គណៈកម្មាធិការទទូចឱ្យរដ្ឋភាគីបន្តកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួន ដើម្បីបង្ការទេសចរផ្លូវភេទកុមារ និងទេសចរកុមារកំព្រា និងការពារកុមារមិនឱ្យក្លាយជាជនរងគ្រោះ តាមរយៈការពង្រឹងក្របខ័ណ្ឌគតិយុត្តិ និងវិធានការលើកកំពស់ការយល់ដឹង រួមទាំងនៅតំបន់ជនបទ និងត្រូវចាត់គ្រប់វិធានការចាំបាច់ដើម្បីធានាថា គ្រប់ករណីនៃទេសចរផ្លូវភេទកុមារ និងទេសចរកុមារកំព្រាត្រូវបើកការស៊ើបសួរ និងថាជនល្មើសដែលជាប់ចោទ ត្រូវបានចោទប្រកាន់ និងត្រូវផ្តន្ទាទោសឱ្យបានត្រឹមត្រូវ។ គណៈកម្មាធិការសូមផ្តល់អនុសាសន៍ថា រដ្ឋភាគីត្រូវ៖

ក). ធ្វើការតស៊ូមតិជាមួយឧស្សាហកម្មទេសចរ និងប្រព័ន្ធផ្សព្វផ្សាយអំពីផលប៉ះពាល់គ្រោះថ្នាក់នៃទេសចរផ្លូវភេទកុមារ ផ្សព្វផ្សាយឱ្យបានទូលាយនូវក្រមសីលធម៌សកលសំរាប់វិស័យទេសចររបស់អង្គការទេសចរពិភពលោក ដល់ភ្នាក់ងាររៀបចំដំណើរកំសាន្ត និងទីភ្នាក់ងារទេសចរនានា ព្រមទាំងលើកទឹកចិត្តដល់សហគ្រាសទាំងនេះឱ្យក្លាយជាហត្ថលេខីនៃក្រមប្រតិបត្តិសំរាប់ការការពារកុមារពីការធ្វើអាជីវកម្មផ្លូវភេទនៅក្នុងវិស័យទេសចរ និងការធ្វើដំណើរកំសាន្ត។

ខ). ជំរុញការចុះទៅឃ្លាំមើល និងការធ្វើអធិការកិច្ចនៅគ្រប់ស្ថាប័នថែទាំជំនួស ដើម្បីលើកកំពស់បទដ្ឋានអប្បបរមាសំរាប់ការថែទាំជំនួស និងនៅតាមកន្លែងកំសាន្តនានា។

គ). ពង្រឹងក្របខ័ណ្ឌច្បាប់ និងក្របខ័ណ្ឌគតិយុត្តិរបស់ខ្លួន ដោយអនុម័តឱ្យបានឆាប់នូវអនុក្រិត្យស្តីពីការគ្រប់គ្រងស្ថាប័នថែទាំជំនួស និងធានាឱ្យមានការអនុវត្តបន្តនូវការចុះបញ្ជីដោយបង្ខំនៃស្ថាប័នថែទាំជំនួសទាំងអស់។

ឃ). ធានាឱ្យមានការត្រួតពិនិត្យសវតារជាប្រព័ន្ធ អំពីបុគ្គលិកទាំងអស់ និង/ឬអ្នកស្ម័គ្រចិត្តដែលនឹងត្រូវធ្វើការដោយផ្ទាល់ជាមួយកុមារ។

បង្កើតនីតិវិធីធ្វើរបាយការណ៍សុវត្ថិភាព និងលាក់ការណ៍សំរាប់កុមារដែលស្ថិតក្នុងការថែទាំតាមផ្ទះ។

*គណៈកម្មាធិការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ* (២០១៣)

CEDAW/C/KHM/CO/4-5

**១៥**. គណៈកម្មាធិការទទូចឲ្យរដ្ឋភាគីត្រូវ៖

(ខ). ឆ្លៀតឱកាសទាញយកប្រយោជន៍ពីដំណើរការនៃការធ្វើសេចក្តីព្រាងផែនការសកម្មភាពជាតិស្តីពីការបញ្ចប់អំពើហិង្សាលើស្ត្រី (NAPVAW) ដំណាក់កាលទី២ ដើម្បីបញ្ចូលបញ្ញត្តិនៃអនុសញ្ញា និងសេចក្តីសម្រេចលេខ ១៣២៥ របស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិឲ្យបានពេញលេញ។

**២១**. ដោយរំលឹកឡើងវិញនូវអនុសាសន៍ទូទៅលេខ១៩ (១៩៩២ឆ្នាំ)ស្តីពីអំពើហិង្សាលើស្ត្រី និងអនុសាសន៍មុនរបស់ខ្លួន (CEDAW/C/KHM/CO/3 កថាខណ្ឌទី១៦) គណៈកម្មាធិការជំរុញឲ្យរដ្ឋភាគី៖

(ក). បង្កើនកិច្ចប្រឹងប្រែងក្នុងការបណ្តុះបណ្តាលមន្ត្រីតុលាការ និងមន្ត្រីអនុវត្តច្បាប់អំពីការអនុវត្តច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះឲ្យបានហ្មត់ចត់ ដើម្បីធានាថា ករណីអំពើហិង្សាលើស្ត្រីរាប់បញ្ចូលទាំងអំពើហិង្សាក្នុងគ្រួសារ និងអំពើហិង្សាផ្លូវភេទ ត្រូវបានចោទប្រកាន់ប្រកបដោយប្រសិទ្ធភាព និងមិនត្រូវបានបង្វែទៅជាការសម្រុះសម្រួលជាលក្ខណៈប្រព័ន្ធ

(ខ). លើកទឹកចិត្តស្ត្រីឲ្យដាក់បណ្តឹងជាផ្លូវការលើអំពើហិង្សាក្នុងគ្រួសារ និងអំពើហិង្សាផ្លូវភេទ តាមរយៈ ការលុបបំបាត់ការមាក់ងាយលើជនរងគ្រោះ និងការលើកកម្ពស់ការយល់ដឹងអំពីលក្ខណៈព្រហ្មទណ្ឌនៃអំពើបែបនេះ

(គ). បន្តយុទ្ធនាការលើកកម្ពស់ការយល់ដឹងជាសាធារណៈអំពីអំពើហិង្សាលើស្ត្រីគ្រប់រូបភាព ជាពិសេស នៅតំបន់ជនបទ និង

| |
|---|
| (ឃ). ផ្តល់ព័ត៌មានអំពីចំនួនដីកាការពារដែលត្រូវបានចេញដោយតុលាការ ក្នុងអំឡុងពេលរាយការណ៍ និងចំនួនទីជម្រកដែលមានសម្រាប់ស្ត្រី ដែលជាជនរងគ្រោះដោយអំពើហិង្សា នៅក្នុងរបាយការណ៍តាមកាលកំណត់លើកក្រោយ។<br>**២៣**. គណៈកម្មាធិការផ្តល់អនុសាសន៍ឲ្យរដ្ឋភាគី ពង្រឹងកិច្ចប្រឹងប្រែងលើការលើកកម្ពស់ការយល់ដឹងក្នុងចំណោមគ្រូពេទ្យអំពីរបៀបគ្រប់គ្រងករណីអំពើហិង្សាលើស្ត្រី។ រដ្ឋភាគីក៏គប្បីលើកកម្ពស់ការយល់ដឹងអំពីគោលនយោបាយរបស់រាជរដ្ឋាភិបាលស្តីពីការលើកលែងការបង់ថ្លៃ សម្រាប់រាល់ការពិនិត្យកោសលវិច័យរបស់ជនរងគ្រោះដោយអំពើរំលោភសេពសន្ថវៈ និងការបំពានផ្លូវភេទ។<br>**២៧**. គណៈកម្មាធិការផ្តល់អនុសាសន៍ឲ្យរដ្ឋភាគី ចាត់វិធានការដែលមានប្រសិទ្ធភាពក្នុងការដោះស្រាយមូលហេតុជាឫសគល់នៃពេស្យាកម្ម រាប់បញ្ចូលទាំងតាមរយៈការផ្តល់កម្មវិធីសម្រាប់ស្ត្រីដែលមានបំណងចាកចេញពីការរកស៊ីផ្លូវភេទ។ លើសពីនេះទៀត រដ្ឋភាគីគប្បីស៊ើបអង្កេត និងចោទប្រកាន់ករណីបំពានផ្លូវភេទដោយមន្ត្រីអនុវត្តច្បាប់ដែលបានប្រព្រឹត្តលើស្ត្រីរកស៊ីផ្លូវភេទ និងធានាថា ជនល្មើសត្រូវបានផ្តន្ទាទោសដោយទណ្ឌកម្មសមស្រប។ គណៈកម្មាធិការក៏សូមផ្តល់អនុសាសន៍ផងដែរឲ្យរដ្ឋភាគីបង្កើតគោលនយោបាយដ៏គ្រប់ជ្រុងជ្រោយ ដើម្បីឆ្លើយតបទៅនឹងបញ្ហាដែលទាក់ទងនឹងតម្រូវការពេស្យាចារ និងពិចារណាលើការដាក់ទណ្ឌកម្មលើអ្នកទិញសេវាផ្លូវភេទ។ |
| *គណៈកម្មាធិការស្តីពីសិទ្ធិកុមារ* (២០១១) CRC/C/KHM/CO/2-3 |
| **៤១**. គណៈកម្មាធិការសូមទទូចឱ្យរដ្ឋភាគី៖<br>ក). លុបចោលមាត្រា១០៤៥ នៃក្រមរដ្ឋប្បវេណី និងបទប្បញ្ញត្តិនានានៃច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ដែលបានផ្តល់សិទ្ធិអំណាចឱ្យមានការដាក់ទណ្ឌកម្មលើរាងកាយកុមារ។<br>ខ). រៀបចំច្បាប់ដែលចែងយ៉ាងច្បាស់លាស់នូវការហាមឃាត់ការដាក់ទណ្ឌកម្មលើរាងកាយកុមារ នៅក្នុងគ្រប់ទីកន្លែង និងគ្រប់ពេលវេលា រួមទាំងនៅក្នុងគ្រួសារផងដែរ។<br>គ). ធានាថា ច្បាប់ដែលហាមឃាត់ការដាក់ទណ្ឌកម្មលើរាងកាយ ត្រូវបានអនុវត្តដោយប្រសិទ្ធភាព និងធានាថា ត្រូវមានចំណាត់ការតាមនីតិវិធីផ្លូវច្បាប់ប្រឆាំងនឹងអ្នកទទួលខុសត្រូវចំពោះអំពើហិង្សាប្រឆាំងនឹងកុមារ។<br>ឃ). ធ្វើយុទ្ធនាការអប់រំសាធារណៈ ការលើកកម្ពស់ការយល់ដឹង និងការកៀរគរផ្នែកសង្គមកិច្ច ចំពោះអានុភាពដ៏គ្រោះថ្នាក់នៃការដាក់ទណ្ឌកម្មលើរាងកាយ ក្នុងគោលបំណងផ្លាស់ប្តូរឥរិយាបថទូទៅចំពោះការប្រព្រឹត្តបែបនេះ ព្រមទាំងលើកកម្ពស់ទម្រង់វិជ្ជមាន អហិង្សា មានលក្ខណៈចូលរួមនៃការចិញ្ចឹមបីបាច់ និងអប់រំកុមារ ជាមធ្យោបាយជំនួសឱ្យការដាក់ទណ្ឌកម្មលើរាងកាយ និង<br>ង). យោងតាមសេចក្តីពន្យល់ទូទៅលេខ៨(២០០៦) របស់គណៈកម្មាធិការស្តីពីសិទ្ធិកុមារ ក្នុងការការពារពីការដាក់ទណ្ឌកម្មលើរាងកាយ និងទម្រង់ឃោរឃៅ ឬបន្ទាបបន្ថោកផ្សេងទៀតនៃការដាក់ទណ្ឌកម្ម។<br>**៤២**. គណៈកម្មាធិការសូមលើកទឹកចិត្តរដ្ឋភាគី៖ |

ក). ចាត់អាទិភាពនូវការលុបបំបាត់រាល់ទម្រង់នៃអំពើហិង្សាលើកុមារ រួមទាំងតាមរយៈការធានាឱ្យមានការអនុវត្តអនុសាសន៍នៃការសិក្សារបស់អង្គការសហប្រជាជាតិស្តីពីអំពើហិង្សាលើកុមារ ដោយយកចិត្តទុកដាក់ជាពិសេសចំពោះបញ្ហាយេនឌ័រ។

ខ). ផ្តល់ព័ត៌មានទាក់ទងនឹងការអនុវត្តដោយរដ្ឋភាគី នូវអនុសាសន៍នៃការសិក្សា នៅក្នុងរបាយការណ៍តាមកាលកំណត់បន្ទាប់ ជាពិសេសអនុសាសន៍ទាំងឡាយដែលបានគូសបញ្ជាក់ដោយតំណាងពិសេសនៃអគ្គលេខាធិការអង្គការសហប្រជាជាតិស្តីពីអំពើហិង្សាលើកុមារ មានជាអាទិ៍៖

i. ការអភិវឌ្ឍយុទ្ធសាស្ត្រជាតិដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ ដើម្បីទប់ស្កាត់ និងដោះស្រាយរាល់ទម្រង់ទាំងអស់នៃអំពើហិង្សាលើកុមារ។

ii. ការដាក់ចេញនូវការហាមប្រាមតាមផ្លូវច្បាប់ជាតិយ៉ាងជាក់ស្តែងលើរាល់ទម្រង់នៃអំពើហិង្សាលើកុមារនៅក្នុងគ្រប់ទីកន្លែង និងគ្រប់ពេល និង

iii. ការរួមបញ្ចូលនៃប្រព័ន្ធប្រមូល វិភាគ និងផ្សព្វផ្សាយទិន្នន័យជាតិ និងរបៀបវារៈនៃការស្រាវជ្រាវអំពីអំពើហិង្សាលើកុមារ។

គ). សហការជាមួយ និងស្វែងរកជំនួយបច្ចេកទេសពីតំណាងពិសេសនៃអគ្គលេខាធិការអង្គការសហប្រជាជាតិលើបញ្ហាអំពើហិង្សាលើកុមារ អង្គការយូនីសេហ្វ ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្ស និងអង្គការសុខភាពពិភពលោក និងទីភ្នាក់ងារពាក់ព័ន្ធដទៃទៀត មានជាអាទិ៍ អង្គការពលកម្មអន្តរជាតិ អង្គការយូណេស្កូ ឧត្តមស្នងការជាន់ខ្ពស់អង្គការសហប្រជាជាតិទទួលបន្ទុកជនភៀសខ្លួន ការិយាល័យប្រឆាំងគ្រឿងញៀននិងឧក្រិដ្ឋកម្មនៃអង្គការសហប្រជាជាតិ ក៏ដូចជាដៃគូអង្គការមិនមែនរដ្ឋាភិបាល។

៥០. គណៈកម្មាធិការសូមទទូចឱ្យរដ្ឋភាគីចាត់វិធានការជាបន្ទាន់ និងមានប្រសិទ្ធភាពដើម្បីប្រយុទ្ធប្រឆាំងនឹងអំពើហិង្សាក្នុងគ្រួសារ និងជាពិសេស៖

ក). ចាត់រាល់វិធានការចាំបាច់សម្រាប់អនុវត្តច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះឱ្យបានពេញលេញ រួមទាំង ការអនុម័តជាបន្ទាន់នូវប្រកាសដែលផ្តល់សមត្ថកិច្ចឱ្យមន្ត្រីឃុំ និងភូមិ ធ្វើសកម្មភាពការពារជនរងគ្រោះដោយសារអំពើហិង្សាក្នុងគ្រួសារ។

ខ). បង្កើតប្រព័ន្ធការពារកុមារមួយ ដោយមានការដាក់ការទទួលខុសត្រូវច្បាស់លាស់ចំពោះអាជ្ញាធរមូលដ្ឋានជាក់លាក់ណាមួយ រួមទាំងប្រព័ន្ធសម្រាប់រាយការណ៍អំពីការរំលោភបំពានលើកុមារ ដោយធ្វើការដោះស្រាយតាមរបាយការណ៍ទាក់ទងនឹងការរំលោភបំពានបែបនោះ ព្រមទាំងធ្វើការអភិវឌ្ឍនូវវិធានការគាំទ្រ និងវិធានការដទៃផ្សេងទៀត ដើម្បីទប់ស្កាត់អំពើហិង្សាដទៃទៀត។

គ). ប្រមូលទិន្នន័យដែលគួរឱ្យទុកចិត្តស្តីពីអំពើហិង្សាក្នុងគ្រួសារ រួមទាំងការបំពានផ្លូវភេទកុមារ និងធ្វើការសិក្សាអំពីឬសគល់នៃបុព្វហេតុ និងវិសាលភាពនៃបញ្ហានៃអំពើហិង្សាលើកុមារ។

ឃ). សម្របសម្រួលកម្មវិធីលើកកម្ពស់ការយល់ដឹងទូទាំងប្រទេស រួមទាំងយុទ្ធនាការអំពីបញ្ហានៃអំពើហិង្សាក្នុងគ្រួសារ ដោយមានគោលបំណងធ្វើការផ្លាស់ប្តូរឥរិយាបថសាធារណៈជន និងទំនៀមទម្លាប់ដែលហាមឃាត់ជនរងគ្រោះ ជាពិសេសស្ត្រី និងកុមារពីការរាយការណ៍ និង

| |
|---|
| ង). ធ្វើការស៊ើបអង្កេតអំពើហិង្សាក្នុងគ្រួសារតាមរយៈនីតិវិធីតុលាការយកចិត្តទុកដាក់កុមារ និងធានាថាមានការដាក់ទណ្ឌកម្មចំពោះជនល្មើសដោយគោរពការធានាសិទ្ធិរបស់កុមារ រួមទាំងសិទ្ធិឯកជនរបស់គេផងដែរ។<br><br>**៧២.** គណៈកម្មាធិការសូមទទូចឱ្យរដ្ឋភាគី៖<br><br>ក). ធ្វើការពង្រឹងកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួនក្នុងការអនុវត្តច្បាប់របស់ខ្លួន ដោយកំណត់ជាទោសព្រហ្មទណ្ឌនូវអំពើធ្វើអាជីវកម្មផ្លូវភេទ និងបំពានផ្លូវភេទ ក្នុងគោលបំណងដើម្បីធានាថា ជនដែលបានប្រព្រឹត្តល្មើសខាងផ្លូវភេទលើកុមារនឹងត្រូវបាននាំមកកាន់តុលាការ និងផ្តន្ទាទោសដ៏សមស្រប។<br><br>ខ). ធ្វើការថ្កោលទោស ព្រមទាំងចាត់វិធានការដ៏សកម្មប្រឆាំងនឹងបុគ្គល និងសហគ្រាសដែលផ្តល់សម្រួលសម្រួល ឬបង្កឱ្យមានទេសចរណ៍ផ្លូវភេទកើតឡើង និង<br><br>គ). បង្កើតជម្រកសម្រាប់ជនរងគ្រោះជាកុមារដោយអំពើបំពានផ្លូវភេទនិងអំពើធ្វើអាជីវកម្មផ្លូវភេទ ព្រមទាំងផ្តល់ដល់ពួកគេនូវការស្តារនីតិសម្បទាដំណោះស្រាយ និងសេវាកម្មសមាហរណកម្មសង្គមកិច្ច។ |
| *គណៈកម្មាធិការប្រឆាំងទារុណកម្ម* (២០១០) CAT/C/KHM/CO/2 |
| **២១.** រដ្ឋភាគីគួរចាត់វិធានការដែលមានប្រសិទ្ធភាពក្នុងការការពារ និងប្រយុទ្ធប្រឆាំងនឹងអំពើហិង្សា និងការរំលោភបំពានផ្លូវភេទទៅលើស្ត្រី និងកុមារ រួមទាំងការរំលោភសេពសន្ថវៈ។ ដើម្បីសម្រេចគោលបំណងនេះ រដ្ឋភាគីគួរបង្កើត និងលើកកម្ពស់យន្តការប្រកបដោយប្រសិទ្ធភាពមួយសំរាប់ទទួលពាក្យបណ្តឹងទាក់ទងនឹងអំពើហិង្សាផ្លូវភេទ និងធ្វើការស៊ើបអង្កេតលើពាក្យបណ្តឹងទាំងនោះ ដោយផ្តល់ការការពារខាងវេជ្ជសាស្ត្រ និងផ្លូវចិត្តដល់ជនរងគ្រោះក៏ដូចជាលទ្ធភាពទទួលបានដំណោះស្រាយ រួមមានសំណង និងការស្តារនីតិសម្បទាបានសមស្រប។ គណៈកម្មាធិការស្នើសុំឲ្យរដ្ឋភាគី ផ្តល់ស្ថិតិនៃចំនួនបណ្តឹងទាក់ទងនឹងការរំលោភសេពសន្ថវៈ ក៏ដូចជាព័ត៌មានស្តីពីការស៊ើបអង្កេត ការចោទប្រកាន់ និងការផ្តន្ទាទោសនៅក្នុងសំណុំរឿងទាំងនេះ។ |
| *គណៈកម្មាធិការសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌* (២០០៩) E/C.12/KHM/CO/1 |
| **២០.** គណៈកម្មាធិការស្នើយ៉ាងទទូចឲ្យរដ្ឋភាគីអនុវត្តយ៉ាងម៉ឹងម៉ាត់ និងផ្តន្ទាទោសចំពោះជនដែលល្មើស នឹងច្បាប់ស្តីពីអំពើហឹង្សាក្នុងគ្រួសារ និងក្រមព្រហ្មទណ្ឌ និងអនុវត្តឲ្យបានពេញលេញនូវផែនការសកម្មភាព ដើម្បីបង្ការអំពើហឹង្សាប្រឆាំងនឹងស្ត្រី។ [...] |
| *អ្នករាយការណ៍ពិសេស* |
| A/HRC/33/62 Para 61 (g). ពង្រឹងយន្តការតុលាការក្នុងការការពារជនរងគ្រោះនៃអំពើហឹង្សាក្នុងគ្រួសារ និងការជួញដូរ ជំរុញកិច្ចខិតខំប្រឹងប្រែងបណ្តុះបណ្តាលមន្ត្រីតុលាការ និងមន្ត្រីអនុវត្តច្បាប់ អំពីច្បាប់ស្តីពីការទប់ស្កាត់អំពើ |

ហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ដើម្បីធានាឱ្យមានការចោទប្រកាន់ដ៏មានប្រសិទ្ធភាព ជាជាងតាមមធ្យោបាយសម្រុះសម្រួល ហើយត្រូវធានាថាការសម្រុះសម្រួល និងយន្តការក្រៅផ្លូវការ អាចត្រូវប្រើបានតែរឿងក្ដីមិនព្រហ្មទណ្ឌ។

A/HRC/33/62 Para 61 (h). បណ្ដុះបណ្ដាលស្រ្តីបន្ថែមទៀត ឱ្យធ្វើការជាមួយជនរងគ្រោះពីអំពើហិង្សា និងការជួញដូរ និងបង្កើតទីតាំងសុវត្ថិភាពមួយសំរាប់ស្ត្រីដែលជាជនរងគ្រោះពីអំពើហិង្សានិងការជួញដូរ និងកម្មវិធីដើម្បីធានាឱ្យមានការជាសះស្បើយឡើងវិញ និងការធ្វើសមាហរណកម្មឡើងវិញទៅក្នុងសង្គម។

A/HRC/33/62 Para 61 (i). អនុវត្តបទប្បញ្ញត្តិដែលពាក់ព័ន្ធនៃក្រមព្រហ្មទណ្ឌ នៅពេលណាដែលស្ត្រីត្រូវបានគេយកទៅគូរពណ៌នាជារូបក្រាហ្វិច ជាពិសេស ជនរងគ្រោះនៃការបៀតបៀនផ្លូវភេទ និងហិង្សាផ្លូវភេទ។

## *ឃ. ពលកម្មកុមារ*

### *អនុសាសន៍នៃការពិនិត្យជាសកលតាមកាលកំណត់ (២០១៤)*

**១១៨.២៦.** អនុម័ត និងអនុវត្តច្បាប់ដែលហាមឃាត់រាល់ទម្រង់នៃការប្រព្រឹត្តិមិនគប្បីលើកុមារ និងដែលការពារពួកគេពីពលកម្មដោយបង្ខំ ការកេងប្រវ័ញ្ចផ្លូវភេទ និងការបំពាន។ (ព័រទុយហ្គាល់);

**១១៨.៦៧.** បន្តកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួនក្នុងការលើកស្ទួយ និងការពារសិទ្ធិកុមារ រួមទាំងការបង្កើយ និងការអនុវត្តសេចក្តីព្រាងថ្មីនៃផែនការជាតិដើម្បីលុបបំបាត់ទម្រង់អាក្រក់បំផុតនៃពលកម្មកុមារសម្រាប់ឆ្នាំ២០១៣-២០១៨។ (ឥណ្ឌូនេស៊ី)

**១១៨.៦៨.** ធានាការគោរពដោយពេញលេញនូវច្បាប់ស្តីពីពលកម្មកុមារនិងអនុវត្តផែនការសកម្មភាពជាតិរបស់ខ្លួនស្តីពីការលុបបំបាត់ទម្រង់អាក្រក់បំផុតនៃពលកម្មកុមារ ពង្រឹងច្បាប់ដែលហាមឃាត់ពលកម្មកុមារ ដោយផ្តល់អាទិភាពទៅលើស្ថានភាពកុមារ នៅក្នុងការងារបំរើតាមផ្ទះ បង្កើនចំនួននៃការចុះអធិការកិច្ចការងារ និងធានាពីការដាក់ពិន័យ និងការដាក់ទណ្ឌកម្មព្រហ្មទណ្ឌចំពោះជនណាដែលប្រើពលកម្មកុមារដោយខុសច្បាប់។ (អ៊ុយរុយហ្គាយ)

**១១៨.៦៩.** ពង្រឹងវិធានការប្រយុទ្ធនឹងពលកម្មកុមារ និងការកេងប្រវ័ញ្ចលើកុមារ។ (អាល់ហ្សេរី)

**១១៨.៧០.** បន្តកិច្ចខិតខំប្រឹងប្រែងរបស់រដ្ឋាភិបាល ដើម្បីលុបបំបាត់ទម្រង់អាក្រក់បំផុតនៃពលកម្មកុមារ និងដើម្បីកែលម្អស្តង់ដារសុវត្ថិភាពនៅកន្លែងធ្វើការ។ (គុយបា)

**១១៨.៧១.** អនុវត្តផែនការសកម្មភាពដើម្បីលុបបំបាត់ទម្រង់អាក្រក់បំផុតនៃពលកម្មកុមារ។ (អ៊ីរ៉ាក់)

**១១៨.១២៥.** ពង្រឹងគោលនយោបាយរបស់ខ្លួន ដើម្បីកែលម្អស្តង់ដារការងារសម្រាប់កម្មករទាំងអស់ និងបន្តកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួន ក្នុងការកាត់បន្ថយពលកម្មកុមារ។ (អេស្ប៉ាញ)

| |
|---|
| ***អនុសាសន៍នៃការពិនិត្យជាសកលតាមកាលកំណត់*** (២០០៩) |
| **៩.** ពង្រឹងសមត្ថភាពស្ថាប័នពាក់ព័ន្ធដើម្បីពង្រីកការអនុវត្តផែនការរយៈពេល៥ឆ្នាំ របស់ខ្លួន(២០០៦ ដល់២០១២) ដើម្បីលុបបំបាត់ទម្រង់ការងារទៅលើកុមារដ៏អាក្រក់បំផុត។ (សហរដ្ឋអាមេរិច)<br><br>**៣៣.** បង្កើនការប្រយុទ្ធប្រឆាំងរបស់ខ្លួនដើម្បីលុបបំបាត់ការងារដោយបង្ខំ និងទម្រង់ការងារលើកុមារធ្ងន់ធ្ងរបំផុត។ (សាធារណៈរដ្ឋកុងហ្គោ) |
| ***គណៈកម្មាធិការស្តីពីសិទ្ធិកុមារ*** (២០១១) CRC/C/KHM/CO/2-3 |
| **៦៨.** គណៈកម្មាធិការសូមទទូចឱ្យរដ្ឋភាគីអនុវត្តឱ្យបានពេញលេញនូវច្បាប់ការងារពាក់ព័ន្ធនឹងកុមារ និងអនុវត្តនូវផែនការសកម្មភាពជាតិស្តីពីការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ តាមរយៈមធ្យោបាយមានជាអាទិ៍៖<br><br>**ក).** ពង្រឹងច្បាប់ជាតិដែលធ្វើការហាមប្រាមពលកម្មកុមារ។<br><br>**ខ).** ផ្តល់អាទិភាពក្នុងករណីនេះ ដោយធ្វើការដោះស្រាយស្ថានភាពងាយរងគ្រោះរបស់កុមារ ដែលជាអ្នកបម្រើតាមផ្ទះ ឱ្យស្របតាមបទដ្ឋានអន្តរជាតិ។<br><br>**គ).** បង្កើនចំនួនអធិការការងារ។ ធានាឱ្យមានការដាក់ពិន័យ និងទោសព្រហ្មទណ្ឌដល់ជនដែលប្រើប្រាស់ពលកម្មកុមារដោយខុសច្បាប់។<br><br>**ឃ).** រៀបចំការបណ្តុះបណ្តាលតាមអាណត្តិសម្រាប់មន្ត្រីអនុវត្តច្បាប់ ព្រះរាជអាជ្ញា និងចៅក្រម និង<br><br>**ង).** ដាក់ចុះនូវវិធានការដ៏សមស្រប ដើម្បីជួយស្តារ និងការទទួលបាននូវឱកាសអប់រំសម្រាប់អតីតកុមារជាកម្មករក្នុងទម្រង់មួយដែលមានការគិតគូរពីបញ្ហារសើបទាក់ទងនឹងយេនឌ័រ។ |
| ***គណៈកម្មាធិការសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌*** (២០០៩) E/C.12/KHM/CO/1 |
| **២៥.** គណៈកម្មាធិការស្នើយ៉ាងទទូចឲ្យរដ្ឋភាគី បង្កើនកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួន ក្នុងការប្រយុទ្ធប្រឆាំងនឹងពលកម្មកុមារ និងការពារកុមារពីរាល់ទម្រង់នៃការធ្វើអាជីវកម្មខាងសេដ្ឋកិច្ច និងអាជីវកម្មផ្លូវភេទ ដោយរួមទាំងទម្រង់ដែលអាក្រក់បំផុតនៃពលកម្មកុមារ ក្នុងចំណោមអាជីវកម្មឯទៀត តាមរយៈការពង្រឹងច្បាប់ជាតិរបស់ខ្លួនដែលហាមប្រាមពលកម្មកុមារស្របតាមបទដ្ឋានអន្តរជាតិ ដោយបង្កើនចំនួនអធិការកិច្ចការងារដើម្បីធានាការគោរពច្បាប់ជាតិរបស់ខ្លួន ដែលហាមប្រាមពលកម្មកុមារ ធានាឲ្យមានការពិន័យជាប្រាក់ និងការដាក់ទោសព្រហ្មទណ្ឌ ចំពោះជនទាំងឡាយណាដែលឆ្លៀតទាញយកប្រយោជន៍ពីពលកម្មកុមារដោយខុសច្បាប់ រៀបចំឲ្យមានការបណ្តុះបណ្តាលជាកាតព្វកិច្ចដល់មន្ត្រីប្រតិបត្តិច្បាប់ ព្រះរាជអាជ្ញា និងចៅក្រម និងអនុម័តវិធានការចាំបាច់ ដើម្បីសម្រួលដល់ការស្តារនីតិសម្បទា និងការទទួលបានឱកាសអប់រំសំរាប់អតីតកម្មករកុមារទាំងនោះ។ |

## ង. គ្រួសារ

| |
|---|
| *អនុសាសន៍នៃការពិនិត្យជាសកលតាមកាលកំណត់* (២០១៤) |
| ១១៨.៤៣. គាំទ្រដល់អភិក្រមដែលតម្រង់ទិសគ្រួសារសម្រាប់កិច្ចការពារសិទ្ធិកុមារ និងអនុវត្តគោលនយោបាយជាតិដែលមានស្រាប់ នៅក្នុងន័យនេះ។ (សែបប៊ី)<br><br>១១៨.១០០. ស្របតាមកាតព្វកិច្ចរបស់ខ្លួនក្រោមច្បាប់សិទ្ធិមនុស្សអន្តរជាតិ ផ្តល់ការការពារដោយប្រសិទ្ធភាពដល់គ្រួសារ ដែលជាកោសិកាគ្រឹះ និងធម្មជាតិនៃសង្គម។ (អេហ្ស៊ីប) |
| *អនុសាសន៍នៃការពិនិត្យជាសកលតាមកាលកំណត់* (២០០៩) |
| ៨៣. ពង្រឹងគោលនយោបាយ ដើម្បីធានាទាំងស្រុងដល់សិទ្ធិកុមារ ដោយយកចិត្តទុកដាក់ទៅលើការអនុវត្តសេចក្តីណែនាំសំរាប់កិច្ចគាំពារកុមារតាមជម្រើសផ្សេងៗ ស្របតាមដំណោះស្រាយរបស់ក្រុមប្រឹក្សាលេខ១១/៧ និងសេចក្តីព្រាងដំណោះស្រាយរបស់មហាសន្និបាតលេខA/C.3/64/L.50។ (ប្រេស៊ីល) |
| *គណៈកម្មាធិការសិទ្ធិកុមារ* (២០១៥) CRC/C/OPSC/KHM/CO/1 |
| ៩. ដោយយោងដល់សេចក្តីសង្កេតសន្និដ្ឋានរបស់ខ្លួន ក្រោមអនុសញ្ញានេះ (CRC/C/KHM/CO/2-3, para. 13), គណៈកម្មាធិការសូមផ្តល់អនុសាសន៍ថា រដ្ឋភាគីត្រូវ៖<br><br>ក). ពន្លឿនការអនុម័តផែនការសកម្មភាពថ្មីប្រឆាំងនឹងការជួញដូរ និងការធ្វើអាជីវកម្មផ្លូវភេទកុមារ ដែលគួរបញ្ចូលគ្រប់បញ្ហាដែលគ្របដណ្តប់ដោយពិធីសារបន្ថែមនេះ ជាមួយនឹងវិធានការសំដៅដល់ការបង្ការ ការការពារ និងការធ្វើឱ្យសះស្បើយទាំងផ្លូវកាយ និងផ្លូវចិត្ត និងការធ្វើសមាហរណកម្មកុមាររងគ្រោះទៅក្នុងសង្គមវិញ ព្រមទាំងការស៊ើបសួរ និងការចោទប្រកាន់បទល្មើសដែលគ្របដណ្តប់ដោយពិធីសារបន្ថែមនេះ។<br><br>ខ). ពិចារណាពីការដាក់បញ្ចូលផែនការសកម្មភាពថ្មីទៅក្នុងគោលនយោបាយ និងយុទ្ធសាស្ត្រមួយដែលគ្រប់ជ្រុងជ្រោយ ដោយមានសូចនាករ និងពេលវេលាកំណត់ច្បាស់លាស់ ដើម្បីវាយតំលៃពីការអនុវត្តផែនការនេះ ព្រមទាំងមានធនធានមនុស្ស បច្ចេកទេស និងហិរញ្ញវត្ថុគ្រប់គ្រាន់។<br><br>គ). ឃ្លាំមើល និងវាយតំលៃឱ្យបានទៀងទាត់នៃវិធានការទាំងអស់ដែលបានចាត់ឡើង ដើម្បីកែសម្រួលបន្ថែមទៀតនូវគោលនយោបាយ និងយុទ្ធសាស្ត្រ។ |

២១. គណៈកម្មាធិការទទូចឱ្យរដ្ឋភាគី កែសម្រួលច្បាប់ស្តីពីការបង្ក្រាបការជួញដូរមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទ និងធ្វើឱ្យច្បាប់នេះស្របតាមទាំងស្រុងនឹងមាត្រា២ និងមាត្រា៣ នៃពិធីសារបន្ថែមនេះ ដោយឱ្យនិយមន័យឱ្យបានត្រឹមត្រូវ និងផ្តន្ទាទោសគ្រប់ទម្រង់នៃការលក់កុមារ និងអំពើអាសអាភាសកុមារ។ ជាពិសេស រដ្ឋភាគីគួរៈ

ក). ធ្វើវិសោធនកម្មច្បាប់ដោយដាក់បញ្ចូលនិយមន័យឱ្យបានទូលាយនៃការលក់កុមារដែលរួមមានអំពើផ្តល់ឱ្យ ប្រគល់ឱ្យ ឬទទួលយកកុមារសំរាប់គោលបំណងអាជីវកម្មផ្លូវភេទឬការសុំកូនខុសច្បាប់ សំរាប់ការចូលរួមរបស់កុមារក្នុងពលកម្មដោយបង្ខំ និងសំរាប់ការផ្ទេរសរីរាង្គរបស់កុមារដើម្បីផលប្រយោជន៍ ស្របតាមមាត្រា៣(ក) នៃពិធីសារបន្ថែម និងលប់ចោលលក្ខខណ្ឌតម្រូវអំពីធាតុផ្សំនៃការប្រើកម្លាំង ឬទម្រង់ដទៃទៀតនៃការបង្ខិតបង្ខំ តាមគ្រប់ទម្រង់នៃការលក់កុមារ ក្នុងមាត្រា១២ នៃច្បាប់នេះ។

ខ). ពង្រីកនិយមន័យនៃរូបភាព/សម្ភារៈអាសអាភាសកុមារ ដូចមានចែងក្នុងមាត្រា២(គ) និងមាត្រា៣(គ)នៃពិធីសារបន្ថែម ដើម្បីដាក់បញ្ចូលឱ្យបានច្បាស់លាស់នូវរូបភាពតំណាងកុមារដែលធ្វើឱ្យគេនឹកគិតដល់ផ្លូវភេទ ដែលមិនបានបរិយាយជារូបភាពកុមារចូលរួមពាក់ព័ន្ធនឹងសកម្មភាពផ្លូវភេទដោយចំហ និងដើម្បីបញ្ចូលឱ្យបានទូលាយនូវអំពើផលិត ចែកចាយ ផ្សព្វផ្សាយ នាំចូល នាំចេញ ផ្តល់ឱ្យ លក់ ព្រមទាំងកាន់កាប់ឬចូលមើលឬឆែកមើលដោយដឹងច្បាស់ពីរូបភាព/សម្ភារៈអាសអាភាសកុមារ

២៧. យោងតាមស្មារតីនៃមាត្រា៩ កថាខ័ណ្ឌទី៣នៃពិធីសារបន្ថែម គណៈកម្មាធិការសូមផ្តល់អនុសាសន៍ថារដ្ឋភាគីត្រូវដាក់អាទិភាពឱ្យបានខ្ពស់ នៅក្នុងរបៀបវារៈសាធារណៈ ស្តីពីការប្រយុទ្ធប្រឆាំងនឹងការធ្វើអាជីវកម្មផ្លូវភេទកុមារតាមគ្រប់ទម្រង់ ដើម្បីពង្រឹងឥទ្ធិពលដែលគួរឱ្យខ្លាចនៃក្របខ័ណ្ឌច្បាប់របស់ខ្លួនដែលនៅជាធរមាន។ ធ្វើដូច្នេះបានរដ្ឋភាគីត្រូវៈ

ក). ធានាថាយន្តការបណ្តឹងនៅថ្នាក់សហគមន៍គឺងាយស្រួលអាចរកបាន ហើយកុមាររងគ្រោះដែលសិទ្ធិរបស់គេក្រោមពិធីសារបន្ថែមនេះ ត្រូវបានបំពាន អាចទៅរកប្តឹងបានដោយងាយស្រួល។

ខ). ពង្រឹងសមត្ថភាពអាជ្ញាធរប្រតិបត្តិច្បាប់ទាំងអស់ រួមទាំងអាជ្ញាធរមូលដ្ឋាន និងតុលាការ តាមរយៈការ បណ្តុះបណ្តាលឯកទេសជំនាញ។

គ). បង្កើតយន្តការ និងនីតិវិធីសំរាប់ការស៊ើបអង្កេតពីដំបូងទី និងការកំណត់អត្តសញ្ញាណកុមាររងគ្រោះពីបទល្មើសនានាក្រោមពិធីសារបន្ថែមនេះ រួមទាំងតាមរយៈការចែករំលែកព័ត៌មាន និងយន្តការសហការគ្នាឱ្យកាន់តែកើនឡើង រវាងទីភ្នាក់ងារប្រតិបត្តិច្បាប់ ស្ថាប័នពាក់ព័ន្ធ និងសេវាសង្គម។

ឃ). ចាត់វិធានការនានាដើម្បីធានាថា កុមាររងគ្រោះទាំងអស់មានសិទ្ធិទទួលបាននីតិវិធីគ្រប់គ្រាន់ដើម្បីស្វែងរកសំណងការខូចខាតពីអ្នកទទួលខុសត្រូវតាមផ្លូវច្បាប់ ដោយគ្មានការរើសអើង ស្របតាមមាត្រា៩ កថាខ័ណ្ឌទី៤ នៃពិធីសារបន្ថែមនេះ និងបង្កើតមូលនិធិសំណងដល់កុមាររងគ្រោះមួយ សំរាប់ករណីទាំងឡាយណាដែលកុមាររងគ្រោះមិនអាចទទួលបានសំណងពីជនល្មើស។

| |
|---|
| *គណៈកម្មាធិការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ* (២០១៣)<br>CEDAW/C/KHM/CO/4-5 |
| ៤៧. គណៈកម្មាធិការ ជំរុញឲ្យរដ្ឋភាគី ធ្វើវិកោរណ៍មាត្រា៩ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ ដែលមាន លក្ខណៈរើសអើង និងរិតត្បឹតដោយមិនសមស្របនូវសិទ្ធិរបស់ស្ត្រីក្នុងការរៀបការម្តងទៀត ពីព្រោះបិតុភាពអាចត្រូវបានបង្កើតឡើងយ៉ាងងាយស្រួល ដោយមធ្យោបាយដែលមិនសូវរិតត្បឹតក្នុងវិស័យវេជ្ជសាស្ត្រ។ គណៈកម្មាធិការក៏ ផ្តល់អនុសាសន៍ផងដែរឲ្យរដ្ឋភាគីចាត់វិធានការនានា ដើម្បីសម្រួលដល់ការរៀបការតាមរយៈច្បាប់ប្រពៃណីដែលមាន លក្ខណៈផ្លូវការ ដោយការធានាថា ការចុះលិខិតបញ្ជាក់អាពាហ៍ពិពាហ៍មានតម្លៃសមរម្យ និងគ្មានបន្ទុកខ្លាំង។ |
| *គណៈកម្មាធិការស្តីពីសិទ្ធិកុមារ* (២០១១) CRC/C/KHM/CO/2-3 |
| ៤៤. គណៈកម្មាធិការសូមស្នើឱ្យរដ្ឋភាគីសហការជាមួយអង្គការជាតិ និងអន្តរជាតិ ធ្វើការពង្រឹងសេវាកម្មផ្តល់ប្រឹក្សាយោបល់ដែលមានស្រាប់ដល់ឪពុកម្តាយ ធ្វើការអភិវឌ្ឍបន្ថែមទៀតនូវការលើកកម្ពស់ការយល់ដឹង និងការអប់រំ ឧទា. តាមរយៈការបណ្តុះបណ្តាលសម្រាប់ឪពុកម្តាយអំពីការថែទាំកុមារតូច ការណែនាំដោយឪពុកម្តាយ និងការទទួលខុសត្រូវរួមរបស់ឪពុកម្តាយ ស្របតាមមាត្រា១៨ នៃអនុសញ្ញា។ គណៈកម្មាធិការក៏សូមស្នើឱ្យរដ្ឋភាគីកសាងនូវប្រព័ន្ធការពារកុមារ ដើម្បីពិនិត្យតាមដានបន្តលើគ្រួសារដែលត្រូវការវិធានការគាំទ្រ ដើម្បីផ្តល់ការថែទាំដ៏សមស្រប និងការយកចិត្តទុកដាក់ចំពោះកូនរបស់ខ្លួន។<br><br>៤៦. គណៈកម្មាធិការសូមអំពាវនាវឱ្យរដ្ឋភាគី ធ្វើការអនុម័តភ្លាមៗនូវប្រកាសដែលពាក់ព័ន្ធនឹងគោលនយោបាយស្តីពីការថែទាំជំនួសចំពោះកុមារ និងផ្តល់ធនធានមនុស្ស បច្ចេកទេស និងហិរញ្ញវត្ថុដ៏ចាំបាច់សម្រាប់ការអនុវត្តដ៏ពេញលេញនៃគោលនយោបាយ និងបទដ្ឋានអប្បបរមាស្តីពីការថែទាំជំនួសចំពោះកុមារ។ គណៈកម្មាធិការក៏សូមទទូចឱ្យរដ្ឋភាគី៖<br><br>ក). ចាត់វិធានការដ៏មានប្រសិទ្ធភាពដើម្បីលើកកម្ពស់ តាមរយៈការផ្តល់ប្រឹក្សា និងកម្មវិធីនៅតាមសហគមន៍ ដែលគ្រួសារគឺជាបរិស្ថានដ៏ប្រសើរបំផុតសម្រាប់កុមារ និងផ្តល់សិទ្ធិអំណាចឱ្យឪពុកម្តាយមើលថែទាំកូនរបស់ខ្លួន ដើម្បីជៀសវាងនូវការទុកដាក់កុមារនៅក្នុងមណ្ឌលថែទាំកុមារ។<br><br>ខ). បង្កើតលក្ខណៈវិនិច្ឆ័យ និងយុទ្ធសាស្ត្រដែលទូលំទូលាយសម្រាប់ទទួលយកកុមារមកស្នាក់នៅ ដើម្បីកាត់បន្ថយចំនួនកុមាររស់នៅក្នុងស្ថាប័នថែទាំ រួមទាំងតាមរយៈគោលនយោបាយដើម្បីពង្រឹង និងគាំទ្រគ្រួសារ ព្រមទាំងដើម្បីធានាថា ការទុកដាក់កុមារនៅក្នុងស្ថាប័នត្រូវបានប្រើប្រាស់ តែជាជម្រើសចុងក្រោយប៉ុណ្ណោះ។<br><br>គ). អនុវត្តយន្តការដើម្បីធ្វើសមាហរណកម្មកុមារដែលបានទុកដាក់នៅក្នុងស្ថាប័នត្រឡប់ទៅគ្រួសារគេវិញ<br><br>ឃ). ជ្រើសរើសបុគ្គលិកថែទាំកុមារបន្ថែមទៀត និងធានាថាពួកគេត្រូវបានបណ្តុះបណ្តាល និងមានប្រាក់បំណាច់គ្រប់គ្រាន់ ក្នុងការពិនិត្យតាមដានវិធានការថែទាំជំនួសប្រភេទគ្រួសារ និង<br><br>ង). ពិចារណាចំពោះគោលការណ៍ណែនាំ សម្រាប់ការថែទាំជំនួសចំពោះកុមារ ដែលស្ថិតនៅក្នុងឧបសម្ព័ន្ធនៃសេចក្តីសម្រេចរបស់មហាសន្និបាតអង្គការសហប្រជាជាតិលេខ៦៤/១៤២ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០០៩។ |

## *ច. ការជួញដូរ*

| *អនុសាសន៍នៃការពិនិត្យជាសកលតាមកាលកំណត់ (២០១៤)* |
|---|
| **១១៨. ៧៥**. បន្តកិច្ចខិតខំប្រឹងប្រែងប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្ស។ (អ៊ុយបេគីស្ថាន)<br><br>**១១៨.៧៦**. បង្កើនកិច្ចខិតខំប្រឹងប្រែងទ្វេដង ដើម្បីប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារ។ (អេក្វាឌ័រ)<br><br>**១១៨.៧៧**. បន្តចាត់វិធានការចាំបាច់នានាដើម្បីប្រយុទ្ធនឹងការជួញដូរមនុស្សនិងពលកម្មកុមារដោយប្រសិទ្ធភាព។ (អាល្លឺម៉ង់)<br><br>**១១៨.៧៨**. បន្តខិតខំប្រឹងប្រែងប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្ស ជាពិសេសកុមារ។ (នីការ៉ាហ្គ័រ) |
| *អនុសាសន៍នៃការពិនិត្យជាសកលតាមកាលកំណត់ (២០០៩)* |
| **៣២**.(ក). បង្កើនកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួន ដើម្បីធ្វើឲ្យរីកចំរើនដល់សិទ្ធិមនុស្សរបស់ស្ត្រី និងប្រយុទ្ធប្រឆាំងនឹងបញ្ហាចំបងៗ ដូចជាអំពើជួញដូរមនុស្ស អំពើហឹង្សាផ្លូវភេទ អំពើហឹង្សាក្នុងគ្រួសារ និងការកេងប្រវ័ញ្ចនារីនិងកុមារ។ (ណ័រវេស)<br><br>(ខ). បន្តប្រយុទ្ធនឹងការរើសអើង និងការកេងប្រវ័ញ្ចផ្លូវភេទស្ត្រី និងកុមារី ជាពិសេស តាមរយៈការលើកកំពស់កិច្ចខិតខំប្រឹងប្រែងប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្ស។ (ហ្វីលីពីន)<br><br>(គ). ពង្រឹង និងប្រសិនជាចាំបាច់ កែប្រែនូវផែនការជាតិទី២របស់ខ្លួន ឆ្នាំ២០០៦-២០១០ ស្តីពីការជួញដូរមនុស្សនិងអំពើជួញដូរផ្លូវភេទ ព្រមទាំងច្បាប់ស្តីពីការប្រឆាំងនឹងការជួញដូរដែលត្រូវបានអនុម័តកាលពីឆ្នាំ២០០៨ និងធានាពីការអនុវត្តឱ្យបានត្រឹមត្រូវ។ (ស្លូវ៉ាគី)<br><br>(ឃ). អនុវត្តឲ្យបានពេញលេញនូវផែនការជាតិទី២ ស្តីពីការជួញដូរមនុស្ស និងអំពើជួញដូរផ្លូវភេទ ជាពិសេស សង្កត់ធ្ងន់លើវិធានការនានាគាំពារដល់ជនរងគ្រោះ ដូចជាកិច្ចគាំពារផ្លូវច្បាប់ វេជ្ជសាស្ត្រ និងចិត្តសាស្ត្រ ព្រមទាំងការផ្តល់ជំរកស្នាក់នៅដល់ពួកគេផង។ (អ៊ីតាលី)<br><br>(ង). បង្កើនកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួន ប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្ស និងលប់បំបាត់នូវអំពើហឹង្សាប្រឆាំងនឹងមនុស្ស។ (បេឡារូស)<br><br>(ច). បង្កើនការប្រយុទ្ធប្រឆាំងរបស់ខ្លួននឹងអំពើជួញដូរ រួមទាំងតាមរយៈការដោះស្រាយពីឬសគល់នៃបញ្ហា ដូចជា ភាពក្រីក្រ ដោយឈរលើមូលដ្ឋានយេនឌ័រ ជាដើម។ (ម៉ាឡេស៊ី) |

(ឆ). ពង្រឹងតួនាទីរបស់មន្ត្រីនគរបាលនិងអាជ្ញាធរអនុវត្តច្បាប់ផ្សេងទៀតក្នុងការដោះស្រាយអំពើជួញដូរកុមារ និងស្ត្រីភេទ។ (ម៉ាឡេស៊ី)

(ជ). ចាត់វិធានការឲ្យកាន់តែស៊ីជំរៅក្នុងការប្រយុទ្ធនឹងពេស្យាកម្មកុមារ និងអំពើជួញដូរអនីតិជន។ (អេស្ប៉ាញ)

(ឈ). បន្តចាត់វិធានការចាំបាច់ដើម្បីប្រយុទ្ធនឹងការជួញដូរមនុស្ស និងពលកម្មកុមារឲ្យកាន់តែប្រសិទ្ធភាព។ (អាឡឺម៉ង់)

*គណៈកម្មាធិការសិទ្ធិមនុស្ស* (២០១៥) (CCPR/C/SR.3157)

១៨. រដ្ឋភាគីគួរបង្កើន និងសម្របសម្រួលកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួនឲ្យបានល្អប្រសើរជាងមុន ក្នុងការប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្ស ហើយក៏គួរពិចារណាផងដែរអំពីការបង្កើតទីភ្នាក់ងារកណ្ដាលផ្លូវការមួយ ដើម្បីទទួលខុសត្រូវចំពោះការប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្ស និងតាមរយៈការស៊ើបអង្កេត និងការផ្ដន្ទាទោសជនល្មើសជាប្រព័ន្ធ និងជាទូទៅ។ លើសពីនេះទៀត រដ្ឋភាគីគួរតែធានានូវកិច្ចការពារគ្រប់គ្រាន់ សំណង និងសំណងជំងឺចិត្តដល់ជនរងគ្រោះ រាប់ទាំងការស្តារនីតិសម្បទាផង។

*គណៈកម្មាធិការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ* (២០១៣)

CEDAW/C/KHM/CO/4-5

២៥. គណៈកម្មាធិការទទូចឲ្យរដ្ឋភាគី៖

(ក). ពង្រឹងការអនុវត្តច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ

(ខ). បង្កើនការផ្សព្វផ្សាយព័ត៌មានអំពីទេសន្តរប្រវេសន៍ដើម្បីការងារ និងផ្តល់ព័ត៌មានអំពីក្រុមហ៊ុនបោកប្រាស់ជ្រើសរើសពលករ ពលការិនី ដែលពាក់ព័ន្ធនឹងអំពើជួញដូរមនុស្ស

(គ). ធានាថា អ្នកជួញដូរមនុស្ស និងអ្នកដទៃទៀតដែលទទួលខុសត្រូវចំពោះអំពើធ្វើអាជីវកម្មផ្លូវភេទលើស្ត្រី និងក្មេងស្រី ត្រូវបានចោទប្រកាន់ និងផ្តន្ទាទោសប្រកបដោយប្រសិទ្ធភាព និង

(ឃ). ពង្រឹងសហប្រតិបត្តិការទ្វេភាគី និងពហុភាគី ក្នុងការប្រយុទ្ធប្រឆាំងការជួញដូរមនុស្សសម្រាប់ការងារបម្រើតាមផ្ទះ និងអំពើធ្វើអាជីវកម្មផ្លូវភេទ

(ង). បញ្ចូលទិន្នន័យអំពីពលករ ពលការិនីទេសន្តរប្រវេសន៍បម្រើការងារតាមផ្ទះ ដែលជាជនរងគ្រោះដោយអំពើជួញដូរ ព័ត៌មានអំពីយន្តការជាតិសម្រាប់ការបញ្ជូន ប្រសិនបើមានក្នុងរបាយការណ៍តាមកាលកំណត់លើកក្រោយ និងធានាថា ជនរងគ្រោះដោយអំពើជួញដូរ ត្រូវបានកំណត់អត្តសញ្ញាណសមស្រប ត្រូវបានគាំទ្រគ្រប់គ្រាន់ និងការពារពីការជួញដូរ។

### *គណៈកម្មាធិការស្តីពីសិទ្ធិកុមារ* (២០១១) CRC/C/KHM/CO/2-3

៤៨. គណៈកម្មាធិការក៏សូមទទូចឱ្យរដ្ឋភាគីធ្វើការអនុម័តដោយឥតបង្អង់នូវប្រកាសស្តីពីការអនុវត្តច្បាប់ស្តីពីសុំកូន អន្តរប្រទេស។ គណៈកម្មាធិការក៏សូមទទូចឱ្យរដ្ឋភាគីធ្វើការធានាពីតម្លាភាពដែលច្បាស់លាស់ និងការត្រួតពិនិត្យតាមដានបន្តដ៏តឹងរ៉ឹង ពាក់ព័ន្ធជាមួយនឹងការសុំកូនអន្តរជាតិ និងធ្វើការចោទប្រកាន់អ្នកទាំងឡាយណាដែលជាប់ពាក់ព័ន្ធក្នុងការសុំកូនខុសច្បាប់ និងអំពើលក់កុមារសម្រាប់គោលដៅសុំកូន។

៧៤. គណៈកម្មាធិការសូមស្នើឱ្យរដ្ឋភាគី ពង្រីកនូវកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួនក្នុងការប្រយុទ្ធប្រឆាំងនឹងការលក់ និងការជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារ ក្នុងគោលដៅកេងប្រវ័ញ្ចផ្លូវភេទ និងធ្វើពលកម្មដោយបង្ខំ មានជាអាទិ៍ តាមរយៈការចោទប្រកាន់ និងការផ្តន្ទាទោសជនល្មើស កម្មវិធីគាំពារ និងយុទ្ធនាការផ្សព្វផ្សាយព័ត៌មានដើម្បីទប់ស្កាត់អំពើជួញដូរ និងផ្តល់ការបណ្តុះបណ្តាលតាមអាណត្តិ សម្រាប់មន្ត្រីអនុវត្តច្បាប់ ព្រះរាជអាជ្ញា និងចៅក្រម អំពីច្បាប់ប្រឆាំងការជួញដូរ និងបង្កើនការផ្តល់ការគាំទ្រ វេជ្ជសាស្ត្រ ចិត្តសាស្ត្រ និងផ្លូវច្បាប់ដល់ជនរងគ្រោះ។

### *គណៈកម្មាធិការប្រឆាំងទារុណកម្ម* (២០១០) CAT/C/KHM/CO/2

២២. រដ្ឋភាគីគួរបង្កើនកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួនក្នុងការការពារ និងប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស ជាពិសេសការជួញដូរស្ត្រី និងកុមារ រួមទាំងអនុវត្តច្បាប់ប្រឆាំងការជួញដូរមនុស្ស ផ្តល់ការការពារដល់ជនរងគ្រោះ និងធានាថាជនរងគ្រោះមានលទ្ធភាពទទួលបានសេវាវេជ្ជសាស្ត្រ សង្គម ស្តារនីតិសម្បទា និងសេវាច្បាប់ រួមមានសេវាប្រឹក្សាយោបល់ប្រកបដោយភាពសមស្រប។ រដ្ឋភាគីក៏គួរបង្កើតលក្ខខណ្ឌឲ្យបានសមរម្យផងដែរសម្រាប់ជនរងគ្រោះ ដើម្បីអាចឲ្យពួកគេប្រើប្រាស់សិទ្ធិក្នុងការដាក់ពាក្យបណ្តឹង ធ្វើការស៊ើបអង្កេតឲ្យបានទាន់ពេលវេលា មិនលំអៀង និងមានប្រសិទ្ធភាពលើការចោទប្រកាន់ទាំងអស់ពីបទជួញដូរមនុស្ស និងធានាថា អ្នកដែលរកឃើញថាមានពិរុទ្ធពីបទឧក្រិដ្ឋទាំងនេះ នឹងត្រូវផ្តន្ទាទោសស្របតាមចរិតលក្ខណៈនៃបទឧក្រិដ្ឋដែលពួកគេបានប្រព្រឹត្ត។

### *គណៈកម្មាធិការសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌* (២០០៩) E/C.12/KHM/CO/1

២៦. គណៈកម្មាធិការផ្តល់ជាអនុសាសន៍ថា រដ្ឋភាគីបង្កើនកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួន ដើម្បីប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារ សំរាប់គោលបំណងធ្វើអាជីវកម្មផ្លូវភេទ និងការងារដោយបង្ខំ ក្នុងចំណោមការធ្វើអាជីវកម្មឯទៀត តាមរយៈការផ្តន្ទាទោស និងការកាត់ទោសជនដែលល្មើសនឹងច្បាប់ប្រឆាំងការជួញដូរមនុស្ស តាមរយៈការគាំទ្រកម្មវិធី និងយុទ្ធនាការផ្សព្វផ្សាយព័ត៌មាន ដើម្បីបង្ការការជួញដូរមនុស្ស ដោយរៀបចំឲ្យមានការបណ្តុះបណ្តាល ជាកាតព្វកិច្ចដល់មន្ត្រីប្រតិបត្តិច្បាប់ ព្រះរាជអាជ្ញា និងចៅក្រម ស្តីពីច្បាប់ប្រឆាំងការជួញដូរមនុស្ស និងបង្កើនការផ្តល់ជំនួយផ្នែកវេជ្ជសាស្ត្រ ចិត្តសាស្ត្រ និងច្បាប់ ដល់ជនរងគ្រោះ។

| អ្នករាយការណ៍ពិសេស |
| --- |
| A/HRC/27/70 Para 83. បន្ថែមពីនេះ អ្នករាយការណ៍ពិសេសសូមផ្តល់អនុសាសន៍ថា រាជរដ្ឋាភិបាលកម្ពុជា និង រាជរដ្ឋាភិបាលថៃ បន្តសម្របសម្រួលតាមរយៈផ្លូវច្បាប់ពីការវិលត្រឡប់ទៅប្រទេសថៃវិញ នៃពលករទេសន្តរប្រវេសន៍កម្ពុជា ដែលមានបំណងចង់ត្រឡប់ទៅវិញ តាមលក្ខណៈមួយដែលត្រូវបង្កើនកិច្ចការពារពួកគេពីការជួញដូរ និងការបំពានសិទ្ធិមនុស្សដទៃទៀត។<br>A/HRC/33/62 Para 61(g). ពង្រឹងយន្តការតុលាការក្នុងការការពារជនរងគ្រោះនៃអំពើហឹង្សាក្នុងគ្រួសារ និងការជួញដូរ ជំរុញកិច្ចខិតខំប្រឹងប្រែងបណ្តុះបណ្តាលមន្ត្រីតុលាការ និងមន្ត្រីអនុវត្តច្បាប់ អំពីច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ដើម្បីធានាឱ្យមានការចោទប្រកាន់ដ៏មានប្រសិទ្ធភាព ជាជាងតាមមធ្យោបាយសម្រុះសម្រួល ហើយត្រូវធានាថាការសម្រុះសម្រួល និងយន្តការក្រៅផ្លូវការ អាចត្រូវប្រើបានតែរឿងក្តីមិនព្រហ្មទណ្ឌ។<br>A/HRC/33/62 Para 61 (h). បណ្តុះបណ្តាលស្ត្រីបន្ថែមទៀត ឱ្យធ្វើការជាមួយជនរងគ្រោះពីអំពើហិង្សា និងការជួញដូរ និងបង្កើតទីតាំងសុវត្ថិភាពមួយសំរាប់ស្ត្រីដែលជាជនរងគ្រោះពីអំពើហិង្សានិងការជួញដូរ និងកម្មវិធីដើម្បីធានាឱ្យមានការជាសះស្បើយឡើងវិញ និងការធ្វើសមាហរណកម្មឡើងវិញទៅក្នុងសង្គម។ |

## ៩. ពិការភាព

| អនុសាសន៍នៃការពិនិត្យជាសកលតាមកាលកំណត់ (២០១៤) |
| --- |
| **១១៨.២៥.** អនុវត្ត និងពង្រឹងគោលនយោបាយ និងច្បាប់នានាដើម្បីការពារ និងលើកស្ទួយសិទ្ធិជនពិការ និងធានាថា យន្តការទាំងនេះមានអភិក្រមផ្អែកលើសិទ្ធិមនុស្ស ដែលមានសង្គតិភាពជាមួយអនុសញ្ញាសិទ្ធិជនពិការ និងដោយពិគ្រោះយោបល់ជាមួយសង្គមស៊ីវិល។ (កូឡុំប៊ី)<br>**១១៨.១៣៧.** បន្តចាត់វិធានការការពារសិទ្ធិសង្គម រួមទាំងសិទ្ធិកុមារ ស្ត្រី និងជនពិការ។ (អ៊ុយបេគីស្ថាន)<br>**១១៨.១៦៩.** បន្តការពារ និងលើកស្ទួយសិទ្ធិជនពិការ។ (ឌ្យីប៊ូទី)<br>**១១៨.១៧០.** បង្កើនកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួន ដើម្បីអនុវត្តឲ្យមានប្រសិទ្ធភាព នូវច្បាប់ស្តីពីការលើកកម្ពស់ និងការការពារសិទ្ធិជនពិការ។ ((សាធារណរដ្ឋអ៊ីស្លាម) អ៊ីរ៉ង់) |

| អនុសាសន៍នៃការពិនិត្យជាសកលតាមកាលកំណត់ (២០០៩) |
| --- |
| **១៦.** ពង្រឹងការតស៊ូមតិរបស់ខ្លួនបន្ថែមទៀតដើម្បីលើកកម្ពស់ការយល់ដឹងជាសាធារណៈអំពីសិទ្ធិមនុស្សជាទូទៅ និងជាពិសេស សិទ្ធិមនុស្សរបស់ក្រុមងាយរងគ្រោះ រាប់បញ្ចូលទាំងស្ត្រី កុមារ ជនពិការ ចាស់ជរា និងជនជាតិដើម។ (សាធារណៈរដ្ឋកូរ៉េ) |

| *គណៈកម្មាធិការស្តីពីសិទ្ធិកុមារ* (២០១១) CRC/C/KHM/CO/2-3 |
| --- |
| **៥២.** គណៈកម្មាធិការសូមទទូចឱ្យរដ្ឋភាគី ធ្វើការធានាឱ្យមានការអនុវត្តប្រកបដោយប្រសិទ្ធភាពនូវច្បាប់ស្តីពីការលើកកម្ពស់ និងកិច្ចការពារសិទ្ធិជនពិការ និងគោលនយោបាយស្តីពីការអប់រំកុមារពិការឆ្នាំ២០០៨ ជាពិសេសដោយផ្តល់នូវធនធានមនុស្ស បច្ចេកទេស និងហិរញ្ញវត្ថុដ៏ចាំបាច់។ គណៈកម្មាធិការក៏សូមស្នើឱ្យរដ្ឋភាគី៖<br><br>ក. ប្រមូលទិន្នន័យដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយស្តីពីកុមារពិការ ដោយធ្វើការបែងចែកតាមអាយុ ភេទ ប្រភេទនៃពិការភាព ទីតាំងភូមិសាស្ត្រ ជនជាតិភាគតិច និងប្រវត្តិសេដ្ឋកិច្ចសង្គម ព្រមទាំងប្រើប្រាស់ទិន្នន័យបែបនេះ សម្រាប់ធ្វើការវិភាគអំពីបុព្វហេតុនៃពិការភាព និងធ្វើការអភិវឌ្ឍគោលនយោបាយ និងកម្មវិធីដើម្បីទប់ស្កាត់ពិការភាព និងដើម្បីជួយកុមារពិការ។<br><br>ខ. អនុម័តគោលនយោបាយសម្រាប់ពិនិត្យឱ្យបានដឹងជាមុន ការកំណត់អត្តសញ្ញាណ ការធ្វើអន្តរាគមន៍ និងការបង្ការពិការភាពឱ្យបានមុន។<br><br>គ. ធានាថាសេវាជាមូលដ្ឋានសម្រាប់កុមារពិការត្រូវបានផ្តល់ដោយមានការទទួលខុសត្រូវពីរដ្ឋ។<br><br>ឃ. ធ្វើការបណ្តុះបណ្តាលអ្នកជំនាញខាងសុខភាពកាន់តែច្រើនថែមទៀត និងបើកគ្លីនីកចល័ត ដោយផ្តល់នូវសេវាសុខភាពដល់កុមារពិការ ជាពិសេស នៅតំបន់ជនបទ។<br><br>ង. អនុវត្តកម្មវិធីដោយមានជំនួយពីប្រព័ន្ធផ្សព្វផ្សាយ អង្គការសង្គមស៊ីវិល និងមេដឹកនាំសហគមន៍ ដើម្បីធ្វើការលើកកម្ពស់ការយល់ដឹងអំពីសិទ្ធិរបស់កុមារពិការ និងដើម្បីប្រយុទ្ធប្រឆាំងនឹងការរើសអើងប្រឆាំងនឹងពួកគេ។<br><br>ច. លើកកម្ពស់គុណភាពនៃការបញ្ច្រាប និងការអប់រំពិសេស ព្រមទាំងធ្វើការអភិវឌ្ឍបន្ថែមទៀត នូវកម្មវិធីអប់រំក្រៅប្រព័ន្ធ ក៏ដូចជាការបណ្តុះបណ្តាលគ្រូបង្រៀនឱ្យបានទៀងទាត់ និងស៊ីជម្រៅ ដើម្បីឱ្យសមស្របទៅនឹងប្រភេទផ្សេងៗនៃពិការភាព។<br><br>ឆ. ផ្តល់សច្ចាប័នចំពោះអនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិជនពិការ និង<br><br>ជ. ពិចារណាសេចក្តីពន្យល់ទូទៅលេខ៩ (ឆ្នាំ២០០៦) របស់គណៈកម្មាធិការស្តីពីសិទ្ធិរបស់កុមារដែលមានពិការភាព (CRC/C/GC/9)។ |
| *គណៈកម្មាធិការសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌* (២០០៩) E/C.12/KHM/CO/1 |
| **១៧.** គណៈកម្មាធិការផ្តល់ជាអនុសាសន៍ថារដ្ឋភាគីគួរអនុម័តច្បាប់ជាតិមួយស្តីពីសិទ្ធិជនពិការ។ គណៈកម្មាធិការស្នើឲ្យរដ្ឋភាគីបញ្ចូលក្នុងរបាយការណ៍តាមកាលកំណត់លើកក្រោយរបស់ខ្លួននូវព័ត៌មានលំអិតអំពីជនពិការ ដោយបញ្ចូលទាំងកុមារ និងស្ត្រីក្នុងនោះផងដែរ ពាក់ព័ន្ធនឹងការទទួលបានសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌។ |

## XIII. អនុសាសន៍នានាពាក់ព័ន្ធនឹងគោលដៅអភិវឌ្ឍន៍ចីរភាព

### គោលដៅទី១៖ បញ្ចប់ភាពក្រីក្រតាមគ្រប់ទម្រង់ គ្រប់ទីកន្លែង

*សូមមើលលេខ IX-ខ អំពីការកាត់បន្ថយភាពក្រីក្រ/គម្លាតទ្រព្យសម្បត្តិ/ទីក្រុង-ជនបទ*

### គោលដៅទី២៖ បញ្ចប់ភាពអត់ឃ្លាន សម្រេចឱ្យបានសន្តិសុខស្បៀង និងអាហារូបត្ថម្ភដែលត្រូវបានកែលម្អ និងលើកកំពស់កសិកម្មប្រកបដោយចីរភាព

| *អនុសាសន៍នៃការពិនិត្យជាសកលតាមកាលកំណត់* (២០១៤) |
|---|
| **១១៨.១៣៤.** បន្តកំណែទម្រង់ប្រព័ន្ធកាន់កាប់ដីធ្លី ដើម្បីឆ្លើយតបនឹងគោលដៅជាតិនៃការកាត់បន្ថយភាពក្រីក្រ សន្តិសុខស្បៀង និងការការពារបរិស្ថាន។ (ម៉ូរ៉ុកកូ)<br>**១១៨.១៣៦.** បង្កើនកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួន ដើម្បីសម្រេចបានគោលដៅជាតិសម្រាប់ការកាត់បន្ថយភាពក្រីក្រ សន្តិសុខស្បៀង និងការអភិវឌ្ឍសង្គមសេដ្ឋកិច្ច រួមទាំងតាមរយៈកំណែទម្រង់ការគ្រប់គ្រងដីធ្លី។ (ម៉ាឡេស៊ី) |
| *គណៈកម្មាធិការស្តីពីសិទ្ធិកុមារ* (២០១១) CRC/C/KHM/CO/2-3 |
| ៥៤. គណៈកម្មាធិការសូមស្នើឱ្យរដ្ឋភាគី៖<br>**ក.** ពង្រីកការទទួលយកបាននូវសេវាកម្មថែទាំសុខភាព ដោយមិនគិតកម្រៃនៅគ្រប់ខេត្ត និងផ្តល់នូវធនធានមនុស្ស បច្ចេកទេស និងហិរញ្ញវត្ថុគ្រប់គ្រាន់ សម្រាប់ផ្គត់ផ្គង់សេវាកម្មទាំងនេះ ក្នុងទម្រង់មួយដែលផ្តល់អត្ថប្រយោជន៍ដល់ប្រជាជនទាំងនៅទីប្រជុំជន និងទាំងនៅទីជនបទ។<br>**ខ.** ពង្រឹងកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួន ដើម្បីកាត់បន្ថយអត្រាមរណភាពកុមារអាយុក្រោម១ឆ្នាំ និងកុមារអាយុក្រោម៥ឆ្នាំ និងម្តាយដែលមានផ្ទៃពោះ រួមទាំងការថែទាំមុន និងពេលសម្រាលកូន។<br>**គ.** ចាត់វិធានការបន្ទាន់ ដើម្បីដោះស្រាយឱ្យបានទូលំទូលាយនូវបញ្ហានៃការខ្វះអាហារូបត្ថម្ភ ចំពោះកុមារអាយុក្រោម៥ឆ្នាំ។<br>**ឃ.** ចាត់វិធានការជាបន្ទាន់ ដើម្បីដោះស្រាយបញ្ហាសុខភាព ដែលអាចបង្ការទប់ស្កាត់បាន ក្នុងចំណោមកុមារ រួមទាំងកង្វះជាតិអ៊ីយ៉ូដ ជំងឺគ្រុនចាញ់ ជំងឺរាគ ជំងឺផ្លូវដង្ហើមស្រួចស្រាវ ជំងឺកញ្ជ្រិល និងជំងឺរលាកស្រោមខួរ។<br>**ង.** អភិវឌ្ឍគោលនយោបាយជាតិកុមារ និងសុខភាពផ្លូវចិត្តដ៏ស៊ីជម្រៅមួយ រួមទាំង រាល់សមាសភាពដែលមានគ្រប់កាតព្វកិច្ចនៃអនុសាសន៍ស្នូលរបស់អង្គការសុខភាពពិភពលោក រួមទាំងការលើកកម្ពស់សុខភាពផ្លូវចិត្ត ការប្រឹក្សាយោបល់ ការបង្ការភាពមិនប្រក្រតីនៃសុខភាពផ្លូវចិត្តនៅក្នុងការថែទាំសុខភាពបឋម នៅក្នុងសាលារៀន និងសហគមន៍ក៏ដូចជាសេវាសុខភាពផ្លូវចិត្តសម្រាប់អ្នកជំងឺពីខាងក្រៅ និងអ្នកជំងឺនៅក្នុងមន្ទីរពេទ្យសម្រាប់កុមារ និងយុវវ័យដែលមានបញ្ហាផ្លូវចិត្តធ្ងន់ធ្ងរ និង<br>**ច.** ស្វែងរកជំនួយបច្ចេកទេស ជាអាទិ៍ពីអង្គការយូនីសេហ្វនិងអង្គការសុខភាពពិភពលោកពាក់ព័ន្ធនឹងបញ្ហានេះ។ |

## គោលដៅទី៣៖ ធានាឱ្យជីវិតមានសុខភាព និងលើកកំពស់សុខមាលភាពសំរាប់ទាំងអស់គ្នា និងគ្រប់វ័យ

*សូមមើលលេខ XI-ក អំពីសុខភាព រួមទាំងHIV*

## គោលដៅទី៤៖ ធានាគុណភាពនៃការអប់រំដែលមានសមធម៌ និងបរិយាប័ន្ន និងលើកកំពស់ឱកាសរៀនសូត្រពេញមួយជីវិតសំរាប់ទាំងអស់គ្នា

*សូមមើលលេខ XI-ខ អំពីការអប់រំ*

## គោលដៅទី៥៖ សម្រេចសមភាពយេនឌ័រ និងពង្រឹងភាពអង់អាចដល់គ្រប់ស្ត្រី និងកុមារី

*សូមមើលលេខ XII. ស្តីពីសិទ្ធិស្ត្រី សិទ្ធិកុមារ និងសិទ្ធិជនពិការ*

## គោលដៅទី៦៖ ធានាឱ្យមាន និងការគ្រប់គ្រងប្រកបដោយចេរភាពនូវទឹកស្អាត និងអនាម័យទាំងអស់គ្នា

| *អ្នករាយការណ៍ពិសេស* |
|---|
| A/HRC/21/63/Add.1/Rev.1. Para. 222. ក្រុមហ៊ុនសម្បទាន គួរចាត់វាល់វិធានការដើម្បីចៀសវាងការបំផ្លាញបរិដ្ឋាននៅក្នុងប្រតិបត្តិការរបស់ខ្លួន រួមទាំងបង្ការមិនឲ្យទឹកកកក្វក់មានរោគ បំផ្លិចបំផ្លាញដល់ដី និងការកាប់រានយកដីដោយមិនចាំបាច់ ឬការកាប់បំផ្លាញព្រៃឈើដោយខុសច្បាប់។ ក្រុមហ៊ុនទាំងនេះគួរធានាថា ការទទួលបានហេដ្ឋារចនាសម្ព័ន្ធ ដូចជាការកសាងផ្លូវថ្មីនៅលើដីសម្បទានរបស់ខ្លួន អាចត្រូវបានប្រើប្រាស់ដោយសហគមន៍នានានៅជុំវិញនោះ ហើយមិនគួររាំងខ្ទប់មិនឲ្យមានការធ្វើដំណើរនៅក្នុងព្រំដែននៃដីសម្បទានរបស់ខ្លួនឡើយ។<br><br>A/HRC/21/63/Add.1/Rev.1. Para.238. ដើម្បីអាចត្រួតពិនិត្យបន្ថែមទៀតពីផលប៉ះពាល់សិទ្ធិមនុស្សនៃសម្បទានដីសេដ្ឋកិច្ច និងសម្បទានដីដទៃទៀត រាជរដ្ឋាភិបាលគួរចេញលិខិតអញ្ជើញជាអចិន្ត្រៃយ៍មួយដល់យន្តការនីតិវិធីពិសេសរបស់សហប្រជាជាតិ ឬយ៉ាងហោចណាស់អញ្ជើញអ្នកកាន់អាណត្តិពាក់ព័ន្ធ ដែលអាចផ្តល់ការវិភាគពិស្តារបាន។ និយាយដោយឡែក អ្នកដែលពាក់ព័ន្ធ គួរតែជាអ្នករាយការណ៍ពិសេសអំពីជនជាតិដើមភាគតិច ក្រុមការងារអំពីធុរកិច្ច និងសិទ្ធិមនុស្ស និងអ្នករាយការណ៍ពិសេសអំពីសិទ្ធិមានអាហារ លំនៅដ្ឋានសមរម្យ សិទ្ធិអប់រំ ទីទាល់ក្រអនាម័យនិងសុវត្ថិភាពទឹកស្អាត និងសិទ្ធិវប្បធម៌។ |

## គោលដៅទី៧៖ ធានាឱ្យទទួលបានទាំងអស់គ្នានូវថាមពលទំនើប ដែលជឿទុកចិត្តបាន មានតម្លៃសមរម្យ និងប្រកបដោយចីរភាព

| |
|---|
| *អនុសាសន៍នៃការពិនិត្យជាសកលតាមកាលកំណត់* (២០០៩) |
| **៧៥.** ធានាឲ្យមានការគ្រប់គ្រងប្រេងឧស្ម័ន និងចំណូលពីរ៉ែប្រកបដោយតម្លាភាព ដើម្បីឆ្លើយតបនឹងសិទ្ធិសង្គមកិច្ច និងសេដ្ឋកិច្ចរបស់ប្រជាជនរស់នៅកម្ពុជា ដោយប្រកាន់យកការអនុវត្តល្អបំផុតជាលក្ខណៈអន្តរជាតិ ក្នុងការអនុវត្តឧស្សាហកម្មចំរាញ់ផលពីធម្មជាតិ។ (អៀកឡង់ដ៍) |
| *គណៈកម្មាធិការសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌* (២០០៩) E/C.12/KHM/CO/1 |
| **៣០.** គណៈកម្មាធិការស្នើយ៉ាងទទូចឲ្យរដ្ឋភាគីធ្វើការផ្អាកជាបណ្តោះអាសន្ននូវរាល់ការបណ្តេញ ចេញរហូតដល់មានក្របខ័ណ្ឌច្បាប់ត្រឹមត្រូវ និងដំណើរការផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លីត្រូវបានបញ្ចប់ ដើម្បីធានាការការពារសិទ្ធិមនុស្សនៃប្រជាជនកម្ពុជាគ្រប់រូប ដោយរួមទាំងជនជាតិដើមភាគតិចផង។ គណៈកម្មាធិការផ្តល់ជាអនុសាសន៍ឲ្យរដ្ឋភាគីធ្វើការពិគ្រោះយោបល់ជាបន្ទាន់ជាមួយស្ថាប័នជាដៃគូពាក់ព័ន្ធនានាដើម្បីឈានទៅបំពេញនិយមន័យនៃពាក្យ"ផលប្រយោជន៍សាធារណ" ដូចមានចែងក្នុងច្បាប់ភូមិបាលឆ្នាំ២០០១ និងបង្កើតគោលការណ៍ណែនាំមួយច្បាស់លាស់សំរាប់ការបណ្តេញចេញ ប្រសិនជាអាចមាន។ គណៈកម្មាធិការស្នើយ៉ាងទទូចផងដែរឲ្យរដ្ឋភាគីកំណត់ព្រំប្រទល់ឲ្យបានច្បាស់លាស់រវាងដីសាធារណៈរបស់រដ្ឋ និងដីឯកជនរបស់រដ្ឋ។ ដោយចាត់ទុកជាបញ្ហាអាទិភាព គណៈកម្មាធិការផ្តល់ជាអនុសាសន៍យ៉ាងខ្លាំងថា រដ្ឋភាគីធ្វើការពិគ្រោះយោបល់ជាចំហរដោយមានការចូលរួមនិងប្រកបដោយអត្ថន័យជាមួយអ្នកភូមិ និងសហគមន៍នានាដែលរងផលប៉ះពាល់ជាមុន មុននឹងអនុវត្តគំរោងអភិវឌ្ឍន៍ និងគំរោងរៀបចំទីក្រុងជាថ្មី ហើយត្រូវធានាថា បុគ្គលទាំងឡាយដែលត្រូវបានបណ្តេញចេញដោយបង្ខំពីដីរបស់ខ្លួន ត្រូវបានផ្តល់សំណងសមរម្យ និង/ឬផ្តល់ជូនគាត់នូវទីតាំងថ្មី ស្របតាមគោលការណ៍ណែនាំដែលបានអនុម័តដោយគណៈកម្មាធិការក្នុងសេចក្តីពន្យល់ទូទៅលេខ៧(១៩៩៧) របស់ខ្លួនស្តីពីការបណ្តេញចេញដោយបង្ខំនិងធានាថាទីតាំងថ្មីត្រូវផ្តល់ឲ្យមានសេវាមូលដ្ឋានផ្សេងៗ រួមទាំងទឹក ភ្លើងអគ្គីសនី សំភារៈសំរាប់ដុសសំអាត និងអានាម័យគ្រប់គ្រាន់ ព្រមទាំងសេវាឯទៀត រួមមាន សាលារៀន មណ្ឌលគាំពារសុខភាព និងមធ្យោបាយដឹកជញ្ជូននៅពេលធ្វើការតាំងលំនៅថ្មី។ គណៈកម្មាធិការទាញចំណាប់អារម្មណ៍ផងដែរដល់រដ្ឋភាគីចំពោះគោលការណ៍ណែនាំស្តីពីការបណ្តេញចេញ និងការធ្វើចំណាកស្រុកផ្អែកលើការអភិវឌ្ឍន៍ (UN Doc. No. A/HRC/4/18) ដែលបានរៀបចំដោយអ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិស្តីពីសិទ្ធិមានលំនៅដ្ឋានសមរម្យ។ |

## គោលដៅទី៨៖ លើកកំពស់កំណើនសេដ្ឋកិច្ចឱ្យបានចិរភាព បរិយាប័ន្ន និងប្រកបដោយចីរភាព ការធ្វើការពេញលេញនិងមានផលិតភាព និងការងារសមរម្យទាំងអស់គ្នា

*គណៈកម្មាធិការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ* (២០១៣)
CEDAW/C/KHM/CO/4-5

៣៥. គណៈកម្មាធិការផ្ដល់អនុសាសន៍ឲ្យរដ្ឋភាគីៈ

(ត). ពិចារណាពីការចូលជាសមាជិកនៃអនុសញ្ញាអង្គការពលកម្មអន្តរជាតិលេខ១៨៩ ស្ដីពីការងារសមរម្យសម្រាប់អ្នកធ្វើការតាមផ្ទះ និងអនុសញ្ញាស្ដីពីការការពារពលករទេសន្តរប្រវេសន៍គ្រប់រូបនិងសមាជិកគ្រួសារពួកគេ។

*គណៈកម្មាធិការសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌* (២០០៩) E/C.12/KHM/CO/1

៤៥. គណៈកម្មាធិការជំរុញលើទឹកចិត្តផងដែរដល់រដ្ឋភាគីឲ្យពិចារណាផ្ដល់សច្ចាប័នលើអនុសញ្ញាអង្គការពលកម្មអន្តរជាតិលេខ៨១(១៩៤៧) ស្ដីពីអធិការកិច្ចការងារក្នុងវិស័យឧស្សាហកម្ម និងពាណិជ្ជកម្ម និងអនុសញ្ញាលេខ ១០២ (១៩៥២) ស្ដីពីបទដ្ឋានអប្បបរមានៃការធានារ៉ាប់រងផ្នែកសង្គម (របបសន្តិសុខសង្គម)។

## គោលដៅទី៩៖ កសាងហេដ្ឋារចនាសម្ព័ន្ធ លើកកំពស់ឧស្សាហូបនីយកម្មប្រកបដោយចីរភាពនិងបរិយាប័ន្ន និងជំរុញនវកម្ម

*គណៈកម្មាធិការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ* (២០១៣)
CEDAW/C/KHM/CO/4-5

៣៣. គណៈកម្មាធិការសូមផ្ដល់អនុសាសន៍ឲ្យរដ្ឋភាគីៈ

(ក). ចាត់វិធានការដែលមានប្រសិទ្ធភាព ដើម្បីបង្កើនការទទួលបានការអប់រំសម្រាប់កុមារី រាប់បញ្ចូលទាំងតាមរយៈការពង្រឹងហេដ្ឋារចនាសម្ព័ន្ធសាលា និងបង្កើនចំនួនកន្លែងឱ្យបានច្រើនថែមទៀតនៅក្នុងសាលាកំរិតមធ្យម សិក្សាពិសេសនៅតាមឃុំនានា។

*គណៈកម្មាធិការប្រឆាំងទារុណកម្ម* (២០១០) CAT/C/KHM/CO/2

១៩. រដ្ឋភាគីគួរពង្រីកកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួនដើម្បីកាត់បន្ថយភាពចង្អៀតណែនហួសហេតុឲ្យមានប្រសិទ្ធភាពនៅទីកន្លែងទាំងឡាយដែលមនុស្សត្រូវបានដកហូតសេរីភាព រួមមានស្ថានីយ៍នគរបាល និងពន្ធនាគារ ហើយដើម្បីកែលំអលក្ខខណ្ឌឃុំខ្លួននៅតាមទីកន្លែងទាំងនេះ ដូចជាអនាម័យ និងការផ្គត់ផ្គង់ម្ហូបអាហារជាដើម។ ដើម្បីសម្រេចបានគោលបំណងនេះ គណៈកម្មាធិការសូមផ្ដល់អនុសាសន៍ថា រដ្ឋភាគីត្រូវអនុវត្តវិធានការផ្សេងៗជំនួសឲ្យការដាក់ពន្ធនាគារ និងធានាឲ្យមានការបែងចែកថវិកាគ្រប់គ្រាន់ ដើម្បីអភិវឌ្ឍ និងជួសជុលហេដ្ឋារចនាសម្ព័ន្ធពន្ធនាគារ និងទីកន្លែងឃុំខ្លួនផ្សេងៗទៀត។ [...]

## គោលដៅទី១០៖ កាត់បន្ថយវិសមភាពក្នុងចំណោម និងរវាងប្រទេសនានា

| *អនុសាសន៍នៃការពិនិត្យជាសកលតាមកាលកំណត់* (២០១៤) |
|---|
| **១១៨.១២៨.** ពង្រឹងកិច្ចខិតខំប្រឹងប្រែងដើម្បីកាត់បន្ថយភាពក្រីក្រនៅក្នុងតំបន់ជនបទ និងភ្ជាប់គម្លាតទ្រព្យធនរវាងតំបន់ជនបទ និងទីក្រុង។ (ស្រីលង្កា) |
| **១១៨.១៣៨.** បង្កើនកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួនដើម្បីកាត់បន្ថយវិសមភាពប្រាក់ចំណូលរវាងតំបន់ជនបទនិងទីក្រុង ដោយមានការគាំទ្រពីសហគមន៍អន្តរជាតិ និងទីភ្នាក់ងារអង្គការសហប្រជាជាតិដែលពាក់ព័ន្ធដទៃទៀត។ (ប៊ូតង់) |
| **១១៨.១៤១.** បន្តកាត់បន្ថយអត្រាភាពក្រីក្រនៅតំបន់ជនបទ និងគម្លាតទ្រព្យធនរវាងអ្នកមាន និងអ្នកក្រ និងរវាងប្រជាជននៅជនបទ និងទីក្រុង។ (មីយ៉ាន់ម៉ា) |
| **១១៨.១៤២.** កាត់បន្ថយគម្លាតរវាងតំបន់ទីក្រុង និងជនបទ តាមរយៈការកាត់បន្ថយភាពក្រីក្រនៅតំបន់ជនបទ។ (អ៊ីរ៉ាក់) |
| **១១៨.១៤៣.** ដោយសហការជាមួយសហគមន៍អន្តរជាតិ អនុវត្តកម្មវិធីនានាប្រកបដោយប្រសិទ្ធភាព សំដៅកាត់បន្ថយភាពក្រីក្រ ជាពិសេស នៅតំបន់ជនបទនៃប្រទេស។ (អារ៉ាប៊ីសាអូឌីត) |
| *អនុសាសន៍នៃការពិនិត្យជាសកលតាមកាលកំណត់* (២០០៩) |
| **៦៣.** សូមពិចារណាពង្រឹងគោលនយោបាយប្រើប្រាស់ដីធ្លី និងចំពោះភាពមិនស្មើភាពនៅតាមតំបន់ទីក្រុង និងជនបទ ព្រមទាំងបន្តកិច្ចខិតខំប្រឹងប្រែង ដើម្បីប្រយុទ្ធប្រឆាំងនឹងភាពក្រីក្រ។ (ប្រេស៊ីល) |

## គោលដៅទី១១៖ ធ្វើឱ្យទីក្រុង និងការតាំងទីលំនៅរបស់ប្រជាជន មានបរិយាប័ន្ន សុវត្ថិភាព រឹងមាំ និងប្រកបដោយចីរភាព

*សូមមើលលេខ X. ស្តីពីដីធ្លី និងសិទ្ធិលំនៅដ្ឋាន*

## គោលដៅទី១២៖ ធានាឱ្យមានលំនាំនៃការប្រើប្រាស់ និងផលិតកម្មប្រកបដោយចីរភាព

| *អនុសាសន៍នៃការពិនិត្យជាសកលតាមកាលកំណត់*(២០០៩) |
|---|
| **៧៣.** លើកកម្ពស់ និងការពារសិទ្ធិប្រជាជនងាយរងគ្រោះ សិទ្ធិអប់រំ និងសិទ្ធិទទួលបានការអភិវឌ្ឍន៍ ដើម្បីកាត់បន្ថយភាពក្រីក្រនៅតាមតំបន់ទីក្រុង និងតំបន់ជនបទ ក្នុងពេលជាមួយគ្នា នៅពេលដែលរក្សាសន្តិភាព ស្ថេរភាព និងការការពារដល់បរិស្ថាន។ (ឡាវ) |

## *គណៈកម្មាធិការសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌* (២០០៩) E/C.12/KHM/CO/1

១៥. គណៈកម្មាធិការស្នើយ៉ាងទទូចដល់រដ្ឋភាគី ឲ្យពិនិត្យឡើងវិញនូវគោលនយោបាយរបស់ខ្លួន ពាក់ព័ន្ធនឹងការបង្វែរតំបន់ការពារឲ្យទៅជាសម្បទានសេដ្ឋកិច្ច ដោយមិនបានធ្វើការវាយតំលៃពីផលប៉ះពាល់សង្គម និងបរិស្ថានជាមុនជាមួយស្ថាប័នជាដៃគូពាក់ព័ន្ធ និងសហគមន៍នានា ដោយគោរពយ៉ាងត្រឹមត្រូវចំពោះសិទ្ធិរបស់ពួកគាត់ ដើម្បីចូលរួមក្នុងការសំរេចផ្សេងៗ ដែលពួកគាត់ត្រូវតែបានដឹងជាមុនអំពីបញ្ហាទាំងឡាយ ដែលប៉ះពាល់ដល់ការរស់នៅរបស់ខ្លួន។ គណៈកម្មាធិការផ្តល់ជាអនុសាសន៍យ៉ាងខ្លាំងថា ការផ្តល់សម្បទានសេដ្ឋកិច្ច គួរតែគិតគូរអំពីសេចក្តីត្រូវការសំរាប់ការអភិវឌ្ឍន៍ប្រកបដោយចេរភាព និងដើម្បីឲ្យប្រជាជនកម្ពុជាគ្រប់រូបទទួលបានអត្ថប្រយោជន៍ពីការរីកចំរើននេះ ជាជាងសំរាប់តែផលប្រយោជន៍របស់បុគ្គលឯកជន។ គណៈកម្មាធិការស្នើឲ្យរដ្ឋភាគីបញ្ចូលក្នុងរបាយការណ៍តាមកាលកំណត់លើកក្រោយរបស់ខ្លួន នូវព័ត៌មានលំអិតស្តីពីសមិទ្ធិផលដែលសំរេចបាន ក្នុងការអនុវត្តន៍គោលនយោបាយទាំងនេះ។

១៦. គណៈកម្មាធិការស្នើយ៉ាងទទូចដល់រដ្ឋភាគីឲ្យអនុវត្តច្បាប់ភូមិបាលឆ្នាំ២០០១ ដោយមិនត្រូវអូសបន្លាយពេលវេលាតទៅទៀត និងធានាថាគោលនយោបាយរបស់ខ្លួនស្តីពីការចុះបញ្ជីដីធ្លី មិនត្រូវឲ្យផ្ទុយនឹងស្មារតីនៃច្បាប់នេះឡើយ។ គណៈកម្មាធិការបញ្ជាក់អំពីសេចក្តីត្រូវការឲ្យមានការវាយតំលៃអំពីផលប៉ះពាល់ខាងសង្គម និងបរិស្ថាន និងការពិគ្រោះយោបល់ជាមួយសហគមន៍នានា ដែលរងផលប៉ះពាល់ពាក់ព័ន្ធនឹងសកម្មភាពសេដ្ឋកិច្ច រួមទាំង ការធ្វើអាជីវកម្មរ៉ែ និងអាជីវកម្មប្រេង ក្នុងគោលដៅធានាថា សកម្មភាពទាំងនេះ មិនត្រូវដកហូតពីជនជាតិដើមភាគតិចនូវការទទួលបានយ៉ាងពេញលេញនូវសិទ្ធិរបស់ពួកគាត់លើដីធ្លី និងធនធានធម្មជាតិនៃបុព្វបុរសរបស់ខ្លួនឡើយ។ គណៈកម្មាធិការជំរុញលើកទឹកចិត្តឲ្យរដ្ឋភាគី ពិចារណាផ្តល់សច្ចាប័នលើអនុសញ្ញាអង្គការពលកម្មអន្តរជាតិលេខ ១៦៩ ស្តីពីជនជាតិដើមភាគតិច និងក្រុមកុលសម្ព័ន្ធ។

## *អ្នករាយការណ៍ពិសេស*

A/HRC/21/63/Add.1/Rev.1.Para.216. គួរធ្វើការពិចារណាឲ្យបានត្រឹមត្រូវដល់សំណើសុំរបស់សម្បទានិក ជាមួយនឹងលក្ខខណ្ឌតម្រូវតាមច្បាប់ និងតាមបទបញ្ជានានាបន្ថែម ដោយភ្ជាប់ទៅនឹងគំរោងវិនិយោគរបស់ពួកគេ (ដូចជាគំរោងបញ្ជាក់ភាគីទី៣ និងក្រមសីលធម៌ដ៏តឹងរឹងជាដើម) ដែលត្រូវស៊ីគ្នានឹងបទដ្ឋានអន្តរជាតិនៃចេរភាពសង្គម និងបរិដ្ឋាន។

A/HRC/21/63/Add.1/Rev.1. para 217. ក្រុមហ៊ុនគ្រប់ទម្រង់ រចនាសម្ព័ន្ធ និងរបៀបប្រតិបត្តិការ ទាំងក្រុមហ៊ុនក្នុងស្រុក និងក្រុមហ៊ុនបរទេស ហើយទោះជាក្រុមហ៊ុនរដ្ឋទាំងស្រុង ឬក្រុមហ៊ុនពាក់កណ្តាលរដ្ឋ គួរដោះស្រាយពីផលប៉ះពាល់សិទ្ធិមនុស្សរបស់ខ្លួន ដោយអនុវត្តតាមវិរិយភាពដ៏ត្រឹមត្រូវ រួមទាំង ការអនុវត្តវិធានការនានា ដើម្បីកំណត់អត្តសញ្ញាណ បង្ការនិងជួយសម្រាលដល់ផលវិបាកសិទ្ធិមនុស្សធ្ងន់ធ្ងរ ព្រមទាំងយកចិត្តទុកដាក់ដល់សកម្មភាពអាជីវកម្មរបស់ខ្លួន។

| |
|---|
| A/HRC/21/63/Add.1/Rev.1. Para. 222. ក្រុមហ៊ុនសម្បទាន គួរចាត់វាល់វិធានការដើម្បីចៀសវាងការបំផ្លាញបរិដ្ឋាននៅក្នុងប្រតិបត្តិការរបស់ខ្លួន រួមទាំងបង្ការមិនឲ្យទឹកកក្វក់មានរោគ បំផ្លិចបំផ្លាញដល់ដី និងការកាប់រានយកដីដោយមិនចាំបាច់ ឬការកាប់បំផ្លាញព្រៃឈើដោយខុសច្បាប់។ ក្រុមហ៊ុនទាំងនេះគួរធានាថា ការទទួលបានហេដ្ឋារចនាសម្ព័ន្ធ ដូចជា ការកសាងផ្លូវថ្មីនៅលើដីសម្បទានរបស់ខ្លួន អាចត្រូវបានប្រើប្រាស់ដោយសហគមន៍នានា នៅជុំវិញនោះ ហើយមិនគួររាំងខ្ទប់មិនឲ្យមានការធ្វើដំណើរនៅក្នុងព្រំដែននៃដីសម្បទានរបស់ខ្លួនឡើយ។<br><br>A/HRC/21/63/Add.1/Rev.1.Para. 224. ក្រុមហ៊ុនសម្បទាន—ដោយប្រើប្រាស់ផលលាភដែលបានពីសកម្មភាពសម្បទានរបស់ខ្លួន—គួរបង្កើនវិភាគទានរបស់ខ្លួនដល់សហគមន៍មូលដ្ឋាន រួមទាំងផ្តល់ផលប្រយោជន៍ដល់សង្គម ដូចជា សេវាកម្មសុខាភិបាល ឱកាសអប់រំ និងវិធានការការពារបរិដ្ឋានជាដើម។ |

## គោលដៅទី១៣៖ ចាត់វិធានការបន្ទាន់ដើម្បីប្រយុទ្ធនឹងការប្រែប្រួលអាកាសធាតុ និងផលប៉ះពាល់របស់វា

| *គណៈកម្មាធិការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ* (២០១៣)<br>CEDAW/C/KHM/CO/4-5 |
|---|
| ៤១. គណៈកម្មាធិការសូមផ្តល់អនុសាសន៍ឲ្យរដ្ឋភាគី៖<br>(គ). បន្តធានាថា ស្ត្រីចូលរួមយ៉ាងសកម្មក្នុងការធ្វើសេចក្តីសម្រេច ទាំងក្នុងគោលនយោបាយ និងកម្មវិធីនៃការទប់ស្កាត់ និងការគ្រប់គ្រងគ្រោះមហន្តរាយ ជាពិសេសគោលនយោបាយ និងកម្មវិធីទាំងឡាយទាក់ទងនឹងការបន្សាំ និងការកាត់បន្ថយពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ។ |

## គោលដៅទី១៤៖ អភិរក្ស និងការប្រើប្រាស់ប្រកបដោយចេរភាពនូវមហាសមុទ្រ សមុទ្រ និងធនធានសមុទ្រសំរាប់ការអភិវឌ្ឍន៍ប្រកបដោយចេរភាព

| *អ្នករាយការណ៍ពិសេស* |
|---|
| A/HRC/21/63/Add.1/Rev.1. Para. 222. ក្រុមហ៊ុនសម្បទាន គួរចាត់វាល់វិធានការដើម្បីចៀសវាងការបំផ្លាញបរិដ្ឋាននៅក្នុងប្រតិបត្តិការរបស់ខ្លួន រួមទាំងបង្ការមិនឲ្យទឹកកក្វក់មានរោគ បំផ្លិចបំផ្លាញដល់ដី និងការកាប់រានយកដីដោយមិនចាំបាច់ ឬការកាប់បំផ្លាញព្រៃឈើដោយខុសច្បាប់។ ក្រុមហ៊ុនទាំងនេះគួរធានាថា ការទទួលបានហេដ្ឋារចនាសម្ព័ន្ធ ដូចជា ការកសាងផ្លូវថ្មីនៅលើដីសម្បទានរបស់ខ្លួន អាចត្រូវបានប្រើប្រាស់ដោយសហគមន៍នានា នៅជុំវិញនោះ ហើយមិនគួររាំងខ្ទប់មិនឲ្យមានការធ្វើដំណើរនៅក្នុងព្រំដែននៃដីសម្បទានរបស់ខ្លួនឡើយ។ |

**គោលដៅទី១៥៖ ការពារ ស្តារឡើងវិញ និងលើកកំពស់ការប្រើប្រាស់ប្រព័ន្ធអេកូធរណីប្រកបដោយចេរនាព គ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព ប្រយុទ្ធនឹងការធ្វើឱ្យទៅជាវាលរហោស្ថាន បញ្ឈប់ការធ្វើឱ្យវិចរិលដី និងបំលែងដីព្រៃវិចរិល និងបញ្ឈប់ការបាត់បង់ប្រព័ន្ធជីវចំរុះ**

| |
|---|
| *អនុសាសន៍នៃការពិនិត្យជាសកលតាមកាលកំណត់* (២០១៤) |
| **១១៨.១៣៤.** បន្តកំណែទម្រង់ប្រព័ន្ធកាន់កាប់ដីធ្លី ដើម្បីឆ្លើយតបនឹងគោលដៅជាតិនៃការកាត់បន្ថយភាពក្រីក្រ សន្តិសុខស្បៀង និងការការពារបរិស្ថាន។ (ម៉ូរ៉ុកកូ) |
| *អនុសាសន៍នៃការពិនិត្យជាសកលតាមកាលកំណត់* (២០០៩) |
| **៧៣.** លើកកម្ពស់ និងការពារសិទ្ធិប្រជាជនងាយរងគ្រោះ សិទ្ធិអប់រំ និងសិទ្ធិទទួលបានការអភិវឌ្ឍន៍ដើម្បីកាត់បន្ថយភាពក្រីក្រនៅតាមតំបន់ទីក្រុង និងតំបន់ជនបទ ក្នុងពេលជាមួយគ្នា នៅពេលដែលរក្សាសន្តិភាព ស្ថេរភាព និងការការពារដល់បរិស្ថាន។ (ឡាវ) |
| *គណៈកម្មាធិការសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌* (២០០៩) E/C.12/KHM/CO/1 |
| **១៥.** គណៈកម្មាធិការស្នើយ៉ាងទទូចដល់រដ្ឋភាគី ឲ្យពិនិត្យឡើងវិញនូវគោលនយោបាយរបស់ខ្លួន ពាក់ព័ន្ធនឹងការបង្វែរតំបន់ការពារឲ្យទៅជាសម្បទានសេដ្ឋកិច្ច ដោយមិនបានធ្វើការវាយតំលៃពីផលប៉ះពាល់ខាងសង្គម និងបរិស្ថានជាមុន ជាមួយស្ថាប័នជាដៃគូពាក់ព័ន្ធ និងសហគមន៍នានា ដោយគោរពយ៉ាងត្រឹមត្រូវចំពោះសិទ្ធិរបស់ពួកគាត់ ដើម្បីចូលរួមក្នុងការសំរេចផ្សេងៗ ដែលពួកគាត់ត្រូវតែបានដឹងជាមុនអំពីបញ្ហាទាំងឡាយដែលប៉ះពាល់ដល់ការរស់នៅរបស់ខ្លួន។ គណៈកម្មាធិការផ្តល់ជាអនុសាសន៍យ៉ាងខ្លាំងថា ការផ្តល់សម្បទានសេដ្ឋកិច្ច គួរតែគិតគូរអំពីសេចក្តីត្រូវការសំរាប់ការអភិវឌ្ឍន៍ប្រកបដោយចិរភាព និងដើម្បីឲ្យប្រជាជនកម្ពុជាគ្រប់រូប ទទួលបានអត្ថប្រយោជន៍ពីការរីកចំរើននេះ ជាជាងសំរាប់តែផលប្រយោជន៍របស់បុគ្គលឯកជន។ គណៈកម្មាធិការស្នើឲ្យរដ្ឋភាគីបញ្ចូលក្នុងរបាយការណ៍តាមកាលកំណត់លើកក្រោយរបស់ខ្លួន នូវព័ត៌មានលំអិតស្តីពីសមិទ្ធិផលដែលសំរេចបាន ក្នុងការអនុវត្តន៍គោលនយោបាយទាំងនេះ។<br><br>**១៦.** គណៈកម្មាធិការស្នើយ៉ាងទទូចដល់រដ្ឋភាគីឲ្យអនុវត្តច្បាប់ភូមិបាលឆ្នាំ២០០១ ដោយមិនត្រូវអូសបន្លាយពេលវេលាតទៅទៀត និងធានាថា គោលនយោបាយរបស់ខ្លួនស្តីពីការចុះបញ្ជីដី មិនត្រូវឲ្យផ្ទុយនឹងស្មារតីនៃច្បាប់នេះឡើយ។ គណៈកម្មាធិការបញ្ជាក់អំពីសេចក្តីត្រូវការឲ្យមានការវាយតំលៃអំពីផលប៉ះពាល់សង្គម និងបរិស្ថាន និងការពិគ្រោះយោបល់ជាមួយសហគមន៍នានា ដែលរងផលប៉ះពាល់ពាក់ព័ន្ធនឹងសកម្មភាពសេដ្ឋកិច្ច រួមទាំងការធ្វើអាជីវកម្មរ៉ែ និងអាជីវកម្មប្រេង ក្នុងគោលដៅធានាថា សកម្មភាពទាំងនេះ មិនត្រូវដកហូតពីជនជាតិដើមភាគតិចនូវការទទួលបានយ៉ាងពេញលេញនូវសិទ្ធិរបស់ពួកគាត់លើដីធ្លី និងធនធានធម្មជាតិនៃបុព្វបុរសរបស់ខ្លួនឡើយ។ គណៈកម្មាធិការ ជំរុញលើកទឹកចិត្តឲ្យរដ្ឋភាគី ពិចារណាផ្តល់សច្ចាប័នលើអនុសញ្ញាអង្គការពលកម្មអន្តរជាតិលេខ១៦៩ ស្តីពីជនជាតិដើមភាគតិច និងក្រុមកុលសម្ព័ន្ធ។ |

| *អ្នករាយការណ៍ពិសេស* |
| --- |
| A/HRC/21/63/Add.1/Rev.1. Para .212. រដ្ឋាភិបាលគួរលើកកំពស់កិច្ចខិតខំប្រឹងប្រែងទាំងអស់ដើម្បីអនុវត្តចំពោះគ្មាននូវច្បាប់ គោលនយោបាយ និងបទបញ្ញានានា ដែលតម្រូវឲ្យមានការវាយតំលៃពីផលប៉ះពាល់សង្គម និងបរិដ្ឋាន ដែលត្រូវធ្វើ *មុនពេល* ការផ្តល់ដីសម្បទាន រួមទាំងច្បាប់ស្តីពីការការពារបរិដ្ឋាន និងការគ្រប់គ្រងធនធានធម្មជាតិ ហើយលទ្ធផលនៃការវាយតំលៃនេះ ត្រូវផ្សព្វផ្សាយជាសាធារណៈ។<br><br>A/HRC/21/63/Add.1/Rev.1. Para. 217. ក្រុមហ៊ុនគ្រប់ទម្រង់ រចនាសម្ព័ន្ធ និងរបៀបប្រតិបត្តិការ ទាំងក្រុមហ៊ុនក្នុងស្រុក និងក្រុមហ៊ុនបរទេស ហើយទោះជាក្រុមហ៊ុនរដ្ឋទាំងស្រុង ឬក្រុមហ៊ុនពាក់កណ្តាលរដ្ឋ គួរដោះស្រាយពីផលប៉ះពាល់សិទ្ធិមនុស្សរបស់ខ្លួន ដោយអនុវត្តតាមវិរិយភាពដ៏ត្រឹមត្រូវ រួមទាំងការអនុវត្តវិធានការនានាដើម្បីកំណត់អត្តសញ្ញាណ បង្ការ និងជួយសម្រាលដល់ផលវិបាកសិទ្ធិមនុស្សធ្ងន់ធ្ងរ ព្រមទាំងយកចិត្តទុកដាក់ដល់សកម្មភាពអាជីវកម្មរបស់ខ្លួន។<br><br>A/HRC/21/63/Add.1/Rev.1. Para. 222. ក្រុមហ៊ុនសម្បទាន គួរចាត់វាល់វិធានការដើម្បីចៀសវាងការបំផ្លាញបរិដ្ឋាននៅក្នុងប្រតិបត្តិការរបស់ខ្លួន រួមទាំងបង្ការមិនឲ្យទឹកកក្តក់មានរោគ បំផ្លិចបំផ្លាញដល់ដី និងការកាប់រានយកដីដោយមិនចាំបាច់ ឬការកាប់បំផ្លាញព្រៃឈើដោយខុសច្បាប់។ ក្រុមហ៊ុនទាំងនេះគួរធានាថា ការទទួលបានហេដ្ឋារចនាសម្ព័ន្ធ ដូចជាការកសាងផ្លូវថ្មីនៅលើដីសម្បទានរបស់ខ្លួន អាចត្រូវបានប្រើប្រាស់ដោយសហគមន៍នានានៅជុំវិញនោះ ហើយមិនគួររាំងខ្ទប់មិនឲ្យមានការធ្វើដំណើរនៅក្នុងព្រំដែននៃដីសម្បទានរបស់ខ្លួនឡើយ។<br><br>A/HRC/21/63/Add.1/Rev.1. Para. 224. ក្រុមហ៊ុនសម្បទាន—ដោយប្រើប្រាស់ផលលាភដែលបានពីសកម្មភាពសម្បទានរបស់ខ្លួន—គួរបង្កើនវិភាគទានរបស់ខ្លួនដល់សហគមន៍មូលដ្ឋាន រួមទាំងផ្តល់ផលប្រយោជន៍ដល់សង្គម ដូចជា សេវាកម្មសុខាភិបាល ឱកាសអប់រំ និងវិធានការការពារបរិដ្ឋានជាដើម។ |

## គោលដៅទី១៦៖ លើកកំពស់សង្គមប្រកបដោយសន្តិភាព និងបរិយាប័ន្ន សំរាប់ការអភិវឌ្ឍន៍ប្រកបដោយចីរភាព ផ្តល់សិទ្ធិទទួលបានយុត្តិធម៌សំរាប់ទាំងអស់គ្នា និងកសាងស្ថាប័ននៅគ្រប់កំរិតឱ្យមានប្រសិទ្ធភាព គណនេយ្យភាព និងបរិយាប័ន្ន

*សូមមើលលេខ II. ស្តីពីកំណែទម្រង់ច្បាប់ និងយុត្តិធម៌ និងនីតិរដ្ឋ*

*សូមមើលលេខ III. ស្តីពីសេរីភាពនៃការសំដែងមតិ សមាគម និងការជួបប្រជុំ*

*សូមមើលលេខ IV. ស្តីពីនិទណ្ឌភាព និងអ្នកការពារសិទ្ធិមនុស្ស*

*សូមមើលលេខ V. ស្តីពីកំណែទម្រង់ការបោះឆ្នោត និងការចូលរួមនយោបាយ*

*សូមមើលលេខ VII. ស្តីពីអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា*

*សូមមើលលេខ VIII. ស្តីពីការប្រតិបត្តិច្បាប់ និង*

*សូមមើលលេខ X. ស្តីពីដីធ្លី និងសិទ្ធិលំនៅដ្ឋាន*

## គោលដៅទី១៧៖ ពង្រឹងមធ្យោបាយនៃការអនុវត្ត និងស្តារឡើងវិញនូវដៃគូសកលសំរាប់ការអភិវឌ្ឍន៍ប្រកបដោយចេរភាព

| *អនុសាសន៍នៃការពិនិត្យជាសកលតាមកាលកំណត់* (២០០៩) |
| --- |
| ៩១. ង) .សូមពង្រឹងភាពជាដៃគូរបស់ខ្លួនជាមួយសហគមអន្តរជាតិ ក្នុងគោលបំណងធ្វើឲ្យប្រសើរឡើង ដល់សុខភាពសាធារណៈរបស់ប្រទេស។ (អង់ហ្គោឡា( |
| *គណៈកម្មាធិការសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌* (២០០៩) E/C.12/KHM/CO/1 |
| ៣៣. គណៈកម្មាធិការផ្តល់ជាអនុសាសន៍យ៉ាងខ្លាំងថា រដ្ឋភាគីពិចារណាអនុម័តច្បាប់ស្តីពីសុខភាពផ្លូវចិត្ត និងអនុម័តផែនការយុទ្ធសាស្ត្រស្តីពីសុខភាពផ្លូវចិត្ត ដែលបញ្ចូលភាពជាដៃគូជាមួយអង្គការក្រៅរដ្ឋាភិបាល (NGOs) និងស្ថាប័នដៃគូក្នុងវិស័យឯកជននានា។ គណៈកម្មាធិការផ្តល់ជាអនុសាសន៍ផងដែរថា រដ្ឋភាគីធានាថា បុគ្គលទាំងឡាយដែលមានបញ្ហាសុខភាពផ្លូវចិត្ត មិនត្រូវបានបញ្ជូនទៅដាក់ពន្ធនាគារឡើយ។ |
| *អ្នករាយការណ៍ពិសេស* |
| A/HRC/33/62 Para 61 (b). ពិគ្រោះយោបល់ឱ្យបានទូលាយ បង្កើយ និងបោះពុម្ពគោលនយោបាល និងផែនការយុទ្ធសាស្ត្រដើម្បីសម្រេចឱ្យបានជោគជ័យដែលអាចវាស់បាន ក្នុងការទទួលបានគោលដៅអភិវឌ្ឍន៍ប្រកបដោយចេរភាព។ |

## គោលដៅទី១៨៖ ការដោះមីន/ប្រោសសំអាតគ្រឿងផ្ទុះសល់ពីសង្រ្គាម និងការជួយជនរងគ្រោះ

| *គណៈកម្មាធិការសិទ្ធិកុមារ* (២០១៥) CRC/C/OPAC/KHM/CO/1 |
| --- |
| ២៥. គណៈកម្មាធិការសូមផ្តល់អនុសាសន៍ថា រដ្ឋភាគីពង្រឹងកម្មវិធីយល់ដឹងអំពីមីននិងសកម្មភាពដោះមីនរបស់ខ្លួនដើម្បីការពារកុមារប្រឆាំងនឹងមីន និងគ្រឿងផ្ទុះសល់ពីសង្រ្គាម។ គណៈកម្មាធិការក៏សូមផ្តល់អនុសាសន៍ថា រដ្ឋភាគីពិចារណាបង្កើតកម្មវិធីកុមារមេត្រី ដើម្បីធានាពីការផ្តល់សេវាកម្មគ្រប់គ្រាន់តបនឹងតម្រូវការជាក់លាក់របស់កុមាររងគ្រោះ ជាពិសេសកុមារពិការដែលបណ្តាលមកពីសំណល់មីននិងគ្រឿងផ្ទុះដែលសល់ពីសង្រ្គាម និងផ្តល់ឱ្យពួកគេនូវការស្តារនីតិសម្បទាទាំងផ្លូវកាយ និងផ្លូវចិត្ត ព្រមទាំងការជួយពីសង្គម។ |

Index

**CAT** ................ 7, 10, 12, 16, 18, 21, 25, 28, 29, 33, 34, 40, 52, 55, 57, 58, 77, 82, 94, 100, 103, 106, 107
**CCPR** ................ 7, 10, 16, 17, 25, 32, 37, 39, 40, 43, 46, 52, 54, 55, 57, 83, 88, 91, 99, 106
**CEDAW** ................ 7, 9, 10, 11, 18, 20, 28, 29, 54, 60, 63, 64, 68, 76, 79, 81, 83, 87, 89, 90, 91, 97, 99, 103, 104, 105, 106, 107
**CERD** ................ 7, 10, 12, 19, 22, 25, 30, 34, 44, 52, 63, 65, 73, 80, 84, 105
**CESCR** ................ 7, 11, 12, 19, 22, 28, 40, 44, 52, 58, 61, 65, 69, 72, 74, 77, 80, 82, 84, 89, 94, 96, 100, 102, 103, 104, 105, 106, 107, 108
**CRC**8, 10, 11, 15, 17, 18, 20, 21, 32, 34, 43, 52, 57, 60, 63, 64, 68, 76, 79, 81, 83, 84, 86, 87, 89, 91, 92, 95, 96, 98, 100, 101, 103, 104, 105, 106, 108
Education ................ 2, 9, 75, 78, 80, 84, 101
employment ................ 1, 63, 64, 65, 68, 86, 107
gender ................ 20, 54, 57, 58, 60, 64, 68, 76, 79, 87, 88, 89, 90, 91, 92, 95, 99, 105
health ................ 32, 55, 57, 59, 60, 61, 62, 63, 65, 68, 69, 72, 75, 76, 77, 78, 80, 84, 101
housing ................ 8, 14, 61, 62, 67, 69, 72
ICCPR ................ 9, 36, 37
indigenous ................ 14, 30, 42, 44, 67, 69, 73, 74, 80, 83, 84, 85
inequality ................ 62, 64, 88, 107
juvenile justice ................ 30, 31, 32, 33
land dispute ................ 28
**Special Rapporteur**.... 4, 8, 13, 14, 15, 19, 22, 23, 25, 28, 30, 35, 37, 39, 41, 42, 43, 44, 46, 47, 53, 54, 59, 62, 63, 65, 67, 68, 69, 72, 74, 80, 85, 90, 94, 100, 103, 104, 105, 107, 108
sustainable development ................ 60, 74, 75, 107, 108
**UPR**3, 4, 6, 7, 9, 11, 13, 14, 16, 17, 20, 23, 24, 27, 29, 31, 36, 38, 39, 40, 41, 42, 46, 51, 54, 55, 57, 60, 62, 64, 67, 72, 73, 75, 76, 78, 80, 81, 82, 86, 87, 88, 90, 94, 95, 96, 98, 101, 103, 104, 105, 106, 107, 108
water ................ 14, 63, 65, 69, 72, 106